# ការសរសើរ និង ការថ្វាយបង្គំ

## ការត្រឡប់មកជាអ្នកថ្វាយបង្គំព្រះ

ដោយលោក
អ៉េអែល និង ចយ ហ្គីល

# ការសរសើរ

# និង

# ការថ្វាយបង្គំ

ដោយលោក

អេ. អែល និង ចយ ហ្គីល

*www.gillministries.com*

## <u>សៀវភៅដែលសរសេរដោយលោកអេ.អិល និងអ្នកស្រីចយ ហ្គីល</u>

<u>និយាយ</u>ពីសេចក្តីសន្យារបស់ព្រះសម្រាប់សេចក្តីត្រូវការរបស់លោកអ្នកគ្រប់ៗគ្នា ទុកសម្រាប់ការគ្រប់គ្រងនៅក្នុងព្រះនាមព្រះយេស៊ូវ គឺជាជ័យជម្នះលើភាពខកចិត្ត ។

## <u>សៀវភៅដែលមាននៅក្នុងចលនានាវាំងនេះគឺ:</u>

**សិទ្ធិអំណាចរបស់អ្នកជឿ**

របៀបដែលមានការបាត់បង់ និងរបៀបដែលចាប់ផ្តើមទទួលជ័យជម្នះ

**ពួកជំនុំដែលមានជ័យជម្នះ**

តាមរយៈព្រះគម្ពីរកិច្ចការ

**ការប្រទានអំណាចរបស់ព្រះសម្រាប់ការប្រោសឱ្យជា**

ការទទួលការងារនូវអំណាច នៃការប្រោសឱ្យជាដែលមកពីព្រះ

**អំណោយទានការងារជា:**

សាវក គ្រូអធិប្បាយ គ្រូផ្សាយដំណឹងល្អ

គ្រូគង្វាល និងគ្រូបង្រៀន

**ការផ្សាយដំណឹងល្អប្រកបដោយការអស្ចារ្យ**

ផែនការរបស់ព្រះ គឺជាការឈោងចាប់ពិភពលោកទាំងមូល

**រូបភាពនៃការកើតជាថ្មី**

គឺជាការដឹងថា លោកអ្នកនៅក្នុងព្រះគ្រីស្ទ

**គំរូនៃការរស់នៅ**

ចាប់ផ្តើមពីព្រះគម្ពីរសញ្ញាចាស់

**ការអធិស្ឋាន**

នាំយកពីស្ថានសួគ៌មកផែនដី

# អំពីអ្នកនិពន្ធ

លោកអេ.អែល និងចយ ហ្គីល គឺជាអ្នកមានចំណេះវោហាជាអន្តរជាតិ ជាអ្នកនិពន្ធ ព្រមទាំងជាអ្នកបង្រៀនព្រះគម្ពីរ។ នៅក្នុងបេសកកម្មការងារជាសាវករបស់គាត់ លោកអេ.អែល បានធ្វើដំណើរទៅជាច្រើនប្រទេសនៃជនជាតិនានា ជាង៥០ជនជាតិលើពិភពលោក ដោយបានអធិប្បាយទៅកាន់ហ្វូងមនុស្សរាប់រយពាន់នាក់ និងមានមនុស្សជាច្រើនរាប់លាននាក់ បានស្តាប់តាមវិទ្យុ និងទស្សនាតាម ទូរទស្សន៍ផងដែរ ។

ពួកគេមានសៀវភៅមេរៀនជាច្រើន ដែលមានជាងពីរលានក្បាល បានដាក់លក់នៅសហរដ្ឋអាមេរិក ។ ពួកគេបានសរសេរសៀវភៅជាច្រើន ដែលបានបកប្រែជាច្រើនភាសា និងត្រូវបានគេយកទៅប្រើនៅសាលាព្រះគម្ពីរ ព្រមទាំងថ្នាក់សិក្ខាសាលានៅជុំវិញពិភពលោក ។

ជីវិតដែលមានការផ្លាស់ប្រែពេញដោយអំណាច ដែលបានមកពីសេចក្តីពិតដោយសារព្រះបន្ទូលនៃព្រះ បានផ្ទុះចេញឡើងទៅដល់ជីវិតអ្នកដទៃទៀត តាមរយៈការអធិប្បាយ ការបង្រៀន ការសរសេរដ៏មានទឹកដមរបស់ពួកគេ ព្រមទាំងការផ្សាយ តាមវីដេអូ និងតាម រយៈការស្តាប់អូឌីយ៉ូរបស់ពួកគេ ។

សិរីល្អដ៏គួរឱ្យព្រឺព្រួចនៃព្រះវត្តមានរបស់ព្រះ គឺត្រូវបានទទួលការពិសោធន៍នៅក្នុងការសរសើរ និងការថ្វាយបង្គំ នៅក្នុងកម្មវិធីសិក្ខាសាលាផ្សេងៗ ពេលដែលអ្នកជឿទាំងឡាយបានស្រាវជ្រាវរកឃើញនូវរបៀប ដែលធ្វើឱ្យពួកគេបានក្លាយជាអ្នកថ្វាយ បង្គំព្រះដោយសេចក្តីពិត និងដោយអស់ពីចិត្ត ។ មានមនុស្សជាច្រើនបានស្រាវជ្រាវរកឃើញនូវខ្នាតនៃជ័យជម្នះថ្មីៗ និងគួរឱ្យ ភ្ញាក់ផ្អើល ព្រមទាំងមានភាពក្លាហាន តាមរយៈការបង្រៀនរបស់ពួកគេ អំពីសិទ្ធិអំណាចរបស់អ្នកជឿ ។

រីឯអ្នកស្រីហ្គីលបានបណ្តុះបណ្តាលដល់អ្នកជឿជាច្រើន ជាជំហានៗឆ្ពោះទៅកាន់ការងារជាអធិធម្មជាតិ ដែលព្រះទ្រង់បានប្រទានដល់ពួកគេដោយផ្ទាល់ខ្លួនម្នាក់ៗ ដោយអំណាចនៃការប្រោសឱ្យជារបស់ព្រះ ដែលហូរតាមរយៈដៃរបស់ពួកគេ ។ មានមនុស្សជាច្រើនបានរៀន ដើម្បីឱ្យបានទទួលនូវការអស្ចារ្យតាមរបៀបអធិធម្មជាតិ ដែលពួកគេបានបង្ហូរតៗគ្នាទៅដល់អ្នកដទៃ ទៀត តាមរយៈអំណោយទាន ទាំង៩នៃព្រះវិញ្ញាណបរិសុទ្ធក្នុងការរស់នៅ និងការបំពេញការងាររបស់ពួកគេ ។

ទាំងលោកអេ.អែល និងអ្នកស្រីចយ បានសិក្សា ហើយទទួលបាននូវកម្រិតថ្នាក់ម៉ាស្ទ័រនៃទេវវិទ្យា ។ រីឯលោកអេ.អែល ក៏ចង់បានទទួលតំណែងបណ្ឌិតផ្នែកទស្សនវិជ្ជា នៅក្នុងកម្រិតថ្នាក់ទេវវិទ្យា ដែលចេញពីសកលវិទ្យាល័យទស្សនៈគ្រីស្ទានផងដែរ ។ កិច្ចការងាររបស់គេ បានតាំងមូលដ្ឋានគ្រឹះនៅលើព្រះបន្ទូលព្រះ គឺបានតាំងលើព្រះយេស៊ូវ ដើម្បីឱ្យមានសេចក្តីជំនឿរឹងមាំ ព្រម ទាំងបានបង្រៀនដោយនូវអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។

ការងាររបស់គេ គឺជាការបង្ហាញបំភ្លឺមកពីសេចក្តីស្រឡាញ់ដ៏អស់ពីចិត្តនៃព្រះដ៏ជាព្រះវរបិតា ។ ការអធិប្បាយ និងការ បង្រៀនរបស់ពួកគេ គឺបានប្រព្រឹត្តទៅដោយអំណាចនៃការចាក់ប្រេងតាំង ដែលមានទីសម្គាល់ ការអស្ចារ្យ និងការប្រោសឱ្យជា គឺជាការអស្ចារ្យដែលមានរលករំពើក ក្រោមអំណាចព្រះចេស្តារបស់ព្រះ ។

ទីសម្គាល់ដ៏រស់រវើក ដែលរាប់បញ្ចូលនូវសំណើចបរិសុទ្ធ ការយំនៅចំពោះព្រះភក្ត្ររបស់ព្រះអម្ចាស់ ព្រមទាំងការសម្តែងនូវការព្រឺព្រួចនៃសិរីល្អរបស់ព្រះ និងអំណាចដែលត្រូវបានទទួលការពិសោធន៍តាមមនុស្សជាច្រើន ដែលបានចូលរួមប្រជុំរបស់ពួក គេ ។

# ព្រះបន្ទូលទៅកាន់គ្រូបង្រៀន និងសិស្ស

នៅក្នុងការសិក្សានេះរៀន *ការសរសើរតម្កើង និងការថ្វាយបង្គំ* នោះពួកអ្នកជឿនឹងរុករកឱ្យឃើញ នូវសេចក្តីអំណរ គឺជាចលនានៅក្នុងព្រះវត្តមាននៃព្រះ និងក្នុងការរំដោះវិញ្ញាណរបស់ពួកគេ នៅក្នុងគ្រប់ទាំងអំណាចចេស្តា ការស្រស់ស្រាយ គឺជាការចង្អុលបង្ហាញនូវការសរសើរតម្កើងដ៏ខ្ពង់ខ្ពស់ និងការថ្វាយបង្គំប្រកបដោយការជិតស្និទ្ធ ចំពោះព្រះ ការទាំងនេះគឺមាននៅក្នុងព្រះ គម្ពីរ ។ ដោយនូវសេចក្តីពិតដែលបានបើកសម្តែងនៅក្នុងសៀវភៅនេះ ពួកអ្នកជឿនឹងបានត្រឡប់មកជាអ្នកថ្វាយបង្គំដល់ព្រះជា ប្រចាំថ្ងៃ ។

ការទម្លុះចូលទៅក្នុងវិញ្ញាណដ៏ពេញដោយអំណាចចេស្តា នោះនឹងកើតឡើងនៅក្នុងជីវិតមនុស្សទាំងអស់ ដែលនឹង "ប្រញាប់ចូលទៅឯព្រះ" ដោយមានសេចក្តីសម្រេចចិត្តថ្មី ដើម្បីរំដោះរូបកាយ ព្រលឹង និងវិញ្ញាណរបស់ពួកគេឱ្យមានការ ពិសោធន៍គ្រប់ទាំងអស់ ដែលជាការបើកសម្តែងនូវអំណាចចេស្តាទាំងនេះ ឱ្យជាជីវិតសិក្សាដែលមានការផ្លាស់ប្តូរបាន ។

វាជាការសំខាន់ចំពោះពេលវេលានោះ គឺត្រូវបានគេចំណាយ មិនមែនត្រឹមតែជាការសិក្សានូវសេចក្តីពិតទាំង នេះនោះទេ គឺជាការអនុវត្តន៍ និងជាការពិសោធន៍នូវគ្រប់ការទាំងអស់ ដែលជាការបើកសម្តែងនៅក្នុងមេរៀនទាំងនេះ នៅពេលដែលការទាំង នេះកើតឡើង គឺជាព្រះវត្តមាន និងសិរីល្អរបស់ព្រះដ៏លើសលុប ដែលនឹងត្រូវបានបើកសម្តែង ។

យើងមានសំណូមពរមុនពេលបង្រៀនមេរៀននេះ សូមឱ្យលោកអ្នកអានសៀវភៅទាំងឡាយ និងស្តាប់តាមកាសែតថេប ទាំងឡាយដែលមានបញ្ជីរាយនាមដូចជា *សំណូមពរនៃការអាន និងការស្តាប់* ជាដើម ។ លោកអ្នកអាចទទួលការជ្រួតជ្រាប ទៅលើសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះ គឺជាការយកចិត្តទុកដាក់តាមរយៈមេរៀន ការសរសើរតម្កើង និងការថ្វាយបង្គំ ដោយខ្លួនឯងផ្ទាល់ច្រើនប៉ុណ្ណា នោះសេចក្តីពិតនឹងធ្វើចលនាចេញពីគំនិត និងវិញ្ញាណរបស់លោកអ្នកច្រើនប៉ុណ្ណោះដែរ ។ បន្ទាប់ពីនោះមក សៀវភៅនេះនឹងផ្តល់នូវការសង្ខេបដល់លោកអ្នក ដើម្បីឱ្យបានប្រើប្រាស ដូចជាលោកអ្នកចែកឱ្យនូវសេចក្តីទុកចិត្តទាំងនេះទៅដល់អ្នកដទៃទៀតដែរ ។

ការបើកសម្តែងពីជីវិតដែលមានលក្ខណៈជាបុគ្គល គឺជាតម្រូវការនៃសេចក្តីបង្រៀនដ៏ជាក់លាក់បំផុត ។ អ្នកនិពន្ធបាន លុបចេញនូវការទាំងនេះ ចេញពីកិច្ចការងារទាំងនេះ ដើម្បីឱ្យគ្រូបង្រៀនផ្តល់ឱ្យនូវការបើកសម្តែង ពីការ ពិសោធន៍របស់ខ្លួនផ្ទាល់ ទៅដល់សិស្សទាំងឡាយណា ដែលមានលទ្ធភាពអាចទទួលបាន ។ វានឹងតែងតែត្រូវបានគេចងចាំថា ព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់បានយាងមកដើម្បីបង្រៀនយើងនូវគ្រប់ការទាំងអស់ ។ ហើយនៅពេលដែលយើងកំពុងធ្វើ ឬពេលដែលយើងកំពុងបង្រៀន នោះយើងតែងតែត្រូវបានផ្តល់ឱ្យនូវអំណាច ព្រមទាំងត្រូវបាន ប្រទានឱ្យដោយនូវព្រះវិញ្ញា បរិសុទ្ធ ។

ការសិក្សានេះគឺជាការប្រសើរបំផុត សម្រាប់ការសិក្សាជាលក្ខណៈបុគ្គល ឬជាការសិក្សាតាមក្រុម សាលាព្រះគម្ពីរ សាលារៀនថ្ងៃអាទិត្យ ព្រមទាំងក្រុមសិក្សាតាមផ្ទះ ។

គឺជាការសំខាន់ ទាំងគ្រូទាំងសិស្ស ដែលត្រូវតែមានសៀវភៅមេរៀនឱ្យបានគ្រប់ដៃ ក្នុងពេលដែលកំពុងសិក្សា ។ សៀវភៅមេរៀនល្អៗ យើងត្រូវតែសរសេរកត់ត្រាចុះ គូសបន្ទាត់ខាងក្រោមពាក្យសំខាន់ៗ ពិនិត្យពិចារណានូវគ្រប់ទាំង ពាក្យនីមួយៗ ព្រមទាំងចេះសង្ខេបអត្ថបទផងដែរ ។ យើងបានទុកឱ្យមានចន្លោះសម្រាប់លោកអ្នកកត់ត្រា និងធ្វើសេចក្តីសង្ខេប ។ របៀបរបប ត្រូវបានគេរៀបចំទុកជាមុន ដោយមានប្រព័ន្ធខយោង អាចមើលបានរហ័សទាន់ចិត្ត សម្រាប់ឱ្យលោកអ្នកមើលសារឡើងវិញ និង ជួយឱ្យលោកអ្នកបានរកឃើញនៅកន្លែងដដែលៗម្តងទៀតបាន ។ មានរបៀបរបបពិសេសៗ ដែលធ្វើឱ្យមានលទ្ធភាពសម្រាប់ ម្នាក់ៗ ពួកគេបានសិក្សាតែម្តងប៉ុណ្ណោះ តាមរយៈសម្ភារៈនេះ ដើម្បីបង្រៀននូវមាតិកានេះ ទៅដល់អ្នកដទៃទៀត ។

លោកសាវ័កប៉ុល បានសរសេរទៅកាន់លោកធីម៉ូថេថា:

*ឯអស់ទាំងសេចក្តីដែលអ្នកបានឮអំពីខ្ញុំ នៅមុខស្មរបន្ទាល់ជាច្រើន នោះក៏ត្រូវផ្ញើទុកនឹងមនុស្សស្មោះត្រង់ ដែលអាចនឹង បង្រៀនតទៅអ្នកឯទៀត ដែរ*(២ធីម៉ូថេ ២:២) ។

សៀវភៅនេះគឺត្រូវបានរៀបចំឡើងធ្វើឱ្យមានការរីកចម្រើន នៅក្នុងការរស់នៅ ការបំពេញការងារ និងការបង្រៀនដល់សិស្សជាច្រើននៅពេលអនាគត ។ យើងជឿថា វាជាផែនការរបស់ព្រះសម្រាប់សិស្សម្នាក់ៗ ឱ្យបានក្លាយទៅជាគ្រូបង្រៀន ។

# មាតិកា


មេរៀនទី ១

ការសរសើរ និងការថ្វាយបង្គំ ---------- ១៧

មេរៀនទី ២

គំរូរបស់ព្រះសម្រាប់ការថ្វាយបង្គំ ---------- ២៩

មេរៀនទី ៣

សេចក្ដីបង្រៀនរបស់ព្រះសម្រាប់ការសរសើរតម្កើង ---------- ៤៣

មេរៀនទី ៤

ការសរសើរតម្កើងនាំមកនូវព្រះពររបស់ព្រះ ---------- ៥៥

មេរៀនទី ៥

ព្រះបន្ទូលនិយាយពីការសរសើរតម្កើងនៅក្នុងព្រះគម្ពីរ ---------- ៦៩

មេរៀនទី ៦

គោលបំណងដ៏អស់កល្បរបស់ព្រះសម្រាប់ការសរសើរតម្កើង ---------- ៨១

មេរៀនទី ៧

ការប្រគំបទភ្លេងគឺជាការបើកសម្ដែងនូវការថ្វាយបង្គំ ---------- ៩៣

មេរៀនទី ៨

ការចង្អុលបង្ហាញនូវការសរសើរតម្កើងខាងផ្នែករូបកាយ ---------- ១០៣

មេរៀនទី ៩

ឧបស័គ្គចំពោះការសរសើរតម្កើង ---------- ១១៧

មេរៀនទី ១០

ការថ្វាយយញ្ញបូជានៃការសរសើរ ---------- ១៣១

មេរៀនទី ១១

មុខងារនៃពួកសង្ឃរបស់យើងគឺជាការសរសើរតម្កើង ---------- ១៤៧

មេរៀនទី ១២

អំពីការរស់នៅជាសង្ឃ ---------- ១៦៣

មេរៀនទី ១៣

ជ័យជម្នះតាមរយៈការសរសើរតម្កើង និងការថ្វាយបង្គំ ---------- ១៧៥

មេរៀនទី ១៤

ភាពជាអ្នកដឹកនាំក្នុងការសរសើរតម្កើង និងការថ្វាយបង្គំ------------------------------------------------១៨៩
មេរៀនទី ១៥
ការបំពេញការងារជាអ្នកដឹកនាំថ្វាយបង្គំ ------------------------------------------------------------២០៥

# សេចក្តីផ្តើម

សូម្បីតែនៅពេលដែលលោកអើរ៉ុនដ៏ជាសង្ឃ បានចូលទៅក្នុងរោងឧបោសថរបស់លោកម៉ូសេប្រចាំថ្ងៃក៏ដោយ ហើយក្រោយមកក៏បានចូលទៅក្នុងព្រះវិហាររបស់ស្តេចសាឡូម៉ូន រីឯសម័យសព្វថ្ងៃនេះ យើងជាអ្នកជឿ គឺជាពួកសង្ឃ ក៏ត្រូវតែចូលទៅក្នុងព្រះវត្តមានរបស់ទ្រង់ជាប្រចាំថ្ងៃផងដែរ ។

រោងឧបោសថរបស់លោកម៉ូសេ បានកើតឡើងដល់ទ្វារដែលបានអនុញ្ញាតឱ្យចូលទៅខាងក្នុងទីលាន ។ ពួកអ្នកជឿទាំងអស់អាចចូលទៅបានត្រឹមទីលានខាងក្រៅ ។ រីឯពួកសង្ឃ បានចូលទៅធ្វើសកម្មភាពដោយឆ្លងកាត់តាម ទីលាន ដើម្បីទៅបំពេញការងារថ្វាយដល់ព្រះអម្ចាស់ នៅក្នុងទីបរិសុទ្ធ ។ ក្នុងមួយឆ្នាំម្តង សម្តេចសង្ឃអាចចូលទៅ ក្នុងទីបរិសុទ្ធបំផុត ដែលមានហឹបនៃសេចក្តីសញ្ញារបស់ព្រះ ។

ទីបរិសុទ្ធបំផុតគឺជាសំណៅមនុស្សដែលនៅផែនដី ដែលស្មើនឹងបល្ល័ង្កដែលនៅស្ថានសួគ៌ គឺជាបន្ទប់របស់ព្រះ ។ ហឹបដែលមានគម្របគ្របដោយមានទីសន្តោសប្រោស គឺជាទីកន្លែងនៅផែនដី គឺជាប្រភេទនៃបល្ល័ង្ករបស់ព្រះ ។ ដើម្បីឱ្យបានចូលទៅក្នុងទីបរិសុទ្ធបំផុត គឺត្រូវតែឱ្យបាននៅក្នុងព្រះវត្តមាននៃព្រះយ៉ាងស្និទ្ធស្នាលសិន ។

ក្នុងមួយរំពេចដែលព្រះយេស៊ូវទ្រង់បានសុគតនៅលើឈើឆ្កាង នោះវាំងននដែលបាំងខ័ណ្ឌជាកណ្តាលរវាង មនុស្ស និងព្រះ គឺបានរហែកដាច់ចេញជាអធិធម្មជាតិ ចាប់ពីលើរហូតក្រោម ។ មនុស្សមិនត្រូវការដាច់ចេញពីព្រះ ដោយសារអំពើបាបយូរអង្វែងឡើយ ។ អំពើបាបរបស់មនុស្សត្រូវតែបានទទួលនូវការអត់ទោសឱ្យ ។ ឥឡូវនេះ មនុស្សប្រុស-ស្រី អាចចូលទៅក្នុងព្រះវត្តមាននៃព្រះដោយអង់អាចហើយ ។

សូម្បីតែមានការជឿនទៅមុខក្នុងការចូលទៅខាងក្នុង ដោយពួកសង្ឃដែលនៅក្នុងព្រះគម្ពីរសញ្ញាចាស់ក៏ ដោយ ក៏មានការជឿនទៅមុខក្នុងការចូលទៅខាងក្នុងនៅសម័យសព្វថ្ងៃនេះដែរ គឺយើងជាពួកអ្នកជឿជាសង្ឃ ដែលបានចូលមកក្នុងព្រះវត្តមាននៃព្រះអង្គជាប្រចាំថ្ងៃ ក្នុងការសរសើរតម្កើង និងការថ្វាយបង្គំផងដែរ ។ យើងត្រូវតែចូលទៅក្នុងជាប្រចាំថ្ងៃដោយផ្ទាល់ខ្លួន នៅពេលសរសើរតម្កើងនោះដែរ ។ យើងត្រូវតែចូលទៅដោយរួមគ្នា ជាមួយនឹងរូបកាយទាំងមូល គឺក្នុងពេលយើងចូលទៅដោយរួមគ្នានោះឯង ។ ដើម្បីចូលទៅតាមការតម្រូវឱ្យមាននូវសកម្មភាព ស្តាប់បង្គាប់ចំពោះផ្នែករបស់យើង ។ ព្រះទ្រង់សម្រេចព្រះទ័យថា យើងចូលទៅក្នុងព្រះវត្តមាននៃព្រះ នោះយើងត្រូវតែចាប់យកនូវការផ្តួចផ្តើមដើម្បីធ្វើការយ៉ាងដូច្នោះ ។

ទីមួយ យើងត្រូវទទួលនូវការបង្រៀនដោយស្តេចដាវីឌ ដើម្បីៈ

**ចូរនាំគ្នាចូលតាមទ្វារទ្រង់ ដោយពោលពាក្យអរព្រះគុណ ហើយចូលទៅក្នុងទីលានទ្រង់ ដោយបទសរសើរ ចូរអរព្រះគុណដល់ទ្រង់ ហើយសរសើរព្រះនាមទ្រង់ចុះ** (ទំនុកដំកើង ១០០:៤) ។

យើងចូលតាមទ្វារព្រះអង្គដោយការអរព្រះគុណ ។ យើងមិនអាចចូលតាមទ្វារព្រះអង្គ ដោយចិត្តមិនពេញលេញនោះឡើយ ។ ចម្រៀងជាដំបូងរបស់យើង គឺនៅពេលដែលយើងកំពុងតែបានចូលទៅក្នុងការសរសើរតម្កើង នោះគួរតែប្បីមានម្នាក់ដែលចង្អុលបង្ហាញ នូវការអរព្រះគុណយ៉ាងអស់ពីចិត្តរបស់យើងនោះ ថ្វាយដល់ព្រះអម្ចាស់ ។

នៅពេលដែលយើងចូលមកតាមទ្វារ នោះយើងបានចូលមកក្នុងទីលានហើយ ។ ដូច្នេះ ត្រូវតែមានការចូលទៅក្នុងព្រះវត្តមាននៃរបស់ទ្រង់ហើយ ។ យើងមិនត្រូវសម្រេចចិត្តចូលទៅឱ្យដល់ទីបរិសុទ្ធបំផុត ដោយមានពេលថ្វាយបង្គំដែលប្រកបដោយភាពព្រឺព្រួចភ្លាមៗនោះឡើយ លុះត្រាណាតែយើងបានចំណាយពេលជាដំបូងនៅក្នុងទីលាននោះសិន ។ នៅក្នុងទីលានខាងក្រៅ យើងត្រូវបានទទួលការបង្រៀនឱ្យសរសើរតម្កើង ។ ដែលយើងចូលទៅខាងក្នុងដោយមានពេញដោយសេចក្ដីអំណរ នោះគឺជាការច្រៀងចម្រៀង ការលេងភ្លេង ការទះដៃ និងការសរសើរតម្កើងដោយដៃរបស់ យើង ហើយជាញឹកញាប់ យើងក៏មានការរាំនៅចំពោះព្រះអម្ចាស់ គឺនៅពេលដែលយើងចង្អុលបង្ហាញនូវការសរសើរ តម្កើងរបស់យើង ។

នៅពេលដែលយើងបង្អែរបង្អង់នៅក្នុងទីធ្លា នៃការសរសើរតម្កើង នោះយើចាប់ផ្ដើមទទួលអារម្មណ៍ថា បានស្អាងនៅខាងក្នុងវិញ្ញាណរបស់យើង ដើម្បីចូលមកឱ្យកាន់តែជិតព្រះ ។ យើងនឹងចាប់ផ្ដើមចូលទៅក្នុងទម្រង់នៃការសរសើរតម្កើងកាន់តែខ្ពស់ឡើងៗ ។ យើងចូលទៅក្នុងទីលាន គឺចូលទៅក្នុងទីបរិសុទ្ធដោយការថ្វាយបង្គំ ។

ក្នុងមួយស្របក់នោះ យើងមិនមែនស្ថិតនៅក្នុងការរាំ ឬការទះដៃយូរអង្វែងឡើយ ។ យើងនឹងបានក្លាយទៅជាអ្នកដឹងខ្លួនថាបាននៅក្នុងព្រះវត្តមាននៃព្រះ ដែលដៃយើងបានចាប់ផ្ដើមសរសើរតម្កើងដល់ទ្រង់ ដោយមានអារម្មណ៍រំភើបក្រៃលែង ។ ភ្លេងក៏កាន់តែយឺតទៅៗ ។ អ្វីដែលធ្វើដំណើរទៅតាមលំដាប់លំដោយក្នុងពេលភ្លាមៗ នោះក៏ត្រូវ បានបញ្ឈប់ ។ ភាពបរិសុទ្ធនៃព្រះវត្តមានរបស់ព្រះ នោះគឺស្ទើរតែនឹងកើតឡើងដោយមានភាពដ៏លើសលុប ។

នៅពេលដែលយើងបន្តការទូលសូមដោយស្រក់ទឹកភ្នែក នោះទឹកភ្នែករបស់យើងនឹងអាចហូរមកលើផែនថ្ពាល់ទាំងគូរជាមិនខាន ។ ជួនកាលគ្រប់រឿងរ៉ាវទាំងអស់ដែលយើងអាចធ្វើ គឺនឹត្រូវបញ្ឈប់ការលេងភ្លេង និងការ ច្រៀងព្រមទាំងទ្រឹងនៅដោយស្ងប់ស្ងៀម ចំពោះព្រះវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ ។ យើងមិនអាចដឹងបានពីមនុស្សដែលនៅជុំវិញយើងទេ ។ និយាយរួម គឺយើងដឹងតែពីការផ្ចង់ចិត្តទៅឯព្រះប៉ុណ្ណោះ ។ យើងកំពុងតែឈរនៅក្នុងព្រះវត្តមានរបស់ទ្រង់ គឺបានស្រាយអស់គ្រប់ទាំងបញ្ហាដោយសារសេចក្ដីស្រឡាញ់របស់ព្រះអង្គ ។

យើងស្ទើរតែហាក់ដូចជាមិនដឹងអ្វីទាំងអស់ គឺដោយការស្លុងអារម្មណ៍ទៅ ដូចជាសម្ដេចសង្ឃដែលនៅខាងក្នុងវាំងននដូច្នោះដែរ ។ យើងកំពុងតែឈរនៅក្នុងទីបរិសុទ្ធបំផុត ។ យើងបានចូលមកដល់ភាពជិតស្និទ្ធយ៉ាងជ្រៅ ចូលទៅក្នុងព្រះវត្តមាននៃព្រះ ។ ការចាក់ប្រេងតាំង និងអំណាចចេស្ដា គឺត្រូវបានពណ៌នានៅក្នុងចំណោមមនុស្សហើយ ។ មានមនុស្សជាច្រើននឹងត្រូវក្រាបចុះ ឬក៏ក្រាបថ្វាយបង្គំដោយខ្លួនឯងផ្ទាល់នៅចំពោះទ្រង់ ។ មានអ្នកខ្លះទៀត ក៏អាចត្រូវសន្លប់ទៅដោយព្រះវិញ្ញាណ ។

យើងមានការពណ៌នាពីភាពដ៏ស្រស់ត្រកាលនៃពេលវេលា គឺនៅពេលដែលហឹបនៃសេចក្ដីសញ្ញា ត្រូវបាននាំចូលទៅក្នុងព្រះវិហាររបស់ស្ដេចសាឡូម៉ូនដូច្នេះថា:

**លុះពួកសង្ឃបានចេញពីទីបរិសុទ្ធមកវិញ នោះពពកក៏មកពេញក្នុងព្រះវិហារនៃព្រះយេហូវ៉ា ដល់ម្ល៉េះបានជាពួកសង្ឃឈរធ្វើការងារពុំបាន ដោយព្រោះពពកនោះ ដ្បិតសិរីល្អនៃព្រះយេហូវ៉ាបាននៅពេញក្នុងព្រះវិហារនៃព្រះអង្គ ហើយ** (១ពង្សាវតារក្សត្រ ៨:១០,១១) ។

នៅសម័យសព្វថ្ងៃនេះ ក៏មានពួកអ្នកជឿពីរបីនាក់ដែរ ដែលមានការពិសោធន៍យ៉ាងដូច្នេះ ។ យើងគួរគប្បីមានចិត្តប្រុងប្រៀបរៀបចំជាស្រេច ។ យើងចូលមកក្នុងដោយយោលទៅលើសេចក្តីបង្រៀន និងគំរូរបស់ទ្រង់ ។ យើងបញ្ចេញវិញ្ញាណ ព្រលឹង និងរូបកាយរបស់យើង ឱ្យចូលទៅក្នុងសេរីភាព និងការចង្អុលបង្ហាញដ៏យូរលង់ ចំពោះការសរសើរតម្កើងដោយគ្មានព្រំដែន នៅពេលដែលយើងបាននៅក្នុងទីលានរួចមកហើយនោះ ។

យើងគួរគប្បីបន្តចូលទៅឱ្យកាន់តែជិតព្រះ ។ ទ្រង់សព្វព្រះហឫទ័យប្រកបស្និទ្ធជាមួយនឹងកូនក្រមុំរបស់ទ្រង់ ជានិច្ច ។ ប៉ុន្តែ យើងត្រូវតែចូលមកឱ្យកាន់តែជិត រហូតដល់យើងអាចបានត្រឡប់មកជាតែមួយនឹងព្រះអង្គ ។ តើព្រះទ្រង់បានសម្រេចព្រះទ័យធ្វើយ៉ាងដូចម្តេចហ្ន៎ ចំពោះការធ្វើឱ្យមានភាពស្និទ្ធស្នាលមួយទល់នឹងមួយនេះ ។ ចិត្តរបស់យើងគឺត្រូវតែបានតាំងនៅមាំ ហើយចុះចូល និងនៅតែបន្តថ្វាយការសរសើរ ភាពបរិសុទ្ធទាំងនេះ ចំពោះការថ្វាយបង្គំ ដ៏ពិតនេះ ។

ម្យ៉ាងទៀត យើងបានចូលទៅខាងក្នុង គឺយើងមិនត្រូវធ្វើឱ្យមានការរួញថយចេញពីព្រះវត្តមានរបស់ទ្រង់នោះ ឡើយ ។ យើងត្រូវតែឈរឱ្យមាំមួន ហើយមិនត្រូវថយនោះឡើយ គឺយើងត្រូវធ្វើឱ្យជីវិតយើងបានផ្លាស់ប្រែ ។ យើងត្រូវបានជាអ្នកឈរឱ្យបានកាន់តែជិតស្និទ្ធឡើង ដែលមានការរំភើបចំពោះបុគ្គលិកលក្ខណៈរបស់ទ្រង់ ដែលមិនអាច រលុបបាន គឺអាចបង្កើតវិញ្ញាណរបស់យើងបាន ។ មានពេលវេលាជាច្រើនដែលយើងបានចំណាយ នៅក្នុងព្រះវត្តមាន របស់ទ្រង់រួមសេចក្តីមកគឺយើងបាននៅក្នុងភាពជិតស្និទ្ធជាមួយនឹងទ្រង់យ៉ាងជ្រៅ រីឯវិញ្ញាណរបស់យើងក៏បានបញ្ជាក់ទៅរូបភាពរបស់ទ្រង់ផងដែរ ហើយជីវិតរបស់យើងក៏មានការផ្លាស់ប្រែ ចូលទៅក្នុងរូបភាពរបស់ព្រះរាជបុត្រានៃព្រះ គឺជាព្រះយេស៊ូវនោះឯង ដែលធ្វើឱ្យយើងរឹតតែបានត្រឡប់ទៅជាដូចព្រះអង្គដូច្នោះដែរ ។

នៅខគម្ពីរខាងក្រោមនេះ ដែលមានការទំនាក់ទនងនូវកម្រិតដ៏ខ្ពស់បំផុត គឺដែលយើងអាចស្តាប់ឮយ៉ាងជាក់ ច្បាស់ពីទ្រង់ ។ ចិត្តរបស់យើងស្រែកថា ត្រូវតែព្រមព្រៀងជាមួយនឹងស្តេចដាវីឌ ដែលទ្រង់បានសរសេរថា:

**ឱព្រះអង្គអើយ ព្រលឹងទូលបង្គំដង្ហក់រកទ្រង់ ដូចជាក្តាន់ញីដង្ហក់រកជ្រោះទឹក ព្រលឹងទូលបង្គំស្រេករកព្រះ គឺព្រះដ៏មានព្រះជន្មរស់នៅ តើដល់កាលណាបានទូលបង្គំ នឹងមកឈរចំពោះទ្រង់** (ទំនុកដំកើង ៤២:១,៣) ។

គឺជាស្តេចដាវីឌដែលបាននាំយកហឹបត្រឡប់មកកាន់ក្រុងយេរូសាឡិមវិញ គឺបន្ទាប់ពីមានការចាប់យកហឹប នោះទៅ ។ ស្តេចដាវីឌគឺជាមនុស្សម្នាក់ ដែលមានចិត្តជិតជាប់នឹងព្រះ ហើយក៏នៅតែបន្តដើរតាមព្រះវត្តមានរបស់ទ្រង់ ជាបន្តទៅទៀតដែរ ។ អស់រយៈកាល៤០ឆ្នាំមកហើយ រហូតមកដល់ព្រះវិហាររបស់ស្តេចសាឡូម៉ូន ដែលត្រូវបានសាង សង់ហើយ រីឯហឹបដែលជាតំណាងឱ្យព្រះវត្តមាននៃព្រះ ក៏បាននៅក្នុងរោងឧបោសថរបស់ស្តេចដាវីឌដែរ ។ គ្មានវាំង នន ដែលខ័ណ្ឌជាកណ្តាលរវាងមនុស្សនិងព្រះទេ ។ ហឹបនោះមានពេញដោយរូបភាពបង្ហាញទាំងអស់របស់ពួកអ្នកថ្វាយ បង្គំ ។

មានតែជង្វាយទេដែលនៅក្នុងរោងឧបោសថរបស់ស្តេចដាវីឌ ដែជាដង្វាយត្រូវថ្វាយជាបន្តចំពោះការសរសើរ តម្កើងដល់ព្រះ ។ រោងឧបោសថរបស់ស្តេចដាវីឌ បានត្រឡប់មកជាគំរូនៃការថ្វាយបង្គំ សម្រាប់ពួកជំនុំនៅសម័យសព្វ ថ្ងៃនេះ ។

នៅក្នុងព្រះគម្ពីរកិច្ចការ ១៥:១៦,១៧ លោកសាវ៉កយ៉ាកុប បានលើកឡើងពីព្រះគម្ពីរអេម៉ុស ៩:១១,១២ បានចែងមកថា:

**នៅថ្ងៃនោះអញនឹងលើកទីលំនៅរបស់ដាវីឌឡើងវិញ គឺជាទីដែលត្រូវរលំ ហើយនឹងបិទចន្លោះបាក់បែកឱ្យជិត អញនឹងលើកទីខូចបង់ឡើង ហើយសង់ឡើងឱ្យដូចជាកាលពីដើម ដើម្បីឱ្យគេបានធ្វើជាម្ចាស់ លើសំណល់នៃសាសន៍ អេដំម និងអស់ទាំងសាសន៍ផ្សេងៗដែលបានហៅតាមឈ្មោះអញ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ា ដែលទ្រង់ធ្វើការ ទាំងនេះ ។**

នៅសម័យសព្វថ្ងៃនេះ យើងកំពុងតែមានការពិសោធន៍ នូវសេចក្តីទំនាយដែលបានសម្រេចហើយទាំងនេះថា គឺជាព្រះដែលទ្រង់បានកែជាថ្មីឡើងវិញ នូវការសរសើរតម្កើង និងការថ្វាយបង្គំដ៏ពិតដល់ពួកជំនុំរបស់ទ្រង់ ។ ដូចជាស្តេចដាវីឌបានអនុញ្ញាតឱ្យយើងម្នាក់ៗ សម្រេចចិត្តឱ្យមានជាចលនាទីករស់ នៅកំឡុងពេលនៃការធ្វើឱ្យជាក់ច្បាស់ទាំង នេះ ។ ចូរយើងចូលទៅក្នុងព្រះវត្តមាននៃទ្រង់ ហើយបញ្ចេញនូវវិញ្ញាណរបស់យើងឱ្យបានស្រស់ស្រាយឡើង ឱ្យបាន ត្រឡប់ទៅជាថ្មី និងទទួលការពិសោធន៍ចំពោះការសរសើរតម្កើងដល់ព្រះ ដែលមានពេញដោយអំណាចចេស្តា ។

**សេចក្តីអធិស្ឋានរបស់ខ្ញុំគឺសូមឱ្យអ្នករាល់គ្នា ចូលឱ្យបានកាន់តែ ជិតស្និទ្ធទៅក្នុងព្រះវត្តមានរបស់ព្រះ និងមានការពិសោធន៍ក្នុងការចូល ទៅកាន់តែជ្រៅ និងបានទទួលនូវបទពិសោធន៍ជីវិតដែលមានការផ្លាស់ ប្រែ នៅក្នុងការថ្វាយបង្គំដ៏ពិត ។**

# មេរៀនទី ១
# *ការសរសើរ និងការថ្វាយបង្គំ*

## សេចក្តីផ្តើម

មានចលនាមួយដ៏ថ្មីៗ ស្រស់ៗនៃព្រះវិញ្ញាណបរិសុទ្ធ ដែលធ្វើឱ្យមានការពិសោធន៍នៅជុំវិញពិភពលោក ។ ម្យ៉ាងទៀត ការងារថ្វាយបង្គំនៅក្នុងពួកជំនុំជាច្រើន គឺហាក់ដូចជាមានការសោះកក្រោះ និងមានការសោកសង្រេងទៅវិញ ។ ចម្រៀងតាមទំនៀមទម្លាប់ គឺបានផុសចេញពីក្នុងចិត្តមកត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ ដែលជាចម្រៀងដកស្រង់ចេញពីទំនុកតម្កើងចាស់ៗមកនោះ ។ នៅសម័យសព្វថ្ងៃនេះ គឺមិនដែលត្រូវបានគេស្វែងរកឃើញពួកអ្នកជឿដែលនៅក្នុង ពួកជំនុំជាច្រើន ឱ្យបានមានជំហរក្នុងការច្រៀងសរសើរ ការទះដៃសរសើរ ដោយដៃរបស់ពួកគេ ព្រមទាំងការសរសើរតម្កើងនៅចំពោះព្រះភ័ក្ត្រនៃព្រះអម្ចាស់ឡើយ ។ មានការពិសោធន៍ជាច្រើនចំពោះអត្ថន័យនៃការថ្វាយបង្គំដ៏ពិត នោះគឺជាការដែលពួកគេបានលុតជង្គង់ចុះ ហើយលើកដៃឡើងសរសើរដល់ព្រះ ទាំងស្រក់ទឹកភ្នែកចេញពីភ្នែករបស់ពួកគេ ដើម្បីកុំឱ្យទទួលការបាត់បង់នូវព្រះវត្តមាននៃព្រះ នៅពេលដែលពួកគេកំពុងតែច្រៀងសរសើរតម្កើងដល់ព្រះ ដើម្បីឱ្យការ ថ្វាយបង្គំដល់ទ្រង់នោះមានកម្លាំងកាន់តែខ្លាំងក្លាឡើង ។

គ្រប់ប្រភេទឧបករណ៍ភ្លេងទាំងអស់ គឺត្រូវតែប្រគល់ឱ្យទៅពួកជំនុំវិញ។ នៅក្នុងព្រះវិហារគឺមិនត្រូវបានប្រគុំបទចម្រៀងដ៏យូរអង្វែងឡើយ គឺពួកក្រុមចម្រៀង ឬពួកអ្នកចម្រៀងមានការប្រកបទាក់ទងជាមួយនឹងព្រះ ដោយមានរយៈពេលខ្លីប៉ុណ្ណោះ។ ផ្ទុយទៅវិញ ពួកអ្នកជឿទាំងឡាយ គឺមានការពិសោធន៍ ក្នុងការចាក់ប្រេងតាំងរបស់ព្រះ តាមមធ្យោបាយថ្មីៗជាប់ជានិច្ច ។

ជាញឹកញាប់ សិរីល្អរបស់ផងព្រះតែងចាក់បំពេញមកដល់សាលប្រជុំ គឺជាអំណោចេស្ដារបស់ទ្រង់បានបក់បោកឆ្លងកាត់ព្រះវិហារ ដោយមានជាការរលកវិពើកឡើង ។ ដូចជានៅក្នុងថ្ងៃនៃការឆ្លងព្រះវិហារ គឺវាមានលទ្ធភាពចំពោះ ការឈរនៅលើបង្គោលពពកនៃសិរីល្អរបស់ទ្រង់ដូច្នោះដែរ ។

ព្រះគម្ពីរ១ពង្សាវតារក្សត្រ ៨:១០,១១ ចែងថា: **លុះពួកសង្ឃបានចេញពីទីបរិសុទ្ធមកវិញ នោះពពកក៏មកពេញក្នុងព្រះវិហារនៃព្រះយេហូវ៉ា លំម្ល៉េះបានជាពួកសង្ឃឈរធ្វើការងារពុំបាន ដោយព្រោះពពកនោះ ដ្បិតសិរីល្អនៃព្រះយេហូវ៉ាបាននៅពេញក្នុងព្រះវិហារនៃព្រះអង្គហើយ ។**

## ការតាំងពិពណ៌របស់ស្ដេចដាវីឌ

ស្ដេចដាវីឌគឺជាមួយអង្គ ដែលបានចេះពីរបៀបថ្វាយនូវការសរសើរដល់ព្រះ ។ ចូរយើងក្រឡេកមើលទៅពាក្យស្លោកនៃការតាំងពិពណ៌ ដែលមានពាក់កណ្ដាល គឺជាអ្វីដែលព្រះវិញ្ញាណបរិសុទ្ធទ្រង់ បានកំពុងតែធ្វើនៅសម័យសព្វថ្ងៃនេះ ក្នុងការកែនូវការថ្វាយបង្គំដ៏ពិតដល់ពួកជំនុំរបស់ទ្រង់ ។

ព្រះគម្ពីរទំនុកដំកើង ១៥០:១-៦ ចែងថា: **ចូរសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះ នៅក្នុងទីបរិសុទ្ធរបស់ទ្រង់ ចូរសរសើរដល់ទ្រង់ នៅចន្លោះអាកាស ជាទីសំដែងព្រះចេស្ដាទ្រង់ ចូរសរសើរដល់ទ្រង់ដោយព្រោះការឥទ្ធិឫទ្ធិរបស់ទ្រង់ ចូរសរសើរដល់ទ្រង់ ឱ្យសមនឹងសណ្ឋានដ៏ធំប្រសើររបស់ទ្រង់ ចូរសរសើរទ្រង់ដោយត្រែ ចូរសរសើរដល់ទ្រង់ដោយដេញពិណ និងចាប៉ីស៊ុង ចូរសរសើរដល់ទ្រង់ដោយវាយក្រាប់ ហើយលោតកញ្ឆេង ចូរសរសើរទ្រង់ដោយប្រដាប់មានខ្សែ ហើយនិងខ្លុយ ចូរសរសើរដល់ទ្រង់ដោយវាយឈឹងឱ្យឮរងំ ចូរសរសើរទ្រង់ដោយវាយឈឹងឮសូរវំពង គួរឱ្យជីវិតទាំងឡាយដែលមានដង្ហើម បានសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។**

យើងរាល់គ្នាគួរគប្បីសរសើរតម្កើងដល់ព្រះអម្ចាស់!

**និយមន័យ**

➢ *ការសរសើរតម្កើង*

ការសរសើរតម្កើង គឺជាការចង្អុលបង្ហាញពីការដឹងគុណ និងការអរព្រះគុណដ៏អស់ពីចិត្តដល់ព្រះ សម្រាប់គ្រប់ការទាំងអស់ ដែលទ្រង់បានធ្វើសម្រេចដល់យើងរាល់គ្នា ។ វាជាការចង្អុលបង្ហាញខាងផ្នែករូបកាយ និងការបញ្ចេញសម្លេងនូវការដឹងគុណដ៏អស់ពីចិត្តរបស់យើង ទៅដល់ព្រះ សម្រាប់គ្រប់ការទាំងអស់ នៃព្រះពរដ៏អស្ចារ្យដែលទ្រង់បានប្រទានមក ។

➢ *ការថ្វាយបង្គំ*

ការថ្វាយបង្គំគឺជាទម្រង់ដ៏ខ្ពស់បំផុតនៃការសរសើរតម្កើង។ ចំពោះគ្រប់ទាំងដំណើរនៃព្រះពរដ៏អស្ចារ្យដែលហួសពីគំនិត ដែលយើងបានគិតនោះ គឺយើងកំពុងតែចង្អុលបង្ហាញនូវការកោតសរសើរ និងការលើកតម្កើងរបស់យើងដល់ព្រះ សម្រាប់ភាពជាបុគ្គល បុគ្គលិកលក្ខណៈរបស់ទ្រង់ ដែលបានកំណត់ដោយមានភាពគ្រប់ល័ក្ខណ៍ ។

យើងរាល់គ្នាកំពុងតែបំពេញការងារថ្វាយព្រះ សម្រាប់អស់អ្នកដែលទ្រង់បានតាំងឡើង គឺមិនត្រឹមតែសម្រាប់អ្វីដែលទ្រង់បានធ្វើសម្រាប់យើងរួចហើយនោះឡើយ ។

## ការប្រៀបធៀបពីការសរសើរតម្កើង និងការថ្វាយបង្គំ

**ការសរសើរតម្កើង**

**ការសរសើរតម្កើងគឺជា:**

- *ការនិយាយនូវពាក្យសម្ដីល្អៗទៅកាន់ព្រះ*
- *ការចង្អុលបង្ហាញពីការកោតសរសើរសម្រាប់...*
- *ការពោលពាក្យសរសើរ*
- *ការលើកសរសើរ*
- *ការសម្ដែងនូវសេចក្ដីសរសើរ*

- *ការសរសើរដោយទះដៃ*
- *ការថ្លែងនូវពាក្យសរសើរ*

ការសរសើរតម្កើងគឺជាការនិយាយ ឬជាការច្រៀងអំពីព្រះថា ទ្រង់គឺជា ព្រះដ៏អស្ចារ្យ គឺសម្រាប់អ្វីៗដែលទ្រង់បានធ្វើសម្រាប់យើងរាល់គ្នានោះឯង ។

**ការថ្វាយបង្គំ**

**ការថ្វាយបង្គំគឺជា:**

- *ការចង្អុលបង្ហាញនូវការថ្វាយបង្គំដោយលុតជង្គង់គោរព*
- *ការមានវិញ្ញាណកោតខ្លាច*
- *ការក្រាបចុះយ៉ាងទាបបំផុតនៅក្នុងការថ្វាយបង្គំ*
- *ការគោរពដ៏មានតម្លៃ*
- *ការថ្វាយគ្រប់ការទាំងអស់ទៅព្រះ*

ការថ្វាយបង្គំគឺជាការនិយាយ ឬជាការច្រៀងថ្វាយទៅកាន់ព្រះ ។ លោកអ្នកបានឆ្លងផុតនូវចំណុចនៃការគិតអំពីរឿងរ៉ាវ ដែលទ្រង់បានធ្វើសម្រេច ព្រមទាំងបានចូលទៅក្នុងការថ្វាយបង្គំ គឺចំពោះអស់អ្នកដែលទ្រង់បានជ្រើសរើសទុក។

- *ការសរសើរតម្កើងដ៏ខ្ពស់បំផុត*

ការថ្វាយបង្គំគឺជាទម្រង់នៃការសរសើរតម្កើងដ៏ខ្ពស់បំផុត ។

**ទីមួយគឺជា:**

- *ការសម្តែងអាកប្បកិរិយាអស់ពីចិត្ត*
- *ការតាំងចិត្តគោរពដ៏មាំមួនចំពោះព្រះអាទិករ*
- *ការចាប់ផ្តើមនូវការជញ្ជឹងគិតនៅក្នុងចិត្តដ៏អស់ពីចិត្ត*
- *ការជញ្ជឹងគិតដ៏មានជម្រៅជ្រៅចំពោះភាពដ៏ធំឧត្តម និងភាពមានតម្លៃរបស់ព្រះ ។*

បន្ទាប់មកវានឹងមានការបង្ហូរមកដោយឯកឯងនៃគំនិត និង អារម្មណ៍ ។ ការថ្វាយបង្គំមិនអាចត្រូវបានគេ "បង្កើតឡើង" បាននោះឡើយ គឺវាត្រូវតែបាន គេបញ្ចូលវាទៅដល់ផ្នែកខាងក្នុងវិញ ។

ជាទីបញ្ចប់ វាជាការចាក់ចេញនៃព្រលឹង ដោយការចង្អុលបង្ហាញដ៏មានជម្រៅជ្រៅនៃការគោរពយ៉ាងជ្រាលជ្រៅ ការកោតខ្លាចខ្លាំង ការអស្ចារ្យ និងការគោរពជាដើម ។

## តើការថ្វាយបង្គំគឺជាអ្វី?

មុនពេលដែលយើងអាចចូលទៅក្នុងការថ្វាយបង្គំ នោះគឺជាការចាំបាច់ ឱ្យយល់នូវអ្វីជាការថ្វាយបង្គំនោះ ។

### ដោយនូវព្រះវិញ្ញាណ

យើងអាចថ្វាយនូវការថ្វាយបង្គំដ៏ពិតដល់ព្រះ ដែលចេញពីវិញ្ញាណរបស់យើងរាល់គ្នា ។

ព្រះគម្ពីរយ៉ូហាន ១៤:២៤ ចែងថា: **អ្នកណាដែលមិនស្រឡាញ់ខ្ញុំ នោះមិនកាន់តាមពាក្យខ្ញុំទេ ឯពាក្យដែលអ្នករាល់គ្នាឮ នោះមិនមែនជាពាក្យខ្ញុំ គឺជាព្រះបន្ទូលរបស់ព្រះវរបិតា ដែលទ្រង់ចាត់ឱ្យខ្ញុំមកទេតើ ។**

ការថ្វាយបង្គំដោយវិញ្ញាណ គឺត្រូវតែថ្វាយបង្គំដោយអស់ពីចិត្តរបស់យើង ការថ្វាយបង្គំដោយវិញ្ញាណ ក៏មានន័យថា ជាការថ្វាយបង្គំដែលចេញពីចិត្តរបស់យើង ដោយនូវអំណាចចេស្តានៃព្រះវិញ្ញាណបរិសុទ្ធដែលគ្រប់ទាំងអស់គឺស្ថិតនៅ ផ្នែកខាងក្នុង ស្ទើរតែគ្រប់កន្លែងដូចៗគ្នា ដែលព្រះគម្ពីរបានហៅថា ជាចិត្ត ឬជាវិញ្ញាណរបស់យើង ។

### ដោយសេចក្តីពិត

ការថ្វាយបង្គំដោយសេចក្តីពិត គឺត្រូវតែថ្វាយបង្គំ និងបើកឱ្យព្រះអម្ចាស់ ទ្រង់បានពិនិត្យមើលជម្រៅចិត្តផ្នែកខាងក្នុងរបស់យើង ។

ព្រះគម្ពីរសុភាសិត ២០:២៧ ចែងថា: **វិញ្ញាណរបស់មនុស្សជាចង្កៀងនៃព្រះយេហូវ៉ា ក៏ស្ទង់មើលទៅគ្រប់ក្នុងចំណែកនៃរាងកាយ ។**

ព្រះគម្ពីរយ៉ូហាន ១៤:១៦,១៧ ចែងថា: **នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹងប្រទានព្រះដ៏ជាជំនួយ១អង្គទៀត មកអ្នករាល់គ្នាឱ្យបានគង់នៅជាមួយ នៅអស់កល្បរៀងទៅ គឺជាព្រះវិញ្ញាណនៃសេចក្តីពិត ដែលលោកិយទទួលពុំបាន ព្រោះមិនឃើញ ហើយមិនស្គាល់ទ្រង់សោះ តែអ្នករាល់គ្នាស្គាល់ទ្រង់ ដ្បិតទ្រង់គង់ជាមួយ ក៏នឹងសណ្ឋិតនៅក្នុងអ្នករាល់គ្នាដែរ ។**

## ការសម្អាតខ្លួនឯង

យើងមិនអាចថ្វាយបង្គំព្រះបាន តាមផ្នែកខាងសាច់ឈាមរបស់យើងនោះបានឡើយ គឺវាជាការសំខាន់ដើម្បីសម្អាត នូវគ្រប់ទាំងគំនិតខាងសាច់ឈាមទាំងអស់របស់យើង ព្រមទាំងសេចក្តីអាក្រក់ ដើម្បីឱ្យវិញ្ញាណរបស់យើង អាចថ្វាយបង្គំព្រះដោយនូវព្រះវិញ្ញាណរបស់ទ្រង់បាន ។

ព្រះគម្ពីរកូល៉ុស ៣:៥ ចែងថា: **ដូច្នេះចូរសំឡាប់និស្ស័យសាច់ឈាមរបស់អ្នករាល់គ្នា ដែលនៅផែនដីនេះចេញ គឺជាការសហាយស្មន់ ស្មោកគ្រោក សំរើបសំរាល ប៉ងប្រាថ្នាអាក្រក់ និងសេចក្តីលោភ ដែលរាប់ទុកដូចជាការថ្វាយបង្គំរូបព្រះ ។**

ព្រះគម្ពីរកូល៉ុស ៣:១៦,១៧ ចែងថា: **ចូរឱ្យព្រះបន្ទូលនៃព្រះគ្រីស្ទ បានសណ្ឋិតនៅក្នុងអ្នករាល់គ្នាជាបរិបូរ ដោយប្រាជ្ញាគ្រប់យ៉ាង ទាំងបង្រៀនហើយទូន្មានគ្នា ដោយនូវទំនុកដំកើង ទំនុកបរិសុទ្ធ និងចំរៀងខាងឯវិញ្ញាណ ទាំងច្រៀងក្នុងចិត្តថ្វាយព្រះ ដោយព្រះគុណ ហើយក្នុងគ្រប់ការទាំងអស់ ទោះបើការអ្វីដែលអ្នករាល់គ្នានឹងធ្វើ ដោយពាក្យសំដីឬកិរិយាក៏ដោយចូរធ្វើទាំងអស់ ដោយព្រះនាមនៃព្រះអម្ចាស់យេស៊ូវ ទាំងអរព្រះគុណដល់ព្រះដ៏ជាព្រះវរបិតា ដោយសារទ្រង់ផង ។**

យើងត្រូវតែសម្អាតដោយខ្លួនឯង និងថ្វាយបង្គំព្រះដែលចេញពីចិត្តដ៏បរិសុទ្ធនោះ។ សាច់ឈាមមិនអាចថ្វាយបង្គំព្រះបានឡើយ ។ ប្រសិនបើ

យើងបានទុំល្អមហើយ នោះគ្រប់ទាំងអស់ដែលមិនបានធ្វើសម្រាប់ព្រះនោះនឹងមិនបានបន្សល់ទុកឡើយ តែឯវិញ្ញាណរបស់យើងនឹងថ្វាយបង្គំដោយនូវព្រះវិញ្ញាណនៃព្រះវិញ ។

## លោកអ័ប្រាហាំគឺជាគំរូទីមួយរបស់យើង

### លោកអ័ប្រាហាំបានថ្វាយបង្គំ

តាមខយោងនៅក្នុងព្រះគម្ពីរជាដំបូងចំពោះថ្វាយបង្គំ គឺជាការតភ្ជាប់ជាមួយនឹងលោកអ័ប្រាហាំ ។

ព្រះគម្ពីរលោកុប្បត្តិ ២២:៥ ចែងថា: **រួចប្រាប់ទៅបាវថា ចូរឯងនៅទីនេះសិនមើលលាផង អញនឹងទៅឯណោះថ្វាយបង្គំជាមួយនឹងកូនអញ រួចសឹមមកឯឯងវិញ ។**

### ក្រឹត្យវិន័យដែលបានបើកសម្តែងលើកទីមួយ

មានគោលការណ៍នៃការបកស្រាយព្រះគម្ពីរ ដែលត្រូវបានទទួលការត្រាស់ហៅថាជា "ក្រឹត្យវិន័យដែលបានបើកសម្តែងលើកទីមួយ" ។ ព្រះគម្ពីរនោះបានចែងថា ការបើកសម្តែងតាមព្រះគម្ពីរជាទីមួយ នៃប្រធានបទជាច្រើន ដែលបានប្រទានឱ្យនូវការបញ្ជាក់បង្ហាញយ៉ាងច្បាស់មួយនៃអត្ថន័យ និងសេចក្តីសំខាន់របស់វា នៅទីកន្លែងដទៃទៀត ដែលបានកើតឡើងនៅក្នុងព្រះគម្ពីរ ។

ការជួបប្រទះជាលើកទីមួយនៃពាក្យ "ថ្វាយបង្គំ" គឺត្រូវបានគេរកឃើញ នៅពេលដែលលោកអ័ប្រាហាំកំពុងតែបាននិយាយជាមួយនឹងមនុស្សកម្លោះ២ ដែលបានលើកតម្លៃដល់លោកអ៊ីសាក និងដល់គាត់ ឱ្យធ្វើដំណើរទៅកាន់ភ្នំម៉ូរ៉ា (Moriah) ។

ភាពធ្ងន់ធ្ងរនៃការថ្វាយបង្គំ គឺត្រូវបានបង្ហាញតាមការបើកសម្តែងទីមួយនេះ ។

**លោកអ័ប្រាហាំបានស្តាប់បង្គាប់**

ការទទួលខុសត្រូវរបស់លោកអ័ប្រាហាំ ចំពោះការតាំងសញ្ញារបស់ព្រះ គឺមានតែការស្តាប់បង្គាប់តែមួយគត់ ។

គ្មានមធ្យោបាយសម្រាប់យើងចំពោះការគិតពីអ្វី ក្រៅពីការស្តាប់បង្គាប់តាមព្រះរាជបញ្ញត្តិនេះ ដែលជាការទាមទាររបស់លោកអ័ប្រាហាំនោះឡើយ ។ លោកអ៊ីសាកគឺជាកូននៃសេចក្តីសន្យា ។ គាត់គឺជាអ្នកត្រូវបានសម្រេចតាមសេចក្តីសញ្ញា ដែលព្រះទ្រង់បានធ្វើជាមួយនឹងលោកអ័ប្រាហាំ ។

**យញ្ញបូជាដ៏មានឥទ្ធិពល**

ចំពោះសកម្មភាពនៃការថ្វាយបង្គំនៅពេលនេះ គឺជាការពិត ដែលជាសកម្មភាពនៃការថ្វាយយញ្ញបូជាដ៏មានឥទ្ធិពលមួយ ។ សកម្មភាពនៃការថ្វាយបង្គំនេះ គឺត្រូវតែបានជាការទាមទាររបស់លោកអ័ប្រាហាំ គឺជាការដ៏ប្រសើរបំផុតរបស់គាត់ ជាដង្វាយដ៏ខ្ពង់ខ្ពស់ដែលគាត់អាចមានលទ្ធភាពធ្វើ ។

សកម្មភាពនៃការថ្វាយបង្គំអាចនៅតែមានអ្នកធ្វើ ជាយញ្ញបូជាលក្ខណៈបុគ្គលដ៏ប្រសើរឧត្តមនោះឯង ។

ព្រះគម្ពីររ៉ូម ១២:១,២ ចែងថាៈ **ដូច្នេះ បងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នាដោយសេចក្តីមេត្តាករុណានៃព្រះ ឱ្យបានថ្វាយរូបកាយទុកជាយញ្ញបូជារស់ ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ជាការគោរពនៃអ្នករាល់គ្នា ដែលមានទំនង កុំឱ្យត្រាប់តាមសម័យនេះឡើយ ចូរឱ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ដើម្បីនឹងអាចលមើលឱ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះ ដែលល្អ ស្រួលទទួល ហើយគ្រប់លក្ខណ៍ផង ។**

ការថ្វាយបង្គំដ៏ពិតមានន័យថា មានការចុះចូលគ្រប់លក្ខណៈទាំងអស់ ទៅដល់ព្រះ ។

**សកម្មភាពនៃការស្តាប់បង្គាប់ និងសេចក្តីជំនឿ**

សកម្មភាពនៃការថ្វាយបង្គំ គឺជាសកម្មភាពនៃការស្តាប់បង្គាប់ និងសេចក្តីជំនឿ ។ លោកអ័ប្រាហាំ គឺពិតប្រាកដណាស់ មិនដែលមានការភ្លាំងភ្លាត់ចំពោះ ការថ្វាយបង្គំនេះឡើយ ។

នៅថ្ងៃទីបីនៃដំណើររបស់គាត់ ដើម្បីនាំយកលោកអ៊ីសាកទៅថ្វាយជាដង្វាយ នោះលោកអ័ប្រាហាំបានមានប្រសាសន៍ថា "យើងនឹងត្រឡប់មកឯអ្នកវិញ" ។

សកម្មភាពនៃការស្តាប់បង្គាប់ បានវិលត្រឡប់មកឯសកម្មភាពនៃសេចក្តីជំនឿវិញ ។

**ការចុះចូលទាំងស្រុងខាងផ្នែករូបកាយ**

សេចក្តីស្លាប់របស់លោកអ៊ីសាក គឺមានន័យថា ជាសេចក្តីស្លាប់គ្រប់បែបយ៉ាង ដែលលោកអ័ប្រាហាំបានរស់នៅសម្រាប់គ្រប់ការទាំងអស់នោះ ។ គ្រប់ទាំងសេចក្តីសន្យា នៅក្នុងការតាំងសញ្ញា គឺជាមូលដ្ឋានគ្រឹះទៅលើកំណើតកូនប្រុសរបស់គាត់នោះឯង ។ គ្រប់យ៉ាងដែលគាត់បានជឿ គឺជាការរួមបញ្ចូលជា មួយនឹងលោកអ៊ីសាកនោះឯង ។ វាជាសកម្មភាពមួយ ដែលសរុបមកនូវការចុះ ចូលចំពោះព្រះនោះឯង ។

ដោយសារតែការស្តាប់បង្គាប់របស់លោកអ័ប្រាហាំ ក្នុងការថ្វាយបង្គំ នោះព្រះទ្រង់បានគង់នៅក្នុងការសរសើតម្កើតងនោះ ព្រមទាំបាននាំមកនូវអំណោយទានពិសេសៗនៃសេចក្តីជំនឿ ដែលបានបង្ខំឱ្យលោកអ័ប្រាហាំប្តេជ្ញាថានឹងថ្វាយលោកអ៊ីសាកទុកជាយញ្ញបូជា ។

ព្រះគម្ពីរទំនុកដំកើង ២២:៣ ចែងថា: **ប៉ុន្តែ ឱព្រះដែលបានតាំងឡើង ក្នុងទំនុកសរសើររបស់អ៊ីស្រាអែលអើយ ទ្រង់បរិសុទ្ធ ។**

លោកអ័ប្រាហាំបាននាំកូនប្រុសរបស់គាត់ ចេញទៅកាន់ទីថ្វាយយញ្ញបូជា ហើយការនេះបានត្រឡប់ទៅជាគំរូនៃការថ្វាយយញ្ញបូជា ផ្ដាច់ព្រាត់ទៅវិញ ។ ក្រោយមកយើងឃើញថា ព្រះដ៏ជាព្រះវរបិតាទ្រង់បានបញ្ជូនដង្វាយយញ្ញបូជា គឺជាព្រះរាជបុត្រារបស់ទ្រង់ព្រះនាមព្រះយេស៊ូវគ្រីស្ទមក ។ មានព្រឹត្តិការណ៍មួយដ៏មានកម្លាំង មានលទ្ធភាព ដែលព្រះយេស៊ូវទ្រង់បានត្រូវទទួលការធ្វើជាយញ្ញបូជា ជំនួសឱ្យលោកអ៊ីសាក ដែលលោកអ័ប្រាហាំបានបញ្ជូនទៅឱ្យធ្វើជាយញ្ញបូជានោះ ។

យើងត្រូវតែចុះចូលគ្រប់ការទាំងអស់ នូវការសម្រេចចិត្តជាលក្ខណៈបុគ្គល ការលោភលន់ខ្លាំង ព្រមទាំងដាក់ផែនការ ចូលទៅដល់ទីថ្វាយបង្គំដ៏ពិតវិញ ។

## តម្លៃនៃការសរសើរតម្កើង

### ចំពោះស្ដេចសូល

➢ *ការមានបញ្ហាដោយពួកវិញ្ញាណអាក្រក់*

ព្រះគម្ពីរ១សាំយូអែល ១៦:១៤-១៧,២៣ ចែងថា: **គ្រានោះព្រះវិញ្ញាណនៃព្រះយេហូវ៉ា ក៏ដកថយចេញពីសូលទៅ ហើយព្រះយេហូវ៉ាទ្រង់ចាត់វិញ្ញាណអាក្រក់១ឱ្យមកបំភ័យទ្រង់ នោះពួកមហាតលិករបស់សូលទូលថា មើល មានវិញ្ញាណអាក្រក់ពីព្រះមកបំភ័យទ្រង់ហើយ ដូច្នេះសូមឱ្យព្រះអម្ចាស់នៃយើងខ្ញុំ បង្គាប់ដល់យើងខ្ញុំជាពួកអ្នកបំរើរបស់ទ្រង់ដែលនៅជំពោះទ្រង់នេះ ឱ្យរកមនុស្សម្នាក់ដែលប្រសប់ចាប់ស៊ុងមកដើម្បីកាលណាវិញ្ញាណអាក្រក់ពីព្រះបានមកសណ្ឋិតលើទ្រង់ នោះគេនឹងចាប់លេងឡើង ឱទ្រង់បានធូរព្រះទ័យថយទៅ សូលក៏មានបន្ទូលទៅពួកអ្នកបំរើថា ដូច្នេះ ចូរទៅរកមនុស្សម្នាក់ដែលចេះលេងពិណោះឱ្យយើងហើយនាំវាមកចុះ... ដូច្នេះ កាលណាវិញ្ញាណអាក្រក់ពីព្រះបានមកសណ្ឋិតលើសូល នោះដាវីឌក៏យកស៊ុងមកចាប់លេងថ្វាយ រួចសូលទ្រង់បានធូរហើយស្រួលឡើងវិញ វិញ្ញាណអាក្រក់ក៏ថយចេញពីទ្រង់ទៅ ។**

➢ *ការប្រគំតន្ត្រីជាការនាំមកនូវការរំដោះ*

កំឡុងពេលដែលវិញ្ញាណអាក្រក់បានមកសណ្ឋិតលើស្តេចសូល នោះដាវីឌបានយកពិណរបស់គាត់មកលេងថ្វាយ ។ បន្ទាប់មក ស្តេចសូលក៏បានទទួលការធូរស្បើយឡើងវិញ គឺទ្រង់មានអារម្មណ៍ល្អឡើងវិញ ហើយវិញ្ញាណអាក្រក់នោះ ក៏បានចាកចេញពីទ្រង់ទៅ ។

ល្អប្រសើរមានន័យថា ពោរពេញដោយជំនាញ ។ អ្នកប្រគំបទភ្លេង និងអ្នកចម្រៀង គួរគប្បីត្រូវបានទទួលនូវជំនាញនេះ ។ អ្នកបម្រើរបស់ស្តេចសូល បានដឹងនូវការស្វែងរកអ្នកជំនាញប្រគំបទភ្លេង ពីព្រោះពួកគេធ្លាប់បានឃើញនូវអំណាចនៃការប្រគំបទភ្លេង ដោយមានការចាក់ប្រេងតាំងជាមុន ។ ដាវីឌក៏ត្រូវបានទទួលការជ្រើសរើសមកធ្វើការនោះ ។

## សំណួររំឭកសារឡើងវិញ

១. ចូរសរសេរពីនិយមន័យ ឬការយល់ដឹងពីការសរសើរតម្កើងរបស់លោកអ្នក ។

២. ចូរសរសេរពីនិយមន័យ ឬការយល់ដឹងពីការថ្វាយបង្គំរបស់លោកអ្នក ។

៣. តើសកម្មភាពរបស់លោកអ័ប្រាហាំមានចរិតលក្ខណៈដូចម្តេចខ្លះ ចំពោះការថ្វាយបង្គំ នៅពេលដែលគាត់ថ្វាយអ៊ីសាក ដែលជាកូនប្រុសរបស់ខ្លួនទៅធ្វើជាយញ្ញបូជា?

# មេរៀនទី ២

## *គំរូរបស់ព្រះសម្រាប់ការថ្វាយបង្គំ*

**ការថ្វាយបង្គំនៅក្នុងរោងឧបោសថ**

គោលការណ៍ដទៃទៀតនៃការបកស្រាយព្រះគម្ពីរគឺជា "ច្បាប់ដែលបានសរសេរទុកជាច្រើន" ។ គោលការណ៍នេះថែងថា ចំនួននៃការសល់ចន្លោះដែលបានប្រទានឱ្យ នូវប្រធានបទដ៏ពិសេសមួយ ដែលបញ្ជាក់បង្ហាញពីសារៈសំខាន់របស់វា ។

នៅជំពូកទី៥១ក្នុងព្រះគម្ពីរសញ្ញាចាស់ គឺត្រូវបានគេបោះបង់រោងឧបោសថ គឺជាការបង្ហាញនូវនូវសារៈសំខាន់របស់ពួកវា ចំពោះយើង ។

**ការរំឭកពីរោងឧបោសថ និងពីព្រះវិហារនៅក្នុងព្រះគម្ពីរសញ្ញាចាស់**

មានរោងឧបោសថ និងព្រះវិហារជាច្រើន ដែលបានបើកសម្តែងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ ចាប់តាំងពីពេលដែលមានកន្លែងខ្វះខាតទាំងនេះ ដែលពួកបណ្តាជនបានជួបជាមួយនឹងព្រះនោះ គឺជាកន្លែងដែលពួកគេបានចូលទៅក្នុងព្រះវត្តមាននៃព្រះអង្គ គឺវាជាការសំខាន់ដែលយើងមានការយល់ដឹងចំពោះពួកគេ និងការផ្សេងគ្នារវាងពួកគេ ។

**រោងឧបោសថរបស់លោកម៉ូសេ**

គំរូ ឬប្លង់អាគារសម្រាប់រោងឧបោសថរបស់លោកម៉ូសេ គឺត្រូវបានប្រទានឱ្យនូវការលម្អិតដ៏ពិតប្រាកដដោយព្រះទ្រង់បានធ្វើទកមក ។ រោងឧបោសថមានន័យថា តង់ ហើយមានប្រយោជន៍ នៅពេលដែលកូនចៅអ៊ីស្រាអែល បាផ្លាស់ប្តូរទីកន្លែងឆ្លងកាត់វាលរហោស្ថាន ។

រោងឧបោសថរបស់លោកម៉ូសេ គឺជាកន្លែងថ្វាយបង្គំនៅក្នុងគ្រាសញ្ញាចាស់ ។ វាជាកន្លែងតាំងនៅបណ្តោះអាសន្នរបស់ហឹបនៃសេចក្តីសញ្ញា ។ នៅទីនោះហើយ ដែលមានព្រះវត្តមាននៃព្រះគង់នៅ ព្រមទាំង

សង្ឃដែលបានបំពេញការងារនៅចំពោះព្រះអម្ចាស់ ។ ជានិច្ចកាល នៅពេលដែលពួកកូនចៅអ៊ីស្រាអែល បានបែរទៅរកអំពើបាប គឺហឹបនោះបានត្រូវដឹកនាំយកទៅដោយខ្មាំងសត្រូវរបស់ពួកគេ ។

រោងឧបោសថរបស់លោកម៉ូសេបានចូលមកតាំងនៅក្នុងភ្នំស៊ីឡូ ។

## រោងឧបោសថរបស់ស្តេចដាវីឌ

ដោយសារតែស្តេចដាវីឌជាអ្នកធ្វើសង្គ្រាម នោះព្រះទ្រង់មិនបានអនុញ្ញាតឱ្យទ្រង់សាងសង់ព្រះវិហារឡើយ ។ ព្រះទ្រង់បានប្រទាននូវគម្រោងផែនការ សម្រាប់សាងសង់ព្រះវិហារដល់ទ្រង់ ហើយស្តេចដាវីឌបានប្រមូលសម្ភារៈមកពីគ្រប់កន្លែង ដើម្បីទុកសម្រាប់ការសាងសង់ព្រះវិហារនោះ ។

រីឯហឹបនៃសេចក្តីសញ្ញាត្រូវដាក់ទុកនៅក្នុងរោងឧបោសថរបស់ស្តេចដាវីឌ ដែលបន្ទាប់ក្រោយមកក៏ត្រូវបាននាំវិលត្រឡប់ទៅវិញ ដោយពួកភីលីស្ទីន ទៅដាក់នៅមុខព្រះវិហាររបស់ស្តេចសាឡូម៉ូន ដែលបានសាងសង់រួចហើយនោះ ។

គោលបំណងជាចម្បងនៃរោងឧបោសថរបស់ស្តេចដាវីឌ គឺត្រូវតែបើកសម្តែងនូវការថ្វាយបង្គំព្រះ តាមមធ្យោបាយដែលត្រូវប្រមូលផ្តុំមកតែមួយកន្លែង ។

រីឯរោងឧបោសថរបស់ស្តេចដាវីឌ គឺត្រូវបានគេមើលឃើញតាម "បង្អួច" ចូលទៅខាងក្នុង ក្នុងការថ្វាយបង្គំនៅគ្រាសញ្ញាថ្មី ។ បង្អួចគឺត្រូវបានធ្វើឡើងដោយប្រភេទនៃត្រសាល ឬជារោងឧបោសថនៅគ្រាសញ្ញាចាស់ ប៉ុន្តែនៅខាងក្នុងគឺត្រូវបានគេធ្វើរួចរាល់ហើយ ដោយបែបផ្សេងៗគ្នានោះឯង ។ រីឯពួកសង្ឃបានចូលទៅខាងក្នុងតាមទ្វារដោយអរព្រះគុណព្រមទាំងចូល ទៅដល់ទីលាននៃការសរសើរ ពីព្រោះហឹបដែលមានព្រះវត្តមាននៃព្រះ គឺពេញទៅដោយលំអ ។ គ្មានទីបរិសុទ្ធបំផុតណា ដែលបាំងដោយវាំងននទៀតទេ គឺមានតែយញ្ញបូជាដែលត្រូវយកចូលទៅថ្វាយតែប៉ុណ្ណោះ គឺជាយញ្ញបូជានៃការសរសើរនោះឯង ។

"បង្គួច" នេះ គឺជា៤០ឆ្នាំចុងក្រោយ រហូតមកដល់ព្រះវិហាររបស់ស្តេចសាឡូម៉ូន ដែលបានសាងសង់រួចហើយនោះឯង ។ បន្ទាប់មក បង្គួចក៏ត្រូវបានបិទ ហើយហឹបនៃសេចក្តីសញ្ញា ក៏ត្រូវបានបញ្ជូនទៅកាន់ព្រះវិហាររបស់ស្តេចសាឡូម៉ូន ។ រីឯសត្វដែលត្រូវធ្វើជាយញ្ញបូជា នោះគឺត្រូវបានគេចាប់ផ្តើមធ្វើជាបន្តទៅទៀត ។

## ព្រះវិហាររបស់ស្តេចសាឡូម៉ូន

ព្រះវិហាររបស់ស្តេចសាឡូម៉ូន គឺត្រូវបានគេគូរប្លង់ជាច្រើន គឺធ្វើដូចជារោងឧបោសថរបស់លោកម៉ូសេ ។ វាត្រូវបានគេសាងសង់ឡើងធ្វើជាដំណាក់ចុងក្រោយ របស់ហឹបនៃសេចក្តីសញ្ញា ។ ទម្រសម្រាប់ប្តូរទីរបស់ហឹបគឺត្រូវរើចេញ ។ ទម្រនេះគឺសម្រាប់ដឹកលំទុកជាអចិន្ត្រៃយ៍ ដែលធ្វើពីថ្មកែវ និងមាស គឺលែងជាត្រសាលបណ្តោះអាសន្នទៀតហើយ ។

ទោះជាយ៉ាងណាក៏ដោយ ជាច្រើនឆ្នាំកន្លងមក ព្រះវិហាររបស់ស្តេចសាឡូម៉ូន គឺត្រូវបានអនុញ្ញាតឱ្យរុះរើចេញ និងជួសជុលសារជាថ្មីឡើងវិញ ។ នៅពេលដែលពួកអ៊ីស្រាអែលត្រូវបានទទួលការបរាជ័យ ហើយពួកស្តេចសាសន៍ដទៃ បានចូលមកសម្លុតទាមទារឱ្យបង់សួយសារអាករដោយកម្រិតខ្ពស់ ដូចជាភាជន៍ធ្វើពីមាសដែលត្រូវបានយកចេញមកពីព្រះវិហារ ដើម្បីទៅជួបដល់ពួកអ្នកសម្លុតទាមទារទាំងនេះ ។ មាសដែលត្រូវបានយកទៅធ្វើជាសួយសារអាករនោះ គឺត្រូវបានយកចេញពីជញ្ជាំង និងពីក្របទ្វារ ។ នៅពេលមួយនោះស្តេចម៉ានាសេបានសង់អាសនាជាច្រើន សម្រាប់ព្រះខុសឆ្គងនៅក្នុងព្រះវិហារ គឺបានធ្វើដំណាក់សម្រាប់ព្រះនៃសាសន៍សូដុំម នៅក្នុងទីធ្លាព្រះវិហារ ព្រមទាំងឆ្លាក់រូបសេះ "សម្រាប់គោរពបូជា" ហើយក៏បានត្រូវសង់នៅទីលានផ្នែកខាងក្នុងថែមទៀតផង ។

ទីបំផុតព្រះវិហាររបស់ស្តេចសាឡូម៉ូន ក៏ត្រូវបានទទួលការបំផ្លាញដោយពួកសាសន៍ខាល់ដេ ដែលបានចូលមកយកវត្ថុដ៏មានតម្លៃគ្រប់បែប

យ៉ាង យកទៅកាន់ប្រទេសបាប៊ីឡូន ហើយក្រោយមក ក៏បានត្រូវយកត្រឡប់មកកាន់ព្រះវិហារដែលជាមូលដ្ឋានដើមវិញ ។

**ព្រះវិហាររបស់សូរ៉ូបាបិល**

ព្រះវិហារនេះគឺត្រូវបានទទួលការសាងសង់ឡើង នៅប្រហែលឆ្នាំ ៥២០ មុន គ.ស. ហើយក៏មិនមែនជាទីកន្លែងដែលរុងរឿង ដូចជាព្រះវិហាររបស់ស្ដេចសាឡូម៉ូននោះទេ គឺមានទំហំធំជាងមុនទៅទៀត ។ វាមានការខ្វះខាតគ្រឿងសង្ហារឹម ដែលមាននៅក្នុងព្រះវិហាររបស់ស្ដេចសាឡូម៉ូនទៅទៀត ។ រីឯហឹបនៃសេចក្ដីសញ្ញាគឺមានការបាត់អស់ហើយ ។

**ព្រះវិហាររបស់ស្ដេចហេរ៉ូត**

នៅពេលដែលស្ដេចហេរ៉ូឌបានគ្រប់គ្រងលើសាសន៍យូដា ទ្រង់បានសាងសង់ឡើងវិញនូវព្រះវិហាររបស់សូរ៉ូបាបិល ។ ស្ដេចហេរ៉ូឌមិនបានសាងសង់ឡើង ដោយមានចិត្តចង់ថ្វាយបង្គំនោះទេ ។ ទ្រង់គ្រាន់តែបានសាងសង់ឡើង ដើម្បីសម្ដែងនូវសេចក្ដីមោទនភាព គឺទ្រង់បានសាងសង់ឡើងនូវសំណង់អាគារជាច្រើន នៅក្នុងរជ្ជកាលរបស់ទ្រង់តែប៉ុណ្ណោះ ។ ព្រះវិហាររបស់សូរ៉ូបាបិល គឺជាធម្មតា១ប៉ុណ្ណោះ មិនមែនជារបស់ដែលមានរិទ្ធិអំណាចគ្រប់គ្រាន់ សម្រាប់ជាការសព្វព្រះទ័យរបស់ទ្រង់នោះឡើយ ។ ការដែលកើតឡើងពិតប្រាកដ គឺជាព្រះវិហាររបស់ស្ដេចហេរ៉ូឌ ដែលព្រះយេស៊ូវទ្រង់បានយាងមក និងទ្រង់យាងវិលត្រឡប់ទៅវិញ ។ ក្រុមរបស់ពួកសង្ឃទាំងអស់នោះ គឺសុទ្ធតែជាមុខងារ ហើយគឺដែលព្រះយេស៊ូវទ្រង់បានផ្កាប់តុសម្រាប់ដូរលុយរបស់ពួកសង្ឃទាំងនោះ ។

ព្រះគម្ពីរម៉ាថាយ ២១:១២,១៣ ចែងថា: **ព្រះយេស៊ូវ ទ្រង់យាងចូលទៅក្នុងព្រះវិហារ ក៏បណ្ដេញអស់ទាំងអ្នកដែលលក់ដូរក្នុងព្រះវិហារចេញ ទ្រង់ផ្កាប់តុនៃពួកអ្នកដូរប្រាក់ និងជើងម៉ារបស់ពួកអ្នកលក់ព្រាប ហើយទ្រង់មានបន្ទូលទៅគេថា មានសេចក្ដីចែងទុកមកដូច្នេះ «ដំណាក់អញត្រូវហៅថា ជាទីសំរាប់អធិស្ឋាន» តែអ្នករាល់គ្នាបានយកធ្វើជារោងចោរវិញ ។**

នៅពេលដែលព្រះយេស៊ូវទ្រង់បានសុគតនៅលើឈើឆ្កាង វាំងនននដែលបាំងនៅជាកណ្តាលរវាងទីបរិសុទ្ធ និងទីបរិសុទ្ធបំផុត (វាំងនននោះមានកម្រាសក្រាសណាស់ គឺប្រហែលជា ៧.២ សង្ទីម៉ែត្រ = ៦ អ៊ីងឯណោះ) គឺកើតឡើងពីភ្យុះអធិធម្មជាតិ ចាប់ពីលើដល់ក្រោម ។

តាមរយៈប្រវត្តិសាស្ត្រនៃពូជពង្សរបស់សាសន៍យូដា គឺមានតែសម្តេចសង្ឃទេ ដែលអាចចេញចូលពីទីបរិសុទ្ធទៅទីបរិសុទ្ធបំផុតបាន ។ ទីបរិសុទ្ធបំផុតគឺជាកន្លែង ដែលបានថែរក្សាហឹបនៃសេចក្តីសញ្ញានៅខាងក្នុងនោះ ។ គឺជាកន្លែងដែលមានព្រះវត្តមាននៃព្រះគង់នៅ ។ រំហែកវាំងននចាប់ពីលើចុះទៅក្រោម គឺជាការប្រកាសប្រាប់ថា ការដាច់ចេញពីព្រះរបស់មនុស្សត្រូវបានផ្សះផ្សាឡើងវិញហើយ ។ មនុស្សជាតិឥឡូវនេះគឺមានឯកសិទ្ធិក្នុងការចូលមករកព្រះវត្តមាននៃព្រះវិញហើយ!

ព្រះយេស៊ូវទ្រង់បានថ្លែងទំនាយថា គ្មានថ្មត្រួតលើថ្មណានៃព្រះវិហារនេះ ដែលមិនត្រូវបំផ្លាញនោះឡើយ ដោយជនជាតិរ៉ូម នៅក្នុងឆ្នាំទី ៧០ មុន គ.ស. គឺទាំងព្រះវិហារ និងបរិវេននៃព្រះវិហារត្រូវបានឆេះខ្ទេចខ្ទី ហើយនៅពេលដែលកំពុងតែឆេះនោះ មាសក៏បានរលាយ និងហូរចូលទៅក្នុងបំណែកថ្មនោះទៅ ។ ដើម្បីធ្វើការយកមាសមកឱ្យបានវិញ ទាល់តែបំបែកថ្មនោះ ដូចជាព្រះយេស៊ូវទ្រង់បានថ្លែងទំនាយទុកមក ។

ព្រះគម្ពីរម៉ាថាយ ២៤:២ ចែងថាៈ **តែទ្រង់មានបន្ទូលទៅគេថា អ្នករាល់គ្នាឃើញវត្ថុទាំងនេះឬទេ ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា នៅទីនេះនឹងគ្មានថ្មនៅត្រួតលើថ្ម ដែលមិនត្រូវទំលាក់ចុះនោះទេ ។**

## ការដើរតាមហឹប

ហឹបបាននៅក្នុងរោងឧបោសថរបស់លោកម៉ូសេ រហូតដល់សម័យរបស់លោកអេលី ។ បន្ទាប់មក ហឹបនោះក៏ត្រូវបានគេលួចយកទៅ គឺជាលទ្ធផលនៃការជំនុំជម្រះដល់ក្រុមគ្រួសាររបស់លោកអេលី ។

ព្រះគម្ពីរ១សាំយូអែល ២:៣០-៣៥ ចែងថាៈ **ហេតុនោះ ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ទ្រង់មានបន្ទូលថា អញបានសន្យា**

**ឱ្យពួកគ្រួឯង និងវង្សព្ធយុកោឯង បានដើរនៅមុខអញជាដរាបទៅ តែឥឡូវនេះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលយ៉ាងនេះវិញថា សូមឱ្យគំនិតនោះបានឆ្ងាយចេញពីអញទៅ ដ្បិតអស់អ្នកណាដែលលើកដំកើងអញ នោះអញនឹងដំកើងអ្នកនោះឡើងដែរ ហើយអ្នកណាដែលមើលងាយដល់អញ នោះអញក៏មិនរាប់អានដល់គេដែរ មើល នឹងមានគ្រាមកដល់ នោះអញនឹងកាត់អំណាចរបស់ឯងចេញ ព្រមទាំងអំណាចនៃពួកវង្សព្ធយុកោឯងដែរ រហូតដល់គ្មានមនុស្សចាស់នៅក្នុងជំនួរវង្សឯងឡើយ នៅកណ្តាលគ្រប់ទាំងការចំរើន ដែលព្រះទ្រង់នឹងប្រោសប្រទានដល់សាសន៍អ៊ីស្រា-អែល នោះឯងនឹងឃើញមានទុក្ខវេទនាកើតដល់ពួកគ្រួសារឯងវិញ ហើយនឹងគ្មានមនុស្សចាស់នៅក្នុងជំនួរវង្សឯងជាដរាបទៅ អញមិនកាត់ពួកឯងទាំងអស់ចេញពីអាសនាអញទេ ជំណែកអ្នកដែលអញមិនកាត់ចេញ នោះនឹងបានសំរាប់នាំឱ្យស្រវាំងដល់ភ្នែកឯង ហើយនឹងបញ្ឈឺចិត្តឯងវិញ ឯពួជដែលចំរើននៅក្នុងគ្រួឯង គេនឹងស្លាប់ទៅ ពីកាលកំពុងនៅពេញវ័យ នេះជាទីសំគាល់ដល់ឯង ជាការដែលត្រូវកើតដល់ហុបនី និងភីនេហាស កូនឯងទាំង២ គឺគេនឹងស្លាប់ទៅទាំង២នាក់នៅថ្ងៃតែ១ រួចអញនឹងបង្កើតឱ្យមានសង្ឃ១ដែលស្មោះត្រង់ដល់អញ ជាអ្នកដែលនឹងធ្វើតាមចិត្តតាមគំនិតអញវិញ ហើយអញនឹងបង្កើតឱ្យអ្នកនោះមានគ្រួដ៏រឹងប៉ឹង អ្នកនោះនឹងដើរនៅចំពោះអ្នកដែលអញចាក់ប្រេងតាំងឱ្យ ជារៀងរាបដរាបទៅ ។**

ហឹបនៃសេចក្តីសញ្ញាគឺត្រូវពួកភីលីស្ទីនលួចយកទៅបាត់ហើយ ក្នុងកំឡុងពេលធ្វើសង្គ្រាម គឺត្រូវបានគេនាំយកទៅនៅជុំវិញទឹកដីរបស់ពួកភីលីស្ទីន ហើយក៏ត្រូវនាំយកនូវការជំនុំជម្រះដល់ពួកគេ នៅទីណាដែលពួកគេបានដឹកនាំហឹបនោះទៅដល់ ។

ព្រះគម្ពីរ១សាំយូអែល ៥:១-៤,៦-៧ ចែងថា: **រីឯពួកភីលីស្ទីនគេចាប់យកបានហឹបនៃព្រះ រួចក៏នាំយកចេញពីអេបេន-អេស៊ើរ ទៅឯក្រុងអាសដូឌទៅ ហើយគេយកទៅដាក់ក្នុងវិហារនៃព្រះដាកុន គឺនៅក្បែរព្រះនោះ លុះស្អែកឡើង កាលពួកក្រុងអាសដូឌបានក្រោកឡើងពីព្រលឹម**

**នោះក៏ឃើញព្រះដាកុនបានដួលផ្កាប់មុខដល់ដី នៅជំពោះហឹបនៃព្រះយេហូវ៉ា រួចគេលើកព្រះដាកុន ទៅដាក់នៅកន្លែងដើមវិញ លុះដល់ថ្ងៃស្អែកទៀត កាលគេក្រោកពីព្រលឹម នោះក៏ឃើញព្រះដាកុនបានដួលផ្កាប់មុខដល់ដី នៅជំពោះហឹបនៃព្រះយេហូវ៉ាទៀតហើយក្បាល និងដៃទាំង២នៃព្រះដាកុន ក៏បាក់ដាច់ នៅលើក្របទ្វារ សល់នៅតែតួព្រះដាកុនប៉ុណ្ណោះ ។**

**ឯព្រះហស្តនៃព្រះយេហូវ៉ា ក៏សង្កត់លើពួកក្រុងអាសដូឌយ៉ាងធ្ងន់ ទ្រង់បំផ្លាញគេ ហើយវាយគេដោយរោគឫសដូងបាត នៅក្រុងអាសដូឌ និងស្រុកជុំវិញទាំងអស់ កាលពួកអាសដូឌឃើញថា កើតមានយ៉ាងដូច្នោះ នោះគេជំនុំគ្នាថា មិនត្រូវឱ្យហឹបនៃព្រះរបស់សាសន៍អ៊ីស្រាអែល នៅជាមួយនឹងយើងទៀតឡើយ ដ្បិតព្រះហស្តនៃទ្រង់សង្កត់លើយើងរាល់គ្នាធ្ងន់ណាស់ ហើយលើព្រះដាកុនជាព្រះនៃយើងដែរ ។**

**ហឹបត្រូវបានបញ្ជូនមកកាន់ក្រុងយេរូសាឡិមវិញ**

ដោយសារតែការជំនុំជម្រះរបស់ព្រះ នោះពួកភីលីស្ទីនក៏បានហៅរកពួកសង្ឃរបស់គេទាំងអស់ ហើយសួរពួកគេពីរបៀបធ្វើដូចម្ដេច ឱ្យហឹបនោះអាចបញ្ជូនត្រឡប់ទៅវិញបាន ។ ពួកគេក៏បានទឹមរទេះនឹងគោញីមួយគូ ដែលនៅជាប់បំបៅដោះកូននៅឡើយ ដើម្បីដឹកយកហឹបនោះដោយគោញីដែលបំបៅដោះកូនទាំងពីរនោះទៅ ។ ក្រៅពីនេះទៀត គោញីទាំងពីរនោះក៏បានធ្វើដំណើរ ឆ្ពោះតម្រង់ទៅកាន់ទឹកដីអ៊ីស្រាអែលទៅ ។

ព្រះទ្រង់បានអនុញ្ញាតឱ្យពួកភីលីស្ទីន ដឹកយកហឹបនឹងរទេះនោះទៅ ។ មិនចាំបាច់មានមនុស្សណាដើម្បីដឹកនាំហឹបនោះយកទៅឡើយ ។ ប៉ុន្តែ សូមមើលឱ្យឃើញនូវអ្វីដែលបានកើតឡើង គឺនៅពេលដែលប្រជារាស្ត្ររបស់ព្រះបានព្យាយាមធ្វើការដូចដែលបានធ្វើនេះចុះ ។

ព្រះគម្ពីរ១សាំយូអែល ៦:៧,៨ ចែងថា: **ដូច្នេះ ចូរធ្វើរទេះ១ថ្មី ហើយយកគោញី២ដែលបំបៅកូន ឥតដែលមានអ្នកណាយកនឹមមកទឹម**

**នៅឡើយ រួចឱ្យទឹមនឹងរទេះនោះ ហើយដេញកូនពីវាឱ្យទៅផ្ទះវិញ នោះត្រូវយកហឹបនៃព្រះយេហូវ៉ាដាក់លើរទេះទៅ ហើយដាក់គ្រឿងមាសទាំងប៉ុន្មាន ដែលអ្នករាល់គ្នាថ្វាយនោះ ទៅក្នុងប្រអប់ដាក់ខាងហឹប រួចលែងវាឱ្យនាំទៅវិញចុះ ។**

**ការព្រមានចំពោះយើងរាល់គ្នា**

ស្ដេចដាវីឌបានចងប្តូរហឹបពីគាយ៉ាត់-យ៉ារីម ទៅកាន់ភ្នំស៊ីយ៉ូន ហើយក៏មានការព្រមានដ៏ខ្លាំងមួយ នៅក្នុងការខំប្រឹងប្រែងប្តូរទីកន្លែងហឹបជាលើកទីមួយ ។

ព្រះគម្ពីរ១របាក្សត្រ ១៣:៧,៨,១០ ចែងថា: **គេក៏យកហឹបនៃព្រះដាក់លើរទេះថ្មី នាំចេញពីផ្ទះអ័ប៊ីនដាប់មក មានអ៊ូសា និងអ័ហ៊ីយ៉ូរជាអ្នកបរ ឯដាវីឌ និងពួកអ៊ីស្រាអែលទាំងអស់គ្នា គេក៏ប្រគំភ្លេងនៅចំពោះព្រះអស់ពីកំឡាំង ព្រមទាំងច្រៀងចំរៀងផង ដោយស៊ុង ពិណ ក្រាប់ឈឹង និងត្រែ... ដូច្នេះ ព្រះយេហូវ៉ាទ្រង់មានសេចក្តីក្រោធនឹងអ៊ូសា ក៏ប្រហារគាត់បង់ ដោយព្រោះគាត់បានលូកដៃទៅពាល់ហឹបគាត់ ក៏ស្លាប់នៅទីនោះចំពោះព្រះទៅ ។**

មានការស្តាប់បង្គាប់ចំពោះនីតិក្រមរបស់ព្រះ ដែលត្រូវតែបានគេដឹង និងត្រូវគេបានយកមកអនុវត្ត ។ ស្ដេចដាវីឌគឺជាអ្នកទទួលខុសត្រូវ គឺគ្រាន់តែយើងត្រូវតែធ្វើឱ្យបានសមរម្យនោះឯង "គឺជាច្បាប់ព្រះវិហារ" ដែលត្រូវធ្វើតាម ។

**ការសរសើរតម្កើងគឺមិនអាចលាក់នូវការស្តាប់បង្គាប់ឡើយ**

ស្ដេចដាវីឌ និងមនុស្សរបស់ទ្រង់ បានប្រើរទេះដើម្បីប្តូរទីកន្លែងរបស់ហឹបនេះបាន គឺទាល់តែពួកសង្ឃលេវីប៉ុណ្ណោះ ដែលអាចសែងហឹបជាមួយនឹងឈើស្នែង ។ ព្រះវត្តមាននៃព្រះ មិនអាចត្រូវបានដឹកនាំដោយរទេះឡើយ ។ គឺត្រូវតែបានដឹកនាំដោយការឧទ្ទិសថ្វាយ ថាតើត្រូវជ្រើសរើសយកមនុស្សប្រភេទណានោះវិញ ។

ស្តេចដាវីឌ និងពួកអ៊ីស្រាអែលទាំងអស់ បានកំពុងតែច្រៀង និងលេងភ្លេង នៅចំពោះព្រះអម្ចាស់ដ៏ជាព្រះ ប៉ុន្តែពួកគេមិនបានស្តាប់បង្គាប់ដូច្នេះហើយ ធ្វើឱ្យមានសេចក្តីស្លាប់បានមកដល់ពួកទៅវិញ ។

ក្រោយមក ហឹបក៏ត្រូវបានទទួលការផ្លាស់ប្តូរទីកន្លែង ដោយមានជោគជ័យ គឺដោយមានការស្តាប់បង្គាប់ដល់សេចក្តីបង្រៀន របស់ព្រះនោះឯង ។

ព្រះគម្ពីរ១របាក្សត្រ ១៥:២ ចែងថា: **រួចដាវីឌទ្រង់មានបន្ទូលថា មិនត្រូវឱ្យអ្នកណាសែងហឹបនៃព្រះឡើយ លើកតែពួកលេវីប៉ុណ្ណោះ ដ្បិតព្រះយេហូវ៉ាទ្រង់បានរើសគេទុកជាអ្នកសែងហឹបនៃព្រះ ហើយធ្វើការងារថ្វាយទ្រង់ជាដរាប ។**

ពីព្រោះតែយើងបានធ្វើការសម្រេចចិត្ត នោះព្រះវត្តមាននៃព្រះអម្ចាស់ បានគង់នៅក្នុងការថ្វាយបង្គំរបស់យើងរាល់គ្នា នោះមិនមែនមានន័យថា យើងអាចធ្វើការនោះ "តាមផ្លូវរបស់យើង" នោះទេ ។ ព្រះវត្តមាននៃព្រះអម្ចាស់ គឺត្រូវតែបានទទួលការដឹកនាំឱ្យចូលទៅខាងក្នុង ដោយទ្រង់ជាអ្នកដឹកនាំដល់គ្រប់គ្នានៅគ្រប់ពេល ។ ដូចគ្នាដែរ "រទេះ" ដែលបានធ្វើការនៅសប្តាហ៍ចុងក្រោយ គឺដែលមានចម្រៀងការលេងលឿន ឬយឺត ការរៀបចំ ។ល។ នឹងមិនមែនជាការងារដែលចាំបាច់បំផុតនោះទេ នៅសប្តាហ៍នេះ ។

## ការសរសើរតម្កើងនៅរោងឧបោសថរបស់ស្តេចដាវីឌ

ការសរសើតម្កើងគឺជាការសំខាន់ គឺជាផ្នែកមួយនៃការថ្វាយបង្គំនៅក្នុងរោងឧបោសថ ។

ស្តេចដាវីឌបាននាំយកនូវហឹបមកកាន់ទីក្រុងស៊ីយ៉ូន ហើយបានដាក់ហឹបនោះនៅក្នុងត្រសាលជំនុំដែលយើងរាល់គ្នាហៅថា រោងឧបោសថរបស់ស្តេចដាវីឌ ។

វាជាការចាប់អារម្មណ៍ចំពោះកំណត់ចំណាំ ដែលព្រះទ្រង់មិនបានអនុញ្ញាតឱ្យស្តេចដាវីឌបានធ្វើការផ្លាស់ប្តូរហឹប ទៅដាក់នៅក្នុងរោង

ឧបោសថរបស់លោកម៉ូសេ ប៉ុន្តែសម្រាប់ការសេសសល់នៃអាយុកាលរបស់ដាវីឌ ហើយរហូតដល់ព្រះវិហាររបស់ស្តេចសាឡូម៉ូនត្រូវបានទទួលការសាងសង់ហើយ ទើបអាចត្រូវបានយកហឹបដែលមានព្រះវត្តមាននៃព្រះ មកដាក់នៅក្នុងរោងឧបោសថរបស់ស្តេចដាវីឌបាន ។

ព្រះគម្ពីរ១របាក្សត្រ ១៦:១,៤-៩,៣១,៣៤ ចែងថា: **គេនាំយកហឹបនៃព្រះមក ដាក់នៅកណ្តាលត្រសាល ដែលដាវីឌបានដំឡើងទុកសំរាប់ រួចក៏ថ្វាយដង្វាយដុត និងដង្វាយមេត្រី នៅចំពោះព្រះ... ទ្រង់ក៏ដំរូវពួកលេវីខ្លះ ឱ្យធ្វើការងារនៅចំពោះហឹបនៃព្រះយេហូវ៉ា ដើម្បីនឹងរំឭក អរព្រះគុណ ហើយនិងសរសើរដល់ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល គឺអេសាភជាមេ ហើយបន្ទាប់មកមានសាការី យីអែល សេមីរ៉ាម៉ូត យេហ៊ីអែល ម៉ាធិធា អេលាប បេណាយ៉ាអូបិឌ-អេដំម និងយីអែល សុទ្ធតែកាន់ពិណនិងស៊ុង ហើយអេសាភជាអ្នកវាយឈឹងឱ្យឮរងំ ឯបេណាយ៉ា និងយ៉ាហាសៀល ជាពួកសង្ឃ ក៏ផ្លុំត្រែជានិច្ច នៅចំពោះហឹបនៃសេចក្តីសញ្ញាផងព្រះ នៅថ្ងៃនោះឯង ដាវីឌបានបង្គាប់មុនដំបូង ឱ្យមានការអរព្រះគុណដល់ព្រះយេហូវ៉ា ដោយសារអេសាភ និងពួកបងប្អូនលោកថា ចូរអរព្រះគុណដល់ព្រះយេហូវ៉ា ចូរអំពាវនាវដល់ព្រះនាមទ្រង់ចុះ ចូរសំដែងពីអស់ទាំងការនៃទ្រង់ នៅកណ្តាលគ្រប់ទាំងសាសន៍ ចូរច្រៀងថ្វាយទ្រង់ ចូរច្រៀងសរសើរដល់ទ្រង់ចុះ ចូរនឹកថ្លែងពីអស់ទាំងការអស្ចារ្យរបស់ទ្រង់... ចូរឱ្យផ្ទៃមេឃមានសេចក្តីអំណរ ហើយឱ្យផែនដីបានត្រេតអរឡើង ឱ្យបានថ្លែងនៅគ្រប់ទាំងសាសន៍ថា ព្រះយេហូវ៉ាទ្រង់សោយរាជ្យ... ចូរអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ ពីព្រោះសេចក្តីសប្បុរសនៃទ្រង់នៅអស់កល្បជានិច្ច ។**

## គ្រឿងភ្លេងសម្រាប់ការថ្វាយបង្គំ

មានឧបករណ៍ភ្លេងជាច្រើនដែលបានត្រូវគេប្រើ នៅក្នុងការថ្វាយបង្គំ នៅក្នុងរោងឧបោសថរបស់ស្តេចដាវីឌ ។

ព្រះគម្ពីរទំនុកដំកើង ១៥០:១-៦ ចែងថា: **ចូរសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះ នៅក្នុងទីបរិសុទ្ធរបស់ទ្រង់ ចូរសរសើរដល់ទ្រង់ នៅចន្លោះអាកាស ជាទីសំដែងព្រះចេស្តាទ្រង់ ចូរសរសើរដល់ទ្រង់ ដោយព្រោះការឥទ្ធិឫទ្ធិរបស់ទ្រង់ ចូរសរសើរដល់ទ្រង់ ឱ្យសមនឹងសណ្ឋានដ៏ធំប្រសើររបស់ទ្រង់ ចូរសរសើរទ្រង់ដោយត្រែ ចូរសរសើរដល់ទ្រង់ដោយដេញពិណ និងចាប់ស៊ុង ចូរសរសើរដល់ទ្រង់ដោយវាយក្រាប់ ហើយលោតកញ្ឆេង ចូរសរសើរទ្រង់ដោយប្រដាប់មានខ្សែ ហើយនិងខ្លុយ ចូរសរសើរដល់ទ្រង់ដោយវាយឈឹងឱ្យឮរងំ ចូរសរសើរទ្រង់ដោយវាយឈឹងឮសូររំពង គួរឱ្យជីវិតទាំងឡាយដែលមានដង្ហើម បានសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។**

នៅក្នុងបទចម្រៀងដ៏ខ្លីមួយនេះ ដែលស្តេចដាវីឌបានធ្វើបញ្ជីរាយឈ្មោះឧបករណ៍ភ្លេងទាំង៧ ដែលត្រូវតែបានគេប្រើធ្វើជាការសរសើរតម្កើងដល់ព្រះ ។ នៅទីបំផុត ហើយជាការសំខាន់បំផុតនោះ "ឧបករណ៍ភ្លេង" នេះដែលមានជាសម្លេងដូចខាងក្រោមនេះ:

- *ត្រែ*
- *ពិណ*
- *ពិណបុរាណ*
- *សំកោរ*
- *គ្រឿងភ្លេងខ្សែ*
- *ខ្លុយ*
- *ឆាប ឬឈ្នោះ*

**អំណាចនៃការសរសើរតម្កើង និងការថ្វាយបង្គំ**

- *ពពកដែលជាសិរីល្អ*

នៅពេលដែលហឹបត្រូវបានគេនាំយកចេញ ពីវាំងឧបោសថរបស់ស្តេចដាវីឌ ទៅកាន់ព្រះវិហាររបស់ស្តេចសាឡូម៉ូន នោះពួកសង្ឃ និងពួក

បណ្តាជន បាននាំគ្នាសរសើរតម្កើងដល់ព្រះអម្ចាស់ រហូតដល់សិរីល្អរបស់ទ្រង់បានមកគ្របបាំងពេញព្រះវិហារទាំងមូល ។

ព្រះគម្ពីរ២របាក្សត្រ ៥:១៣,១៤ ចែងថា: **នៅខណនោះ កាលពួកផ្លុំត្រែនិងពួកចំរៀង គេប្រគុំភ្លេងព្រមគ្នាឮសំឡេងតែ១ ដើម្បីលើកសរសើរ ហើយអរព្រះគុណដល់ព្រះយេហូវ៉ា គឺកាលគេឡើងសំឡេងដោយផ្លុំត្រែវាយឈឹង ហើយលេងប្រដាប់ភ្លេងទាំងប៉ុន្មាន ព្រមទាំងលើកសរសើរដល់ព្រះយេហូវ៉ា ដោយពាក្យថា ទ្រង់ប្រកបដោយករុណាគុណសេចក្តីសប្បុរសទ្រង់នៅអស់កល្បជានិច្ច នោះស្រាប់តែព្រះវិហារព្រះយេហូវ៉ា មានពេញដោយពពក ដល់ម៉្លេះបានជាពួកសង្ឃឈរធ្វើការងារមិនបាន ដ្បិតសិរីល្អនៃព្រះយេហូវ៉ា នៅពេញក្នុងព្រះវិហារនៃព្រះ ។**

**គំរូរបស់ពួកជំនុំ**

ដោយសារតែហឹបនៃសេចក្តីសញ្ញា បានត្រូវទទួលការអនុញ្ញាតឱ្យបានមើលឃើញ អស់រយៈពេល៤០ឆ្នាំ នោះរោងឧបោសថរបស់ស្តេចដាវីឌគឺត្រូវបានជាគំរូដល់ពួកជំនុំ ឱ្យបានចូលរួបរួមគ្នា ព្រមទាំងបានធ្វើដោយផ្ទាល់ខ្លួនម្នាក់ៗថែមទៀតផង ក្នុងការថ្វាយបង្គំព្រះ ។

ព្រះគម្ពីរកិច្ចការ ១៥:១៦,១៧ ចែងថា: **«ក្រោយនោះ អញនឹងត្រឡប់មក លើកទីលំនៅរបស់ហ្លួងដាវីឌ ដែលរលំនោះឡើង អញនឹងសង់ត្រង់កន្លែងបាក់បែក ហើយដំឡើងឱ្យត្រង់ឡើងវិញ ដើម្បីឱ្យសំណល់មនុស្ស បានស្វះស្វែងរកព្រះអម្ចាស់ ព្រមទាំងសាសន៍ដទៃទាំងប៉ុន្មានដែលបានហៅតាមឈ្មោះអញនោះផង នេះហើយជាព្រះបន្ទូលនៃព្រះអម្ចាស់ ជាព្រះដែលធ្វើការទាំងនោះ»** ។

លោកសាវ័កយ៉ាកុបក៏បានស្តាប់ស្តង់មើលនូវពាក្យទំនាយ ដែលហោរាអេម៉ុសបានថ្លែងទំនាយនៅក្នុងព្រះព្រះគម្ពីរនេះដូច្នេះថា:

**នៅថ្ងៃនោះអញនឹងលើកទីលំនៅរបស់ដាវីឌឡើងវិញ គឺជាទីដែលត្រូវរលំ ហើយនឹងបិទចន្លោះបាក់បែកឱ្យជិត អញនឹងលើកទីខូចបង់ឡើងហើយសង់ឡើងឱ្យដូចជាកាលពីដើម ដើម្បីឱ្យគេបានធ្វើជាម្ចាស់ លើ**

**សំណល់នៃសាសន៍អេដំម និងអស់ទាំងសាសន៍ផ្សេងៗ ដែលបានហៅតាមឈ្មោះអញ នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ាដែលទ្រង់ធ្វើការទាំងនេះ** (អេម៉ុស ៩:១១,១២) ។

ព្រះទ្រង់កំពុងតែកែប្រែជាថ្មីឡើងវិញ នូវផ្នែកខាងវិញ្ញាណ នៅក្នុងរោងឧបោសថរបស់ស្តេចដាវីឌ ។ ពិតប្រាកដណាស់ ទ្រង់នឹងកែប្រែជាថ្មីឡើងវិញ នូវទម្រង់ទាំងអស់នៃការថ្វាយបង្គំ គឺដោយបានអាងលើហេតុផលចំពោះរោងឧបោសថនោះ ដែលមាននៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ ។

## សំណួររំឭកសារឡើងវិញ

១. នៅក្នុងពេលរបស់ស្តេចដាវីឌ រោងឧបោសថរបស់ទ្រង់នៅក្នុងត្រសាលដ៏ពិតប្រាកដ តើរោងឧបោសថរបស់ស្តេចដាវីឌនៅសម័យសព្វថ្ងៃនេះសំដៅលើអ្វីដែរ?

២. នៅពេលដែលស្តេចដាវីឌ បានកំពុងតែខំប្រឹងប្រែងដើម្បីផ្លាស់ប្តូរទីកន្លែងរបស់ហឹបជាលើកទីមួយ តើហេតុអ្វីបានលោកឧសារត្រូវទទួលនូវសេចក្តីស្លាប់ទៅវិញ?

៣. តើរោងឧបោសថរបស់លោកម៉ូសេ មានការផ្សេងគ្នាដោយរបៀបណាពីរោងឧបោសថរបស់ស្តេចដាវីឌ ក្នុងការបង្ហាញនូវគំរូ នៃកាថ្វាយបង្គំសារជាថ្មីឡើងវិញ?

# មេរៀនទី ៣
## *សេចក្ដីបង្រៀនរបស់ព្រះសម្រាប់ការសរសើរតម្កើង*

ព្រះបន្ទូលរបស់ព្រះគឺពេញទៅដោយសេចក្ដីបង្រៀនរបស់ព្រះ ដល់ប្រជារាស្ត្ររបស់ទ្រង់ ឱ្យបានត្រឡប់ទៅជាអ្នកសរសើរតម្កើង និងជាអ្នកថ្វាយបង្គំដល់ព្រះអង្គ ។ វាជាការសំខាន់ចំពោះការចំណាយពេលអានពីព្រះបន្ទូល ដើម្បីឱ្យយើងរាល់គ្នាបានដឹងថាៈ

- *ហេតុអ្វីបានជាយើងរាល់គ្នាគួរតែប្រើសរសើរតម្កើងដល់ព្រះអង្គ*
- *តើអ្នកណាគួរតែប្រើសរសើរតម្កើងដល់ព្រះអង្គ*
- *តើនៅពេលណាដែលយើងគួរតែប្រើសរសើរតម្កើងដល់ព្រះអង្គ*
- *តើទីកន្លែងណាដែលយើងគួរតែប្រើសរសើរតម្កើងដល់ព្រះអង្គ*

### ហេតុអ្វីបានជាយើងរាល់គ្នាគួរតែប្រើសរសើរតម្កើងដល់ព្រះអម្ចាស់

**ពីព្រោះទ្រង់គឺថា**

- *មានកិត្តិយសសម្រាប់ការអរព្រះគុណ*

ព្រះគម្ពីរទំនុកដំកើង ១០៧:១,២,៨ ចែងថាៈ **ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ សេចក្ដីសប្បុរសនៃទ្រង់ស្ថិតស្ថេរនៅជានិច្ច គួរឱ្យពួកអ្នកដែលព្រះយេហូវ៉ាបានប្រោសលោះ បានថាដូច្នេះដែរ គឺអស់អ្នកដែលទ្រង់បានលោះ ឱ្យរួចពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវនោះ... ឱសូមឱ្យមនុស្សទាំងឡាយសរសើរដល់ព្រះយេហូវ៉ា ដោយព្រោះសេចក្ដីសប្បុរសរបស់ទ្រង់ ហើយដោយព្រោះអស់ទាំងការអស្ចារ្យ ដែលទ្រង់បានប្រោសដល់មនុស្សជាតិ ។**

➢ *មានកិត្តិយសសម្រាប់ការសរសើរតម្កើង*

ព្រះគម្ពីរ២សាំយូអែល ២២:៤ ចែងថា: **ទូលបង្គំនឹងអំពាវនាវដល់ព្រះយេហូវ៉ា ដែលទ្រង់គាប់គួរសរសើរយ៉ាងនោះ ទូលបង្គំនឹងបានសង្គ្រោះឱ្យរួចពីពួកខ្មាំងសត្រូវហើយ ។**

➢ *ទ្រង់ធំឧត្ដម*

ព្រះគម្ពីរទំនុកដំកើង ៤៨:១ ចែងថា: **ព្រះយេហូវ៉ាទ្រង់ធំប្រសើរ ហើយគួរសរសើរណាស់ ក្នុងទីក្រុងរបស់ព្រះនៃយើងខ្ញុំ គឺនៅលើភ្នំបរិសុទ្ធនៃទ្រង់ ។**

ព្រះគម្ពីរទំនុកដំកើង ៩៦:៤ ចែងថា: **ដ្បិតព្រះយេហូវ៉ាទ្រង់ធំប្រសើរ ហើយក៏គួរសរសើរណាស់ ទ្រង់ជាទីគួរកោតខ្លាចលើសជាងអស់ទាំងព្រះ ។**

➢ *ការឥទ្ធិឫទ្ធិរបស់ទ្រង់*

ព្រះគម្ពីរទំនុកដំកើង ១៥០:២ ចែងថា: **ចូរសរសើរដល់ទ្រង់ ដោយព្រោះការឥទ្ធិឫទ្ធិរបស់ទ្រង់ ចូរសរសើរដល់ទ្រង់ ឱ្យសមនឹងសណ្ឋានដ៏ធំប្រសើររបស់ទ្រង់ ។**

ទ្រង់មានសិទ្ធិអំណាចដ៏ឧត្តុង្គឧត្តមបំផុត និងមានអំណាចចេស្ដាដ៏ខ្ពស់បំផុតផងដែរ ។ ទ្រង់មានមុនគ្រប់អ្វីៗទាំងអស់ ហើយក៏ឧត្តុង្គឧត្តមជាងអ្វីៗទាំងអស់ផងដែរ ។

**ទ្រង់បានជ្រើសរើសយើងខ្ញុំ**

ព្រះគម្ពីរលូកា ១០:២០ ចែងថា: **ប៉ុន្តែកុំឱ្យអរសប្បាយ ដោយព្រោះអារក្សចុះចូលអ្នករាល់គ្នានោះឡើយ ត្រូវឱ្យរីករាយ ដោយព្រោះឈ្មោះអ្នករាល់គ្នាបានកត់ទុកនៅស្ថានសួគ៌វិញ ។**

➢ *សូមថ្វាយសិរីល្អដល់ព្រះ*

ព្រះគម្ពីរទំនុកដំកើង ៥០:២៣ ចែងថា: **អ្នកណាដែលថ្វាយដង្វាយជាសេចក្ដីអរព្រះគុណ នោះក៏លើកដំកើងអញដែរ ហើយអញនឹង**

**សំដែងសេចក្តីសង្គ្រោះរបស់ព្រះ ដល់អ្នកណាដែលរៀបផ្លូវរបស់ខ្លួនឱ្យត្រង់ ។**

ព្រះគម្ពីរទំនុកដំកើង ៦៩:៣០ ចែងថាៈ **ទូលបង្គំនឹងច្រៀងទំនុកសរសើរ ដល់ព្រះនាមរបស់ព្រះ ហើយនឹងលើកដំកើងទ្រង់ដោយអរព្រះគុណ ។**

**ការបញ្ជាឱ្យសរសើតម្កើង**

➢ *តាមរយៈស្តេចដាវីឌ*

ព្រះគម្ពីរទំនុកដំកើង ១៤៩:១ ចែងថាៈ **ចូរសរសើរដល់ព្រះយេហូវ៉ា ចូរច្រៀងបទ១ថ្មីថ្វាយព្រះយេហូវ៉ា ព្រមទាំងសេចក្តីសរសើរពីទ្រង់ នៅក្នុងជំនុំនៃពួកអ្នកបរិសុទ្ធផង ។**

➢ *តាមរយៈលោកសាវ័កប៉ុល*

ព្រះគម្ពីរអេភេសូរ ៥:១៩ ចែងថាៈ **ហើយនិយាយគ្នាទៅវិញទៅមក ដោយបទទំនុកដំកើង ទំនុកបរិសុទ្ធ និងចំរៀងខាងឯវិញ្ញាណ ទាំងច្រៀង ហើយសរសើរដល់ព្រះអម្ចាស់ដោយចិត្ត ។**

➢ *តាមរយៈលោកសាវ័កយ៉ូហាន*

ព្រះគម្ពីរវិវរណៈ ១៩:៥ ចែងថាៈ **រួចមានសំឡេងចេញពីបល្ល័ង្កមកថា អស់ទាំងបាវបំរើទ្រង់ និងពួកអ្នកដែលកោតខ្លាចទ្រង់ ទាំងធំទាំងតូចអើយ ចូរសរសើរដល់ព្រះនៃយើងរាល់គ្នាចុះ ។**

**ពីព្រោះគឺជាការល្អ**

ព្រះគម្ពីរទំនុកដំកើង ៩២:១,២ ចែងថាៈ **នេះជាការល្អហើយ គឺដែលនឹងអរព្រះគុណដល់ព្រះយេហូវ៉ា ហើយច្រៀងសរសើរដល់ព្រះនាមនៃទ្រង់ ជាព្រះដ៏ខ្ពស់បំផុត ព្រមទាំងសំដែងពីសេចក្តីសប្បុរសនៃទ្រង់នៅពេលព្រឹក ហើយពីសេចក្តីស្មោះត្រង់របស់ទ្រង់រាល់តែយប់ ។**

**ពីព្រោះថាទីគាប់ព្រះហឫទ័យ**

ព្រះគម្ពីរទំនុកដំកើង ១៤៧:១ ចែងថា: **ចូរសរសើរដល់ព្រះយេហូវ៉ា ដ្បិតការដែលច្រៀងសរសើរ ដល់ព្រះនៃយើងខ្ញុំ នោះជាការសំណំហើយ ក៏ពិរោះផង សេចក្តីសរសើរជាការគួរគប្បី ។**

**ពីព្រោះថាការល្អស្រស់ត្រកាល**

ព្រះគម្ពីរទំនុកដំកើង ៣៣:១ ចែងថា: **ឱពួកអ្នកសុចរិតអើយ ចូរមានចិត្តរីករាយក្នុងព្រះយេហូវ៉ាចុះ ដ្បិតសេចក្តីសរសើរនោះ សំណំដល់មនុស្សទៀងត្រង់ ។**

មានការកោតខ្លាចចំពោះការសរសើរតម្កើងដល់ព្រះ សម្រាប់ដល់អស់អ្នកខ្លះ ពីព្រោះពួកគេមិនមានអារម្មណ៍ចំពោះការថ្វាយកិត្តិយស ។ នេះគឺជាឧបស័គ្គចំពោះព្រះបន្ទូលរបស់ព្រះ ។

ព្រះគម្ពីរ២សាំយូអែល ៦:១៤-១៦,២១-២៣ ចែងថា: **ដាវីឌក៏លោតកញ្ឆេងអស់ពីកំឡាំងទ្រង់នៅចំពោះព្រះយេហូវ៉ា ទ្រង់ពាក់អេផូឌធ្វើពីសំពត់ខ្លូតទេស ដូច្នេះ ដាវីឌនិងជំនួរវង្សនៃសាសន៍អ៊ីស្រាអែលទាំងអស់ បាននាំហឹបនៃព្រះយេហូវ៉ាឡើងមកដោយសំឡេងហ៊ោឡើង និងសូរផ្លុំត្រែផង ក្នុងវេលាដែលហឹបនៃព្រះយេហូវ៉ា កំពុងតែចូលមកក្នុងក្រុងដាវីឌ នោះមីកាលជាបុត្រីសូលក៏ទតតាមបង្អួចទៅឃើញស្តេចដាវីឌកំពុងតែហក់លោតកញ្ឆេងនៅចំពោះព្រះយេហូវ៉ា នាងក៏មានព្រះទ័យប្រមាថមើលងាយដល់ទ្រង់ ។**

**តែដាវីឌមានបន្ទូលតបថា នោះគឺនៅចំពោះព្រះយេហូវ៉ាទេ ជាព្រះដែលបានរើសអញជាជាងបិតាឯង និងវង្សានុវង្សរបស់ឯងទាំងអស់គ្នាដែរ ដើម្បីនឹងតាំងអញឡើងជាស្តេចលើសាសន៍អ៊ីស្រាអែល ជារាស្ត្ររបស់ព្រះយេហូវ៉ា ហេតុដូច្នេះបានជាអញនឹងលេងសប្បាយ នៅចំពោះព្រះយេហូវ៉ា ហើយនឹងចេះតែប្រព្រឹត្តអាក្រក់ជាងនោះទៅទៀត ព្រមទាំងបានទាបថោកដល់ភ្នែកខ្លួនអញផង តែចំណែកពួកបាវស្រីដែលឯង**

**បាននិយាយនោះ គេនឹងលើកសរសើរដល់អញវិញ ដូច្នេះ មីកាលជាបុត្រី សូល នាងឥតមានបុត្រឡើយ រហូតដល់អស់ជីវិត ។**

### ព្រះទ្រង់គង់នៅក្នុងការសរសើរតម្កើង

ព្រះគម្ពីរទំនុកដំកើង ២២:៣ ចែងថា: **ប៉ុន្តែ ឱព្រះដែលបានតាំងឡើង ក្នុងទំនុកសរសើររបស់អ៊ីស្រាអែលអើយ ទ្រង់បរិសុទ្ធ ។**

ប្រសិនបើចិត្តរបស់យើងរាល់គ្នា បានពេញដោយការសរសើតម្កើង ការនោះក៏មានពេញដោយមានព្រះដែរ ។ ប្រសិនបើផ្ទះរបស់យើងរាល់គ្នា មានពេញដោយការសរសើតម្កើង នោះក៏មានព្រះគង់នៅជាមួយដែរ ។

យើងរាល់គ្នាបានចុះចូលជាមួយនឹងព្រះវត្តមានរបស់ព្រះ ដោយការចុះចូលរួមជាមួយនឹងការសរសើរតម្កើងនោះឯង ។

### ការសរសើរតម្កើងគឺបានបំពេញដោយមានកម្លាំង

ព្រះគម្ពីរនេហេមា ៨:១០ខ ចែងថា: **...កុំឱ្យមានចិត្តព្រួយឡើយ ពីព្រោះសេចក្តីអំណររបស់ព្រះយេហូវ៉ាជាកំឡាំងនៃអ្នករាល់គ្នា ។**

ព្រះគម្ពីរទំនុកដំកើង ២៨:៧ ចែងថា: **ព្រះយេហូវ៉ាទ្រង់ជាកំឡាំង ហើយជាខែលនៃខ្ញុំ ចិត្តខ្ញុំបានសង្ឃឹមដល់ទ្រង់ ហើយបានសេចក្តីជំនួយ ហេតុនោះចិត្តខ្ញុំមានសេចក្តីរីករាយជាខ្លាំង ខ្ញុំនឹងសរសើរដល់ទ្រង់ ដោយបទចំរៀងរបស់ខ្ញុំ ។**

### ការសរសើរតម្កើងគឺបាននាំមកនូវការបានសម្រេច

ការសរសើរតម្កើងដោយមានសេចក្តីអំណរអស់ពីព្រលឹង ដែលមានព្រះអម្ចាស់ ហើយព្រះទ្រង់ក៏បានប្រទានពរដល់អ្នកនោះ ឱ្យមានសេចក្តីអំណរអស់ពីចិត្តដ៏យូរអង្វែងតទៅ ។

ព្រះគម្ពីរទំនុកដំកើង ៣៧:៤ ចែងថា: **ចូរយកព្រះយេហូវ៉ាជាសេចក្តីអំណររបស់អ្នក នោះទ្រង់នឹងប្រទានឱ្យអ្នកបានដូចបំណងចិត្ត ។**

ចូរកត់ចំណាំថា ការសរសើរតម្កើងគឺត្រូវតែបានមកជាដំបូង មុនពេលដែលយើងបានទទួល ។ រឿងនោះគឺដោយសារតែការសរសើរតម្កើងបានដាក់ចូលទៅក្នុងអាទិភាពរបស់យើងជាលំដាប់លំដោយ ហើយបន្ទាប់មក ព្រះទ្រង់រែងយើងឱ្យមានការសម្រេចចិត្តយ៉ាងអស់ពីចិត្ត ។

**ការសរសើរតម្កើងនាំមកនូវជ័យជម្នះ**

ព្រះគម្ពីរទំនុកដំកើង ១៨:៣ ចែងថា: **ទូលបង្គំនឹងអំពាវនាវដល់ព្រះយេហូវ៉ា ដែលទ្រង់គួរសរសើរ យ៉ាងនោះទូលបង្គំនឹងបានសង្គ្រោះរួចពីពួកសត្រូវរបស់ទូលបង្គំ ។**

ព្រះគម្ពីរ២របាក្សត្រ ២០:២១,២២ ចែងថា: **រួចកាលទ្រង់បានពិគ្រោះនឹងបណ្តាជនហើយ នោះទ្រង់ក៏ដំរូវឱ្យមានពួកអ្នក ដែលត្រូវច្រៀងថ្វាយព្រះយេហូវ៉ា ហើយពោលសរសើរ ដោយស្លៀកពាក់ជាប្រដាប់បរិសុទ្ធ ក្នុងកាលដែលគេនាំមុខពួកទ័ពចេញទៅ ដោយពោលថា ចូរអរព្រះគុណដល់ព្រះយេហូវ៉ាចុះ ដ្បិតសេចក្តីសប្បុរសទ្រង់នៅជាប់អស់កល្បជានិច្ច ដូច្នេះ កាលគេចាប់តាំងច្រៀង ហើយសរសើរឡើង នោះព្រះយេហូវ៉ាទ្រង់បង្កប់ទ័ពទាស់នឹងពួកកូនចៅអាំម៉ូន ម៉ូអាប់ និងពួកភ្នំសៀរ ដែលមកច្បាំងនឹងពួកយូដា ឱ្យគេត្រូវចាញ់ ។**

## *តើអ្នកណាគួរគប្បីសរសើរតម្កើងដល់ព្រះអម្ចាស់?*

**គ្រប់អស់ទាំងសាច់**

ព្រះគម្ពីរទំនុកដំកើង ១៤៥:២១ខ ចែងថា: ...**គួរឱ្យមនុស្សទាំងឡាយ បានសូមឱ្យព្រះនាមបរិសុទ្ធរបស់ទ្រង់បានពរ នៅអស់កល្បជានិច្ចដែរ ។**

**ព្រលឹងផងខ្ញុំ**

ព្រះគម្ពីរទំនុកដំកើង ១០៣:១,២ ចែងថា: **ឱព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ា ហើយគ្រប់ទាំងអស់ដែលរួមនៅក្នុងខ្លួនអញ ចូរសរសើរដល់ព្រះនាមបរិសុទ្ធនៃទ្រង់ដែរ ព្រលឹងអញអើយ ចូរសរសើរ**

**ដល់ព្រះយេហូវ៉ាចុះ ហើយកុំឱ្យភ្លេចបណ្តាព្រះគុណណាមួយរបស់ទ្រង់ឡើយ ។**

**គ្រប់ទាំងអស់ដែលមានដង្ហើម**

ព្រះគម្ពីរទំនុកដំកើង ១៥០:៦ ចែងថា: **គួរឱ្យជីវិតទាំងឡាយដែលមានដង្ហើម បានសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។**

**គ្រប់មនុស្សទាំងអស់**

ព្រះគម្ពីរទំនុកដំកើង ៦៧:៨៣,៥ ចែងថា: **ឱព្រះអង្គអើយ សូមឱ្យជនទាំងឡាយសរសើរដល់ទ្រង់ ឱ្យជនទាំងអស់សរសើរដល់ទ្រង់... ឱព្រះអង្គអើយ សូមឱ្យជនទាំងឡាយសរសេរដល់ទ្រង់ ឱ្យជនទាំងអស់សរសើរដល់ទ្រង់ចុះ ។**

ព្រះគម្ពីរទំនុកដំកើង ៧៨:៤ ចែងថា: **យើងក៏មិនលាក់សេចក្តីទាំងនោះ ទុកចំពោះកូនចៅរបស់គាត់ដែរ គឺនឹងប្រកាសពីអស់ទាំងសេចក្តីសរសើរនៃព្រះយេហូវ៉ា ដល់ដំណមនុស្សជាន់ក្រោយឱ្យបានស្តាប់ ព្រមទាំងឥទ្ធានុភាព និងការអស្ចារ្យ ដែលទ្រង់បានធ្វើផង ។**

ព្រះគម្ពីរទំនុកដំកើង ៧៩:១៣ ចែងថា: **យ៉ាងនោះ យើងខ្ញុំ ជារាស្ត្ររបស់ទ្រង់ ហើយជាហ្វូងចៀមនៅទីគង្វាលទ្រង់ យើងខ្ញុំនឹងអរព្រះគុណដល់ទ្រង់ជាដរាបតទៅ យើងខ្ញុំនឹងសំដែងសេចក្តីសរសើររបស់ទ្រង់ នៅអស់ទាំងដំណតរៀងទៅ ។**

**ពួកអ្នកសុចរិត**

ព្រះគម្ពីរទំនុកដំកើង ១៤០:១៣ ចែងថា: **ពួកមនុស្សសុចរិតនឹងអរព្រះគុណដល់ព្រះនាមទ្រង់ ហើយមនុស្សទៀងត្រង់ នឹងនៅចំពោះទ្រង់ជាមិនខាន ។**

**ពួកអ្នកបរិសុទ្ធរបស់ព្រះ**

ព្រះគម្ពីរទំនុកដំកើង ១៤៥:១០ ចែងថា: **ឱព្រះយេហូវ៉ាអើយ អស់ទាំងស្នាដៃរបស់ទ្រង់នឹងអរព្រះគុណដល់ទ្រង់ ហើយពួកអ្នកបរិសុទ្ធរបស់ទ្រង់នឹងសូមឱ្យទ្រង់បានប្រកបដោយព្រះពរ ។**

**ពួកអ្នកដែលត្រូវបានប្រោសលោះ**

ព្រះគម្ពីរទំនុកដំកើង ១០៧:១,២ ចែងថា: **ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ សេចក្ដីសប្បុរសនៃទ្រង់ស្ថិតស្ថេរនៅជានិច្ច គួរឱ្យពួកអ្នកដែលព្រះយេហូវ៉ាបានប្រោសលោះ បានថាដូច្នេះដែរ គឺអស់អ្នកដែលទ្រង់បានលោះ ឱ្យរួចពីកណ្ដាប់ដៃនៃពួកខ្មាំងសត្រូវនោះ ។**

**អស់អ្នកដែលកោតខ្លាចដល់ព្រះអម្ចាស់**

ព្រះគម្ពីរទំនុកដំកើង ២២:២៣ ចែងថា: **ឯអ្នករាល់គ្នាដែលកោតខ្លាចដល់ព្រះយេហូវ៉ាអើយ ចូរសរសើរទ្រង់ចុះ អស់អ្នកដែលជាពូជយ៉ាកុបអើយ ចូរដំកើងទ្រង់ឡើង អស់ពូជពង្សនៃអ៊ីស្រាអែលអើយ ចូរកោតខ្លាចនៅចំពោះទ្រង់ចុះ ។**

**ពួកអ្នកបម្រើព្រះ**

ព្រះគម្ពីរទំនុកដំកើង ១១៣:១ ចែងថា: **ចូរសរសើរដល់ព្រះយេហូវ៉ា ឱពួកអ្នកបំរើនៃព្រះយេហូវ៉ាអើយ ចូរសរសើរចុះ ចូរសរសើរដល់ព្រះនាមព្រះយេហូវ៉ា ។**

ព្រះគម្ពីរទំនុកដំកើង ១៣៤:១ ចែងថា: **នែ អស់អ្នកបំរើរបស់ព្រះយេហូវ៉ា ដែលឈរនៅក្នុងដំណាក់ទ្រង់ នៅពេលយប់អើយ ចូរថ្វាយពរដល់ព្រះយេហូវ៉ាចុះ ។**

ព្រះគម្ពីរទំនុកដំកើង ១៣៥:១ ចែងថា: **ចូរសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះនាមព្រះយេហូវ៉ា ឱពួកអ្នកបំរើរបស់ព្រះយេហូវ៉ាអើយ ចូរសរសើរទ្រង់ចុះ ។**

**អស់ទាំងទេវតារបស់ទ្រង់**

ព្រះគម្ពីរទំនុកដំកើង ១៤៨:២ ចែងថា: **អស់ទាំងទេវតានៃទ្រង់អើយ ចូរសរសើរដល់ទ្រង់ អស់ទាំងពួកពលបរិវារទ្រង់អើយ ចូរសរសើរដល់ទ្រង់ចុះ ។**

**ធម្មជាតិទាំងអស់**

ព្រះគម្ពីរទំនុកដំកើង ១៤៨:៧-១០ ចែងថា: **ចូរសរសើរដល់ព្រះយេហូវ៉ាពីផែនដីដែរ នែ អស់ទាំងសត្វសំបើមនៅក្នុងសមុទ្រ និងទីជំរៅទាំងប៉ុន្មាន អស់ទាំងភ្លើង និងព្រិល ហិមៈ និងចំហាយទឹក ទាំងខ្យល់ព្យុះ ដែលសំរេចតាមព្រះបន្ទូលទ្រង់ ព្រមទាំងភ្នំធំតូចទាំងអស់ ដើមឈើដែលមានផ្លែ និងដើមតាត្រាវទាំងប៉ុន្មាន គ្រប់ទាំងសត្វព្រៃ សត្វស្រុក សត្វលូនវារ និងសត្វស្លាប ។**

**ទាំងស្តេចទាំងប្រជារាស្ត្រ**

ព្រះគម្ពីរទំនុកដំកើង ១៤៨:១១-១៣ ចែងថា: **អស់ទាំងស្តេចនៅផែនដី និងបណ្តាជនទាំងឡាយ ពួកអ្នកធំៗ និងពួកចៅក្រមនៅផែនដី ទាំងមនុស្សកំឡោះ និងស្រីក្រមុំ ទាំងចាស់ទាំងក្មេងអើយ ត្រូវឱ្យទាំងអស់សរសើរដល់ព្រះនាមព្រះយេហូវ៉ាចុះ ដ្បិតមានតែព្រះនាមទ្រង់១ដែលខ្ពស់ប្រសើរ សិរីល្អនៃទ្រង់ខ្ពស់ជាងផែនដី និងផ្ទៃមេឃទៅទៀត ។**

## ពេលណាដែលយើងត្រូវសរសើរតម្កើងដល់ព្រះអម្ចាស់?

**ចាប់តាំងពីព្រឹករហូតដល់ល្ងាច**

ព្រះគម្ពីរទំនុកដំកើង ១១៣:៣ ចែងថា: **ចាប់តាំងពីទីថ្ងៃរះរហូតដល់ទីថ្ងៃលិច នោះព្រះនាមព្រះយេហូវ៉ាគួរសរសើរ ។**

**គ្រប់ថ្ងៃទាំងអស់**

ព្រះគម្ពីរទំនុកដំកើង ៧១:៨ ចែងថា: **មាត់ទូលបង្គំនឹងពេញដោយសេចក្តីសរសើរដល់ទ្រង់ ហើយនិងពោលពីកិត្តិសព្ទនៃព្រះនាមទ្រង់ដរាបរាល់ថ្ងៃ ។**

**ពេលដែលយើងនៅមានជីវិតរស់**

ព្រះគម្ពីរទំនុកដំកើង ១៤៦:២ ចែងថា: **កាលខ្ញុំកំពុងរស់នៅឡើយ នោះខ្ញុំនឹងសរសើរដល់ព្រះយេហូវ៉ា ខ្ញុំនឹងច្រៀងសរសើរដល់ព្រះនៃខ្ញុំ ក្នុងកាលដែលនៅមានជីវិតតទៅ ។**

**នៅតែសរសើតម្កើងដល់ទ្រង់ជានិច្ច**

ព្រះគម្ពីរទំនុកដំកើង ៣៤:១ ចែងថា: **ខ្ញុំនឹងលើកសរសើរដល់ព្រះយេហូវ៉ាគ្រប់ពេលវេលា សេចក្តីសរសើរពីទ្រង់នឹងនៅក្នុងមាត់ខ្ញុំជានិច្ច ។**

**នៅពេលដែលអស់កម្លាំង**

ព្រះគម្ពីរទំនុកដំកើង ៤២:១១ ចែងថា: **ឱព្រលឹងអញអើយ ហេតុអ្វីបានជាឯងត្រូវបង្អោនចុះ ហើយមានសេចក្តីសាប់រសល់នៅក្នុងខ្លួនដូច្នេះ ចូរសង្ឃឹមដល់ព្រះចុះ ដ្បិតអញនឹងបានសរសើរដល់ទ្រង់ទៀត ដែលទ្រង់ជាសេចក្តីជំនួយ ហើយជាព្រះនៃអញ ។**

**សរសើតម្កើងជានិច្ច**

ព្រះគម្ពីរអេភេសូរ ៥:២០ ចែងថា: **ទាំងអរព្រះគុណដល់ព្រះដ៏ជាព្រះ វរបិតាជាដរាប ក្នុងគ្រប់ការទាំងអស់ ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ។**

## តើយើងត្រូវសរសើរតម្កើងដល់ព្រះអម្ចាស់នៅទីណា?

**នៅក្នុងព្រះវិហារ**

ព្រះគម្ពីរទំនុកដំកើង ២២:២២,២៥ ចែងថា: **ទូលបង្គំនឹងប្រកាសប្រាប់ពីព្រះនាមទ្រង់ ដល់ពួកបងប្អូន ទូលបង្គំនឹងសរសើរដំកើងទ្រង់ នៅកណ្តាលពួកជំនុំ... ទ្រង់ជាដើមហេតុនៃការដែលទូលបង្គំសរសើរនៅក្នុងជំនុំធំ ទូលបង្គំនឹងលាបំណន់របស់ទូលបង្គំ នៅចំពោះមុខពួកអ្នកដែលកោតខ្លាចដល់ទ្រង់ ។**

ព្រះគម្ពីរទំនុកដំកើង ១០៧:៣២ ចែងថា: **គួរឱ្យគេលើកដំកើងទ្រង់នៅក្នុងជំនុំនៃជនទាំងឡាយ ហើយសរសើរទ្រង់នៅទីអង្គុយរបស់ពួកចាស់ទុំដែរ ។**

ព្រះគម្ពីរទំនុកដំកើង ១៤៩:១ ចែងថា: **ចូរសរសើរដល់ព្រះយេហូវ៉ា ចូរច្រៀងបទ១ថ្មីថ្វាយព្រះយេហូវ៉ា ព្រមទាំងសេចក្តីសរសើរពីទ្រង់ នៅក្នុងជំនុំនៃពួកអ្នកបរិសុទ្ធផង ។**

**នៅក្នុងទីស្នាត់កំបាំង**

ព្រះគម្ពីរទំនុកដំកើង ១៥០:១ ចែងថា: **ចូរសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះ នៅក្នុងទីបរិសុទ្ធរបស់ទ្រង់ ចូរសរសើរដល់ទ្រង់ នៅចន្លោះអាកាស ជាទីសំដែងព្រះចេស្តាទ្រង់ ។**

**នៅក្នុងចំណោមប្រជាជាតិទាំងឡាយ**

ព្រះគម្ពីរទំនុកដំកើង ៥៧:៩ ចែងថា: **ឱព្រះអម្ចាស់អើយ ទូលបង្គំនឹងប្រទូលដែដល់ទ្រង់នៅ កណ្តាលពួកជន ទូលបង្គំនឹងច្រៀងសរសើរទ្រង់ នៅកណ្តាលពួកសាសន៍ដទៃ ។**

**នៅក្នុងទីលានរបស់ព្រះអង្គ**

ព្រះគម្ពីរទំនុកដំកើង ១០០:៤ ចែងថា: **ចូរនាំគ្នាចូលតាមទ្វារទ្រង់ ដោយពោលពាក្យអរព្រះគុណ ហើយចូលទៅក្នុងទីលានទ្រង់ ដោយបទសរសើរ ចូរអរព្រះគុណដល់ទ្រង់ ហើយសរសើរព្រះនាមទ្រង់ចុះ ។**

**នៅក្នុងចំណោមមនុស្សជាច្រើន**

ព្រះគម្ពីរទំនុកដំកើង ១០៩:៣០ ចែងថា: **មាត់ទូលបង្គំនឹងអរព្រះគុណដល់ ព្រះយេហូវ៉ាយ៉ាងក្រៃលែង អើ ទូលបង្គំនឹងសរសើរដល់ទ្រង់ នៅកណ្តាលជនទាំងឡាយ ។**

## សំណួររំឭកសារឡើងវិញ

១. ចូរផ្ដល់ឱ្យនូវហេតុផលបីយ៉ាង ដែលយើងរាល់គ្នាគួរគប្បីសរសើរតម្កើងដល់ព្រះអម្ចាស់ ។

២. តើនៅពេលណាដែលត្រូវតែសរសើរតម្កើងដល់ព្រះអម្ចាស់? ចូរឱ្យនូវឧទាហរណ៍មួយដែលដកស្រង់ចេញពីព្រះគម្ពីរ ហើយមួយទៀតដែលដកស្រង់ចេញពីការដកពិសោធន៏ផ្ទាល់របស់លោកអ្នក ។

៣. ចូរធ្វើបញ្ជីឈ្មោះខគម្ពីរទាំងបី ដែលលោកអ្នកមានបំណងទន្ទេញចាំមាត់ ខគម្ពីរនោះនឹងមានទាំងការលើកទឹកចិត្ត ដើម្បីឱ្យបានសរសើរតម្កើងដល់ព្រះ ដល់ខ្លួនឯងផ្ទាល់ ឬក៏លើកទឹកចិត្តដល់អ្នកដទៃទៀតផងដែរ ។

# មេរៀនទី ៤
## *ការសរសើរតម្កើងនាំមកនូវព្រះពររបស់ព្រះ*

### ការសរសើរតម្កើងគឺបានប្រដូចទៅនឹងវង្វង់ទឹកភ្លៀង

**វង្វង់នៃផលវិទ្យា**

មានកន្លែងជាច្រើននៅក្នុងព្រះគម្ពីរ ដែលនិយាយពីការសរសើរតម្កើង គឺបានប្រដូចទៅនឹងវង្វង់ទឹកភ្លៀង ។ វង្វង់នេះគឺគ្មានទីបញ្ចប់ទេ គឺនៅតែមានជាបន្ត ដែលហូរចេញទៅពីម្នាក់ទៅម្នាក់ទៀត ។

- *ទឹកនៅលើផែនដីនេះនឹងត្រូវហួតទៅវិញ*
- *គឺជាទម្រង់ពពកដែលមាននៅក្នុងអាកាស*
- *ទឹកភ្លៀងនោះនឹងវិលត្រឡប់មកផែនដីវិញ*

**វង្វង់នៃការសរសើរតម្កើង**

ការសរសើរតម្កើងគឺត្រូវតែគ្មានទីបញ្ចប់ឡើយ ។ យើងរាល់គ្នាថ្វាយការសរសើរតម្កើងដល់ព្រះ នោះនឹងនាំមកនូវៈ

- *ព្រះពរ*
- *ជ័យជម្នះ*
- *ការលូតលាស់*

ព្រះគម្ពីរអេម៉ុស ៥:៨ ចែងថាៈ **ចូរស្វែងរកព្រះដែលទ្រង់បានបង្កើតផ្កាយកូនមាន់ និងផ្កាយនាយព្រាន ក៏ធ្វើឱ្យម្លប់នៃសេចក្ដីស្លាប់ប្រែទៅជាព្រលឹមស្រាង ហើយឱ្យថ្ងៃត្រឡប់ទៅជាយប់វិញ ព្រមទាំងហៅទឹកសមុទ្រមក រួចចាក់ទៅលើផែនដី ព្រះនាមទ្រង់ គឺព្រះយេហូវ៉ា ។**

ព្រះគម្ពីរអេម៉ុស ៩:៦ ចែងថាៈ **ឯព្រះដែលបានសាងអស់ទាំងស្ថានដ៏ខ្ពស់របស់ទ្រង់ នៅលើស្ថានសួគ៌ ហើយតាំងជីវិតទាំងឡាយ ឱ្យនៅផែនដី ក៏តែងតែបង្គាប់ទឹកសមុទ្រឱ្យឡើងទៅលើ រួចចាក់មកលើផែនដីវិញ ទ្រង់ព្រះនាមជា «ព្រះយេហូវ៉ា» ។**

**ព្រះទ្រង់បានចាក់ចេញមកនូវព្រះពរ**

គ្រាន់តែព្រះទ្រង់បានត្រាស់ហៅទឹកដែលបានបង្ហូតទៅ នោះទឹកភ្លៀងក៏ធ្លាក់ចុះមកភ្លាម រីឯទ្រង់ដែលបានហៅយើងរាល់គ្នាមក ឱ្យសរសើរតម្កើងដល់ទ្រង់ នោះគឺដើម្បីឱ្យទ្រង់បានចាក់ចេញនូវព្រះពររបស់ទ្រង់មកយើងរាល់គ្នានោះឯង ។

ព្រះគម្ពីរយ៉ូប ៣៦:២៧,២៨ ចែងថា: **គឺទ្រង់ដែលជក់ទឹកនៅលើឱ្យប្រែជាចំហាយ រួចទំលាក់ជាភ្លៀងវិញ ជាទឹកដែលពពកចាក់ចុះមកឱ្យធ្លាក់ជាបរិបូរ ស្រោចស្រប់លើមនុស្សលោក ។**

ព្រះគម្ពីរអេសាយ ៤៥:៨ ចែងថា: **ឱផ្ទៃមេឃអើយ ចូរស្រក់ទឹកពីលើមក ហើយឱ្យពពកចាក់សេចក្តីសុចរិតចុះ មក ចូរឱ្យផែនដីហាឡើង ឱ្យបានបង្កើតផលជាសេចក្តីសង្គ្រោះ ហើយឱ្យសេចក្តីសុចរិតពន្លកឡើងជាមួយគ្នា ឯអញ គឺយេហូវ៉ា អញបានបង្កើតសេចក្តីនោះឡើង ។**

**ការសរសើរតម្កើងសម្តៅទៅខាងលើ**
**រីឯព្រះពរវិញត្រូវបានទម្លាក់ចុះមក**

នៅពេលដែលយើងរាល់គ្នាថ្វាយការសរសើរទៅព្រះ នោះទ្រង់បានបង្ហូរព្រះពរឱ្យធ្លាក់ចុះមក ដូចជាទឹកភ្លៀងដែលបានវិលមកឯយើងវិញដូច្នោះដែរ ។

ព្រះគម្ពីរសុភាសិត ១១:២៥ ចែងថា: **មនុស្សដែលមានចិត្តសទ្ធានឹងបានបរិបូរ ហើយអ្នកណាដែលស្រោចទឹកដល់គេ នោះនឹងបានគេស្រោចទឹកដល់ខ្លួនដែរ ។**

ព្រះគម្ពីរទំនុកដំកើង ៦៧:៥,៦ ចែងថា: **ឱព្រះអង្គអើយ សូមឱ្យជនទាំងឡាយសរសេរដល់ទ្រង់ ឱ្យជនទាំងអស់សរសើរដល់ទ្រង់ចុះ នោះនឹងបង្កើតផលឡើង ហើយព្រះដ៏ជាព្រះនៃយើងខ្ញុំ ទ្រង់នឹងប្រទានពរមកយើងខ្ញុំ ។**

ព្រះគម្ពីរទំនុកដំកើង ១៤៧:៧,៨ ចែងថា: **ចូរច្រៀងថ្វាយព្រះយេហូវ៉ា ដោយពាក្យអរព្រះគុណ ចូរច្រៀងបទសរសើរដល់ព្រះនៃយើងខ្ញុំ ដោយចាប់ស៊ុង ទ្រង់បាំងមេឃដោយពពក ក៏ចាត់ចែងភ្លៀងសំរាប់ផែនដី ហើយធ្វើឱ្យមានស្មៅដុះឡើងនៅលើភ្នំ ។**

ព្រះគម្ពីរសាការី ១០:១ ចែងថា: **ចូរឱ្យឯងរាល់គ្នាសូមទឹកភ្លៀងពីព្រះយេហូវ៉ា នៅវេលាភ្លៀងចុងរដូវ គឺសូមពីព្រះយេហូវ៉ា ដែលទ្រង់ធ្វើឱ្យមានផ្លេកបន្ទោរ នោះទ្រង់នឹងប្រោសប្រទាន ឱ្យមានភ្លៀង១មេៗដល់ឯង ឱ្យគ្រប់គ្នាមានស្មៅនៅចំការរបស់ខ្លួន ។**

### វង្វង់ដែលមិនចេះចប់ឡើយ

ព្រះគម្ពីរយ៉ាកុប ៥:៧ ចែងថា: **បងប្អូនអើយ ចូរមានចិត្តអត់ធ្មត់ដរាបដល់ព្រះអម្ចាស់ទ្រង់យាងមក មើល អ្នកធ្វើស្រែគេរង់ចាំផលវិសេស ដែលកើតពីដីមកដោយសេចក្តីអត់ធ្មត់ ទាល់តែបានភ្លៀងធ្លាក់មកខាងដើមរដូវ និងចុងរដូវផង ។**

ចំពោះកសិករគឺមិនដែលប្រមូលផល នៅរដូវសាបព្រោះឡើយ គាត់ក៏ត្រូវតែអត់ធ្មត់រង់ចាំពេលវេលា ដែលលោកអ្នកនឹងត្រូវច្រូតកាត់ នៅក្នុងរដូវច្រូតកាត់របស់លោកអ្នក ឬក៏ជាព្រះពរនោះ ។

ព្រះទ្រង់បានបណ្តាលឱ្យព្រះពររបស់ទ្រង់ បានបញ្ចេញមកដល់មនុស្សជាតិ គឺដូចជាព្រះអាទិត្យដែលបានបញ្ចេញរស្មីមកលើទឹកសមុទ្រដូច្នោះដែរ ។ ចិត្តរបស់មនុស្សគួរគប្បីត្រូវបានទទួលនូវការព្រមាន រហូតដល់ព្រះទ្រង់បានសម្រេចព្រះហឫទ័យប្រទានពរ ដែលទ្រង់បានបង្ហាញដល់គេ ។

ការសរសើរតម្កើងរបស់មនុស្សគឺត្រូវតែលើដៃចុះចូលចំពោះព្រះដូចជាចំហាយទឹក ដែលត្រូវបានបង្កើតឡើងដោយព្រះអាទិត្យ ដែលបានចាំងរស្មីទៅលើទឹកសមុទ្រនោះ ។

អស់អ្នកដែលសរសើរតម្កើង នោះប្រៀបដូចជាដុំពពកនៃព្រះពរ ។

ព្រះទ្រង់បានបណ្ដាលឱ្យព្រះពរ ដើម្បីចម្រាញ់ឱ្យចូលទៅក្នុងទឹកភ្លៀង ដែលត្រូវតែទម្លាក់មកលើផែនដីជាបន្ទបន្ទាប់ ។

ទម្រង់ទឹកភ្លៀងដែលមានហួសកំណត់នៅតាមដងស្ទឹង នោះក៏ត្រូវធ្លាក់មកឯសមុទ្រ ហើយដែលវាបានចេញមកពីទីណា នោះក៏វាធ្លាក់ទៅវិញ ដែលវាបានមកនោះដែរ ហើយចំពោះរបៀបរបបទាំងអស់ ក៏វានឹងចាប់ផ្ដើមសារជាថ្មីឡើងវិញដែរ ។

## ផលកម្រៃដែលបានមកពីការសរសើរតម្កើង

### ត្រូវទុកឱ្យព្រះទ្រង់បញ្ចេញសកម្មភាព

ព្រះគម្ពីរកិច្ចការ ១៦:២៥,២៦ ចែងថា: **លុះពេលប្រហែលជាកណ្ដាលអធ្រាត្រ ប៉ុល និងស៊ីឡាស កំពុងតែអធិស្ឋាន ហើយច្រៀងសរសើរដល់ព្រះ ឯពួកអ្នកទោសក៏ស្ដាប់ដែរ នោះស្រាប់តែកើតមានកក្រើកដីជាខ្លាំង ដល់ម៉្លេះបានជារញ្ជួយដល់ជើងជញ្ជាំងគុកផង ហើយទ្វារទាំងប៉ុន្មានរបើកចេញភ្លាម ខ្នោះក៏របើបចេញទាំងអស់ទៅ ។**

### ផែនដីនាំមកនូវការរីកចម្រើន

ព្រះគម្ពីរទំនុកដំកើង ៦៧:៥,៦ ចែងថា: **ឱព្រះអង្គអើយ សូមឱ្យជនទាំងឡាយសរសេរដល់ទ្រង់ ឱ្យជនទាំងអស់សរសើរដល់ទ្រង់ចុះ នោះនឹងបង្កើតផលឡើង ហើយព្រះដ៏ជាព្រះនៃយើងខ្ញុំ ទ្រង់នឹងប្រទានពរមកយើងខ្ញុំ ។**

### ជ័យជម្នះក៏បានមកដែរ

ព្រះគម្ពីរ២របាក្សត្រ ២០:២១,២២ ចែងថា: **រួចកាលទ្រង់បានពិគ្រោះនឹងបណ្ដាជនហើយ នោះទ្រង់ក៏ដំរូវឱ្យមានពួកអ្នក ដែលត្រូវច្រៀងថ្វាយព្រះយេហូវ៉ា ហើយពោលសរសើរ ដោយស្លៀកពាក់ជាប្រដាប់បរិសុទ្ធ ក្នុងកាលដែលគេនាំមុខពួកទ័ពចេញទៅ ដោយពោលថា ចូរអរព្រះគុណដល់ព្រះយេហូវ៉ាចុះ ដ្បិតសេចក្ដីសប្បុរសទ្រង់នៅជាប់អស់កល្បជានិច្ច ដូច្នេះ កាលគេចាប់តាំងច្រៀង ហើយសរសើរឡើង នោះព្រះ**

**យេហូវ៉ាទ្រង់បង្កប់ទ័ពទាស់នឹងពួកកូនចៅអាំម៉ូន ម៉ូអាប់ និងពួកភ្នំសៀរ ដែលមកច្បាំងនឹងពួកយូដា ឱ្យគេត្រូវចាញ់ ។**

**នាំមកនូវការប្រោសឱ្យជា**

ព្រះគម្ពីរសុភាសិត ១៧:២២ ចែងថា: **ចិត្តដែលសប្បាយជាថ្នាំយ៉ាងវិសេស តែវិញ្ញាណបាក់បែករមែងឱ្យឆ្អឹងរីងស្ងួតទៅ ។**

**នាំមកនូវសេចក្ដីសុខសាន្ត**

ព្រះគម្ពីរអេសាយ ៦០:១៨ ចែងថា: **នៅក្នុងស្រុកឯងនឹងមិនដែលឮនិយាយពីសេចក្ដីច្រឡោតទៀត ឬពីការរឹបជាន់ ឬពីការបំផ្លាញនៅក្នុងព្រំដែនឯងឡើយ គឺឯងនឹងហៅកំផែងឯងថា «សេចក្ដីសង្គ្រោះ» ហើយទ្វារឯងថា «សេចក្ដីសរសើរ» ។**

**បំផ្លាស់បំប្រែយើងរាល់គ្នា**

យើងរាល់គ្នានឹងត្រូវបានបំផ្លាស់បំប្រែឱ្យចូលទៅក្នុងសិរីល្អដូចៗគ្នាដូចជាព្រះ ដែលយើងរាល់គ្នាថ្វាយបង្គំនោះ ។

ព្រះគម្ពីរ២កូរិនថូស ៣:១១,១៨ ចែងថា: **ដ្បិតបើសិនជាសេចក្ដីនោះ ដែលកំពុងតែសូន្យបាត់ទៅ បានមកដោយសារសិរីល្អ នោះសេចក្ដីដែលជាប់នៅ ប្រាកដជាមានសិរីល្អលើសទៅទៀត... ហើយយើងរាល់គ្នាទាំងអស់ ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់ ទាំងមុខទទេ ដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់ យើងកំពុងតែផ្លាស់ប្រែទៅ ឱ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ ។**

ព្រះគម្ពីរ១យ៉ូហាន ៣:១,២ ចែងថា: **មើល សេចក្ដីស្រឡាញ់យ៉ាងណាហ្ន៎ ដែលព្រះវរបិតាបានផ្ដល់មកយើងរាល់គ្នា ឱ្យយើងបានហៅថាជាកូនរបស់ព្រះដូច្នេះ គឺដោយហេតុនោះបានជាលោកិយមិនស្គាល់យើងទេ ពីព្រោះមិនស្គាល់ទ្រង់ដែរ ពួកស្ងួនភ្ងាអើយ ឥឡូវនេះ យើងរាល់គ្នាជាកូនព្រះហើយ តែដែលយើងរាល់គ្នានឹងបានទៅជាយ៉ាងណាទៀត នោះមិនទាន់សំដែងមកនៅឡើយ ប៉ុន្តែ យើងដឹងថាកាលណាទ្រង់លេច**

**មក នោះយើងនឹងបានដូចជាទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង ។**

## អំណរនៅក្នុងព្រះអម្ចាស់

### មុខដែលក្រៀមក្រំ

ទឹកមុខដែលក្រៀមក្រំ គឺជាការបង្ហាញនូវចិត្តដែលមិនមានពេញទៅដោយសេចក្តីអំណរ ។

ព្រះគម្ពីរនេហេមា ២:១,២ ចែងថា: **លុះដល់ខែចេត្រឆ្នាំទី២០ ក្នុងរាជ្យរបស់ស្តេចអើថាសើកសេស ក្នុងពេលមានស្រាទំពាំងបាយជូរដាក់នៅចំពោះស្តេច នោះខ្ញុំបានលើកថ្វាយដល់ទ្រង់ ឯពីមុន ខ្ញុំមិនដែលមានសេចក្តីព្រួយ នៅចំពោះទ្រង់ឡើយ ដូច្នេះ ស្តេចទ្រង់មានបន្ទូលសួរខ្ញុំថា អ្នកឥតមានឈឺសោះ ហេតុអ្វីបានជាមានទឹកមុខព្រួយដូច្នេះ នេះកើតតែពីសេចក្តីទុក្ខក្នុងចិត្តទេ នៅខ្ញុំក៏ភ័យខ្លាចណាស់ ។**

នៅពេលដែលស្តេចបានបញ្ចេញនូវការទទួលស្គាល់ ដល់ទឹកមុខដែលក្រៀមស្រពោនរបស់លោកនេហេមា នោះលោកនេហេមាក៏មានការភ័យខ្លាច ។ ទឹកមុខក្រៀមក្រំ គឺអាចមានន័យថា គាត់មិនសប្បាយចិត្តនៅក្នុងការបម្រើដល់ស្តេច និងអាចមានន័យថា គាត់នឹងត្រូវស្លាប់ ។

ដើម្បីឱ្យបានចូលមកឯវត្តមាននៃស្តេច ដោយអារម្មណ៍មិនមានការសប្បាយចិត្តយ៉ាងដូច្នោះ នោះគឺឈ្មោះថាប្រមាថដល់ស្តេចហើយ ។ រីឯការចូលមកឯព្រះវត្តមាននៃព្រះវិញ ដោយមានការបង្ហាញពីភាពមិនសប្បាយចិត្តយ៉ាងដូច្នោះ នោះគឺត្រូវតែបញ្ជាក់ថា យើងមិនសប្បាយចិត្តជាមួយនឹងការដែលទ្រង់បាន:

- *ប្រទានឱ្យមកយើង*
- *ធ្វើសម្រាប់យើង*
- *ប្រទានពរសម្រាប់យើង*
- *មានផែនការសម្រាប់យើង*

**ទ្រង់បញ្ជាឱ្យយើងមានសេចក្តីអំណរ**

យើងរាល់គ្នាត្រូវបានទទួលបញ្ជា ឱ្យមានសេចក្តីអំណរនៅចំពោះព្រះអម្ចាស់ ។

ព្រះគម្ពីរចោទិយកថា ១២:៧,១១,១២ ចែងថាៈ **ហើយនៅទីនោះ ត្រូវឱ្យឯងរាល់គ្នាបរិភោគនៅចំពោះព្រះយេហូវ៉ា ជាព្រះនៃឯង ហើយឯងនិងពួកគ្រួសារឯង ត្រូវអរសប្បាយឡើង ដោយព្រោះគ្រប់ទាំងរបស់ដែលដៃឯងលូកទៅចាប់យក ពីរបស់ទាំងប៉ុន្មានដែលព្រះយេហូវ៉ាជាព្រះនៃឯង បានប្រទានពរដល់ឯងហើយ... នោះត្រូវនាំយកអស់ទាំងដង្វាយ ដែលអញបង្គាប់ឯង ទៅថ្វាយនៅកន្លែងណាដែលព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងរើសសំរាប់តាំងព្រះនាមទ្រង់ចុះ គឺអស់ទាំងដង្វាយដុតយញ្ញបូជា ដង្វាយ១ភាគក្នុង១០ ដង្វាយលើកចុះឡើង ហើយគ្រប់ទាំងផលជ្រើសរើស ដែលឯងបានបន់ថ្វាយព្រះយេហូវ៉ាផង ត្រូវឱ្យឯងរាល់គ្នាអរសប្បាយឡើង នៅចំពោះព្រះយេហូវ៉ា ជាព្រះនៃឯង ព្រមទាំងកូនប្រុសកូនស្រីឯង និងបាវប្រុសបាវស្រីឯង ហើយនិងពួកលេវីដែលនៅក្នុងទីក្រុងឯងផង ដ្បិតពួកលេវីគ្មានចំណែក គ្មានមរដកនៅជាមួយនឹងឯងទេ ។**

ព្រះគម្ពីរ១របាក្សត្រ ១៦:១០ ចែងថាៈ **ចូរមានចិត្តរីករាយដោយនូវព្រះនាមបរិសុទ្ធរបស់ទ្រង់ ចូរឱ្យអស់អ្នកដែលស្វែងរកព្រះយេហូវ៉ា មានចិត្តអរសប្បាយឡើង ។**

ព្រះគម្ពីរទំនុកដំកើង ៣៣:១ ចែងថាៈ **ឱពួកអ្នកសុចរិតអើយ ចូរមានចិត្តរីករាយក្នុងព្រះយេហូវ៉ាចុះ ដ្បិតសេចក្តីសរសើរនោះ សំណំដល់មនុស្សទៀងត្រង់ ។**

ព្រះគម្ពីរលូកា ១:៤៦,៤៧ ចែងថាៈ **រួចម៉ារានិយាយឡើងថា ព្រលឹងខ្ញុំលើកដំកើងព្រះអម្ចាស់ វិញ្ញាណខ្ញុំក៏រីករាយនឹងព្រះដ៏ជាព្រះអង្គសង្គ្រោះនៃខ្ញុំ ។**

ព្រះគម្ពីរភីលីព ៤:៤ ចែងថា: **ចូរអរសប្បាយ ក្នុងព្រះអម្ចាស់ជានិច្ច ខ្ញុំប្រាប់ម្តងទៀតថា ចូរអរសប្បាយឡើង ។**

**សេចក្តីអំណរអរសប្បាយបានមកដល់ហើយ**

សេចក្តីអំណរអរសប្បាយគឺបានមកពីការបើកសម្តែង និងការជញ្ជឹងគិតពីព្រះបន្ទូលរបស់ព្រះ ។

ព្រះគម្ពីរយេរេមា ១៥:១៦ ចែងថា: **ទូលបង្គំបានឃើញព្រះបន្ទូលទ្រង់ ទូលបង្គំបានទទួលទានលេបចូលអស់ហើយ ព្រះបន្ទូលរបស់ទ្រង់ជាសេចក្តីអំណរ ហើយជាទីរីករាយដល់ចិត្តទូលបង្គំ ដ្បិតព្រះយេហូវ៉ាជាព្រះនៃពួកពលបរិវារអើយ ទូលបង្គំបានហៅតាមព្រះនាមទ្រង់ ។**

**បន្ទាប់ពីគ្រាប់ពូជដែលត្រូវបានព្រោះចុះ**

យើងត្រូវតែ "ចេញទៅដោយមានសេចក្តីអំណរ" គឺបន្ទាប់ពីគ្រាប់ពូជនៃព្រះបន្ទូលរបស់ព្រះ ដែលត្រូវបានព្រោះចូលមកក្នុងចិត្តយើង ។

ព្រះគម្ពីរអេសាយ ៥៥:១០-១២ ចែងថា: **ពីព្រោះដែលភ្លៀង និងហិមៈធ្លាក់ចុះមកពីលើមេឃ ឥតវិលត្រឡប់ទៅលើវិញ គឺមកស្រោចដី ធ្វើឱ្យកើតចេញជាពន្លកឡើង ហើយក៏ឱ្យពូជពង្រោះដល់អ្នកដែលព្រោះ និងអាហារដល់អ្នកដែលបរិភោគជាយ៉ាងណា នោះពាក្យអញ ដែលចេញពីមាត់អញទៅ ក៏មិនដែលវិលមកឯអញវិញ ដោយឥតកើតផលយ៉ាងដូច្នោះដែរ គឺនឹងធ្វើសំរេចតាមសេចក្តីប៉ងប្រាថ្នានៅក្នុងចិត្តអញ ហើយនឹងចំរើនកើនឡើង ក្នុងការអ្វីដែលអញចាត់ទៅធ្វើនោះ ដ្បិតឯងរាល់គ្នានឹងចេញទៅដោយអំណរ ហើយគេនឹងនាំឯងចេញទៅដោយសុខសាន្ត ឯអស់ទាំងភ្នំធំ និងភ្នំតូចទាំងប៉ុន្មាននឹងធ្លាយចេញជាចំរៀងនៅមុខឯង ហើយគ្រប់ទាំងដើមឈើនៅព្រៃនឹងទះដៃផង ។**

**បញ្ឈប់សាតាំងដោយមានសេចក្តីអំណរ**

តើសាតាំងព្យាយាមធ្វើដូចម្តេចខ្លះ បន្ទាប់ពីព្រះបន្ទូលដែលបានព្រោះចូលទៅក្នុងចិត្តរបស់យើងហើយ? គឺវាមកយ៉ាងប្រញាប់ប្រញាល់

ជាមួយនឹងការឈឺចាប់ និងការបៀតបៀនរបស់វា ដើម្បីលួចនូវគ្រាប់ពូជនោះ ។

ប្រសិនបើយើងបានត្រឡប់មកជាមានការបាក់ទឹកចិត្ត និងបាត់បង់នូវសេចក្តីអំណរ នោះយើងអនុញ្ញាតឱ្យសាតាំងមកលួចនូវគ្រាប់ពូជនៃព្រះបន្ទូល ដែលបានព្រោះមកក្នុងចិត្តរបស់យើងហើយ ។

ព្រះគម្ពីរម៉ាកុស ៤:៤,១៤-១៧ ចែងថា: **កំពុងដែលព្រោះ មានខ្លះធ្លាក់ចុះតាមផ្លូវហើយសត្វហើរលើអាកាសក៏មកចឹកស៊ី... ឯអ្នកព្រោះពូជ គឺព្រោះព្រះបន្ទូលឯពួកអ្នកតាមផ្លូវ គឺជាកន្លែងដែលបានព្រោះព្រះបន្ទូលចុះ កាលគេឮ នោះអារក្សសាតាំងក៏មកលួចឆក់យកព្រះបន្ទូលដែលព្រោះក្នុងចិត្តគេទៅភ្លាម ឯពួកអ្នកដែលទទួលពូជក្នុងកន្លែងថ្មក៏ដូចគ្នាដែរ កាលណាគេឮព្រះបន្ទូល នោះគេទទួលភ្លាមដោយអំណរ តែគ្មានចាក់ឫសនៅក្នុងខ្លួនសោះ ហើយក៏នៅជាប់តែបន្តិចទេ បើកាលណាកើតមានសេចក្តីទុក្ខលំបាក ឬសេចក្តីបៀតបៀន ដោយព្រោះព្រះបន្ទូល នោះគេរវាតចិត្តចេញភ្លាម ។**

**សេចក្តីអំណរគឺបង្កើតនូវផលផ្លែ**

គ្រាប់ពូជនៃព្រះបន្ទូលរបស់ទ្រង់ បាននៅក្នុងយើងគឺនៅពេលដែលសេចក្តីអំណររបស់ទ្រង់ បានធ្វើការនៅក្នុងយើង ។

ព្រះគម្ពីរយ៉ូហាន ១៥:១០,១១ ចែងថា: **បើអ្នករាល់គ្នា កាន់តាមបញ្ញត្តិខ្ញុំ នោះនឹងនៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ខ្ញុំ ដូចជាខ្ញុំបានកាន់តាមបញ្ញត្តិនៃព្រះវរបិតាខ្ញុំ ហើយក៏នៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ទ្រង់ដែរ ខ្ញុំបាននិយាយសេចក្តីទាំងនេះ ប្រាប់ដល់អ្នករាល់គ្នា ដើម្បីឱ្យសេចក្តីអំណររបស់ខ្ញុំ បាននៅជាប់ក្នុងអ្នករាល់គ្នា ហើយឱ្យសេចក្តីអំណររបស់អ្នករាល់គ្នាបានពោរពេញផង ។**

តាមរយៈការស្តាប់បង្គាប់ដល់ព្រះបន្ទូលរបស់ព្រះ នោះសេចក្តីអំណររបស់ទ្រង់ នឹងធ្វើការនៅក្នុងយើង ។ សេចក្តីអំណររបស់ទ្រង់គឺមិន

មែននៅជាបណ្ដោះអាសន្ន ជាការមានលំអៀង ឬជាការទៅតាមកាលៈទេសៈនោះឡើយ ។ គឺមានន័យថា គ្រប់ល័ក្ខណ៍វិញ ។

ព្រះគម្ពីរហេព្រើរ ១០:៣២-៣៤ ចែងថាៈ **ចូរនឹកចាំពីជាន់មុន គឺពីកាលដែលអ្នករាល់គ្នាទើបនឹងបានភ្លឺឡើង នោះក៏ទ្រាំនឹងទុក្ខលំបាកទាំងតតាំងជាខ្លាំងដែរ ដោយសារគេយកអ្នករាល់គ្នាទុកជាល្បែងមើលលេង ទាំងត្មះតិះដៀល ហើយធ្វើទុក្ខដល់អ្នករាល់គ្នានោះម្យ៉ាង ហើយមួយទៀត ដោយអ្នករាល់គ្នាបានភប់ប្រសព្វនឹងពួកអ្នក ដែលត្រូវទុក្ខលំបាកដូច្នោះម្យ៉ាងផង ដ្បិតអ្នករាល់គ្នាមានចិត្តអាណិតអាសូរ ដល់ពួកអ្នកដែលជាប់ចំណង ក៏ទ្រាំឱ្យមនុស្សប្លន់យករបស់ទ្រព្យខ្លួនដោយអំណរ ដោយដឹងថា ខ្លួនមានទ្រព្យសម្បត្តិ ដែលប្រសើរជាង ហើយក៏នៅជាប់លាប់ផង នៅឯស្ថានសួគ៌ ។**

ព្រះគម្ពីរ១ពេត្រុស ៤:១២,១៣ ចែងថាៈ **ពួកស្ងួនភ្ងាអើយ កុំឱ្យមានប្លែកក្នុងចិត្ត ដោយភ្លើងដ៏ក្ដៅក្រហាយ ដែលកំពុងតែល្បងអ្នករាល់គ្នា ទុកដូចជាកើតមានសេចក្ដីចំឡែកនោះឡើយ ត្រូវអរសប្បាយវិញ ដោយព្រោះមានចំណែកក្នុងការរងទុក្ខរបស់ព្រះគ្រីស្ទ ដើម្បីឱ្យអ្នករាល់គ្នាបានត្រេកអររីករាយជាខ្លាំង ក្នុងកាលដែលសិរីល្អទ្រង់លេចមក ។**

ព្រះគម្ពីរម៉ាថាយ ៥:១១,១២ ចែងថាៈ **អ្នករាល់គ្នាមានពរ ក្នុងកាលដែលគេជេរប្រទេចបៀតបៀន ហើយនិយាយបង្កុសគ្រប់ទាំងសេចក្ដីអាក្រក់ពីអ្នករាល់គ្នាដោយព្រោះខ្ញុំ ចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ ដ្បិតអ្នករាល់គ្នាមានរង្វាន់ជាធំនៅឯស្ថានសួគ៌ ពីព្រោះគេក៏បានធ្វើទុក្ខដល់ពួកហោរា ដែលនៅមុនអ្នករាល់គ្នាបែបដូច្នេះដែរ ។**

ព្រះគម្ពីរយ៉ូហាន ១៦:២២ ចែងថាៈ **ឥឡូវនេះ អ្នករាល់គ្នាមានសេចក្ដីព្រួយដូច្នោះមែន ប៉ុន្តែ ខ្ញុំនឹងឃើញអ្នករាល់គ្នាម្ដងទៀត នោះអ្នករាល់គ្នានឹងមានចិត្តអរសប្បាយវិញ ក៏នឹងឥតមានអ្នកណាដកយកសេចក្ដីអំណរនោះ ចេញពីអ្នករាល់គ្នាបានឡើយ ។**

**សេចក្ដីអំណរនាំមកនូវកម្លាំង**

ពេលដែលយើងអរសប្បាយ និងសរសើរតម្កើងដល់ព្រះអម្ចាស់ នោះយើងទទួលបាននូវកម្លាំងរបស់ទ្រង់ ។

ព្រះគម្ពីរនេហេមា ៨:១០ខ ចែងថាៈ **...កុំឱ្យមានចិត្តព្រួយឡើយ ពីព្រោះសេចក្ដីអំណររបស់ព្រះយេហូវ៉ាជាកំឡាំងនៃអ្នករាល់គ្នា ។**

**សេចក្ដីអំណរឈ្នះលើវិញ្ញាណអាក្រក់**

ការអរសប្បាយគឺជាកូនសោរដែលធ្វើមានជ័យជម្នះ "លើវិញ្ញាណអាក្រក់" (គឺជាអារក្សសាតាំង) ។

នៅពេលដែលយើងអរសប្បាយ ព្រមទាំងបានថែរក្សានូវគ្រាប់ពូជនៃព្រះបន្ទូលរបស់ទ្រង់ នោះយើងរាល់គ្នាមានកម្លាំង និងមានជ័យជម្នះនៅក្នុងជីវិតជាគ្រីស្ទានរបស់យើង ។

ព្រះគម្ពីរ១យ៉ូហាន ២:១៣,១៤ ចែងថាៈ **ឪពុករាល់គ្នាអើយ ខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានស្គាល់ព្រះ ដែលទ្រង់គង់នៅតាំងពីដើមរៀងមក កំឡោះរាល់គ្នាអើយ ខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានឈ្នះមេកំណាចហើយ ក្មេងរាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានស្គាល់ព្រះវរបិតា ឪពុករាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះបានស្គាល់ព្រះដែលគង់នៅតាំងពីដើមរៀងមក កំឡោះរាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះមានកំឡាំង ហើយព្រះបន្ទូលក៏ស្ថិតនៅក្នុងអ្នករាល់គ្នា អ្នករាល់គ្នាបានឈ្នះមេកំណាចហើយ ។**

**សេចក្ដីអំណរនាំមកនូវការកែជាថ្មីឡើងវិញ**

ប្រសិនបើសាតាំងបានលួចនូវសេចក្ដីអំណររបស់យើង ហើយយើងបានបាត់បង់នូវគ្រាប់ពូជនៃព្រះបន្ទូល នោះសេចក្ដីល្អ និងជ័យជម្នះរបស់យើង យើងនឹងអាចទទួលបានពីពួកវាមកវិញជាមិនខាន ។

នៅពេលដែលយើងបញ្ចេញសម្លេងដោយសេចក្តីអំណរ ហើយបានថ្វាយដង្វាយនៃការសរសើរ នៅក្នុងដំណាក់នៃព្រះអម្ចាស់ នោះការជាប់ទោសរបស់យើង នឹងត្រូវបានវិលត្រឡប់មកយើងវិញ ហើយសាតាំងក៏ត្រូវតែវិលត្រឡប់ថយក្រោយពីការលួចនោះវិញជាក់ជាមិនខានដែរ ។

ព្រះគម្ពីរយេរេមា ៣៣:៩-១១ ចែងថា: **ឯទីក្រុងនេះនឹងបានសំរាប់ជាហេតុនាំឱ្យអរសប្បាយដល់អញ សំរាប់ជាសេចក្តីសរសើរ និងសេចក្តីល្អផង នៅចំពោះអស់ទាំងនគរនៅផែនដី ជាពួកអ្នកដែលនឹងឮនិយាយពីអស់ទាំងការល្អ ដែលអញប្រោសដល់គេ រួចគេនឹងកោតខ្លាចហើយភ័យញ័រ ដោយព្រោះគ្រប់ទាំងសេចក្តីល្អនឹងសេចក្តីសុខទាំងប៉ុន្មានដែលអញផ្តល់ដល់គេ... ព្រះយេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះថា នៅទីនេះដែលឯងរាល់គ្នាថា ជាទីខូចបង់ឥតមានមនុស្ស ឬសត្វណានៅទៀត គឺនៅក្នុងទីក្រុងនៃស្រុកយូដាទាំងប៉ុន្មាន ហើយនៅអស់ផ្លូវរបស់ក្រុងយេរូសា-ឡិម ដែលចោលស្ងាត់នេះ ឥតមានអ្នកណាអាស្រ័យនៅ ឬមនុស្ស ឬសត្វណាឡើយ នោះនឹងមានឮសំលេងមនុស្សម្តងទៀត ជាសំលេងអរសប្បាយ និងសំលេងរីករាយ គឺសំលេងរបស់ប្តីប្រពន្ធថ្មោងថ្មី និងសំលេងពួកអ្នកដែលពោលថា ចូរលើកសរសើរព្រះយេហូវ៉ានៃពួកពលបរិវារ ដ្បិតព្រះយេហូវ៉ាទ្រង់ល្អ ពីព្រោះសេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅអស់កល្ប ហើយសំឡេងរបស់ពួកដែលនាំយកដង្វាយអរព្រះគុណចូលក្នុងព្រះវិហារនៃព្រះយេហូវ៉ាដែរ ដ្បិតអញនឹងធ្វើឱ្យពួកអ្នកស្រុកនេះ ដែលនៅជាឈ្លើយបានវិលមកវិញ ដូចកាលពីដើម នេះហើយជាព្រះបន្ទូលនៃព្រះយេហូវ៉ា ។**

## ត្រូវតែអធិស្ឋានតាមការអធិស្ឋានទាំង៧ចំណុច

នៅពេលដែលយើងមានសេចក្តីអំណរ នោះយើងអាចសម្លុតដល់ចោរ (សាតាំង) ឱ្យវាបង់សងយើងវិញ តាមការអធិស្ឋានទាំង៧ចំណុចដែលវាបានលួចយកទៅនោះ ។

ព្រះគម្ពីរយ៉ូហាន ១០:១០ ចែងថា: **ឯចោរ វាមកប្រយោជន៍តែនឹងលួច សំឡាប់ ហើយបំផ្លាញប៉ុណ្ណោះ តែឯខ្ញុំវិញ ខ្ញុំបានមក ដើម្បីឱ្យវារាល់គ្នាមានជីវិត ហើយឱ្យមានជីវិតនោះពេញបរិបូរផង ។**

ព្រះគម្ពីរសុភាសិត ៦:៣០,៣១ ចែងថា: **មនុស្សរមែងមិនស្អប់ដល់ចោរ គឺបើវាលួច ឱ្យតែបានឆ្អែតពោះប៉ុណ្ណោះ ក្នុងវេលាដែលស្រេកឃ្លាននោះទេ តែបើទាន់ឃើញវា នោះគង់តែត្រូវឱ្យវាសង១ជា៧វិញដែរ វាត្រូវសងដល់ទៅគ្រប់របស់ដែលនៅក្នុងផ្ទះខ្លួនទាំងអស់ផង ។**

ចូរយើងចាប់ផ្ដើមប្រើសិទ្ធិអរសប្បាយនៅពេលឥឡូវនេះ!

## សំណួររំឭកសារឡើងវិញ

១. ចូរពណ៌នាពីរបៀបសរសើរតម្កើងដែលស្រដៀងគ្នានឹង រង្វង់ទឹកហូរ ។

២. ចូរធ្វើបញ្ជីពីផលកម្រៃទាំងពីរនៃការសរសើរតម្កើង ។

៣. ចូរដាក់ឈ្មោះនូវរឿងពីរយ៉ាង ដែលនិយាយពី "សេចក្ដីអំណរនៅក្នុងព្រះអម្ចាស់" ដែលអាចធ្វើទៅរួច ។

# មេរៀនទី ៥
## *ព្រះបន្ទូលនិយាយពីការសរសើរតម្កើងនៅក្នុងព្រះគម្ពីរ*

### ព្រះបន្ទូលនិយាយពីការសរសើរតម្កើងដែលបានបកប្រែនៅគ្រាសញ្ញាចាស់

ចំនួនពាក្យជាភាសាហេព្រើរ ដែលប្លែកៗផ្សេងៗពីគ្នា នៅគឺត្រូវបានគេប្រើ ដើម្បីពណ៌នាពីការសរសើរតម្កើងនៅគ្រាសញ្ញាចាស់ ។ ការសិក្សានូវពាក្យទាំងនេះគឺបានបើកសម្ដែង ឱ្យមានការយល់ដឹងបានច្បាស់លាស់ នូវអត្ថន័យនៃការសរសើរតម្កើងដល់ព្រះ នៅសម័យសព្វថ្ងៃនេះ ។

ពាក្យជាភាសាហេព្រើរសម្រាប់ការសរសើរតម្កើង គឺបានបញ្ជាក់បង្ហាញនូវសកម្មភាពនៃការរំជើបរំជួលជាច្រើន ។

**ហាឡុល**

ពាក្យហាឡាល "Halal" គឺជាពាក្យដែលត្រូវបានគេប្រើជាញឹកញាប់បំផុត គឺត្រូវបានគេបកប្រែជាពាក្យសរសើរតម្កើង ។ ពាក្យនេះត្រូវបានគេប្រើចំនួន១៦០ដង នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។

ពាក្យនេះមានន័យថា: ការសរសើរតម្កើងរបស់ទ្រង់បានមកពីទ្រង់ (ដោយវិញ្ញាណ និងសេចក្ដីពិត) ។

➢ *ដើម្បីធ្វើការបង្ហាញ*

ព្រះគម្ពីរទំនុកដំកើង ២២:២២ ចែងថា: **ទូលបង្គំនឹងប្រកាសប្រាប់ពីព្រះនាមទ្រង់ ដល់ពួកបងប្អូន ទូលបង្គំនឹងសរសើរដំកើងទ្រង់ នៅកណ្ដាលពួកជំនុំ ។**

➢ *មានអំនួត*

ព្រះគម្ពីរទំនុកដំកើង ១០២:១៨ ចែងថា: **សេចក្ដីនេះនឹងបានកត់ទុកសំរាប់ដំណមនុស្សជាន់ក្រោយ ឱ្យបណ្ដាមនុស្សដែលនឹងកើតឡើងបានសរសើរដំកើងដល់ព្រះយេហូវ៉ា ។**

➢ *ការធ្វើពិធីបុណ្យ*

ព្រះគម្ពីរទំនុកដំកើង ៣៥:១៨ ចែងថា: **ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ នៅក្នុងពួកជំនុំធំ ទូលបង្គំនឹងសរសើរដល់ទ្រង់ នៅកណ្តាលមហាជន ។**

➢ *ការសរសើរតម្កើងដោយហួសហេតុអំពី*

ព្រះគម្ពីរទំនុកដំកើង ១០៧:៣២ ចែងថា: **គួរឱ្យគេលើកដំកើងទ្រង់នៅក្នុងជំនុំនៃជនទាំងឡាយ ហើយសរសើរទ្រង់នៅទីអង្គុយរបស់ពួកចាស់ទុំដែរ ។**

➢ *ថ្វាយសិរីល្អ*

ព្រះគម្ពីរទំនុកដំកើង ៦៤:១០ ចែងថា: **ពួកមនុស្សសុចរិតនឹងអរសប្បាយដោយនូវព្រះយេហូវ៉ា គេនឹងពឹងជ្រកក្នុងទ្រង់ អស់អ្នកណាដែលមានចិត្តទៀងត្រង់ គេនឹងអួតសរសើរ ។**

➢ *ចាំងជះរស្មី*

ព្រះគម្ពីរយ៉ូប ៤១:១៨ ចែងថា: **កាលណាវាព្រួសទឹកចេញ នោះក៏បែកជាពន្លឺ ភ្នែកវាក៏ដូចជាអរុណរះ ។**

ដូច្នេះ ការសរសើរតម្កើងដោយពិតត្រង់ នោះគួរគប្បីបញ្ចេញសម្លេងឱ្យបានច្បាស់លាស់បំផុត ។ គួរគប្បីកុំឱ្យមានការភ័នច្រឡំ ចំពោះអ្វីដែលជាការតាំងចិត្តនោះឱ្យសោះ ។ វាជាការកត់ចំណាំចំពោះពិធីបុណ្យដោយសេចក្តីអំនួតនៅក្នុងព្រះអម្ចាស់ ។

ព្រះគម្ពីរ២របាក្សត្រ ២០:២១,២២ ចែងថា: **រួចកាលទ្រង់បានពិគ្រោះនឹងបណ្តាជនហើយ នោះទ្រង់ក៏ដំរូវឱ្យមានពួកអ្នក ដែលត្រូវច្រៀងថ្វាយព្រះយេហូវ៉ា ហើយពោលសរសើរ ដោយស្លៀកពាក់ជាប្រដាប់បរិសុទ្ធ ក្នុងកាលដែលគេនាំមុខពួកទ័ពចេញទៅ ដោយពោលថា ចូរអរព្រះគុណដល់ព្រះយេហូវ៉ាចុះ ដ្បិតសេចក្តីសប្បុរសទ្រង់នៅជាប់អស់**

**កល្បជានិច្ច ដូច្នេះ កាលគេចាប់តាំងច្រៀង ហើយសរសើរឡើង នោះព្រះយេហូវ៉ាទ្រង់បង្កប់ទ័ពទាស់នឹងពួកកូនចៅអាំម៉ូន ម៉ូអាប់ និងពួកភ្នំសៀរ ដែលមកច្បាំងនឹងពួកយូដា ឱ្យគេត្រូវចាញ់ ។**

**តេហ៊ិឡាស គឺជាពាក្យ (ដែលក្លាយមកពីពាក្យហាឡាល)**

ការសង្កត់សម្លេងចំពោះពាក្យតេហ៊ិឡាស "tehillah" នៅលើការច្រៀង ។ វាត្រូវបានគេប្រើចំនួន៥៧ដង នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។

➢ *ច្រៀងនូវចម្រៀងនៃការសរសើរតម្កើងយ៉ាងច្បាស់លាស់*

វាមានន័យថា ច្រៀងនូវចម្រៀងនៃការសរសើរតម្កើងដល់ព្រះយ៉ាងច្បាស់លាស់ជាបន្តបន្ទាប់ ។

ព្រះគម្ពីរទំនុកដំកើង ១១៩:១៧១ ចែងថា: **សូមអនុញ្ញាតឱ្យបបូរមាត់ទូលបង្គំ បានពោលពាក្យសរសើរ ដ្បិតទ្រង់បង្រៀនអស់ទាំងបញ្ញត្តិរបស់ទ្រង់ដល់ទូលបង្គំ ។**

➢ *ការធ្វើពិធីបុណ្យថ្វាយទ្រង់ដោយច្រៀង*

ព្រះគម្ពីរហាបាកុក ៣:៣ ចែងថា: **ព្រះទ្រង់កំពុងយាងមកពីថេម៉ាន គឺព្រះដ៏បរិសុទ្ធទ្រង់យាងមកពីភ្នំប៉ារ៉ាន-បង្អង់-សិរីល្អនៃទ្រង់បិទបាំងផ្ទៃមេឃ ហើយផែនដីបានពេញដោយសេចក្តីសរសើរដល់ទ្រង់ ។**

➢ *ការមានសេចក្តីអំនួតអំពី*

យើងត្រូវតែមានសេចក្តីអំនួតអំពីទ្រង់ ដោយពាក្យចម្រៀង និងការលេងភ្លេង ។

ព្រះគម្ពីរចោទិយកថា ១០:២១ ចែងថា: **ទ្រង់ជាទំនុកសរសើរ ហើយជាព្រះនៃឯង ទ្រង់បានធ្វើអស់ទាំងការដ៏ធំគួរស្ញែងខ្លាចនេះឱ្យឯងជាការដែលភ្នែកឯងបានឃើញហើយ ។**

**សាបាស**

➢ *ការស្រែកដោយសម្រែកខ្លាំងៗ*

ព្រះគម្ពីរទំនុកដំកើង ៦៣:៣ ចែងថា: **ដ្បិតសេចក្ដីសប្បុរសនៃទ្រង់ នោះវិសេសជាងជីវិត បបូរមាត់ទូលបង្គំនឹងសរសើរដល់ទ្រង់ ។**

➢ *ការស្រែកដោយសម្លេងត្រែ*

ព្រះគម្ពីរដានីយ៉ែល ២:២៣ ចែងថា: **ឱព្រះនៃពួកឰយុកោទូលបង្គំអើយ ទូលបង្គំអរព្រះគុណ ហើយក៏សរសើរដល់ទ្រង់ ពីព្រោះទ្រង់បានប្រោសឱ្យទូលបង្គំមានប្រាជ្ញា និងអំណាច ហើយឥឡូវនេះទ្រង់បានសំដែង ឱ្យទូលបង្គំដឹងសេចក្ដី ដែលយើងខ្ញុំបានសូមពីទ្រង់ ដ្បិតទ្រង់បានសំដែងឱ្យយើងខ្ញុំស្គាល់រឿងរ៉ាវរបស់ស្តេច ។**

➢ *ការថ្វាយសិរីល្អដោយនូវជ័យជម្នះ*

ព្រះគម្ពីរទំនុកដំកើង ១១៧:១ ចែងថា: **ឱសាសន៍ទាំងឡាយអើយ ចូរសរសើរដល់ព្រះយេហូវ៉ា ឱជនរាល់គ្នាអើយ ចូរដំកើងទ្រង់ចុះ ។**

ការសរសើរតម្កើង គឺមិនមែនសុទ្ធតែជាសេចក្ដីត្រូវការក្នុងការធ្វើសម្លេងខ្លាំងៗគ្រប់ពេលនោះទេ ។ យើងមិនត្រូវស្រែកគ្រប់ពេលជានិច្ចនោះទេ គឺមានពេលដែលត្រូវធ្វើតម្រូវទៅតាមប្រធានបទ នៃការសរសើរតម្កើងដល់ព្រះតែប៉ុណ្ណោះ ។

ព្រះគម្ពីរទំនុកដំកើង ៤៧:១ ចែងថា: **ម្នាល ជនទាំងឡាយអើយ ចូរទះដៃទាំងអស់គ្នាចុះ ចូរស្រែកហ៊ោរថ្វាយព្រះ ដោយសំឡេងជាជ័យជំនះ ។**

**ហ្សាម៉ារ**

ហ្សាម៉ារមានន័យថា:

- ➢ *ដេញ ឬលេងភ្លេងដោយប្រដាប់មានខ្សែ*
- ➢ *ព្រមទាំងមានការយល់ដឹងដោយការច្រៀងសរសើរតម្កើងដោយបន្ទរតាមបទភ្លេង*

ព្រះគម្ពីរទំនុកដំកើង ១០៨:១-៣ ចែងថា: **ឱព្រះអង្គអើយ ចិត្តទូលបង្គំបានតាំងនៅមាំហើយ ទូលបង្គំនឹងច្រៀង អើ នឹងច្រៀងសរសើរ**

**ដោយសារកិត្តិយសរបស់ទូលបង្គំដែរ ឱពិណ ហើយនិងស៊ុងអើយ ចូរភ្ញាក់ឡើង ឯទូលបង្គំនឹងភ្ញាក់ពីព្រលឹមដែរ ឱព្រះយេហូវ៉ាអើយ ទូលបង្គំអរព្រះគុណដល់ទ្រង់ នៅកណ្តាលជនទាំងឡាយ ទូលបង្គំនឹងច្រៀងសរសើរទ្រង់ នៅកណ្តាលសាសន៍ដទៃទាំងប៉ុន្មាន ។**

**យ៉ាដាស**

យ៉ាដាសមានន័យថា:

- *ការថ្វាយការលន់តួដោយអរព្រះគុណ*

ព្រះគម្ពីរទំនុកដំកើង ១០៩:៣០ ចែងថា: **មាត់ទូលបង្គំនឹងអរព្រះគុណដល់ព្រះយេហូវ៉ាយ៉ាងក្រៃលែង អើ ទូលបង្គំនឹងសរសើរដល់ទ្រង់ នៅកណ្តាលជនទាំងឡាយ ។**

- *ព្រមទាំងថ្វាយនូវការអរព្រះគុណដោយលើកដៃទាំងគូសន្ទឹងទៅឯព្រះ ។*

ព្រះគម្ពីរទំនុកដំកើង ៣៣:២ ចែងថា: **ចូរអរព្រះគុណដល់ព្រះយេហូវ៉ា ដោយចាប់ស៊ុង ហើយច្រៀងសរសើរថ្វាយទ្រង់ ដោយដេញពិណខ្សែ១០ ។**

- *ការចុះចូល*

ព្រះគម្ពីរ២របាក្សត្រ ៧:៣ ចែងថា: **ឯពួកកូនចៅអ៊ីស្រាអែលទាំងអស់គ្នាគេក៏មើលឃើញ ក្នុងកាលដែលភ្លើងចុះមក និងសិរីល្អនៃទ្រង់បាននៅលើព្រះវិហារដែរ ហើយគេឱនខ្លួនក្រាបចុះផ្កាប់មុខដល់ដី ថ្វាយបង្គំនៅទីក្រាលថ្ម ព្រមទាំងអរព្រះគុណដល់ព្រះយេហូវ៉ាថា ទ្រង់ប្រកបដោយករុណាគុណ ឯសេចក្តីសប្បុរសរបស់ទ្រង់ ក៏នៅអស់កល្បជានិច្ច ។**

**ថាវដាស**

ពាក្យថាវដាស "Towdah" គឺមកពីឫសគល់ដូចគ្នានឹងពាក្យយ៉ាដាស "Yadah" ហើយដែលមានន័យថា:

- *ការលាតដៃ ដោយការគោរពបូជា និងការអរព្រះគុណ*

ព្រះគម្ពីរទំនុកដំកើង ៤២:៤ ចែងថា: **ឯដំណើរដែលទូលបង្គំបានទៅជាមួយនឹងហ្វូងមនុស្ស ព្រមទាំងនាំមុខគេទៅដល់ដំណាក់នៃព្រះ ដោយសំឡេងអរសប្បាយ និងសេចក្តីសរសើរ គឺជាពួកកកកុញ ដែលកំពុងតែកាន់ថ្ងៃបរិសុទ្ធ កាលណាទូលបង្គំនឹកចាំពីសេចក្តីនេះ នោះទូលបង្គំក៏ប្លុងព្រលឹងចេញ ។**

➢ *ការថ្វាយយញ្ញបូជាដោយការទទួលស្គាល់ និងការធានារ៉ាប់រង*

ព្រះគម្ពីរទំនុកដំកើង ៥០:២៣ ចែងថា: **អ្នកណាដែលថ្វាយជង្វាយជាសេចក្តីអរព្រះគុណ នោះក៏លើកដំកើងអញដែរ ហើយអញនឹងសំដែងសេចក្តីសង្គ្រោះរបស់ព្រះ ដល់អ្នកណាដែលរៀបផ្លូវរបស់ខ្លួនឱ្យត្រង់ ។**

**បារ៉ាក**

ពាក្យបារ៉ាក "Barak" មានន័យថា:

➢ *ការលុតជង្គង់ចុះដោយមានការគោរពបូជា*

ព្រះគម្ពីរទំនុកដំកើង ៩៦:៦ខ ចែងថា: ...**ឥទ្ធិឫទ្ធិ និងភាពលំអនៅក្នុងទីបរិសុទ្ធរបស់ទ្រង់ ។**

ដើម្បីលុតជង្គង់នៅចំពោះមុខអ្នកណាម្នាក់ គឺត្រូវតែបន្ទាបខ្លួន និងបង្ហាញនូវចៅហ្វាយនាយរបស់ពួកគេ ដ៏មានតម្លៃនិងមានជំហរយ៉ាងជាក់លាក់បំផុត ។

**ស្ហាកាស**

ពាក្យជាភាសាហេព្រើរជាច្រើន ដែលត្រូវបានបកប្រែថា "ថ្វាយបង្គំ" គឺមានតែភាសាហេព្រើរតែមួយគត់ ដែលត្រូវបានគេប្រើនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដើម្បីបញ្ជាក់ពីការថ្វាយបង្គំដល់ព្រះ ។

➢ *ការក្រាបចុះ*

ពាក្យស្ហាកាស "Shachah" មានន័យថា ក្រាបចុះនៅចំពោះព្រះដោយការថ្វាយបង្គំ និងការគោរពបូជា ។ វាក៏បានចង្អុលបង្ហាញនូវ

អាកប្បកិរិយាខាងផ្លូវចិត្ត សូម្បីតែរូបកាយរបស់មនុស្ស ដែលមិនត្រូវបានគេក្រាបថ្វាយបង្គំក៏ដោយ ។

ព្រះគម្ពីរទំនុកដំកើង ៩៥:៦ក ចែងថា: **កិត្តិយស និងតេជានុភាពនៅចំពោះទ្រង់...** ។

## ការរុករកឃើញនូវការសរសើរ និងការថ្វាយបង្គំដកស្រង់ចេញពីពាក្យជាភាសាហេព្រើរ

### ការចង្អុលបង្ហាញពីរូបនិយម

ការសរសើរតម្កើងគឺជាការចង្អុលបង្ហាញខាងផ្នែករូបកាយ ចំពោះអាកប្បកិរិយាខាងវិញ្ញាណ ការទទួលខុសត្រូវផ្នែកខាងក្នុងចិត្ត គឺជាការបើកសម្ដែងរបស់ព្រះ និងភាពដ៏អស្ចារ្យបំផុតរបស់ទ្រង់ ។

ជានិច្ចកាល គឺមានសកម្មភាពខាងរូបកាយ ក្នុងការសរសើរតម្កើងនោះគឺមានការខ្លះដែលយើងត្រូវធ្វើ ។ វារួមបញ្ចូលនូវការបង្ហាញ ការធ្វើពិធីបុណ្យ ការថ្វាយសីរីល្អ ការសរសើរដោយហួសហេតុ ការលេងភ្លេងដោយប្រើឧបករណ៍ ការលើកដៃចុះចូល និងការលុតជង្គង់ចុះជាដើម ។

ការសរសើរតម្កើងដោយពិតត្រង់ គឺវាត្រូវតែមានការជាក់ស្ដែង ។

### ការចង្អុលបង្ហាញនូវការបញ្ចេញសម្លេង

ការចូលរួមនូវការសរសើរតម្កើងជាច្រើន គឺចង្អុលបង្ហាញនូវការបញ្ចេញសម្លេង ។ ពាក្យជាភាសាហេព្រើរគឺបានពណ៌នាយ៉ាងដូច្នេះ: ចម្រៀងនៃការសរសើរតម្កើងបានយ៉ាច្បាស់លាស់ ការសម្លេងបានយ៉ាងច្បាស់លាស់ ការស្រែកច្រៀងដោយមានសម្លេងខ្លាំងៗ ការថ្វាយសម្លេងត្រែ ដោយសម្លេងខ្លាំងៗ និងការប្រកាសសារភាព ដោយអរព្រះគុណដល់ព្រះ ។

### ការរំដោះអារម្មណ៍ឱ្យមានសេរីភាព

ការសរសើរតម្កើងអាចត្រូវបានទទួលការរំដោះអារម្មណ៍ ឱ្យមានសេរីភាព ។

ការសរសើរតម្កើងដល់ព្រះ គឺមិនមែនជាការធ្វើលំហាត់ផ្នែកខាងអារម្មណ៍នោះទេ គឺជាការធ្វើសកម្មភាពខាងវិញ្ញាណវិញ ។

ការសរសើរតម្កើងដ៏ពិតប្រាកដ នោះនឹងនាំមកនូវការរំដោះខាងអារម្មណ៍ ។

អារម្មណ៍គឺមិនមែនជាការចាំបាច់ ដល់រូបកាយ ឬខាងផ្នែកសាច់ឈាមនោះទេ ។

ព្រះទ្រង់បានប្រទានដល់យើងនូវអារម្មណ៍ ហើយអារម្មណ៍ទាំងនោះ គឺត្រូវតែបានគេប្រើដើម្បីថ្វាយសិរីល្អដល់ទ្រង់ ។ អារម្មណ៍គឺរួមបញ្ចូលទាំងការធ្វើពិធី ការនិយាយសរសើរដ៏លើសលុប និងការថ្វាយនូវការបញ្ជាក់បង្ហាញដោយស្រែកជាសម្រែកខ្លាំងៗថ្វាយព្រះជាដើម ។

**ការធានារ៉ាប់រង**

ការសរសើរតម្កើងគួរតែត្រូវបានគេធ្វើ ដោយអាកប្បកិរិយា ជាការធានារ៉ាប់រង ។ ការធានារ៉ាប់រងមានន័យថា ស្មោះចំពោះ និងសរសើរដល់អ្នកណាម្នាក់ ដោយមានការសមរម្យ ។

សកម្មភាពនៃការសរសើរតម្កើង មិនគួរតែធ្លាប់ត្រូវបានគេអនុញ្ញាត ដើម្បីឱ្យមានភាពខិនថយទាំងខាងក្នុង និងខាងក្រៅខ័ណ្ឌសីមានៃការចាក់ប្រេងតាំង ព្រមទាំងការហូរមកនៃព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងការប្រជុំដ៏ពិសេសនោះ ។

ការសរសើរតម្កើងព្រះ គឺគ្មានកំណត់ព្រំដែននូវអត្ថន័យនៃសេចក្តីអំណរអរសប្បាយរបស់យើងនោះទេ គឺត្រូវបានផ្តល់ឱ្យជាការបញ្ជាក់បង្ហាញនូវការធានារ៉ាប់រង និងអរព្រះគុណដល់ព្រះតែប៉ុណ្ណោះ ។

**សេចក្តីបញ្ចប់**

យើងអាចគូសបញ្ជាក់នូវសេចក្តីបញ្ចប់ខ្លះៗ ដែលដកស្រង់ចេញពីពាក្យជាភាសាហេព្រើរ ។

ព្រះទ្រង់ជាវិញ្ញាណ ហើយយើងរាល់គ្នាត្រូវតែថ្វាយបង្គំទ្រង់ដោយវិញ្ញាណ និងសេចក្ដីពិតដែរ ។

ការសរសើរតម្កើងគឺអាចត្រូវបានគេសរសើរដោយអារម្មណ៏ ប៉ុន្តែយើងត្រូវតែចាំយាម ប្រឆាំងទាស់នឹងការសរសើរតម្កើងដោយធម្មតាៗ ដែលមានសេចក្ដីអំណរតែត្រឹមរូបកាយ គឺមិនបានទទួលនូវការប្រទានមកខាងឯវិញ្ញាណនោះចេញ ។

ព្រះគម្ពីរយ៉ូហាន ៤:២៣,២៤ ចែងថា: **តែនឹងមានពេលវេលាមក ក៏នៅឥឡូវនេះហើយ នោះពួកអ្នកដែលថ្វាយបង្គំដោយពិតត្រង់ គេនឹងថ្វាយបង្គំព្រះវរបិតាដោយវិញ្ញាណ និងសេចក្ដីពិត ពីព្រោះព្រះវរបិតាទ្រង់រកពួកអ្នកយ៉ាងនោះ ឱ្យបានថ្វាយបង្គំទ្រង់ ឯព្រះទ្រង់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់ នោះត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណ និងសេចក្ដីពិតដែរ ។**

## ពាក្យដែលបានបកប្រែមកថាការសរសើរតម្កើង និងការថ្វាយបង្គំនៅក្នុងព្រះគម្ពីរសញ្ញាថ្មី

មានពាក្យជាភាសាក្រិកជាច្រើន ដែលត្រូវបានគេប្រើចំពោះការពណ៌នានូវការសរសើរតម្កើង នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ការសិក្សាចំពោះពាក្យទាំងនេះ នឹងដោះយើងរាល់គ្នាឱ្យមានសកម្មភាពបន្ថែម និងមានការបញ្ជាក់បង្ហាញបន្ថែម នៅក្នុងការសរសើរតម្កើងដល់ព្រះរបស់យើង ។

**អាយណេអូ** (Aineo)

➢ *ដង្វាយ ឬពិធីនៃការសរសើរតម្កើង*

ព្រះគម្ពីររ៉ូម ១៥:១១ ចែងថា: **ក៏មាន១ទៀតថា «ឱសាសន៍ទាំងឡាយអើយ ចូរសរសើរដល់ព្រះអម្ចាស់ ឱជនរាល់គ្នាអើយ ចូរដំកើងទ្រង់ចុះ» ។**

➢ *ការបញ្ចេញសម្លេងក្នុងការអរព្រះគុណ*

ព្រះគម្ពីរលូកា ១៩:៣៧ ចែងថា: **លុះទ្រង់យាងជិតដល់ហើយ គឺត្រង់ផ្លូវចុះពីភ្នំដើមអូលីវមក នោះពួកសិស្សទ្រង់ទាំងហ្វូងចាប់តាំងមានសេចក្ដីរីករាយ ក៏ពោលសរសើរដល់ព្រះ ដោយសំឡេងយ៉ាងខ្លាំង ដោយព្រោះអស់ទាំងការឫទ្ធិបារមីដែលគេបានឃើញនោះ ។**

**អេពអាយណេអូ (Epaineo)**

➢ *ការសរសើរដោយទះដៃសាទរ*

ព្រះគម្ពីរ១ពេត្រុស ១:៧ ចែងថា: **ដើម្បីឲ្យការសាកលសេចក្ដីជំនឿនៃអ្នករាល់គ្នា ដ៏វិសេសជាងមាសដែលតែងតែខូច ទោះបើបានសាកនឹងភ្លើងក៏ដោយ នោះបានឃើញសំរាប់ជាសេចក្ដីសរសើរ កេរ្ដិ៍ឈ្មោះ និងសិរីល្អ ក្នុងកាលដែលព្រះយេស៊ូវគ្រីស្ទទ្រង់លេចមក ។**

➢ *ការលើកតម្កើងចំពោះ*

ព្រះគម្ពីរអេភេសូរ ១:៦ ចែងថា: **ដើម្បីនឹងសរសើរដល់ព្រះគុណដ៏ឧត្ដមរបស់ទ្រង់ ដែលបានផ្ដល់មកយើងរាល់គ្នាទទេ ក្នុងព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់ ។**

**អឺឡូជីអូ (Eulogeo)**

➢ *ការបើកមាត់ពិពណ៌នាសរសើរ*

ព្រះគម្ពីរលូកា ១:៦៤ ចែងថា: **ខណៈនោះ មាត់លោកបើកឡើងជា១រំពេច អណ្ដាតក៏រលាស់បាន ហើយលោកពណ៌នាសរសើរដល់ព្រះ ។**

**ដុកសា (Doxa)**

➢ *ការថ្វាយសិរីល្អ*

ដុកសា គឺជាការចង្អុលបង្ហាញបន្ថែមទៀត ចំពោះរបស់ដែលព្រះទ្រង់បានបង្កើតមក ដោយការថ្វាយបង្គំជាជាងការចង្អុលបង្ហាញ ខាងផ្នែករូបនិយមទៅទៀត ។

ព្រះគម្ពីរយ៉ូហាន ៩:២៤ក ចែងថា: **គេក៏ហៅមនុស្សដែលពីដើមខ្វាក់នោះ មកម្ដងទៀតប្រាប់ថា ចូរសរសើរដំកើងដល់ព្រះវិញ... ។**

**ប្រុសគុណោអ្វ (Proskuneo)**

➢ *ការលុតជង្គង់ចុះ*

ប្រុសគុណោអ្វ មានន័យថា "ក្រាបថ្វាយបង្គំដោយការគោរពបូជា"

ព្រះគម្ពីរម៉ាថាយ ២:២ ចែងថា: **តើព្រះអង្គដែលប្រសូតមក ធ្វើជាស្តេចសាសន៍យូដាទ្រង់គង់នៅឯណា ពីព្រោះយើងបានឃើញផ្កាយរបស់ទ្រង់ពីទិសខាងកើតមក ហើយយើងមកថ្វាយបង្គំទ្រង់ ។**

## និយមន័យនៃពាក្យសរសើរនិងថ្វាយបង្គំ

**ទំនុកតម្កើង**

ពាក្យទំនុកតម្កើង គឺមកពីពាក្យជាភាសាក្រិកថា ផ្សមម៉ូស (psalmos) ។ ជាទូទៅមានន័យថា "ទំនុកដែលបានចងក្រងឡើងសម្រាប់ច្រៀង" ។

**ផ្សមម៉ូស (Psalmos)**

ផ្សមម៉ូស គឺជាទំនុកតម្កើងដែលមានឧបករណ៍ភ្លេងលាយជាមួយ អត្ថន័យជាទូទៅគឺ "ជាការឆក់ ឬកន្ត្រាក់ទាញ ដោយមានការប្រើម្រាមដៃ ដើម្បីប្រគំបទភ្លេងដោយមានខ្សែ" ជាដើម ។

**ចម្រៀងទំនុកតម្កើង**

ចម្រៀងទំនុកតម្កើង គឺដកស្រង់ចេញពីពាក្យជាភាសាក្រិក ថា ហាំណាស (humnas) គឺជាអត្ថន័យនៃចម្រៀងសរសើរតម្កើងដល់ព្រះ ឬដែលដកស្រង់ចេញពីពាក្យជាភាសាក្រិកថា ហាំណេអូ (humneo) មានន័យថា "ច្រៀងចម្រៀងសរសើរតម្កើងថ្វាយដល់ព្រះ" ។

**ចម្រៀងខាងវិញ្ញាណ**

ពាក្យជាភាសាក្រិកថា ញ្ញឹម៉ាទីកុស អូដេ (pneumatikos ode) (ចម្រៀងខាងវិញ្ញាណ) មានន័យថា "ចម្រៀងដែលច្រៀងចេញទៅ

ដោយឯងៗ ដោយមានពាក្យនិងការផ្តល់ឱ្យនូវចម្រៀងនៅក្នុងពេលវេលា ដោយព្រះវិញ្ញាណបរិសុទ្ធ” ។

## សំណួររំឭកសារឡើងវិញ

១. ចូរធ្វើបញ្ជីរាយនាមនូវពាក្យពីរម៉ាត់ ដែលដកស្រង់ចេញពីព្រះគម្ពីរសញ្ញាចាស់ ដែលត្រូវបានគេបកប្រែថា ការសរសើរតម្កើង និងឱ្យនិយមន័យដែលស្រង់ចេញមកពីភាសាហេព្រើរ ។

២. ចូរធ្វើបញ្ជីនូវពាក្យពីរម៉ាត់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលនិយាយពីការសរសើរតម្កើង ។ ចូរផ្តល់ឱ្យនូវអត្ថន័យ ដែលស្រង់ចេញពីភាសាក្រិក ។

៣. តើពាក្យជាភាសាហេព្រើរមានន័យដូចម្តេច ដែលត្រូវបានគេប្រើសម្រាប់ពាក្យថ្វាយបង្គំព្រះ?

៤. ចូរឱ្យអត្ថន័យនូវពាក្យជាភាសាក្រិកពីរយ៉ាង ដែលត្រូវបានគេបកប្រែថាជាពាក្យថ្វាយបង្គំ ។

# មេរៀនទី ៦
## *គោលបំណងដ៏អស់កល្បរបស់ព្រះសម្រាប់ការសរសើរតម្កើង*

យើងរាល់គ្នាត្រូវបានបង្កើតឡើងមក គឺសម្រាប់ការសរសើរតម្កើង និងការថ្វាយបង្គំ ។ បំណងចិត្តដ៏ធំបំផុតនៃជីវិតរបស់យើង គឺត្រូវតែសរសើរតម្កើង និងថ្វាយបង្គំដល់ព្រះ ។ ហេតុផលដែលយើងរស់នៅ គឺត្រូវតែថ្វាយបង្គំដល់ទ្រង់នោះឯង ។ លោកសាវ័កយ៉ូហានប្រាប់យើងថា ព្រះទ្រង់កំពុងតែស្វែងរកកូនប្រុស-ស្រីឱ្យថ្វាយបង្គំដល់ទ្រង់!

ព្រះគម្ពីរយ៉ូហាន ៤:២៣ ចែងថាៈ **តែនឹងមានពេលវេលាមក ក៏នៅឥឡូវនេះហើយ នោះពួកអ្នកដែលថ្វាយបង្គំដោយពិតត្រង់ គេនឹងថ្វាយបង្គំព្រះវរបិតាដោយវិញ្ញាណ និងសេចក្តីពិត ពីព្រោះព្រះវរបិតាទ្រង់រកពួកអ្នកយ៉ាងនោះ ឱ្យបានថ្វាយបង្គំទ្រង់ ។**

### ព្រះទ្រង់អរសប្បាយជាមួយនឹងការច្រៀង

ព្រះទ្រង់អរសប្បាយដោយបានឮយើងច្រៀងចម្រៀង!

ព្រះគម្ពីរសេផានា ៣:១៧ ចែងថាៈ **ព្រះយេហូវ៉ា ដ៏ជាព្រះនៃឯង ទ្រង់គង់នៅកណ្តាលឯង ទ្រង់ជាព្រះដ៏មានឥទ្ធិឫទ្ធិ ដើម្បីជួយសង្គ្រោះ ទ្រង់នឹងមានសេចក្តីរីករាយអរសប្បាយចំពោះឯង ទ្រង់នឹងសំរាកក្នុងសេចក្តីស្រឡាញ់របស់ទ្រង់ ក៏នឹងអរសប្បាយនឹងឯង ដោយសំឡេងច្រៀង ។**

ពាក្យជាភាសាហេព្រើរបានប្រើពណ៌នា នូវសកម្មភាពរបស់ព្រះ ដោយការអរសប្បាយ គឺមានន័យថា "លោតឡើងលោតចុះ បង្វិលជុំវិញ ដែលបញ្ចេញនូវសេចក្តីរំភើបដោយអរសប្បាយក្រៃលែង" ។

យើងអាចទូលសួរថា "ហេតុអ្វីបានជាព្រះទ្រង់បានធ្វើឱ្យមានការរំភើបចិត្តដល់យើង ដែលទ្រង់កំពុងតែអរសប្បាយ លោតឡើងលោតចុះ ដែលបញ្ចេញនូវសេចក្តីរំភើបដោយអរសប្បាយក្រៃលែងយ៉ាងដូច្នេះ?"

ដើម្បីឱ្យបានយល់នូវចម្លើយ ចំពោះសំណួរនេះ យើងត្រូវត្រឡប់បែរទៅឯអតីតកាលដ៏អស់កល្ប ហើយឱ្យបានយល់ពីមុខងារនៃការសរសើរតម្កើង និងថ្វាយបង្គំដោយពួកទេវតា ។

## ពួកទេវតាដែលបានបង្កើតឡើង

ពួកទេវតាត្រូវបានបង្កើតឡើងដោយព្រះ សម្រាប់ឱ្យមានមុខងារដ៏ពិតប្រាកដច្បាស់លាស់ ។ ពួកទេវតាទាំងសល់សែន គឺត្រូវបានទទួលការចែកឱ្យនៅក្រោមការដឹកនាំរបស់ពួកមហាទេវតា ។

- *មហាទេវតាមីកែល គឺជាអ្នកដឹកនាំពួកទេវតាមួយក្រុមដ៏ធំ គឺជាពួកទេវតាចម្បាំង ។*
- *មហាទេវតាកាព្រីយ៉ែល គឺជាអ្នកដឹកនាំពួកទេវតា ផ្នែកនាំសារ ។*
- *មហាទេវតាលូស៊ីហ្វឺ គឺជាអ្នកដឹកនាំពួកទេវតា ដែលត្រូវបានបង្កើតមកជាពិសេសសម្រាប់សរសើរតម្កើង និងថ្វាយបង្គំ គឺជាអ្នកចាំយាមដល់បល្ល័ង្កនៃព្រះ ។*

### មហាទេវតាលូស៊ីហ្វឺ

- *គឺជាទេវតាចេរូប៊ីនដែលទទួលការចាក់ប្រេងតាំង*

ព្រះទ្រង់បានបង្កើតទេវតាលូស៊ីហ្វឺ ឱ្យធ្វើជាទេវតាចេរូប៊ីនចាំយាមការពារដល់បល្ល័ង្កនៃព្រះ ។

ព្រះគម្ពីរអេសេគាល ២៨:១៤ ចែងថា: **ឯងជាចេរូប៊ីនដែលបានចាក់ប្រេងតាំងឡើងជាអ្នកគ្របបាំង គឺអញបានតាំងឯងឡើង ឱ្យឯងបាននៅលើភ្នំបរិសុទ្ធរបស់ព្រះ ឯងក៏បានដើរទៅមកនៅកណ្តាលថ្មភ្លឺចាំង ។**

ទេវតាចេរូប៊ីនគឺជាអ្នកគ្របបាំងនៅទីសន្ដោសប្រោស នៅពីលើហឹបនៃសេចក្ដីសញ្ញា ដោយមានស្លាបទាំងសងខាង ហើយលូស៊ីហ្វឺក៏បានជាអ្នកយាមបល្ល័ង្កនៃព្រះនៅបន្ទាប់នោះ "គឺជាទេវតាចេរូប៊ីនដែលបានទទួលការចាក់ប្រេងតាំងឱ្យធ្វើជាអ្នកគ្របបាំង" ។

## ➤ *អត្ថន័យនៃឈ្មោះ*

នៅក្នុងភាសាហេព្រើរ ពាក្យថា លូស៊ីហ្វឺគឺ "ហិយឡែល" (heylel) គឺបានមកពីពាក្យដើមថា "ហាឡាល" (halal) គឺជាពាក្យដែលយើងទទួលបានមកពីពាក្យថា ហាលេលូយ៉ា (hallelujah) ។ ពាក្យនោះមានន័យថា សរសើរតម្កើង គឺជាអ្នកដែលមានពេញដោយពន្លឺចាំងចែងប្រសើររុងរឿង ជាអ្នកធ្វើពិធី ថ្វាយសិរីល្អ និងជាអ្នកល្បីល្បាញ ។ ឈ្មោះលូស៊ីហ្វឺ គឺជាអ្នកចង្អុលបង្ហាញដ៏ល្អ ដែលមុខងារដើមរបស់គាត់ គឺជាអ្នកសរសើរតម្កើង និងថ្វាយបង្គំ ។

ពាក្យជាទូទៅរបស់លូស៊ីហ្វឺ គឺហាលេលូយ៉ា (hallelujah) គឺជាអ្នកសរសើរតម្កើង ដែលបានធ្វើពិធី និងបានចាំងចែសពន្លឺដោយមានរស្មីត្រចះត្រចង់ ភ្លឺចិញ្ចាចចិញ្ចែង ជាសិរីល្អនៃព្រះអម្ចាស់ ។ យើងទាំងអស់គ្នាក៏មានការឯកភាពជាមួយនឹងហោរាអេសាយ ដែលបានសរសេរទុកមកយ៉ាងដូច្នេះថា:

**ឯសេចក្តីរុងរឿងឧត្តមរបស់ឯង បានត្រូវនាំចុះមកដល់ស្ថានឃុំព្រលឹងមនុស្សស្លាប់ ព្រមទាំងសូរដេញពិណរបស់ឯងផង... ឱតារាប្រចាំថ្ងៃ ជាផ្កាយព្រឹកអើយ ន៏ ឯងបានធ្លាក់ចុះមកពីលើមេឃហើយ** (១៤:១១ក,១២ក) **។**

## ➤ *ត្រូវបានបង្កើតមកសម្រាប់ការប្រគំបទភ្លេង*

ព្រះគម្ពីរអេសេគាល ២៨:១៣ខ ចែងថា: ...**ឯក្រាប់ និងខ្លុយរបស់ឯង នោះបានត្រៀមទុកសំរាប់ឯងតាំងពីថ្ងៃដែលឯងកើតមក ។**

លូស៊ីហ្វឺមិនមែនគ្រាន់តែជាអ្នកចេះប្រើឧបករណ៍ភ្លេងប៉ុណ្ណោះទេ គឺគាត់ក៏ជាអ្នកជើងឯកតែម្នាក់គត់ ។ សម្លេងរបស់គាត់គឺដូចជាវង់ភ្លេងដែលមានឧបករណ៍ភ្លេងគ្រប់គ្រាន់ ដូចជាខ្លុយ ស្នែង និងរបស់ដែលមានសម្លេងផ្សេងៗទៀត ។

លូស៊ីហ្វឺក៏ជាអ្នកដែលមានការតាក់តែងសម្អិតសម្អាង ដោយមានការរំលេចដោយត្បូងជាច្រើន គឺនៅពេលគាត់បានធ្វើចលនា និងដកដង្ហើម នោះក៏គ្មានទីបញ្ចប់ឡើយ គឺតែងតែមានការផ្លាស់ប្តូរនូវទស្សនីយភាពនៃសិរីល្អដោយនូវពន្លឺ និងមានសម្លេងនៅឯនគរស្ថានសួគ៌ ។

ចូរចងចាំថា ប្រភេទនៃឧបករណ៍ទាំងបីនេះ គឺជាវង់ភ្លេង ដែលមានខ្យល់សម្លេង និងខ្សែគឺត្រូវបានបើកសម្តែងមក ។

ការគ្របបាំងបល្ល័ង្កនៃព្រះ ដោយទេវតាដែលបានទទួលនូវការចាក់ប្រេងតាំង ដែលបានលេចឡើង ដោយមានការគ្របបាំងដល់ការសរសើរតម្កើង និងការថ្វាយបង្គំ ។

លូស៊ីហ្វឺត្រូវតែបានទទួលការអនុញ្ញាត ឱ្យបានធ្វើជាទេវតាដ៏ធំសម្បើម គឺគាត់បានទៅជាវង់ភ្លេង និងជាអ្នកចម្រៀងក្នុងការសរសើរតម្កើង និងថ្វាយបង្គំជាបន្តនៅមុខបល្ល័ង្ក ។

ព្រះគម្ពីរយ៉ូប ៣៨:៧ ចែងថា: **ក្នុងកាលដែលផ្កាយព្រឹកបានច្រៀងជាមួយគ្នា ហើយអស់ទាំងកូនព្រះបានស្រែកអរសាទរ ។**

## លូស៊ីហ្វឺត្រូវបានទុកកន្លែងឱ្យនៅទំនេ

ការធ្លាក់ចុះរបស់លូស៊ីហ្វឺពីស្ថានសួគ៌ គឺបានទុកនូវទីចំហមួយ ។ នៅពេលដែលលូស៊ីហ្វឺបានធ្វើកាតទាស់ទទឹងប្រឆាំងនឹងព្រះ ហើយក៏ត្រូវបានបណ្តេញចេញពីស្ថានសួគ៌ "គឺពីភាពជាទេវតារបស់គាត់" មក នោះផ្នែកទីបីដែលជាតារាប្រចាំថ្ងៃ (ទេវតា) នៅនគរស្ថានសួគ៌ ដែលបានទាស់ទទឹង នោះត្រូវបានទុកកន្លែងគាត់នៅ ។

ព្រះគម្ពីរអេសាយ ១៤:១២ ចែងថា: **ឱតារាប្រចាំថ្ងៃ ជាផ្កាយព្រឹកអើយ ទ្រង់ឯងបានធ្លាក់ចុះមកពីលើមេឃហើយ ឯងដែលបានផ្តេកអស់ទាំងនគរឱ្យរាប ឯងបានត្រូវកាប់រំលំដល់ដីដែរហ្ន៎ ។**

ព្រះគម្ពីរអេសេគាល ២៨:១៥,១៦ ចែងថា: **ចាប់តាំងពីថ្ងៃដែលឯងកើតមកនោះ ឯងបានគ្រប់លក្ខណ៍ក្នុងគ្រប់ទាំងផ្លូវរបស់ឯង ដរាបដល់**

**វេលាដែលឃើញមានសេចក្តីទុច្ចរិតនៅក្នុងឯង ដ្បិតដោយសារការជួញប្រែដ៏បរិបូររបស់ឯង នោះគេបានបំពេញឯងដោយសេចក្តីច្រឡោត ហើយឯងបានធ្វើបាប ហេតុនោះអញបានបោះចោលឯងចេញពីភ្នំនៃព្រះ ទុកដូចជារបស់អាប់ ឱនទេវិញ ឱចេរូប៊ីនដែលគ្របបាំងអើយ អញបានបំផ្លាញឯងចេញពីកណ្តាលថ្មភ្លឺចាំងនោះទៅ ។**

ព្រះគម្ពីរវិវរណៈ ១២:៧-៩ ចែងថាៈ **នោះមានចំបាំងនៅលើមេឃ គឺមីកែល និងពួកទេវតារបស់លោកច្បាំងនឹងនាគ ហើយនាគ និងទេវតាវាក៏ច្បាំងនឹងលោកដែរ តែមិនបានឈ្នះទេ ក៏មិនឃើញមានកន្លែងណាឱ្យវា នៅលើមេឃទៀតផង នោះនាគធំត្រូវបោះទំលាក់ទៅ គឺជាពស់ពីបុរាណ ដែលឈ្មោះហៅថាអារក្ស ហើយសាតាំងផង ដែលបាននាំលោកិយទាំងមូលឱ្យវង្វេងចេញ វាត្រូវបោះទំលាក់ទៅផែនដីវិញ ព្រមទាំងពួកទេវតារបស់វាផង ។**

ព្រះគម្ពីរវិវរណៈ ១២:៤ក ចែងថាៈ **កន្ទុយវាក៏ទាញផ្កាយនៅលើមេឃ ១ភាគក្នុង៣ គ្រវាត់ចោលទៅផែនដី... ។**

ភាពទទេគឺត្រូវបានកើតឡើងក្នុងពេលរំពេច នៅឯនគរស្ថានសួគ៌ គឺដោយសារលូស៊ីហ្វឺ និងពួកទេវតារបស់វាត្រូវបានបណ្តេញចេញ ។

## ព្រះទ្រង់បានបំពេញនៅកន្លែងទទេ

ព្រះទ្រង់បានមានផែនការដើម្បីបំពេញ នៅកន្លែងចន្លោះដែលបានចាកចេញទៅ ដោលលូស៊ីហ្វឺ និងពួកទេវតារបស់វា! ព្រះទ្រង់បានបង្កើតមនុស្សមក ដើម្បីកាន់កាប់នូវអំណាចគ្រប់គ្រងលើផែនដី គឺឱ្យគ្រប់គ្រងលើលូស៊ីហ្វឺ (សាតាំង) ព្រមទាំងពួកទេវតារបស់វា (ពួកវិញ្ញាណអាក្រក់) ។ មនុស្សត្រូវតែសម្តែងបំភ្លឺនូវការបរាជ័យរបស់សាតាំង នៅលើផែនដីនេះ ។ ព្រះទ្រង់បានបង្កើតមនុស្សមក ឱ្យមានចំណែកបន្ទាប់ពីព្រះអង្គ និងសោយរាជ្យជាមួយនឹងទ្រង់ នៅលើបល្ល័ង្ករបស់ទ្រង់ ។

ភាពទទេឥឡូវនេះគឺត្រូវបានបំពេញ ដោយពួកជំនុំរបស់ទ្រង់ ។

ព្រះគម្ពីរអេភេសូរ ១:២៣ ចែងថា: **គឺជាសេចក្តីពោរពេញរបស់ព្រះអង្គ ដែលបំពេញគ្រប់ទាំងអស់ក្នុងទាំងអស់ ។**

ពួកជំនុំគឺត្រូវបានផ្គុំឡើងពីមនុស្សប្រុសស្រី ដែលជាពួកអ្នកជឿ គឺត្រូវតែចាប់យកកន្លែងរបស់ចេរូប៊ីដែលជាអ្នកយាម និងទេវតារបស់វា ។ ពួកជំនុំឥឡូវនេះគឺស្ថិតនៅក្នុងចំណែកនៃបល្ល័ង្ករបស់ផងព្រះ ។

មនុស្សគឺត្រូវបានបង្កើតមកសម្រាប់ជាគោលបំណង និងមុខងារដ៏សំខាន់ ដើម្បីសរសើរតម្កើង និងថ្វាយបង្គំព្រះ!

ព្រះគម្ពីរអេភេសូរ ៣:២១ ចែងថា: **នោះសូមឱ្យទ្រង់បានសិរីល្អនៅក្នុងពួកជំនុំ ដោយសារព្រះគ្រីស្ទយេស៊ូវ រហូតដល់គ្រប់ទាំងដំណមនុស្ស នៅអស់កល្បជានិច្ចរៀងរាបតទៅ ។ អាម៉ែន ។**

## សាតាំង និងដូរតន្ត្រី

### លូស៊ីហ្វឺគឺជាប្រធានលើដូរតន្ត្រី

មុនពេលនៃការធ្លាក់ចុះរបស់វា លូស៊ីហ្វឺគឺជាប្រធាលើក្រុមដូរតន្ត្រីនោះ នៅឯនគរស្ថានសួគ៌ ។

ព្រះគម្ពីរអេសេគាល ២៨:១៣ខ ចែងថា: ...**ឯក្រាប់ និងខ្លុយរបស់ឯង នោះបានត្រៀមទុកសំរាប់ឯងតាំងពីថ្ងៃដែលឯងកើតមក ។**

អំណោយទានខាងផ្នែកដូរតន្ត្រីរបស់វា គឺត្រូវតែបានគេប្រើនៅក្នុងការសរសើរតម្កើងដល់ព្រះ ប៉ុន្តែនៅពេលដែលវាបានធ្លាក់ចុះមក នោះអំណោយទាននេះក៏បានត្រឡប់មកជាខូចអស់ទៅ ។

### ឧបករណ៍ភ្លេងត្រូវបានបង្កើតឡើង

ឧបករណ៍ភ្លេងត្រូវបានបង្កើតឡើងដោយលោកកាអ៊ីន គឺទាំងឧបករណ៍ភ្លេង ទាំងឧបករណ៍ធ្វើសង្គ្រាម ។

ព្រះគម្ពីរលោកុប្បត្តិ ៤:២១,២២ក ចែងថា: **ប្អូនគាត់ឈ្មោះយូបាល ជាឪពុកនៃពួកអ្នកលេងស៊ុងនិងខ្លុយ ឯនាងស៊ីឡាក៏បង្កើតបានទូបាល-កាអ៊ីន ជាមេបង្រៀនពួកជាងលង្ហិន និងជាងដែក... ។**

**ការបំភាន់ឧបករណ៍ភ្លេង**

សាតាំងគឺជាអ្នកនិពន្ធដោយបំភាន់ និងជាអ្នកបំភាន់នូវដួរតន្ត្រី គឺជាទីសម្គាល់ដ៏អាក្រក់បំផុតរបស់វា ។

ព្រះគម្ពីរ១កូរិនថូស ១៤:៣៣ក ចែងថា: **ដ្បិតព្រះទ្រង់មិនមែនជាព្រះនៃសេចក្តីវឹកវរទេ គឺទ្រង់ជាព្រះនៃសេចក្តីសុខសាន្តវិញ... ។**

➢ *កូនគោមាស*

នៅពេលដែលពួកកូនចៅអ៊ីស្រាអែល បានធ្វើរូបកូនគោ និងថ្វាយបង្គំដល់រូបនោះ នោះលោកម៉ូសេបានឮដោយមានសម្លេងបំភាន់ ដ៏ខ្លាំងក្លាដែលគាត់មិនអាចមើលឃើញ តែម្តងនូវសញ្ញាសម្គាល់នោះឡើយ ។

ព្រះគម្ពីរនិក្ខមនំ ៣២:១៧,១៨ ចែងថា: **កាលយ៉ូស្វេបានឮសូរសំឡេងរបស់បណ្តាជនទាំងឡាយដែលគេនាំគ្នាស្រែកដូច្នោះ នោះក៏ជំរាបម៉ូសេថា មានឮសូរចំបាំងនៅទីដំឡើងត្រសាលហើយ តែម៉ូសេឆ្លើយថា តាមដែលអញឮ នោះមិនមែនជាសូរសំរែកនៃពួកដែលឈ្នះ ឬពួកចាញ់ទេ គឺជាសូរសំឡេងនៃមនុស្សដែលច្រៀងវិញទេតើ ។**

➢ *រូបធ្វើពីមាស*

ស្តេចនេប៊ូក្នេសារបានប្រើប្រភេទឧបករណ៍ដូរតន្ត្រី ដើម្បីនាំគ្នាធ្វើការថ្វាយបង្គំដល់រូបដែលធ្វើពីមាស ដែលទ្រង់បានសាងសង់ឡើងនោះ ។

ព្រះគម្ពីរដានីយ៉ែល ៣:៥,៧ ចែងថា: **វេលាណាដែលអ្នករាល់គ្នាឮសូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ និងប៉ី ហើយដន្ត្រីគ្រប់យ៉ាង នោះត្រូវក្រាបថ្វាយបង្គំដល់រូបមាស ដែលព្រះករុណាទ្រង់បានតាំងឡើងទៅ... ដូច្នេះ នៅវេលានោះ កាលជនទាំងឡាយបានឮសូរត្រែ ខ្លុយ ស៊ុង ចាប៉ី ពិណ និងដន្ត្រីគ្រប់យ៉ាងហើយ នោះជនទាំងឡាយ ព្រមទាំងសាសន៍ដទៃនឹងមនុស្សគ្រប់ភាសាផង ក៏ក្រាបថ្វាយបង្គំដល់រូបមាស ដែលស្តេចនេប៊ូក្នេសាបានតាំងទុកនោះ ។**

## សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសម្រេចនៅផែនដីដូចជានៅស្ថានសួគ៌ដែរ

ព្រះយេស៊ូវទ្រង់បានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ ឱ្យចេះអធិស្ឋានថា **សូមឱ្យបំណងព្រះហឫទ័យទ្រង់បានសម្រេច នៅផែនដីដូចជានៅស្ថានសួគ៌ដែរ** ។ តើបំណងព្រះហឫទ័យរបស់ព្រះនៅស្ថានសួគ៌ នោះយ៉ាងដូចម្តេច? តើបំណងព្រះហឫទ័យរបស់ព្រះបានសម្រេចយ៉ាងដូចម្តេចខ្លះនៅទីនោះ?

លោកសាវ័កយ៉ូហានក៏បានផ្តល់ឱ្យ នូវការជាក់ស្តែងដ៏ធំអស្ចារ្យចំពោះអ្វីដែលបានកើតឡើង នៅឯស្ថានសួគ៌សម័យសព្វថ្ងៃនេះ ហើយចំពោះអ្វីដែលបានកើតឡើងនៅពេលអនាគតខាងមុខ ។ ការជាក់ស្តែងដ៏ច្រើនលើសលប់នេះ គឺបានរួមបញ្ចូលទាំងការសរសើរតម្កើង និងការថ្វាយបង្គំផងដែរ ។

### ការសរសើរតម្កើងនៅតែបន្ត

ពួកទេវតាបានចាប់ផ្តើមបន្តផ្តល់ឱ្យ នូវការសរសើរតម្កើងដល់ព្រះ

ព្រះគម្ពីរវិវរណៈ ៤:៨-១១ ចែងថា: **តួមានជីវិតទាំង៤នោះមានស្លាប៦គ្រប់រូប ក៏មានភ្នែកពេញខ្លួននៅជុំវិញ ហើយទាំងខាងក្នុងដែរ ក៏ចេះតែពោលពាក្យឥតឈប់ឈរទាំងយប់ទាំងថ្ងៃ ថា បរិសុទ្ធ បរិសុទ្ធ បរិសុទ្ធ គឺព្រះអម្ចាស់ ជាព្រះដ៏មានព្រះចេស្តាបំផុត ដែលទ្រង់គង់នៅតាំងតែពីដើម ក៏នៅឥឡូវនេះ ហើយត្រូវយាងមកទៀត កាលណាតួមានជីវិតទាំង៤នោះបានថ្វាយសិរីល្អ ល្បីព្រះនាម និងពាក្យអរព្រះគុណ ដល់ព្រះអង្គដែលគង់លើបល្ល័ង្ក ជាព្រះដ៏មានព្រះជន្មរស់អស់កល្បជានិច្ច រៀងរាបដរាបទៅរួចហើយ នោះពួកចាស់ទុំទាំង២៤នាក់ ក៏ទំលាក់ខ្លួនក្រាបចុះនៅចំពោះព្រះអង្គដែលគង់លើបល្ល័ង្ក ទាំងថ្វាយបង្គំដល់ព្រះដ៏មានព្រះជន្មរស់អស់កល្បជានិច្ច រៀងរាបតទៅនោះ ហើយក៏ដាក់មកុដខ្លួនចុះថ្វាយនៅមុខបល្ល័ង្ក ដោយទូលថា ឱព្រះអម្ចាស់ ជាព្រះនៃយើងរាល់គ្នាអើយ ទ្រង់គួរនឹងទទួលសិរីល្អ កិត្តិនាម និងព្រះចេស្តា ដ្បិតទ្រង់បានបង្កើតរបស់**

**សព្វសារពើមក ហើយគឺដោយបំណងព្រះហឫទ័យទ្រង់ហើយ ដែលរបស់ទាំងនោះបានកើតមក ហើយមាននៅផង ។**

**ទាំងពាន់រាប់ជាពាន់**

មានពពួកទេវតារាប់រយលាន ព្រមទាំងស្នាព្រះហស្តទាំងឡាយបានថ្វាយបង្គំ និងសរសើរតម្កើងដល់ព្រះ ។

ព្រះគម្ពីរវិវរណៈ ៥:១១-១៣ ថែងថា: **នោះខ្ញុំឃើញ ហើយក៏ឮសំឡេងទេវតាជាច្រើននៅជុំវិញបល្ល័ង្ក ព្រមទាំងតួមានជីវិត និងពួកចាស់ទុំផង ឯចំនួននៃទេវតានោះ មានទាំងម៉ឺនទាំងសែន ហើយទាំងពាន់រាប់ជាពាន់ គ្រប់គ្នាក៏បន្លឺសំឡេងថា កូនចៀមដែលគេបានសំឡាប់ នោះគួរនឹងបានព្រះចេស្តា ទ្រព្យសម្បត្តិ ប្រាជ្ញា ឥទ្ធិឫទ្ធិ កិត្តិនាម សិរីល្អនិងព្រះពរ នោះខ្ញុំក៏ឮគ្រប់ទាំងអស់ដែលមានជីវិត នៅស្ថានសួគ៌ នៅផែនដី នៅក្រោមដី ហើយនៅក្នុងសមុទ្រ និងគ្រប់ទាំងអស់ដែលនៅស្ថានទាំងនោះ និយាយថា សូមថ្វាយព្រះពរ កិត្តិនាម សិរីល្អ និងព្រះចេស្តា ដល់ព្រះអង្គដែលគង់លើបល្ល័ង្ក ហើយដល់កូនចៀម នៅអស់កល្បជានិច្ចរៀងរាបតទៅ ។**

ព្រះយេស៊ូវបានអធិស្ឋានថា "សូមឱ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដី ដូចនៅស្ថានសួគ៌ដែរ" ។

**សរុបការថ្វាយបង្គំ**

មានការសរសើរតម្កើង និងការថ្វាយបង្គំ នៅតែបន្តក្នុងនគរស្ថានសួគ៌នៅសម័យសព្វថ្ងៃនេះ ។ ការថ្វាយបង្គំដោយពួកទេវតាទាំងសល់សែន និងការថ្វាយបង្គំដោយពហុគុណនៃមនុស្សពីគ្រប់ជាតិសាសន៍ ជនជាតិ និងគ្រប់ភាសា ។

ព្រះគម្ពីរវិវរណៈ ៧:៩,១០ ថែងថា: **ក្រោយនោះមក ខ្ញុំក្រឡេកទៅឃើញមនុស្ស១ហ្វូងយ៉ាងធំ ដែលគ្មានអ្នកណាអាចនឹងរាប់បានឡើយ គេមកពីគ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ ហើយ**

**គ្រប់ទាំងភាសា ក៏ឈរនៅមុខបល្ល័ង្ក និងកូនចៀម ទាំងពាក់អាវសវែង ហើយកាន់ធាងចាកនៅដៃ គេបន្លឺសំឡេងថា សេចក្តីសង្គ្រោះស្រេចនូវព្រះនៃយើងរាល់គ្នា ដែលគង់លើបល្ល័ង្ក ហើយស្រេចនឹងកូនចៀមផង ។**

ព្រះយេស៊ូវក៏បានបង្រៀនពួកសិស្សទ្រង់ ឱ្យអធិស្ឋានដូច្នេះថា "សូមឱ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដី ដូចនៅស្ថានសួគ៌ដែរ" ។

**ដោយមានបទចម្រៀងថ្មីៗ**

ព្រះគម្ពីរវិវរណៈ ១៤:១-៣ ចែងថា: **ខ្ញុំក្រឡេកទៅឃើញកូនចៀម ឈរនៅលើភ្នំស៊ីយ៉ូន ហើយមានមនុស្ស១សែន៤ម៉ឺន៤ពាន់នាក់ ដែលមានព្រះនាមទ្រង់ និងព្រះនាមព្រះវរបិតាទ្រង់កត់លើថ្ងាស គេបានឈរជាមួយដែរ រួចខ្ញុំឮសំឡេងមកពីលើមេឃ ដូចជាសូរទឹកច្រើន ហើយដូចផ្គរលាន់យ៉ាងខ្លាំង រីឯសំឡេងដែលខ្ញុំឮនោះ ក៏ដូចជាសូរសព្ទរបស់ពួកដន្ត្រីដែលកំពុងតែចាប់ស៊ុង គេច្រៀងបទ១ថ្មី នៅមុខបល្ល័ង្ក ហើយមុខតួមានជីវិតទាំង៤ និងពួកចាស់ទុំដែរ គ្មានអ្នកណាអាចនឹងរៀនបទនោះបានទេ មានតែមនុស្ស ១សែន៤ម៉ឺន៤ពាន់នាក់ ដែលទ្រង់លោះពីផែនដីចេញប៉ុណ្ណោះ ។**

យើងទាំងអស់គ្នាត្រូវតែអធិស្ឋានយ៉ាងដូច្នេះដែរថា "សូមឱ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដី ដូចនៅស្ថានសួគ៌ដែរ" ។

**ការថ្វាយបង្គំនៅពេលអនាគត**

លោកសាវ័កយ៉ូហានបានឃើញ ពួកសង្ឃហើយបានរួមបញ្ចូលជាមួយនឹងពួកយើងដែរ ក្នុងការថ្វាយបង្គំដល់ព្រះ បន្ទាប់ពីបានទទួលសេចក្តីបង្រៀនគ្រប់គ្រាន់របស់សាតាំងរួចមកហើយនោះ ។

ព្រះគម្ពីរវិវរណៈ ១៥:២-៤ ចែងថា: **រួចខ្ញុំមើលទៅឃើញដូចជាសមុទ្រកែវ លាយនឹងភ្លើង ហើយពួកអ្នកដែលបានឈ្នះសត្វនោះ និងរូបវា ហើយលេខឈ្មោះវាផង គេឈរលើសមុទ្រនោះ ទាំងកាន់ស៊ុងរបស់ព្រះគ្រប់គ្នា គេច្រៀងទំនុករបស់លោកម៉ូសេ ជាបាវបំរើនៃព្រះ និងទំនុករបស់**

**កូនចៀមថា ឱព្រះអម្ចាស់ ជាព្រះដ៏មានព្រះចេស្តាបំផុតអើយ ការទ្រង់សុទ្ធតែធំ ហើយអស្ចារ្យ ឱស្តេចនៃអស់ទាំងសាសន៍អើយ ផ្លូវទ្រង់សុទ្ធតែសុចរិត ហើយពិតត្រង់ ឱព្រះអម្ចាស់អើយ តើមានអ្នកឯណាដែលមិនត្រូវកោតខ្លាចដល់ទ្រង់ ហើយសរសើរដំកើងដល់ព្រះនាមទ្រង់ ដ្បិតមានតែទ្រង់១ដែលបរិសុទ្ធ គ្រប់ទាំងសាសន៍នឹងមកក្រាបថ្វាយបង្គំនៅចំពោះទ្រង់ ដ្បិតការសុចរិតរបស់ទ្រង់ បានសំដែងមកឱ្យឃើញហើយ ។**

ព្រះគម្ពីរវិវរណៈ ១៩:១,៣,៧ ចែងថា: **ក្រោយនោះមក ខ្ញុំឮសំឡេងយ៉ាងខ្លាំងរបស់មនុស្ស១ហ្វូងដ៏ធំ នៅលើស្ថានសួគ៌ថា ហាលេលូ-យ៉ា សេចក្តីសង្គ្រោះ សិរីល្អ និងព្រះចេស្តា នោះជារបស់ផងព្រះនៃយើងរាល់គ្នាហើយ... ពួកនោះក៏ពោលពាក្យម្តងទៀតថា ហាលេលូយ៉ា ហើយផ្សែងវាក៏ហុយឡើងនៅអស់កល្បជានិច្ចរៀងរាបតទៅ... ចូរឱ្យយើងអរសប្បាយ ហើយរីករាយឡើង ទាំងថ្វាយសិរីល្អដល់ទ្រង់ចុះ ដ្បិតបានដល់ពេលរៀបវិវាហមង្គលនៃកូនចៀមហើយ ភរិយាទ្រង់បានរៀបខ្លួនជាស្រេច ។**

ឥឡូវនេះ ការទាំងអស់គឺស្រេចនៅលើយើង ដែលជាកូនក្រមុំរបស់ទ្រង់ហើយ ក្នុងការរៀបចំខ្លួនដើម្បីឱ្យបានក្លាយជាអ្នកច្រៀងសរសើរ និងអ្នកថ្វាយបង្គំព្រះ ។ លោកសាវ័កយ៉ូហានបានបន្តទៀតថា "ចូរឱ្យយើងអរសប្បាយ ហើយរីករាយឡើង ទាំងថ្វាយសិរីល្អដល់ទ្រង់ចុះ ដ្បិតបានដល់ពេលរៀបវិវាហមង្គលនៃកូនចៀមហើយ ភរិយាទ្រង់បានរៀបខ្លួនជាស្រេច" ។

## សំណួររំឭកសារឡើងវិញ

១. តើអ្នកណាដែលត្រូវបានបង្កើតឡើង ដើម្បីឱ្យបានដឹកនាំការថ្វាយបង្គំនៅឯនគរស្ថានសួគ៌? ចូរពន្យល់តាម ចម្លើយរបស់លោកអ្នក ។

២. តើអ្នកណាដែលត្រូវបានបំពេញ នៅកន្លែងចន្លោះទទេ ជំនួសឱ្យអ្នកដឹកនាំថ្វាយបង្គំ? ចូរធ្វើការពន្យល់ ។

៣. តើគ្រប់ទាំងឧបករណ៍ភ្លេងទាំងអស់សុទ្ធតែបានបើកសម្តែងមកដោយព្រះឬ? តើលោកអ្នកអាចប្រាប់ពីភាព ផ្សេងគ្នានោះបានដោយរបៀបណា?

# មេរៀនទី ៧
## *ការប្រគំបទភ្លេងគឺជាការបើកសម្តែងនូវការថ្វាយបង្គំ*

### ឧបករណ៍ភ្លេង ឬដូរតន្ត្រី

ឧបករណ៍ភ្លេង គឺត្រូវបានគេប្រើជាញឹកញាប់ ដើម្បីបញ្ជាក់បង្ហាញពីការសរសើរតម្កើង និងការថ្វាយបង្គំ ។

### ដោយស្តេចដាវីឌ

ព្រះគម្ពីរទំនុកដំកើង ១៥០:៣-៥ ចែងថាៈ **ចូរសរសើរទ្រង់ដោយត្រែ ចូរសរសើរដល់ទ្រង់ដោយដេញពិណ និងចាប៉ីស៊ុង ចូរសរសើរដល់ទ្រង់ដោយវាយក្រាប់ ហើយលោតកញ្ឆេង ចូរសរសើរទ្រង់ដោយប្រដាប់មានខ្សែ ហើយនិងខ្លុយ ចូរសរសើរដល់ទ្រង់ដោយវាយឈឹងឱ្យឮរងំ ចូរសរសើរទ្រង់ដោយវាយឈឹងឮសូររំពង ។**

ពួកក្រុមដូរតន្ត្រីដែលត្រូវតែថ្វាយនូវការសរសើរតម្កើងតាមរយៈឧបករណ៍ភ្លេង នោះពួកគេត្រូវតែស្វែងរកនូវការដ៏ប្រសើរ ដោយការធ្វើយ៉ាងដូច្នោះ ។

ព្រះគម្ពីរទំនុកដំកើង ៣៣:៣ ចែងថាៈ **ចូរច្រៀងទំនុកថ្មីថ្វាយទ្រង់ ហើយលេងភ្លេងឱ្យឮរងំ ដោយប៉ិនប្រសប់ ។**

ការនេះគឺអាចជាជំនាញខាងផ្នែកឯវិញ្ញាណ ហើយបន្ទាប់មកទើបអាចរកបាននូវការប៉ិនប្រសព្វខាងឯរូបកាយដែលប្រសើរជាងទៅទៀត ។ ចំពោះជំនាញគឺ មិនមែនសំដៅទៅលើតែការលេងគ្រឿងភ្លេងប៉ុណ្ណោះទេ គឺជាការយល់ដឹង និងជាការចង្អុលបង្ហាញ នូវការហូរមក និងការសោយនូវអារម្មណ៏របស់ព្រះវិញ្ញាណថែមទៀតផង ។

ជំនាញនៃការលេងភ្លេងដ៏ប៉ិនប្រសព្វរបស់ស្តេចដាវីឌ ចំពោះការដេញពិន ដែលអាចបណ្តេញវិញ្ញាណអាក្រក់ចេញពីស្តេចសូល និងបាននាំមកនូវការស្រស់ស្រាយ ព្រមទាំងបានទទួលនូវការប្រោសឱ្យជា ។

ព្រះគម្ពីរ១សាំយូអែល ១៦:២៣ ចែងថា: **ដូច្នេះ កាលណាវិញ្ញាណអាក្រក់ពីព្រះបានមកសណ្ឋិតលើសូល នោះដាវីឌក៏យកស៊ុងមកចាប់លេងថ្វាយ រួចសូលទ្រង់បានធូរ ហើយស្រួលឡើងវិញ វិញ្ញាណអាក្រក់ក៏ថយចេញពីទ្រង់ទៅ ។**

**ដោយពួកសង្ឃ**

ព្រះគម្ពីរ១របាក្សត្រ ២៣:៥ ចែងថា: **មាន៤ពាន់នាក់ជាអ្នកឆ្មាំទ្វារ៤ពាន់នាក់ទៀត ជាអ្នកច្រៀងសរសើរដល់ព្រះយេហូវ៉ា ដោយប្រដាប់ភ្លេង ដែលដាវីឌបានធ្វើសំរាប់ការច្រៀងសរសើរ ។**

**នៅក្នុងនគរស្ថានសួគ៌**

ព្រះគម្ពីរវិវរណៈ ១៤:២ ចែងថា: **រួចខ្ញុំឮសំឡេងមកពីលើមេឃ ដូចជាសូរទឹកច្រើន ហើយដូចផ្គរលាន់យ៉ាងខ្លាំង រីឯសំឡេងដែលខ្ញុំឮនោះក៏ដូចជាសូរសព្ទរបស់ពួកដន្ត្រីដែលកំពុងតែចាប់ស៊ុង ។**

## ព្រះវិញ្ញាណបរិសុទ្ធបានធ្វើការតាមរយៈដូរតន្ត្រី

**ការបញ្ចេញដោយការចាក់ប្រេងតាំង**

ព្រះវិញ្ញាណបរិសុទ្ធបានប្រើប្រាស់នូវគ្រឿងឧបករណ៍ភ្លេង ដើម្បីថ្វាយសិរីល្អដល់ព្រះ និងសម្រាប់ការសាងដល់ពួកបណ្ដាជន ។ ដូរតន្ត្រីគឺអាចជួយបង្កើតឱ្យមានបរិយាកាស សម្រាប់អំណោយទានជាភាសាដទៃ ការបកប្រែភាសាដទៃ ការអធិប្បាយ ការប្រោសឱ្យជា ពាក្យសម្ដីនៃចំណេះចេះស្ទាត់ និងពាក្យសម្ដីនៃប្រាជ្ញា អំណោយទាននៃសេចក្ដីជំនឿ និងអំណោយទាននៃការឫទ្ធិបារមីជាដើម ។

ព្រះគម្ពីរ២ពង្សាវតារក្សត្រ ៣:១៥ ចែងថា: **តែឥឡូវនេះ សូមនាំអ្នកភ្លេងម្នាក់មកឯទូលបង្គំ រួចកាលអ្នកនោះកំពុងតែលេងភ្លេង នោះព្រះហស្តនៃព្រះយេហូវ៉ា ក៏មកលើអេលីសេ ។**

**ការចង្អុលបង្ហាញចល់ការប្រោសលោះ**

- *ដោយការជាប់ទោស*

នៅពេលដែលពួកអ៊ីស្រាអែលស្ថិតនៅក្នុងការជាប់ទោស ក្រុមភ្លេងរបស់ពួកគេក៏បានត្រូវឈប់ផ្អាក ។

ព្រះគម្ពីរទំនុកដំកើង ១៣៧:១-៤ ចែងថា: **យើងបានអង្គុយចុះនៅមាត់ទន្លេស្រុកបាប៊ីឡូន អើ យើងបានយំ ដោយនឹករឭកដល់ក្រុងស៊ីយ៉ូន យើងបានពាក់ព្យួរស៊ុងរបស់យើងនៅដើមចាក នាកណ្តាលស្រុកនោះ ដ្បិតនៅទីនោះពួកអ្នកដែលនាំយើងទៅជាឈ្លើយ គេបង្ខំឱ្យយើងច្រៀងបទ គឺពួកអ្នកដែលបំផ្លាញយើង គេឱ្យយើងលេង ឱ្យគេបានអរសប្បាយ ដោយពាក្យថា ចូរច្រៀងបទ១របស់ក្រុងស៊ីយ៉ូនមក ឱ្យយើងស្តាប់មើល តែយើងនឹងច្រៀងបទនៃព្រះយេហូវ៉ា នៅក្នុងប្រទេសដទៃដូចម្តេចបាន ។**

- *ដោយមានសេរីភាព*

នៅពេលដែលការជាប់ទោសរបស់ពួកគេ ត្រូវបានបញ្ឈប់ហើយ ៧០ឆ្នាំក្រោយមក ពួកគេក៏បានធ្វើដំណើរវិលត្រឡប់មកកាន់ផ្ទះសម្បែងខ្លួនវិញ ដោយមានសេចក្តីអំណរអរសប្បាយ ទាំងច្រៀង និងស្រែកជ័យឃោសដោយកងរំពងឡើង ។

ព្រះគម្ពីរទំនុកដំកើង ១២៦:១,២ ចែងថា: **កាលព្រះយេហូវ៉ាទ្រង់បាននាំពួកឈ្លើយមកឯក្រុងស៊ីយ៉ូនវិញ នោះយើងរាល់គ្នាបាន ដូចជាមនុស្សដែលយល់សប្តិទេ គ្រានោះ មាត់យើងបានពេលដោយការសើចសប្បាយ ហើយអណ្តាតក៏ពេញដោយបទចំរៀង នោះនៅគ្រប់ទាំងសាសន៍មានគេថា ព្រះយេហូវ៉ាទ្រង់បានធ្វើការយ៉ាងធំសំរាប់ពួកនោះពិត ។**

## ឧបករណ៍ភ្លេងនៅក្នុងការសរសើរតម្កើង និងថ្វាយបង្គំនៅក្នុងព្រះគម្ពីរសញ្ញាចាស់

**ការសរសេរចែងជាដំបូង**

ព្រះគម្ពីរលោកុប្បត្តិ ៤:២១ ចែងថាៈ **ប្អូនគាត់ឈ្មោះយូបាល ជាឪពុកនៃពួកអ្នកលេងស៊ុងនិងខ្លុយ ។**

អំពីឈ្មោះយ៉ាបាល (Yabal) ឬ យ៉ាបាល (Jubal)ជាភាសា (ហេព្រើរ) មានន័យថា ហូរមកដោយមានក្បួនដង្ហែរយ៉ាងអធឹកអធម ដូចជាខ្សែទឹកហូរ ។

**ចំពោះលោកម៉ូសេ**

ចំពោះលោកម៉ូសេ និងពួកកូនចៅអ៊ីស្រាអែលបានច្រៀងថ្វាយដល់ព្រះយេហូវ៉ា ។

ព្រះគម្ពីរនិក្ខមនំ ១៥:១,២ ចែងថាៈ **រួចពីនោះមក ម៉ូសេ និងពួកកូនចៅអ៊ីស្រាអែល ក៏នាំគ្នាច្រៀងទំនុកនេះថ្វាយព្រះយេហូវ៉ាថា ខ្ញុំនឹងច្រៀងថ្វាយព្រះយេហូវ៉ា ដ្បិតទ្រង់មានជ័យជំនះយ៉ាងឧត្តម ទ្រង់បានផ្តួលទាំងសេះ ទាំងអ្នកជិះទៅក្នុងសមុទ្រ ព្រះយេហូវ៉ាទ្រង់ជាកំឡាំងនៃខ្ញុំ ហើយជាទំនុកដែលខ្ញុំច្រៀងផង ទ្រង់បានជួយសង្គ្រោះខ្ញុំ ហើយជាព្រះនៃខ្ញុំ ឯខ្ញុំនឹងលើកសរសើរដល់ទ្រង់ គឺជាព្រះនៃឪពុកខ្ញុំៗនឹងដំកើងទ្រង់ ។**

**ចំពោះនាងម៉ារាម**

នាងម៉ារាម និងពួកស្រីៗទាំងអស់បានជាអ្នកទទួលខុសត្រូវ ខាងផ្នែកចម្រៀងថ្វាយដល់ព្រះយេហូវ៉ាដែលនាងម៉ារាមបានច្រៀង ។

ព្រះគម្ពីរនិក្ខមនំ ១៥:២០,២១ ចែងថាៈ **ឯហោរាម៉ារាម ជាបងស្រីរបស់អើរ៉ុន នាងក៏យកក្រាប់មកនៅដៃ ហើយបណ្តាស្ត្រីទាំងអស់គ្នា ក៏ទៅតាមទាំងបន្ទរក្រាប់ហើយលោតកញ្ឆេងកញ្ឆោត់ផង ម៉ារាមនាងក៏ទទួលពាក្យឆ្លើយនឹងគេថា ចូរច្រៀងថ្វាយព្រះយេហូវ៉ា ដ្បិតទ្រង់មានជ័យជំនះយ៉ាងឧត្តម ទ្រង់បានផ្តួលទាំងសេះទាំងអ្នកជិះទៅក្នុងសមុទ្រ ។**

**ពួករាស្ត្រអ៊ីស្រាអែល**

ពួករាស្ត្រអ៊ីស្រាអែលបានធ្វើពិធីច្រៀងចម្រៀង ។

ព្រះគម្ពីរជនគណនា ២១:១៧ ចែងថាៈ **រួចពួកអ៊ីស្រាអែលគេក៏ច្រៀងទំនុកនេះថា «ឱ្យផុសឡើង អណ្តូងអើយ ចូរច្រៀងសរសើរអណ្តូងនេះចុះ» ។**

**ហោរាស្រីដេបូរ៉ា និងលោកបារ៉ាក**

ហោរាស្រីដេបូរ៉ា និងលោកបារ៉ាកបានប្រារព្ធពិធីជ័យជម្នះរបស់ពួកគេ ដោយច្រៀងចម្រៀង ។

ព្រះគម្ពីរពួកចៅហ្វាយ ៥:១-៣ ចែងថាៈ **នៅថ្ងៃនោះ ដេបូរ៉ា និងបារ៉ាក ជាកូនអ័ប៊ីណោមក៏ច្រៀងថា ចូរក្រាបថ្វាយបង្គំដល់ព្រះយេហូវ៉ា ដ្បិតពួកអ្នកនាំមុខបានតាំងខ្លួននាំពួកអ៊ីស្រាអែល ហើយបណ្តាជនបានប្រគល់ខ្លួនដោយស្ម័គ្រពីចិត្ត ពួកស្តេចអើយ ចូរស្តាប់ ពួកមេត្រួតត្រាអើយ ចូរផ្ទៀងត្រចៀកស្តាប់ចុះ ខ្ញុំនឹងច្រៀងថ្វាយព្រះយេហូវ៉ា ខ្ញុំនឹងច្រៀងសរសើរ ដល់ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ។**

**ក្រុមស្ត្រីសាសន៍អ៊ីស្រាអែល**

ក្រុមស្ត្រីសាសន៍អ៊ីស្រាអែល បានប្រារព្ធពិធីជ័យជម្នះរបស់ស្តេចដាវីឌលើយក្សកូលីយ៉ាត ។

ព្រះគម្ពីរ១សាំយូអែល ១៨:៦,៧ ចែងថាៈ **គ្រាកាលដែលគេត្រឡប់វិលមក គឺនៅវេលាដែលដាវីឌមកពីសំឡាប់សាសន៍ភីលីស្ទីនម្នាក់នោះវិញហើយ នោះពួកស្រីទាំងឡាយ ក៏នាំគ្នាចេញពីទីក្រុងរបស់សាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន មកទទួលស្តេចសូលដោយអំណរព្រមទាំងច្រៀង និងលោតកញ្ឆេង ហើយបន្ទរក្រាប់ និងប្រដាប់ភ្លេងផ្សេងៗ កំពុងដែលគេលេងភ្លេង នោះក៏ច្រៀងឆ្លើយឆ្លងគ្នាទៅវិញទៅមក ដោយពាក្យថា សូលទ្រង់បានសំឡាប់ទាំងពាន់ ហើយដាវីឌទាំងម៉ឺន ។**

**ចំពោះស្តេចដាវីឌ**

រីឯស្តេចដាវីឌវិញ គឺបាននៅតែបន្តច្រៀងសរសើរតម្កើងដល់ព្រះយេហូវ៉ាជាប់ជានិច្ច ។

ព្រះគម្ពីរទំនុកដំកើង ៧:១៧ ចែងថា: **ខ្ញុំនឹងសរសើរដល់ព្រះយេហូវ៉ា តាមសេចក្តីសុចរិតទ្រង់ ហើយនឹងច្រៀងដំកើងថ្វាយព្រះនាមព្រះយេហូវ៉ា ដ៏ខ្ពស់បំផុត ។**

ព្រះគម្ពីរទំនុកដំកើង ១៣:៦ ចែងថា: **ទូលបង្គំនឹងច្រៀងថ្វាយព្រះយេហូវ៉ា ដ្បិតទ្រង់បានប្រោសការល្អជាបរិបូរដល់ទូលបង្គំហើយ ។**

ព្រះគម្ពីរទំនុកដំកើង ២១:១៣ ចែងថា: **ឱព្រះយេហូវ៉ាអើយ សូមឱ្យទ្រង់បានថ្កើងឡើងដោយឥទ្ធិឫទ្ធិរបស់ទ្រង់ នោះយើងខ្ញុំនឹងច្រៀងសរសើរពីព្រះចេស្តានៃទ្រង់ ។**

**ចំពោះពួកសង្ឃ**

មានពួកលេវីដ៏ជាសង្ឃចំនួនជា៤000នាក់ បានច្រៀងសរសើរតម្កើងដល់ព្រះអម្ចាស់ ជាមួយនឹងឧបករណ៍ភ្លេង ។

ព្រះគម្ពីរ១របាក្សត្រ ១៥:១៦ ចែងថា: **ដាវីឌក៏ប្រាប់ឱ្យមេពួកលេវីជំរុវឱ្យពួកចំរៀងជាបងប្អូនគេ កាន់ប្រដាប់ភ្លេង គឺពិណ ស៊ុង និងឈឹងលេងឱ្យឮសូរក្រលួច ហើយឡើងសំឡេងច្រៀងដោយអំណរ ។**

ព្រះគម្ពីរ១របាក្សត្រ ២៣:៥ ចែងថា: **មាន៤ពាន់នាក់ជាអ្នកឆ្មាំទ្វារ៤ពាន់នាក់ទៀត ជាអ្នកច្រៀងសរសើរដល់ព្រះយេហូវ៉ា ដោយប្រដាប់ភ្លេង ដែលដាវីឌបានធ្វើសំរាប់ការច្រៀងសរសើរ ។**

ព្រះគម្ពីរ២របាក្សត្រ ៣០:២១ ចែងថា: **ពួកកូនចៅអ៊ីស្រាអែលដែលបានមកឯក្រុងយេរូសាឡិម គេធ្វើបុណ្យនំបុ័ងឥតដំបែនោះអស់៧ថ្ងៃ ដោយសេចក្តីរីករាយជាខ្លាំង ហើយពួកលេវីនឹងពួកសង្ឃ ក៏ច្រៀងសរសើរ**

**ថ្វាយព្រះយេហូវ៉ារាល់ៗថ្ងៃ ផ្សំដោយភ្លេងមានសូរយ៉ាងខ្លាំងថ្វាយព្រះយេហូវ៉ា ។**

## ឧបករណ៍ភ្លេងក្នុងការសរសើរ និងថ្វាយបង្គំនៅក្នុងព្រះគម្ពីរសញ្ញាថ្មី

### ពួកសិស្ស

ព្រះយេស៊ូវ និងពួកសិស្សទ្រង់បានច្រៀងទំនុក១ជាមួយគ្នា ។

ព្រះគម្ពីរម៉ាថាយ ២៦:៣០ ចែងថា: **រួចកាលបានច្រៀងទំនុកមួយហើយ នោះក៏នាំគ្នាចេញទៅឯភ្នំដើមអូលីវ ។**

ទំនុកតម្កើងគឺជាចម្រៀងសរសើរតម្កើងដល់ព្រះ ។

### លោកសាវ័កប៉ុល

លោកសាវ័កប៉ុលបានបង្រៀនពួកជំនុំ ដោយការច្រៀងចម្រៀងដែលមានការចាក់ប្រេងតាំង ។

ព្រះគម្ពីរ១កូរិនថូស ១៤:១៥ ចែងថា: **ដូច្នេះ ត្រូវធ្វើដូចម្តេច ខ្ញុំត្រូវអធិស្ឋាន ដោយនូវវិញ្ញាណ ហើយត្រូវអធិស្ឋានដោយនូវប្រាជ្ញាផង ខ្ញុំនឹងច្រៀងដោយវិញ្ញាណ ហើយនឹងច្រៀងដោយប្រាជ្ញាដែរ ។**

ព្រះគម្ពីរអេភេសូរ ៥:១៩,២០ ចែងថា: **ហើយនិយាយគ្នាទៅវិញទៅមក ដោយបទទំនុកដំកើង ទំនុកបរិសុទ្ធ និងចំរៀងខាងឯវិញ្ញាណ ទាំងច្រៀង ហើយសរសើរដល់ព្រះអម្ចាស់ដោយចិត្ត ទាំងអរព្រះគុណដល់ព្រះដ៏ជាព្រះវរបិតាជាដរាប ក្នុងគ្រប់ការទាំងអស់ ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ។**

ព្រះគម្ពីរកូល៉ុស ៣:១៦ ចែងថា: **ចូរឲ្យព្រះបន្ទូលនៃព្រះគ្រីស្ទបានសណ្ឋិតនៅក្នុងអ្នករាល់គ្នាជាបរិបូរ ដោយប្រាជ្ញាគ្រប់យ៉ាង ទាំងបង្រៀនហើយទូន្មានគ្នា ដោយនូវទំនុកដំកើង ទំនុកបរិសុទ្ធ និងចំរៀងខាងឯវិញ្ញាណ ទាំងច្រៀងក្នុងចិត្តថ្វាយព្រះ ដោយព្រះគុណ ។**

### ទំនុកតម្កើង

ទំនុកតម្កើង គឺជាចម្រៀងនៃការសរសើរតម្កើងដល់ព្រះ ។

### ចម្រៀងខាងវិញ្ញាណ

ចម្រៀងខាងឯវិញ្ញាណ គឺជាចម្រៀងដែលបានប្រទានឱ្យ មកពីព្រះវិញ្ញាណបរិសុទ្ធ ហើយដែលបានច្រៀងចេញទៅដោយឯង១ គឺជាព្រះវិញ្ញាណទ្រង់បានប្រទានឱ្យ ទាំងពាក្យសម្តី និងទាំងមានពក្យជូនល្អថែមទៀតផង ។

បទចម្រៀងទាំងអស់នោះ គឺអាចមានជាចម្រៀងជាភាសារបស់មនុស្ស ឬជាភាសាដទៃដែលគ្មានអ្នកណាដឹងបាន ។

### ជាវត្ថុបំណងដ៏សំខាន់

វត្ថុបំណងជាចម្បងនៅក្នុងចម្រៀង គឺត្រូវតែជាការសរសើរ និងការលើកតម្កើងដល់ព្រះ ។ គឺមិនមែនជាការច្រៀងដោយខឹតខំប្រឹងប្រែង ឬដោយច្រៀងសម្រាប់ការជប់លៀងនោះឡើយ ។ ចម្រៀងទាំងនោះគឺមិនមែនជាការចេញមកពីមនុស្សនោះឡើយ គឺចេញមកពីព្រះសម្រាប់ធ្វើឱ្យព្រះទ្រង់សព្វព្រះហឫទ័យតែប៉ុណ្ណោះ ។

ព្រះគម្ពីរហេព្រើរ ២:១២ ចែងថា: **ទ្រង់មានបន្ទូលថា «ទូលបង្គំនឹងប្រកាសប្រាប់ពីព្រះនាមទ្រង់ ដល់ពួកបងប្អូន ទូលបង្គំនឹងច្រៀងសរសើរពីទ្រង់ នៅកណ្តាលពួកជំនុំ»** ។

## ការបញ្ជាក់បង្ហាញពីការសរសើរតម្កើងខាងឯវិញ្ញាណ

---

### ការសរសើរតម្កើងព្រះដោយសម្លេង

ព្រះគម្ពីរ១របាក្សត្រ ១៦:៩ ចែងថា: **ចូរច្រៀងថ្វាយទ្រង់ ចូរច្រៀងសរសើរដល់ទ្រង់ចុះ ចូរនឹកថ្លែងពីអស់ទាំងការអស្ចារ្យរបស់ទ្រង់ ។**

- *ធ្វើការទម្លាប់ដើម្បីនិយាយជជែកជាមួយនឹងព្រះ*
- *ចូរសរសើរពីការអស្ចារ្យរបស់ទ្រង់*
- *ចូរចាប់ផ្តើមនិយាយពីការសរសើរតម្កើងព្រះពីមួយថ្ងៃទៅ១ថ្ងៃ*
- *ចូរសរសើរតម្កើងដល់ព្រះដោយការនិយាយ និងការសរសើរ*

➢ *ចូរទម្លាប់ខ្លួនក្នុងការសរសើរតម្កើងដល់ព្រះ*

ព្រះគម្ពីរទំនុកដំកើង ៤០:១៦ ចែងថាៈ **ចំណែកពួកអស់អ្នកដែលស្វែងរកទ្រង់ នោះសូមឱ្យគេបានរីករាយសប្បាយក្នុងទ្រង់ចុះ សូមឱ្យអស់អ្នកដែលស្រឡាញ់សេចក្តីសង្គ្រោះនៃទ្រង់ បានពោលជានិច្ចថា សូមឱ្យព្រះយេហូវ៉ាបានថ្កើងឡើង ។**

ព្រះគម្ពីរទំនុកដំកើង ៦៦:៨ ចែងថាៈ **ម្នាល ជនទាំងឡាយអើយ ចូរលើកដំកើងព្រះនៃយើងរាល់គ្នា ហើយបន្លឺឡើងឱ្យបានឮសេចក្តីសរសើរទ្រង់ទូទៅ ។**

ការសរសើរតម្កើងដល់ព្រះអម្ចាស់ គឺធ្វើដោយមានការច្រៀងចម្រៀង គឺជាអ្នកធ្វើការចង្អុលបង្ហាញនូវអារម្មណ៍អំណរ ដែលចេញមកដោយឯងៗ ។ វាក៏អាចបានជាអ្វីដែលយើងបាននិយាយផងដែរ ។ ការសរសើរតម្កើងគឺជាការចង្អុលបង្ហាញនូវសុខភាពជាវិជ្ជមាន គឺដែលមានអារម្មណ៍ ចំពោះការបំពេញការងារដោយកម្លាំង ។

**ចូរស្រែកហោថ្វាយព្រះ**

មានពេលសម្រាប់បន្លឺសម្លេង និងមានពេលសម្រាប់ស្រែកហ៊ោ ។

ព្រះគម្ពីរទំនុកដំកើង ៤៧:១ ចែងថាៈ **ម្នាល ជនទាំងឡាយអើយ ចូរទះដៃទាំងអស់គ្នាចុះ ចូរស្រែកហ៊ោរថ្វាយព្រះ ដោយសំឡេងជាជ័យជំនះ ។**

ព្រះគម្ពីរអេសាយ ១២:៦ ចែងថាៈ **ឱពួកអ្នកនៅក្រុងស៊ីយ៉ូនអើយ ចូរបន្លឺសំឡេងឡើង ហើយស្រែកហ៊ោដោយអំណរចុះ ដ្បិតព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ទ្រង់ធំប្រសើរនៅកណ្តាលឯងរាល់គ្នា ។**

ព្រះគម្ពីរ១សាំយូអែល ៤:៥ ចែងថាៈ **កាលហឹបនៃសេចក្តីសញ្ញារបស់ព្រះយេហូវ៉ា បានមកដល់ក្នុងទីបោះទ័ពហើយ នោះស្រាប់តែពួកអ៊ីស្រាអែលទាំងអស់គ្នា គេស្រែកឡើងជាខ្លាំង ដល់ម៉្លេះបានជាឮខ្ទរខ្ទារនៅផែនដី ។**

ព្រះគម្ពីរលូកា ១៩:៣៧ ចែងថា: **លុះទ្រង់យាងជិតដល់ហើយ គឺត្រង់ផ្លូវចុះពីភ្នំដើមអូលីវមក នោះពួកសិស្សទ្រង់ទាំងហ្វូងចាប់តាំងមានសេចក្តីរីករាយ ក៏ពោលសរសើរដល់ព្រះ ដោយសំឡេងយ៉ាងខ្លាំង ដោយព្រោះអស់ទាំងការឫទ្ធិបារមីដែលគេបានឃើញនោះ ។**

## សំណួររំឭកសារឡើងវិញ

១. ចូរផ្តល់ឱ្យនូវគំរូពីក្នុងព្រះគម្ពីរ ដែលនិយាយពីឧបករណ៍ភ្លេងដែលត្រូវបានគេប្រើនៅក្នុងការសរសើរតម្កើង ។

២. ចូរផ្តល់ឱ្យនូវគំរូពីក្នុងព្រះគម្ពីរ ដែលនិយាយពីការរំដោះដោយការប្រគំបទភ្លេង គឺជាការចាក់ប្រេងតាំងឱ្យធ្វើ ការអធិប្បាយ ។

៣. ចូរផ្តល់ឱ្យនូវគំរូពីការប្រគំបទភ្លេង ដែលត្រូវបានគេប្រើក្នុងការសរសើរតម្កើង និងថ្វាយបង្គំនៅក្នុងព្រះគម្ពីរ សញ្ញាចាស់ ។

៤. ចូរផ្តល់ឱ្យនូវគំរូពីការប្រគំបទភ្លេង ដែលត្រូវបានគេប្រើក្នុងការសរសើរតម្កើង និងថ្វាយបង្គំនៅក្នុងព្រះគម្ពីរ សញ្ញាថ្មី ។

# មេរៀនទី ៨
## *ការចង្អុលបង្ហាញនូវការសរសើរតម្កើងខាងផ្នែករូបកាយ*

**កំណត់ចំណាំៈ** ចម្រៀងទាំងឡាយ គួរគប្បីត្រូវបានគេជ្រើសរើសជាមុនដំបូង ចំពោះការចាប់ផ្តើមមេរៀននេះ ដែលនឹងបានជាការខនតខំប្រឹងប្រែង ក្នុងការបញ្ចេញសកម្មភាព ដែលបើកបង្ហាញពីការសរសើរតម្កើងខាងផ្នែករូបកាយម្នាក់ៗ គឺដែលពួកគេបានសិក្សារួចមកហើយ ។ បន្ទាប់ពីការបញ្ជាក់បង្ហាញខាងឯរូបកាយ ដែលត្រូវបានគេទទួលការសិក្សារួចមកហើយ នោះចូរចំណាយពេលវេលា ដើម្បីធ្វើការពិសោធន៍នូវការបញ្ជាក់បង្ហាញជាពិសេសនោះ នៅក្នុងពេលវេលានៃការសរសើរតម្កើងដ៏មានកម្រិតខ្ពស់ ឬនៅក្នុងការថ្វាយបង្គំដែលស្ថិតនៅក្នុងចិត្ត ។ វាជាការធ្វើឱ្យឆ្ងល់ថាតើព្រះវត្តមាននៃព្រះ នឹងចូលមកគង់ក្នុងចិត្តរបស់យើងដោយវិធីណា នៅពេលដែលយើងមានការពិសោធន៍ នូវការចង្អុលបង្ហាញពីការសរសើរតម្កើង និងការថ្វាយបង្គំនៅក្នុងព្រះគម្ពីរនោះឯង ។

## ការចង្អុលបង្ហាញពីការសរសើរតម្កើងខាងផ្នែករូបកាយ

---

### ដោយការឈរ

ការឈរគឺជាសញ្ញានៃការគោរព ។

ព្រះគម្ពីរ២របាក្សត្រ ២០:១៩ ចែងថាៈ **ឯពួកលេវី ខាងពួកកូនចៅកេហាត់ និងពួកកូនចៅកូរេគេឈរឡើង សរសើរដល់ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ដោយសំឡេងយ៉ាងខ្លាំងក្រៃលែង ។**

ព្រះគម្ពីរវិវរណៈ ៧:៩,១០ ចែងថាៈ **ក្រោយនោះមក ខ្ញុំក្រឡេកទៅឃើញមនុស្ស១ហ្វូងយ៉ាងធំ ដែលគ្មានអ្នកណាអាចនឹងរាប់បានឡើយ គេមកពីគ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ ហើយគ្រប់ទាំងភាសា ក៏ឈរនៅមុខបល្ល័ង្ក និងកូនចៀម ទាំងពាក់អាវសវែង ហើយកាន់ធាងចាកនៅដៃ គេបន្លឺសំឡេងថា សេចក្តីសង្គ្រោះស្រេចនូវព្រះនៃយើងរាល់គ្នា ដែលគង់លើបល្ល័ង្ក ហើយស្រេចនឹងកូនចៀមផង ។**

ព្រះគម្ពីរទំនុកដំកើង ៣៣:៨ ចែងថាៈ **ចូរឱ្យគ្រប់ផែនដីខ្លាចចំពោះព្រះយេហូវ៉ា ហើយឱ្យគ្រប់មនុស្សនៅលោកិយកោតក្រែងដល់ទ្រង់ចុះ ។**

ព្រះគម្ពីរទំនុកដំកើង ១៣៥:១,២ ចែងថា: **ចូរសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះនាមព្រះយេហូវ៉ា ឱពួកអ្នកបំរើរបស់ព្រះយេហូវ៉ាអើយ ចូរសរសើរទ្រង់ចុះ ពួកអ្នករាល់គ្នាដែលឈរនៅក្នុងដំណាក់នៃព្រះយេហូវ៉ា គឺក្នុងទីព្រះលាននៃដំណាក់របស់ព្រះនៃយើងខ្ញុំអើយ ។**

## ដោយការទះដៃ

ការទះដៃរបស់លោកអ្នក គឺជាការចង្អុលបង្ហាញចំពោះភាពសប្បាយរីករាយ អំណរអរ និងការឯកភាព ។

ព្រះគម្ពីរទំនុកដំកើង ៤៧:១ ចែងថា: **ម្នាល ជនទាំងឡាយអើយ ចូរទះដៃទាំងអស់គ្នាចុះ ចូរស្រែកហ៊ោរថ្វាយព្រះ ដោយសំឡេងជាជ័យជំនះ ។**

ព្រះគម្ពីរអេសាយ ៥៥:១២ ចែងថា: **ដ្បិតឯងរាល់គ្នានឹងចេញទៅដោយអំណរ ហើយគេនឹងនាំឯងចេញទៅដោយសុខសាន្ត ឯអស់ទាំងភ្នំធំ និងភ្នំតូចទាំងប៉ុន្មាននឹងធ្លាយចេញជាចំរៀងនៅមុខឯង ហើយគ្រប់ទាំងដើមឈើនៅព្រៃនឹងទះដៃផង ។**

## ការដើរជង្វែរ

ការដើរជង្វែរគឺជាការចង្អុលបង្ហាញ នូវជ័យជម្នះខាងផ្នែករូបកាយ ។ ការដើរជង្វែរនៅជុំវិញទីក្រុងយេរីខូរ គឺជាការបង្ហាប់បញ្ហា ដែលនាំមកនូវជ័យជម្នះបានពេញលេញ ។

ព្រះគម្ពីរយ៉ូស្វេ ៦:២-៥ ចែងថា: **ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងយ៉ូស្វេថា មើល អញបានប្រគល់ក្រុងយេរីខូរ ព្រមទាំងស្តេចគេ និងពួកមនុស្សខ្លាំងពូកែស្ទាត់ជំនាញទាំងប៉ុន្មាន មកក្នុងកណ្តាប់ដៃឯងហើយ ដូច្នេះត្រូវឱ្យឯងរាល់គ្នា ជាពួកថ្មឹកច្បាំង ដើរជុំវិញទីក្រុងអស់៦ថ្ងៃ ក្នុង១ថ្ងៃ១ជុំ ត្រូវឱ្យមានសង្ឃ៧រូប កាន់ត្រែស្នែងចៀមដើរនាំមុខហឹប រួចដល់ថ្ងៃទី៧ នោះត្រូវឱ្យដើរព័ទ្ធទីក្រុងអស់៧ជុំថែមទៀត ហើយពួកសង្ឃត្រូវផ្លុំត្រែឡើង កាលណាគេផ្លុំស្នែងចៀម មានសំឡេងយ៉ាងវែង ឮដល់ឯង**

**រាល់គ្នា នោះទាំងអស់គ្នាត្រូវស្រែកឡើង ជាសំរែកយ៉ាងខ្លាំង ដូច្នេះកំផែងទីក្រុងនឹងរលំដួលទៅ រួចត្រូវឱ្យបណ្តាជនទាំងអស់ឡើងចំទៅមុខរៀងខ្លួន ។**

កូនក្រមុំរបស់ព្រះគ្រីស្ទ គឺជារូបភាពមួយដូចជាទាហានដែលដើរដង្ហែររួមគ្នាដូច្នោះដែរ ។

ព្រះគម្ពីរបទចំរៀងសាឡូម៉ូន ៦:៤,១០ ចែងថាៈ **ឱមាសសំឡាញ់អើយ ឯងស្រស់បស់ល្អដូចក្រុងធើសា ហើយស្រស់ប្រិមប្រិយដូចជាក្រុងយេរូសាឡិម ក៏គួរស្ញែងខ្លាចដូចជាពលទ័ព មានទាំងទង់ជ័យផង... តើនាងណានុ៎ះ ដែលលេចចេញមកដូចជាអរុណរះ ស្រស់ល្អដូចជាព្រះចន្ទ ហើយភ្លឺត្រចះដូចជាព្រះអាទិត្យ មានទាំងទង់ជ័យផងដូច្នេះ ។**

## ដោយការលោតកញ្ឆោង

ការលោតកញ្ឆោង គឺជាការចង្អុលបង្ហាញពីការសរសើរតម្កើងខាងផ្នែករូបកាយ គឺជាការបើកសម្តែងដ៏ច្រើនលើសលប់ ។ វាជាតម្រូវការក្នុងការប្រើប្រាស់នូវរូបរាង្គកាយទាំងមូល ។ វាជាការចូលរួមដ៏ពេញលេញ និងការបញ្ចេញនូវការហាមឃាត់ដោយខ្លួនឯង និងសេចក្តីដឹងខ្លួន គឺនៅពេលដែលយើងស្តាប់បង្គាប់ព្រះ ព្រមទាំងបានលោតរាំនៅចំពោះព្រះអង្គដោយនូវអំណាចចេស្តារបស់យើង ។

ព្រះគម្ពីរទំនុកដំកើង ១៤៩:៣ ចែងថាៈ **គួរឱ្យគេសរសើរព្រះនាមទ្រង់ ដោយលោតកញ្ឆោង គួរឱ្យគេច្រៀងសរសើរទ្រង់ ដោយក្រាប់និងស៊ុង ។**

ព្រះគម្ពីរ២សាំយូអែល ៦:១៤ ចែងថាៈ **ដាវីឌក៏លោតកញ្ឆោងអស់ពីកំឡាំងទ្រង់នៅចំពោះព្រះយេហូវ៉ា ទ្រង់ពាក់អេផូឌធ្វើពីសំពត់ខ្លូតទេស ។**

យើងនឹងសិក្សាបន្ថែមទៀតអំពីការលោតរាំ នៅចុងមេរៀននេះ ។

**ដោយការសើចសប្បាយ**

មានការចង្អុលបង្ហាញមួយស្តីពីអំណរនៅក្នុងព្រះអម្ចាស់ ដែលមានតែផ្លូវមួយនេះទេ ដើម្បីបញ្ជាក់បង្ហាញថា វាគឺជាការកើតឡើងតាមរយៈសំណើច ។ ការប្រោសឱ្យជា និងការរំដោះដ៏ធំឧត្តម គឺតែងតែមកនៅកំឡុងពេលនៃការសើចដ៏បរិសុទ្ធ នៅចំពោះព្រះអម្ចាស់ ។ សំណើចដ៏ពិតប្រាកដ គឺជាការបើកសម្តែងនូវសេចក្តីអំណរផ្នែកខាងក្នុង ។

ព្រះគម្ពីរទំនុកដំកើង ១២៦:២ ចែងថា: **គ្រានោះ មាត់យើងបានពេញដោយការសើចសប្បាយ ហើយអណ្តាតក៏ពេញដោយបទចំរៀង នោះនៅគ្រប់ទាំងសាសន៍មានគេថា ព្រះយេហូវ៉ាទ្រង់បានធ្វើការយ៉ាងធំសំរាប់ពួកនោះពិត ។**

ព្រះគម្ពីរយ៉ូប ៨:២០,២១ ចែងថា: **មើល ព្រះទ្រង់មិនដែលលះបង់មនុស្សគ្រប់លក្ខណ៍ ឬទប់ទល់មនុស្សដែលប្រព្រឹត្តអាក្រក់ឡើយ ដល់ចុងបំផុត ទ្រង់នឹងឱ្យមាត់អ្នកបានពេញដោយសេចក្តីសំណើច ហើយឱ្យបបូរមាត់អ្នកបានស្រែកឡើង ដោយអំណរវិញ ។**

## ការចង្អុលបង្ហាញពីការថ្វាយបង្គំខាងផ្នែករូបកាយ

**ការលើកដៃប្រទូលឡើង**

នៅក្នុងតំបន់ផ្នែកខាងរូបកាយ គឺជាការលើកដៃលោកអ្នកឡើង ដែលជាទីសម្គាល់នៃការចុះចូល ។ នៅក្នុងការថ្វាយបង្គំ វាជាទីសម្គាល់នៃការថ្វាយយញ្ញបូជា និងការចុះចូល ។

ព្រះគម្ពីររ៉ូម ១២:១ ចែងថា: **ដូច្នេះ បងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នាដោយសេចក្តីមេត្តាករុណានៃព្រះ ឱ្យបានថ្វាយរូបកាយទុកជាយញ្ញបូជារស់ ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ជាការគោរពនៃអ្នករាល់គ្នាដែលមានទំនង ។**

ព្រះគម្ពីរទំនុកដំកើង ១៤១:២ ចែងថា: **សូមឱ្យសេចក្តីអធិស្ឋានរបស់ទូលបង្គំបានផ្សាយឡើង ដូចជាគ្រឿងក្រអូបនៅចំពោះទ្រង់ និងការលើកដៃប្រណម្យរបស់ទូលបង្គំ បានដូចជាយញ្ញបូជាពេលល្ងាច ។**

វាជាការឈោងចាប់ និងសេចក្តីស្រេកឃ្លានដល់ព្រះ ។

ព្រះគម្ពីរទំនុកដំកើង ១៤៣:៦ ចែងថា: **ទូលបង្គំលើកដៃប្រណម្យដល់ទ្រង់ ព្រលឹងទូលបង្គំស្រេករកទ្រង់ ដូចជាដីហួតហែង ស្រេករកទឹក ។**

ព្រះគម្ពីរទំនុកដំកើង ៤២:១,២ ចែងថា: **ឱព្រះអង្គអើយ ព្រលឹងទូលបង្គំដង្ហក់រកទ្រង់ ដូចជាក្តាន់ញីដង្ហក់រកជ្រោះទឹក ព្រលឹងទូលបង្គំស្រេករកព្រះ គឺព្រះដ៏មានព្រះជន្មរស់នៅ តើដល់កាលណាបានទូលបង្គំនឹងមកឈរចំពោះទ្រង់ ។**

ការលើកដៃលោកអ្នកឡើង នោះក៏ជាការធ្វើសកម្មភាពចំពោះព្រះដ៏មានពរដែរ ។

ព្រះគម្ពីរទំនុកដំកើង ១៣៤:២ ចែងថា: **ចូរប្រណម្យដៃទៅឯទីបរិសុទ្ធ ហើយសូមឱ្យព្រះយេហូវ៉ាបានព្រះពរចុះ ។**

ព្រះគម្ពីរទំនុកដំកើង ៦៣:៤ ចែងថា: **គឺយ៉ាងនោះដែលទូលបង្គំនឹងលើកដំកើងទ្រង់ ក្នុងកាលដែលនៅរស់នៅឡើយ ទូលបង្គំនឹងប្រទូលដៃឡើង ដោយនូវព្រះនាមទ្រង់ ។**

ការលើកដៃលោកអ្នកឡើង គឺជាការចង្អុលបង្ហាញចំពោះការអធិស្ឋាន និងការទូលអង្វរដែលសម្តែងចេញផ្នែកខាងរូបកាយ ។

ព្រះគម្ពីរទំនុកដំកើង ២៨:២ ចែងថា: **សូមស្តាប់សំឡេងដែលទូលបង្គំទូលអង្វរ ក្នុងកាលដែលទូលបង្គំអំពាវនាវដល់ទ្រង់ គឺក្នុងកាលដែលទូលបង្គំប្រទូលដៃទៅឯទីបរិសុទ្ធរបស់ទ្រង់ ។**

ព្រះគម្ពីរ១ធីម៉ូថេ ២:៨ ចែងថា: **ដូច្នេះ ខ្ញុំចង់ឱ្យពួកប្រុសៗលើកដៃបរិសុទ្ធឡើង នឹងអធិស្ឋាននៅគ្រប់ទីកន្លែង ដោយឥតខឹង ឬឈ្លោះប្រកែកឡើយ ។**

**ការក្រាបចុះ ឬការលុតជង្គង់ចុះ**

ការក្រាបចុះ ឬការលុតជង្គង់ចុះ គឺជាអាកប្បកិរិយានៃការធានារ៉ាប់រង និងការគោរព ។

ព្រះគម្ពីរទំនុកដំកើង ៩៥:៦ ចែងថា: **មកចុះ ចូរយើងឱនកាយថ្វាយបង្គំទាំងអស់គ្នា ចូរយើងលុតជង្គង់នៅចំពោះព្រះយេហូវ៉ា ជាព្រះដ៏បង្កើតយើងខ្ញុំ ។**

**ការឱនក្បាលក្រាបថ្វាយបង្គំ**

ការដួលក្រាបចុះទៅលើកម្រាល គឺជាការបញ្ជាក់បង្ហាញពីការគោរព និងការថ្វាយបង្គំដ៏មានជម្រៅជ្រៅបំផុត ចំពោះការធានារ៉ាប់រងដ៏ពេញលេញ នោះគឺជាការបន្ទាបខ្លួនដ៏ពិតប្រាកដនោះឯង ។

ព្រះគម្ពីរ១ពង្សាវតារក្សត្រ ១៨:៣៩ ចែងថា: **កាលពួកជនទាំងឡាយបានឃើញ នោះគេក៏ក្រាបផ្កាប់មុខពោលថា ព្រះយេហូវ៉ាទ្រង់ជាព្រះ ព្រះយេហូវ៉ាទ្រង់ជាព្រះពិតហើយ ។**

ព្រះគម្ពីរ១របាក្សត្រ ២៩:២០ ចែងថា: **ឯដាវីឌទ្រង់មានបន្ទូលដល់ពួកជំនុំទាំងអស់គ្នាថា ចូរអ្នករាល់គ្នាបង្គំទូលដល់ព្រះយេហូវ៉ា ជាព្រះនៃអ្នករាល់គ្នាចុះ ដូច្នេះពួកជំនុំទាំងអស់ក៏សូមឱ្យព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោគេបានព្រះពរ រួចគេឱនក្បាលថ្វាយបង្គំដល់ព្រះយេហូវ៉ា និងស្តេចផង ។**

**ការស្ងប់ស្ងាត់**

ការស្ងប់ស្ងាត់គឺអាចជាការចង្អុលបង្ហាញចំពោះការសរសើរតម្កើងនោះឯង ។

ព្រះគម្ពីរសាស្តា ៣:៧ ចែងថា: **មានពេលសំរាប់ហែកចោល ហើយពេលសំរាប់ដេរភ្ជាប់ មានពេលដែលគួរនៅស្ងៀម ហើយពេលសំរាប់និយាយ ។**

ព្រះគម្ពីរទំនុកដំកើង ៤៦:១០ ចែងថា: **ចូរបង្អង់សិន ឱ្យបានដឹងថា អញជាព្រះ អញនឹងបានថ្កើងឡើង នៅកណ្តាលពួកសាសន៍ដ៏ទៃ អញនឹងបានថ្កើងឡើងនៅផែនដី ។**

**ការស្រក់ទឹកភ្នែក**

ជានិច្ចកាល ការស្រក់ទឹកភ្នែកគឺតែងតែត្រូវបានទទួលខុសត្រូវចំពោះការពិសោធន៍ នូវសេចក្តីស្រឡាញ់ និងសេចក្តីមេត្តាករុណា យ៉ាងខ្លាំងក្លារបស់ព្រះ ។

ព្រះគម្ពីរកិច្ចការ ២០:៣៦,៣៧ ចែងថា: **លុះបាននិយាយសេចក្តីទាំងនោះរួចហើយ នោះប៉ុលក៏លុតជង្គង់អធិស្ឋានជាមួយនឹងគេទាំងអស់គ្នា ហើយគ្រប់គ្នាក៏យំជាច្រើន រួចគេឱបកគាត់ថើបដោយថ្មិតថ្មម ។**

ការសរសើរតម្កើងដែលបន្ទរតាមដោយការស្រក់ទឹកភ្នែក គឺជាការចង្អុលបង្ហាញ នូវការដឹងគុណ និងការគោរព ដែលធ្វើឱ្យមានការរំភើបខ្លាំង ។ ជារឿយៗ ពួកគេតែងនាំមកនូវការបញ្ចេញអារម្មណ៏ដ៏មានជម្រៅជ្រៅ និងការប្រោសឱ្យជាផ្នែកខាងក្នុង ។

ព្រះគម្ពីរលូកា ៧:៣៧,៣៨ ចែងថា: **ហើយមើល នៅក្រុងនោះមានស្ត្រីម្នាក់ដែលមានបាបនាងបានដឹងថា ទ្រង់គង់នៅតុក្នុងផ្ទះអ្នកផារិស៊ីនោះក៏យកដបថ្មកែវដាក់ប្រេងក្រអូបមក នាងឈរពីខាងក្រោយទៀបព្រះបាទទ្រង់ទាំងយំ ចាប់តាំងសំរក់ទឹកភ្នែក ទទឹកព្រះបាទទ្រង់ រួចយកសក់ក្បាលនាងជូត ក៏ថើបព្រះបាទ ដោយស្រឡាញ់ ហើយយកប្រេងក្រអូបលាបផង ។**

ជារឿយៗ ការស្រក់ទឹកភ្នែកគឺជាការផលិតនូវសេចក្តីអំណរ និងជ័យជម្នះដ៏ធំឧត្តម ។

ព្រះគម្ពីរទំនុកដំកើង ១២៦:៥,៦ ចែងថា: **អស់អ្នកដែលសាបព្រោះដោយស្រក់ទឹកភ្នែក នោះនឹងបានច្រូតវិញដោយច្រៀងអរសប្បាយ ឯអ្នកដែលកណ្តៀតពូជ សំរាប់សាបព្រោះ ចេញទៅទាំងយំ នោះប្រាកដជានឹងចូលមកវិញដោយអំណរ ព្រមទាំងយកកណ្តាប់មកផង ។**

## អំពីការលោតរាំ

ការលោតរាំគឺមិនមែនជាការសំខាន់ជាជាង ការចង្អុលបង្ហាញនូវការសរសើរតម្កើងដទៃៗទៀតនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ វាក៏អាចបន្ថែមនូវការពោលសរសើរ និងសេចក្តីត្រូវការនូវការពន្យល់បន្ថែមទៀតជាជាងធ្វើជាទម្រង់ផ្សេងៗនោះទៅទៀត ។

## និយមន័យ

ការលោតរាំគឺជាការបើកសម្តែងដ៏ខ្ពស់បំផុត ។ វាតម្រូវឱ្យប្រើប្រាស់ នូវរូបកាយទាំងមូល តាមលំដាប់នៃការបញ្ជាក់ពីសេចក្តីអំណរ ពីការសរសើរ និងថ្វាយបង្គំនៅចំពោះព្រះយេហូវ៉ា ។

ពាក្យជាភាសាហេព្រើរ និងភាសាក្រិកគឺត្រូវបានគេបកប្រែថា "ការលោតរាំ" មានន័យថា "ការលោត ការលោតកញ្ឆេង ការលើកជើងឡើង ឬការលោត" ។ ចំពោះពាក្យដទៃទៀត ពាក្យខ្លះគឺជាធ្វើទៅដោយឯងៗ ព្រមទាំងការធ្វើដោយមិនចាំបាច់រៀនសូត្រតាមបែបធម្មជាតិនោះឡើយ ។

ព្រះគម្ពីរកិច្ចការ ៣:៨ ចែងថា: **គាត់ក៏ស្ទុះឈរឡើងដើរទៅមក ហើយចូលទៅក្នុងព្រះវិហារជាមួយនឹងអ្នកទាំង២នោះ ទាំងដើរ ទាំងលោត ទាំងសរសើរដល់ព្រះផង ។**

ព្រះគម្ពីរទំនុកដំកើង ១៤៩:៣ ចែងថា: **គួរឱ្យគេសរសើរព្រះនាមទ្រង់ ដោយលោតកញ្ឆេង គួរឱ្យគេច្រៀងសរសើរទ្រង់ ដោយក្រាប់ និងស៊ុង ។**

## គំរូនៃការលោតរាំនៅក្នុងព្រះគម្ពីរសញ្ញាចាស់

### នៅក្នុងពិធីបុណ្យ

ពួកកូនចៅអ៊ីស្រាអែលបានលោតរាំនៅក្នុងពិធី នៃការសង្គ្រោះ និងការប្រោសលោះ គឺនៅពេលដែលពួកគេត្រូវបានរំដោះចេញពីជនជាតិអេស៊ីព្ទ ។

ព្រះគម្ពីរនិក្ខមនំ ១៥:២០ ចែងថា: **ឯហោរាម៉ារាម ជាបងស្រីរបស់អើរ៉ុន នាងក៏យកក្រាប់មកនៅដៃ ហើយបណ្តាស្ត្រីទាំងអស់គ្នា ក៏ទៅតាមទាំងបន្ទរក្រាប់ ហើយលោតកញ្ឆែងកញ្ឆោត់ផង ។**

ពួកគេមានសេចក្តីអំណរអរសប្បាយ គឺនៅពេលដែលហឹបនៃសេចក្តីសញ្ញាត្រូវបានរៀបចំឡើងវិញ ។

ព្រះគម្ពីរ២សាំយូអែល ៦:១៤ ចែងថា: **ដាវីឌក៏លោតកញ្ឆែងអស់ពីកំឡាំងទ្រង់នៅចំពោះព្រះយេហូវ៉ា ទ្រង់ពាក់អេផូឌធ្វើពីសំពត់ខ្លូតទេស ។**

### ការរាំដោយនូវវិញ្ញាណ

ការលោតរាំដោយនូវវិញ្ញាណ គឺជាការធ្វើទៅដោយឯង១ ជាមុនដំបូងបង្អស់ ជាការមិនស្មុកស្មាញ តាមរចនាបថ និងអាចត្រូវបានគេចង្អុលបង្ហាញដោយការលោតកញ្ឆែង ការលោតបង្វិល ការលោតផ្លោះ និងការលោតចុះឡើង ។ ជួនកាលវាត្រូវបានគេបន្ទរតាមភ្លេង ដែលចេញពីឧបករណ៍ភ្លេង និងដោយការបន្ទរតាមការច្រៀងចម្រៀងជាដើម ។

ព្រះគម្ពីរទំនុកដំកើង ១៤៩:៣ ចែងថា: **គួរឱ្យគេសរសើរព្រះនាមទ្រង់ ដោយលោតកញ្ឆែង គួរឱ្យគេច្រៀងសរសើរទ្រង់ ដោយក្រាប់ និងស៊ុង ។**

➢ *តាមឯកត្តបុគ្គល ឬជាក្រុម*

ស្តេចដាវីឌបានលោតរាំនៅចំពោះព្រះយេហូវ៉ា ។

នាងម៉ារាម និងពួកស្ត្រីទាំងអស់បានលោតរាំ ។

ការលោតរាំដោយនូវវិញ្ញាណ គឺមិនមែនជាការលោតរាំដោយមានសមាជិកដែលមានភេទផ្ទុយគ្នានោះទេ ។

➢ *នាងម៉ារាម និងពួកស្ត្រីទាំងអស់បានលោតរាំ*

➢ *ការលោតរាំទាំងចាស់ទាំងក្មេង*

ព្រះគម្ពីរយេរេមា ៣១:១៣ក ចែងថា: **គ្រានោះ នាងក្រមុំនឹងមានចិត្តរីករាយក្នុងការលោតកញ្ឆេង ព្រមទាំងពួកកំឡោះៗ និងពួកចាស់ៗទាំងអស់គ្នាផង... ។**

➢ *គ្មានការកំណត់អាយុ*

គ្មានការកំណត់អាយុចំពោះការលោតរាំដោយនូវវិញ្ញាណនោះទេ គឺជាការចំណាំនូវពាក្យថា "ការលោតរាំទាំងចាស់ទាំងក្មេង" ។

## ការច្រៀង និងការលោតរាំ

ការច្រៀង និងការលោតរាំ គឺតែងតែទៅដោយទន្ទឹមនឹងគ្នា ។

ព្រះគម្ពីរ១សាំយូអែល ២៩:៥ ចែងថា: **តើនេះមិនមែនជាវីឌទេឬអី ជាអ្នកដែលគេបានច្រៀងឆ្លើយគ្នាពីដំណើររាំក្នុងរបាំគេថា សូលបានសំឡាប់ទាំងពាន់ តែដាវីឌទាំងម៉ឺន ។**

## ពេលវេលាដែលត្រូវលោតរាំ

មានពេលវេលាត្រឹមត្រូវ ដែលត្រូវលោតរាំ ។

ព្រះគម្ពីរសាស្តា ៣:៤ ចែងថា: **មានពេលយំ និងពេលសើច មានពេលសំរាប់សោយសោក និងពេលសំរាប់លោតកញ្ឆេង ។**

## ការលោតរាំនៅចំពោះព្រះអម្ចាស់

ការចង្អុលបង្ហាញពីការសរសើរតម្កើងនេះ គឺជាការស្តាប់បង្គាប់នូវព្រះបន្ទូលរបស់ព្រះដែលបានបើកសម្តែងហើយ ដែលយើងរាល់គ្នាត្រូវតែសរសើរតម្កើងដល់ទ្រង់ ដោយការលោតរាំនោះ ។ គឺជាសកម្មភាព ដែលជាបំណងចិត្តរបស់យើង សូម្បីតែយើងមានអារម្មណ៍ថាឆោតល្ងង់ ដោយការធ្វើយ៉ាងដូច្នោះ នោះគឺដោយសារតែយើងស្តាប់បង្គាប់ដល់ព្រះ ហើយ

បានរួមសហការណ៍ជាមួយនឹងអ្នកជឿដទៃទៀត នៅពេលដែលពួកគេបានលោតរាំនៅចំពោះព្រះអម្ចាស់ ។

**ការលោតរាំដោយព្រះវិញ្ញាណ**

ការលោតរាំដោយនូវវិញ្ញាណ គឺនៅពេលដែលរូបកាយទាំងមូលរបស់យើង បានក្រោមការដឹកនាំពេញលេញ របស់ព្រះវិញ្ញាណបរិសុទ្ធ ។ ពួកអ្នកជឿនៅក្នុងកំឡុងពេលនេះ គឺត្រូវបាន "បាត់បង់" ខាងឯវិញ្ញាណ ហើយក៏ត្រូវបានស្រូបទាញយកទៅ នូវអំណាចព្រះចេស្ដារបស់ទ្រង់ ដែលពួកគេបានប្រុងប្រយ័ត្នដោយខ្លួនឯងផ្ទាល់ ឬក៏ដោយអ្នកដទៃផ្សេងទៀតផងដែរ ។ វានឹងតែងតែបានស្ថិតនៅក្នុងពេលដ៏គ្រប់ល័ក្ខណ៍របស់ព្រះ ដូច្នេះគឺមិនមែនជាការដែលធ្វើឱ្យខូចចេញពីសេចក្ដីអំណរនោះទេ គឺធ្វើឱ្យបានល្អម ឱ្យស៊ីសង្វាក់គ្រប់គ្រាន់ និងឱ្យហូរទៅ ដោយមានចលនារបស់ព្រះនៅក្នុងពេលភ្លាមៗនោះ ។

**ការកែជាថ្មីឡើងវិញដែលបានទាយទុកមក**

ការកែជាថ្មីឡើងវិញចំពោះការលោតរាំ គឺជាការដែលបានទាយទុកមក ។

ព្រះគម្ពីរយេរេមា ៣១:៤,១៣ ចែងថា: **ឱព្រហ្មចារីនៃសាសន៍អ៊ីស្រាអែលអើយ អញនឹងសង់ឯងឡើងវិញ នោះឯងនឹងបានតាំងនៅ ឯងនឹងបានតាក់តែងដោយក្រាប់ជាថ្មីទៀត ព្រមទាំងចេញទៅ លោតកញ្ឆេងជាមួយនឹងពួកអ្នកដែលលេងសប្បាយ... គ្រានោះ នាងក្រមុំនឹងមានចិត្តរីករាយក្នុងការលោតកញ្ឆេង ព្រមទាំងពួកកំឡោះៗ និងពួកចាស់ៗទាំងអស់គ្នាផង ដ្បិតអញនឹងបំប្រែសេចក្ដីសោកសៅរបស់គេ ទៅជាសេចក្ដីអំណរវិញ ហើយកំសាន្តចិត្តគេ ព្រមទាំងឱ្យគេរីករាយចេញពីសេចក្ដីទុក្ខព្រួយរបស់គេ ។**

ប្រសិនបើយើងរាល់គ្នាជារាស្ត្រអ៊ីស្រាអែលខាងឯវិញ្ញាណ អញ្ចឹងការនេះគឺសម្រាប់យើរាល់គ្នានៅសម័យសព្វថ្ងៃនេះហើយ ។

## ការព្រមាន

### ការប្រយ័ត្នចំពោះការលោតរាំខាងរូបកាយ

ការលោតរាំនៃរាង្គកាយដែលជាផ្នែកជាធម្មជាតិ ក៏ត្រូវបានរាប់បញ្ចូលជាមួយនឹងការត្រឡប់មកប្រព្រឹត្តការបែបអាក្រក់ឡើងវិញផងដែរ ដូចជាការថ្វាយបង្គំរូបព្រះ ការកំផិត និងការប្រព្រឹត្តតាមផ្លូវលោកិយជាដើម ។ សាតាំងមានការក្លែងបន្លំ សម្រាប់ការគ្រប់បែបយ៉ាង ។ ការក្លែងបន្លំ គឺជាការធ្វើឱ្យបានដូចសុទ្ធសាត ដូចជារបស់ដើមសុទ្ធអញ្ចឹង ។

### មិនមែនសម្រាប់តែការបង្ហាញនោះទេ

គោលបំណងនៃការលោតរាំសរសើរតម្កើងដល់ព្រះ គឺមិនធ្លាប់ដែលបានត្រូវគេតាំងចិត្តធ្វើសម្រាប់ "បង្ហាញ" ឬសម្រាប់ការសម្តែង ដែលត្រូវតែគួសបញ្ជាក់ពីការប្រុងប្រយ័ត្នរបស់មនុស្ស ចំពោះអ្នកលោតរាំនោះឡើយ ។ ជំនួសឱ្យនូវការនេះ ការលោតរាំគឺត្រូវតែជាការទទួលខុសត្រូវ និងជាការតាំងចិត្ត នូវការចង្អុលបង្ហាញពីការសរសើរតម្កើងដល់ព្រះខាងផ្នែករូបកាយ ដែលជាការចូលរួមជាមួយនឹងពួកបងប្អូនដែលជាអ្នកជឿទាំងអស់ ។

វាត្រូវតែបានជាចំណែកពិសេស១ ទាំងបុរស ទាំងស្ត្រី ទាំងក្មេងទាំងចាស់ ។

ព្រះគម្ពីរយេរេមា ៣១:១៣ក ចែងថា: **គ្រានោះ នាងក្រមុំនឹងមានចិត្តរីករាយក្នុងការលោតកញ្ឆេង ព្រមទាំងពួកកំឡោះ១ និងពួកចាស់១ទាំងអស់គ្នាផង... ។**

ពួកអ្នកជឿទាំងឡាយ មិនត្រូវបញ្ឈប់នូវការសរសើរតម្កើង និងត្រឡប់មកជា "អ្នកស្រាវជ្រាវ" ឬឱ្យបានត្រឡប់មកជាអ្នកបំបែកចេញដោយមធ្យោបាយណាមួយ ដែលមកពីការសរសើរតម្កើងយ៉ាងខ្លាំងក្លាកំឡុងពេលនៃ "ការលោតរាំខាងវិញ្ញាណ" ឬជា "ការលោតរាំនៅចំពោះព្រះអម្ចាស់" នោះឡើយ ។ មិនត្រូវបានទទួលការអនុញ្ញាតឱ្យបានត្រឡប់

មកជា "ការបង្កើតឡើងពីមនុស្សធម្មតា" នោះឡើយ គឺទាំងក្នុងការលោតរាំនៅកន្លែងដែលបានជ្រើសរើសទុកយ៉ាងច្បាស់លាស់ ចំនួនពីរបីកន្លែង និងការសម្តែងសម្រាប់ជាការរំជើបរំជួលចំពោះអ្នកដទៃទៀត ។

នៅពេលដែលលោតរាំ គឺត្រូវតែជាការសម្តែងដោយសេរី ចំពោះការសរសើរតម្កើង ដែលបានចូលរួមជាមនុស្សដ៏ពេញលេញ ខាងឯវិញ្ញាណ ទាំងព្រលឹង និងរូបកាយ ដោយមានការប្រុងប្រយ័ត្នយ៉ាងប្រត្យក្ស ។ សម្លៀកបំពាក់ និងសកម្មភាពរបស់យើង គឺត្រូវតែបានជាអ្នកថ្វាយសិរីល្អដល់ព្រះអម្ចាស់ជាប់ជានិច្ច ហើយមិនត្រូវបានទទួលការហៅមក ដោយខ្លួនឯងនោះឡើយ ។

**ការចូលមកក្នុង**

ចំពោះពួកអ្នកជឿ ដើម្បីបដិសេធនូវការចូលមកក្នុងការលោតរាំសរសើរតម្កើង នៅចំពោះព្រះអម្ចាស់ គឺនៅពេលដែលព្រះវិញ្ញាណបរិសុទ្ធកំពុងតែធ្វើចលនា ដោយនូវមធ្យោបាយ ដែលស្ថិតនៅក្នុងសកម្មភាពទាស់ទទឹងនៅចំពោះព្រះ ។ ដើម្បីឱ្យមានការដឹងខ្លួនដោយខ្លួនឯង ព្រមទាំងមានការកោតខ្លាច ចំពោះការបាត់បង់នូវការចេះគោរពខ្លួនឯងរបស់បុគ្គលណាម្នាក់ ដែលអាចមានការព្រួយចិត្ត ឬក៏មានការរំងាប់ នូវការបង្ហូរមកនៃព្រះវិញ្ញាណបរិសុទ្ធ ។

ការដ៏អស្ចារ្យបំផុតខ្លះៗ គឺជា "ការវាយទម្លុះយកបាន" ដែលបានកើតឡើង គឺជាចលនានៃព្រះវិញ្ញាណបរិសុទ្ធ ដែលបានយាងមកឯរូបកាយរបស់ពួកអ្នកជឿ គឺនៅពេលដែលម្នាក់ៗបានស្លាប់ខាងឯអាត្មានិយម និងធ្វើចលនាដោយការស្តាប់បង្គាប់ដល់ព្រះវិញ្ញាណបរិសុទ្ធ គឺគេបានធ្វើការដែលស្តេចដាវីឌបានធ្វើដែរ "ការលោតរាំនៅចំពោះព្រះអម្ចាស់ ដោយមានពេញនូវគ្រប់ទាំងឫទ្ធិតេជះរបស់ផងទ្រង់" ។

## សំណួររំឭកសារឡើងវិញ

១. ចូរឱ្យឈ្មោះបីយ៉ាងជាការចង្អុលបង្ហាញ នូវការសរសើរតម្កើង ដែលត្រូវបានគេបកប្រែថា ជាតិរិយាបថនៃការ ធានារ៉ាប់រង និងការគោរព ។

២. នៅក្នុងការបន្ថែមចំពោះរោងឧបោសថរបស់ស្តេចដាវីឌ តើការចង្អុលបង្ហាញនូវការថ្វាយបង្គំ គឺជាទំនាយ ចំពោះការកែពួកជំនុំសារជាថ្មីឡើងវិញឬ?

៣. តើការចង្អុលបង្ហាញនូវការសរសើរតម្កើង ខាងផ្នែករូបកាយនោះយ៉ាងដូចម្តេចដែរ ដែលលោកអ្នកមាន អារម្មណ៍មិនសុខស្រួលស្ទើរតែគ្រប់ពេលជាមួយអ្នកផ្សេង? តើព្រះបន្ទូលរបស់ព្រះថែងមកដូចម្តេចដែរ អំពី ចំណុចពិសេសៗនោះ? តើលោកអ្នកមានបំណងនឹងសរសើរតម្កើងដល់ព្រះ ដោយមធ្យោបាយដូច្នេះបានឬទេ ប្រសិនបើទ្រង់សព្វព្រះហឫទ័យឱ្យលោកអ្នកធ្វើយ៉ាងដូច្នោះ?

# មេរៀនទី ៩

## ឧបស័គ្គចំពោះការសរសើរតម្កើង

ការគ្មានលទ្ធភាពដើម្បីចូលទៅសរសើរតម្កើង និងថ្វាយបង្គំ គឺជាឧបស័គ្គ ដែលមានបញ្ហាជាមូលដ្ឋានរវាងព្រះ និងយើង ។ វាជាការសំខាន់ដែលអ្នកជឿម្នាក់ៗ មានការស្វែងរកព្រះអង្គ រហូតដល់ពួកគេដឹងនូវអ្វីដែលជាបញ្ហារបស់ពួកគេ ឬក៏ជាបញ្ហាដែលមាន ហើយពួកគេនៅតែទាក់ទងជាមួយនឹងបញ្ហានោះ ។ ដូចគ្នាដែរ ឧបស័គ្គដែលនៅតែមាននៅក្នុងយើង គឺជាការរារាំងនៅចំពោះការសរសើរតម្កើងដល់ព្រះអម្ចាស់ គឺវាអាចទុកឱ្យយើងនៅសរសើរតម្កើង តែគ្មានចម្លើយក្នុងការអធិស្ឋាន ឬក៏មិនបានទទួលនូវការប្រោសឱ្យជាជាដើម ។

**ការអត់ទោសតែងតែត្រូវបានប្រទានឱ្យ**

"ខ្ញុំមិនបានចាកចេញទៅណាទេ!"

"ខ្ញុំសែនអាម៉ាសណាស់ ខ្ញុំមានអារម្មណ៍ថា ខ្ញុំដឹងខ្លួនពីភាពអាត្មានិយម!"

ទោះជាយ៉ាងណាក៏ដោយ ការសរសើរតម្កើង គឺជាព្រះរាជបញ្ញត្តិមកពីព្រះ ហើយគ្មានកំណត់នូវការអត់ទោសដែរ!

ព្រះគម្ពីរទំនុកដំកើង ១៥០:៦ ចែងថា: **គួរឱ្យជីវិតទាំងឡាយដែលមានដង្ហើម បានសរសើរដល់ព្រះយេហូវ៉ា ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។**

## ឧបស័គ្គចំពោះការសរសើរតម្កើងដែលយើងត្រូវទាក់ទងជាមួយព្រះ

**គឺជាអំពើបាប**

អំពើបាបគឺជាការបំបែកនូវការប្រកបទាក់ទង និងការប្រាស្រ័យទាក់ទងជាមួយនឹងព្រះ ។ អំពើបាបរារាំងយើងពីព្រះវត្តមានរបស់ព្រះ ។

ព្រះគម្ពីរទំនុកដំកើង ៦៦:១៨ ចែងថា: **បើប្រសិនជាខ្ញុំឃើញមានសេចក្ដីទុច្ចរិតនៅក្នុងចិត្ត នោះព្រះអម្ចាស់ទ្រង់មិនព្រមស្ដាប់ខ្ញុំទេ ។**

ព្រះគម្ពីរអេសាយ ៥៩:២ ចែងថា: **គឺជាអំពើទុច្ចរិតរបស់ឯងរាល់គ្នា ដែលបានខណ្ឌជាកណ្ដាលឯង ហើយនិងព្រះនៃឯងទេតើ ហើយអំពើបាបរបស់ឯងរាល់គ្នា បានបាំងព្រះភក្ត្រទ្រង់មិនឱ្យឯងឃើញ ដល់ម៉្លេះបានជាទ្រង់មិនព្រមស្ដាប់ទេ ។**

➡ ***ដំណោះស្រាយ***

ចម្លើយគឺត្រូវតែសារភាពបាប ឬនូវការធ្វើបាបរបស់យើង ព្រមទាំងទទួលនូវយកការអត់ទោសរបស់ព្រះអង្គ ។

ព្រះគម្ពីរ១យ៉ូហាន ១:៩ ចែងថា: **បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឱ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង ។**

**ការផ្ដន្ទាទោស**

ការផ្ដន្ទាទោសគឺត្រូវបានដាក់មកលើយើងដោយសាតាំង មិនមែនមកពីព្រះឡើយ ។

យើងបានទូលសូមដល់ព្រះម្ដង ដើម្បីឱ្យទ្រង់បានអត់ទោសបាបឱ្យយើង នោះយើងត្រូវតែអត់ទោសបាបឱ្យខ្លួនយើងដែរ ។ ការផ្ដន្ទាទោសគឺជាលទ្ធផលដែលមាននៅក្នុង:

- *ការទទួលស្គាល់នូវភាពគ្មានតម្លៃ ដូច្នេះយើងបានលំអៀងទៅរក "ការឱនក្បាលរបស់យើង" ចូលទៅក្នុងព្រះវត្តមាននៃព្រះ ។*
- *ការដឹងខ្លួនពីភាពគ្មានតម្លៃរបស់យើង ដែលយើងបានបំភ្លេចនូវសេចក្ដីមេត្តាករុណា និងព្រះគុណរបស់ព្រះ ។ យើងបានត្រឡប់ជាអ្នកដឹងខ្លួនពីអាត្មានិយម ជំនួសឱ្យការដឹងខ្លួនដែលមកពីព្រះ ។*

➡ ***ដំណោះស្រាយ***

ព្រះគម្ពីររ៉ូម ៨:១ ចែងថា: **ហេតុនោះ នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះគ្មានទោសសោះ ។**

- *ចូរដោះគំនិតអាត្មានិយម ហើយដាក់ការទាំងនោះថ្វាយដល់ព្រះយេស៊ូវ ។*
- *ពេលវេលាដែលយើងត្រូវបន្ថែម គឺជាការគិតដល់ព្រះយេស៊ូវ គឺយើងត្រូវសម្រេចចិត្តសរសើរតម្កើងដល់ទ្រង់បន្ថែមទៀត ។*

ព្រះគម្ពីរហេព្រើរ ១២:២ ចែងថា: **ទាំងរំពឹងមើលដល់ព្រះយេស៊ូវដ៏ជាមេផ្តើម ហើយជាមេសំរេចសេចក្តីជំនឿរបស់យើង ដែលទ្រង់បានរងទ្រាំនៅឈើឆ្កាង ទាំងមើលងាយចំពោះសេចក្តីអាមាស់ខ្មាសនោះ ឲ្យតែបានសេចក្តីអំណរដែលនៅចំពោះទ្រង់ រួចទ្រង់ក៏គង់ខាងស្តាំបល្ល័ង្កនៃព្រះ ។**

## ភាពលោកិយនិយម

ភាពលោកិយនិយមកំពុងតែមាននៅក្នុងចិត្ត និងគំនិតរបស់យើងបានដាក់ទៅលើការងាររបស់លោកិយនេះ ។

ការសម្រេចចិត្ត "ការគោរពខ្លួនឯង" ឬ "សុភាវធម៌" បន្ថែមលើការបំពេញការងារថ្វាយព្រះ នៅក្នុងការថ្វាយបង្គំ ។

➡ ***ដំណោះស្រាយ***

ព្រះគម្ពីរ១ពេត្រុស ៥:៧ ចែងថា: **ហើយចូរផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា ។**

ព្រះគម្ពីរភីលីព ៤:៨ ចែងថា: **មួយទៀត បងប្អូនអើយ ឯសេចក្តីណាដែលពិត សេចក្តីណាដែលគួររាប់អាន សេចក្តីណាដែលសុចរិត សេចក្តីណាដែលបរិសុទ្ធ សេចក្តីណាដែលគួរស្រឡាញ់ សេចក្តីណាដែលមានឈ្មោះល្អ បើមានសគុណណា ឬជាសេចក្តីសរសើរណា នោះចូរពិចារណាពីសេចក្តីទាំងនោះចុះ ។**

ព្រះគម្ពីរ១យ៉ូហាន ២:១៥ ចែងថា: **កុំឱ្យស្រឡាញ់លោកិយ ឬរបស់អ្វីដែលនៅក្នុងលោកិយនេះឱ្យសោះ បើអ្នកណាស្រឡាញ់លោកិយ អ្នកនោះគ្មានសេចក្តីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ ។**

ព្រះគម្ពីររ៉ូម ១២:២ ចែងថា: **កុំឱ្យ ត្រាប់តាមសម័យនេះឡើយ ចូរឱ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ដើម្បីនឹងអាចល មើលឱ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះ ដែលល្អ ស្រួលទទួល ហើយគ្រប់លក្ខណ៍ផង ។**

**សេចក្តីព្រងើយកន្តើយ**

ការខ្វះភាពកក់ក្តៅ ឬការព្រងើយកន្តើយចំពោះព្រះអម្ចាស់ គឺតែងតែបង្អាក់មនុស្សម្នាក់ៗ ពីការចូលទៅក្នុងការសរសើរតម្កើង និងការថ្វាយបង្គំ ។

ព្រះគម្ពីរវិវរណៈ ២:៤ ចែងថា: **តែអញប្រកាន់សេចក្តីនេះនឹងឯង គឺថា ឯងបានបោះបង់ចោលសេចក្តីស្រឡាញ់ដើមចេញ ។**

➥ ***ដំណោះស្រាយ***

ចូរធ្វើការសម្រេចចិត្តវិលបែរមករកព្រះ ដោយការប្រែចិត្តយ៉ាងពេញលេញ ហើយបន្ទាប់មក ធ្វើសកម្មភាពដោយការស្តាប់បង្គាប់ ហើយចាប់ផ្តើមសរសើរតម្កើងដល់ទ្រង់ ។

ព្រះគម្ពីរម៉ាឡាគី ៣:៧ក ចែងថា: **ឯងរាល់គ្នាបានបោះបង់ចោលសេចក្តីបញ្ញត្តរបស់អញ ចាប់តាំងពីគ្រាពួកឰយុកោរៀងមក ឥតកាន់តាមឡើយ ព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់បង្គាប់ថា ចូរវិលមកឯអញវិញចុះ នោះអញនឹងត្រឡប់មកឯឯងដែរ... ។**

**ការបះបោរ**

ការបះបោរចំពោះព្រះ ចំពោះឪពុកម្តាយ ឬចំពោះសិទ្ធិអំណាចដែលព្រះទ្រង់បានជ្រើសរើសនៅក្នុងពួកជំនុំ គឺជាឧបសគ្គដ៏ចម្បង ចំពោះការសរសើរតម្កើង ។

ព្រះគម្ពីរ១សាំយូអែល ១៥:២២,២៣ ចែងថា: **សាំយូអែលទូលឆ្លើយថា តើព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យនឹងដង្វាយដុត ហើយនិងយញ្ញបូជា ឱ្យស្មើនឹងការស្តាប់តាមទ្រង់ឬអី មើល ដែលស្តាប់បង្គាប់ នោះវិសេសលើសជាងយញ្ញបូជា ហើយដែលផ្ទៀងត្រចៀក នោះក៏វិសេសជាងខ្លាញ់នៃចៀមឈ្មោលទៅទៀត ឯសេចក្តីរឹងទទឹង នោះក៏ជាបាបដូចជាការមន្តវិជ្ជាដែរ ហើយសេចក្តីចចេសសោត ក៏ដូចជាអំពើអាក្រក់ណាមួយ ហើយនិងការថ្វាយបង្គំដល់រូបព្រះដែរ ឥឡូវនេះ ព្រះយេហូវ៉ាបានបោះបង់ចោលទ្រង់ មិនឱ្យធ្វើជាស្តេចទៀត ដោយព្រោះទ្រង់បានបោះបង់ចោល លែងតាមព្រះបន្ទូលនៃព្រះយេហូវ៉ាហើយ ។**

➡ ***ដំណោះស្រាយ***

ចូរចុះចូលចំពោះសិទ្ធអំណាច ហើយប្រែចិត្តចេញពីការបះបោររបស់លោកអ្នកនោះ ។

ព្រះគម្ពីរហេព្រើរ ១៣:១៧ ចែងថា: **ចូរស្តាប់តាម ហើយចុះចូលនឹងពួកអ្នកដែលនាំមុខអ្នករាល់គ្នាចុះ ដើម្បីឱ្យអ្នកទាំងនោះបានថែរក្សាព្រលឹងអ្នករាល់គ្នាដោយអំណរ មិនមែនដោយស្រែកថ្ងូរទេ ដ្បិតបើត្រូវស្រែកថ្ងូរ នោះបង់ប្រយោជន៍ដល់អ្នករាល់គ្នាហើយ ពីព្រោះអ្នកទាំងនោះថែរក្សា ហាក់ដូចជានឹងត្រូវរាប់រៀបទូលដល់ទ្រង់វិញ ។**

**ការមិនលើកទឹកចិត្ត**

មានមនុស្សជាច្រើននាំមកនូវបញ្ហារបស់ពួកគេ ចូលទៅក្នុងពួកជំនុំ ហើយបង្កបញ្ហានោះជាមួយពួកគេ ។ វាជាការសំខាន់ដែលយើង ប្រុងប្រៀបរៀបចំនូវចិត្តរបស់យើង ដើម្បីសរសើរតម្កើងដល់ព្រះ មុនពេលដែលយើងចូលមកដល់ ។

ព្រះគម្ពីរ២កូរិនថូស ៤:៨,៩ ចែងថា: **ដែលយើងខ្ញុំត្រូវគេសង្កត់សង្កិនគ្រប់ជំពូក តែមិនទ័លផ្លូវឡើយ មានសេចក្តីវិលវល់ តែមិនទ័ល**

**គំនិតទេ មានគេធ្វើទុក្ខ តែមិនមែនត្រូវចោលនៅម្នាក់ឯងទេ ត្រូវគេវាយដួលស្តូក តែមិនស្លាប់ទេ ។**

➡ ***ដំណោះស្រាយ***

នៅពេលដែលយើងចាប់ផ្តើមស្តាប់បង្គាប់ ដោយការសរសើរតម្កើង និងការថ្វាយបង្គំដល់ព្រះ នោះគ្រប់ទាំងការបាក់ទឹកចិត្តទាំងអស់នឹងត្រូវចាកចេញពីចិត្តរបស់យើងរាល់គ្នាទៅ ។

ព្រះគម្ពីរអេសាយ ៥១:១១ ចែងថាៈ **ឯពួកអ្នកប្រោសលោះរបស់ព្រះយេហូវ៉ា គេនឹងវិលមកវិញ ហើយមកដល់ក្រុងស៊ីយ៉ូនដោយច្រៀងចំរៀង គេនឹងមានសេចក្តីអំណរដ៏នៅអស់កល្បជានិច្ចពាក់លើក្បាល គេនឹងទទួលបានសេចក្តីរីករាយ និងសេចក្តីអំណរ ឯសេចក្តីទុក្ខព្រួយនិងដំងូរ នោះនឹងខ្ចាត់បាត់ទៅ ។**

**សេចក្តីកំហឹង**

វាគ្មានលទ្ធភាពនឹងចូលមកឯព្រះ ក្នុងការសរសើរតម្កើង និងការថ្វាយបង្គំឡើយ ប្រសិនបើយើងទប់ទល់នូវសេចក្តីកំហឹង ដែលមាននៅក្នុងចិត្តរបស់យើងបាន ទៅដល់អ្នកដទៃទៀត ដល់យើងផ្ទាល់ ឬក៏ដល់ព្រះ ។

ព្រះគម្ពីរយ៉ាកុប ១:១៩,២០ ចែងថាៈ **ដូច្នេះ បងប្អូនស្ងួនភ្ងាអើយ ចូរឱ្យគ្រប់គ្នាបានឆាប់នឹងស្តាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹងដែរ ដ្បិតសេចក្តីកំហឹងរបស់មនុស្ស មិនដែលសំរេចតាមសេចក្តីសុចរិតរបស់ព្រះទេ ។**

➡ ***ដំណោះស្រាយ***

ការអត់ទោសដល់អស់អ្នក ដែលបានធ្វើខុសមកដល់លោកអ្នក និងបដិសេធ មិនអនុញ្ញាតឱ្យសេចក្តីកំហឹងនោះ មកតាំងនៅក្នុងចិត្តរបស់លោកអ្នកបាន ។

ព្រះគម្ពីរអេភេសូរ ៤:៣១,៣២ ចែងថាៈ **ចូរខំដកគ្រប់ទាំងសេចក្តីជូរល្វីង ក្តៅក្រហាយ កំហឹង ឡូឡា ជេរប្រមាថ និងគ្រប់ទាំង**

**សេចក្តីអាក្រក់ ចេញពីពួកអ្នករាល់គ្នាទៅ ចូរមានចិត្តសប្បុរសនឹងគ្នាទៅវិញទៅមក ព្រមទាំងមានចិត្តទន់សន្តោស ហើយអត់ទោសគ្នា ដូចជាព្រះទ្រង់បានអត់ទោសឱ្យអ្នករាល់គ្នា ដោយព្រះគ្រីស្ទដែរ ។**

## ការព្រួយបារម្ភ

ការព្រួយបារម្ភ គឺជាការចង្អុលបង្ហាញនូវការសង្ស័យ និងភាពមិនជឿ ដែលផ្ទុយទៅនឹងសេចក្តីជំនឿ ។ វាគ្មានលទ្ធភាពនឹងចូលមកក្នុងការសរសើរតម្កើង និងការថ្វាយបង្គំបានឡើយ ប្រសិនបើគំនិតរបស់យើងរាល់គ្នាពេញទៅដោយការព្រួយបារម្ភនោះ ។

ព្រះគម្ពីរយ៉ូហាន ១៤:២៧ ចែងថាៈ **ខ្ញុំទុកសេចក្តីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឱ្យសេចក្តីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឱ្យនោះ មិនមែនដូចជាលោកិយឱ្យទេ កុំឱ្យចិត្តអ្នករាល់គ្នាថប់បារម្ភឬភ័យឡើយ ។**

➡ ***ដំណោះស្រាយ***

នៅពេលដែលយើងផ្តោតភ្នែករបស់យើងទៅឯព្រះយេស៊ូវ និងសេចក្តីសន្យានៃព្រះបន្ទូលរបស់ព្រះអង្គ ជំនួសឱ្យនូវការព្រួយបារម្ភនោះ ហើយចាប់ផ្តើមអរព្រះគុណដល់ទ្រង់ សម្រាប់ការអ្វីដែលទ្រង់បានធ្វើ និងអស់អ្នកដែលទ្រង់បានគង់ជាមួយ នោះចិត្តរបស់យើងរាល់គ្នានឹងត្រូវបានជន់ជោរឡើង ដោយនូវសេចក្តីសុខសាន្ត ហើយការសរសើរតម្កើងក៏នឹងចាប់ផ្តើមហូរចេញពីចិត្តរបស់យើងទៅដល់ព្រះ ។

ព្រះគម្ពីរភីលីព ៤:៦,៧ ចែងថាៈ **កុំឱ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះ ឱ្យជ្រាបពីសេចក្តីសំណូមរបស់អ្នករាល់គ្នាក្នុងគ្រប់ការទាំងអស់ ដោយសេចក្តីអធិស្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង យ៉ាងនោះសេចក្តីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិតនឹងជួយការពារចិត្ត ហើយនិងគំនិតរបស់អ្នករាល់គ្នាក្នុងព្រះគ្រីស្ទយេស៊ូវ ។**

**ការក្រៀមក្រំចិត្ត**

ដើម្បីឱ្យយើងរាល់គ្នាបានត្រឡប់ទៅជាអ្នកមានជ័យជម្នះ ចំពោះវិញ្ញាណនៃការក្រៀមក្រំចិត្ត គឺដោយសារតែព្រឹត្តិការណ៍របស់យើង ត្រូវបញ្ឈប់បង្អួរនូវការសរសើរតម្កើង ដែលមាននៅក្នុងជីវិតរបស់យើង ។

ព្រះគម្ពីរ១ពេត្រុស ៤:១២,១៣ ចែងថា: **ឯពួកប្រុសៗ នោះក៏ត្រូវនៅជាមួយនឹងប្រពន្ធដោយប្រាជ្ញាដែរ ដូចនឹងគ្រឿងភាជនៈដែលខ្សោយជាង គឺជាមនុស្សស្រី ព្រមទាំងរាប់អាននាង ទុកដូចជាអ្នកគ្រងព្រះគុណនៃជីវិត ទុកជាមរដកជាមួយគ្នា ដើម្បីកុំឱ្យមានអ្វីបង្អាក់ដល់សេចក្តីអធិស្ឋានរបស់អ្នករាល់គ្នាឡើយ ។**

➥ ***ដំណោះស្រាយ***

គឺជាដង្វាយនៃការសរសើរ ដែលយើងរាល់គ្នាត្រូវតែចាប់ផ្តើមដោយមានសេចក្តីអំណរអរសប្បាយ ។ គឺជាសកម្មភាពនៃការស្តាប់បង្គាប់ដល់ព្រះ ដែលយើងរាល់គ្នាត្រូវតែស្លៀកពាក់នូវសម្លៀកបំពាក់ នៃការសរសើរតម្កើងរបស់យើង ។

ព្រះគម្ពីរអេសាយ ៦១:៣ ចែងថា: **នឹងចែកឱ្យដល់ពួកអ្នកដែលសោយសោកនៅក្រុងស៊ីយ៉ូនបានភួងលំអជំនួសផេះ ហើយប្រេងនៃសេចក្តីអំណរជំនួសសេចក្តីសោកសៅ ព្រមទាំងអាវពាក់នៃសេចក្តីសរសើរជំនួសទុក្ខធ្ងន់ដែលគ្របសង្កត់ ដើម្បីឱ្យគេបានហៅថា ជាដើមឈើនៃសេចក្តីសុចរិត គឺជាដើមដែលព្រះយេហូវ៉ាបានដាំ មានប្រយោជន៍ឱ្យទ្រង់បានថ្កើងឡើង ។**

**គំនិតខុសឆ្គងចំពោះព្រះវរបិតា**

មានមនុស្សជាច្រើនបានទទួលអារម្មណ៍ ជាអវិជ្ជមានដំពីព្រះ ។ ពួកគេមានអារម្មណ៍ថា ព្រះទ្រង់តែងតែជំនុំជម្រះដល់ពួកគេជានិច្ច ។ រីឯអ្នកដទៃទៀតទទួលអារម្មណ៍ថា ព្រះទ្រង់មិនសព្វព្រះហឫទ័យចង់ឱ្យមនុស្សមានសេចក្តីអំណរដោយខ្លួនគាត់ ឬដោយខ្លួននាងនោះវិញ ។

➥ ***ដំណោះស្រាយ***

ចម្លើយគឺត្រូវតែទទួលនូវកម្រៃ "ដ៏ត្រឹមត្រូវ" គឺជាគំនិតរបស់ព្រះ ដែលទ្រង់បានចំណាយពេលវេលា នៅក្នុងព្រះបន្ទូលរបស់ទ្រង់ ។

ព្រះគម្ពីរយ៉ូហាន ៣:១៦ ចែងថា: **ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឱ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ ។**

ព្រះគម្ពីររ៉ូម ៨:៣១,៣២,៣៨,៣៩ ចែងថា: **ដូច្នេះ យើងនឹងថ្លែងប្រាប់ពីសេចក្តីទាំងនេះថាដូចម្តេច បើសិនជាព្រះកាន់ខាងយើង តើអ្នកណាអាចទាស់នឹងយើងបាន ឯព្រះអង្គដែលមិនបានសំចៃទុកនូវព្រះរាជបុត្រាទ្រង់បង្កើត គឺបានបញ្ជូនទ្រង់ទៅជំនួសយើងរាល់គ្នា នោះតើមានទំនងអ្វី ឱ្យទ្រង់មិនប្រទានគ្រប់ទាំងអស់មកយើង ជាមួយនឹងព្រះរាជបុត្រាទ្រង់នោះផង... ដ្បិតខ្ញុំជឿជាក់ថាទោះស្លាប់ឬរស់ ពួកទេវតា ឬអំណាចអ្វីការអ្វីនៅជាន់នេះ ឬទៅមុខ ឬឥទ្ធិឫទ្ធិអ្វី ទីមានកំពស់ ទីជំរៅ ឬរបស់អ្វីដែលកើតមកឯទៀតក្តី នោះពុំអាចនឹងពង្រាត់យើង ចេញពីសេចក្តីស្រឡាញ់របស់ព្រះ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នាទៅបានឡើយ ។**

**ច្បាប់ប្រពៃណីយ៍របស់សាសនា**

សាសនាគឺជាការជិះជាន់សង្កត់សង្កិន ប៉ុន្តែក៏មានការបញ្ឆេញ នូវការប្រោសលោះដែរ ។

ព្រះគម្ពីរម៉ាថាយ ១៥:៦ខ ចែងថា: ...**អ្នករាល់គ្នាលើកបញ្ញត្តិនៃព្រះចោលហើយ ដោយសារទំនៀមទំលាប់ពីបុរាណរបស់អ្នករាល់គ្នា ។**

➥ ***ដំណោះស្រាយ***

ចម្លើយគឺត្រូវតែមានការប្រុងប្រយ័ត្ន នូវសេចក្តីរាយការណ៍ ពីប្រពៃណីយ៍របស់យើង ទៅចំពោះព្រះបន្ទូលរបស់ព្រះ ព្រមទាំងអនុញ្ញាតឱ្យព្រះវិញ្ញាណបរិសុទ្ធបង្ហាញយើងនូវផ្លូវដ៏ត្រឹមត្រូវផងដែរ ។

**សេចក្តីអំនួត**

សេចក្តីអំនួតគឺត្រូវបានគេខ្វល់ខ្វាយកម្រិតខ្ពស់ ដោយមានរូបភាពជាអាត្មានិយមរបស់យើង ចំពោះចំណងចង់បានតែល្អដែលគេគិតទៅដល់នោះ ។ សេចក្តីអំនួតគឺបានដាក់មនុស្សទៅក្នុងអាត្មានិយម គឺគេចង់អង្គុយនៅលើបល្ល័ង្កជំនួសព្រះ ។ ការសម្រេចចិត្តរបស់ពួកគេ គឺចង់សរសើរតម្កើងដល់មនុស្ស ដែលផ្ទុយពីដង្វាយនៃការសរសើរតម្កើងដល់ព្រះ ។

ព្រះយេស៊ូវទ្រង់បានពណ៌នាពីពួកអ្នកដឹកនាំសាសនា ដែលមានសេចក្តីអំនួត នៅក្នុងពេលរបស់ទ្រង់ ។

ព្រះគម្ពីរម៉ាថាយ ២៣:១,២,៥-៧ ចែងថា: **គ្រានោះ ព្រះយេស៊ូវទ្រង់មានបន្ទូលនឹងហ្វូងមនុស្ស ហើយនិងពួកសិស្សទ្រង់ថា ពួកអាចារ្យនិងពួកផារីស៊ី គេបានតាំងខ្លួនគេ អង្គុយនៅទីបង្រៀនរបស់លោកម៉ូសេ... គ្រប់ទាំងការដែលគេធ្វើទាំងប៉ុន្មាន នោះសុទ្ធតែធ្វើឱ្យតែមនុស្សមើលឃើញទេ គឺគេធ្វើស្លាកធំៗកត់ក្រិត្យវិន័យ និងរំយោលអាវគេឱ្យវែងៗ គេគាប់ចិត្តនឹងកន្លែងលេខ១ក្នុងការស៊ីលៀង និងកន្លែងដែលមុខគេក្នុងសាលាប្រជុំ ព្រមទាំងគាប់ចិត្តឱ្យមនុស្ស គំនាប់ខ្លួននៅទីផ្សារ ហើយឱ្យគេហៅខ្លួនថា លោកគ្រូៗផង ។**

➥ ***ដំណោះស្រាយ***

ចំពោះដំណោះស្រាយ គឺត្រូវតែធ្វើការបន្ទាបខ្លួនដោយខ្លួនលោកអ្នកផ្ទាល់ ។

ព្រះគម្ពីរម៉ាថាយ ២៣:១១,១២ ចែងថា: **តែអ្នកណាដែលធំជាងគេក្នុងពួកអ្នករាល់គ្នា នោះត្រូវធ្វើជាអ្នកបំរើដល់អ្នករាល់គ្នាវិញ អ្នក**

**ណាដែលដំកើងខ្លួន នោះនឹងត្រូវបន្ទាបចុះវិញ ហើយអ្នកណាដែលបន្ទាបខ្លួន នោះនឹងបានដំកើងឡើង ។**

ព្រះគម្ពីររ៉ូម ១២:៣ ចែងថា: **ដ្បិតខ្ញុំនិយាយនឹងមនុស្សទាំងអស់ក្នុងពួកអ្នករាល់គ្នា ដោយព្រះគុណដែលទ្រង់បានផ្តល់មកខ្ញុំថា ចូរគិតបែបឱ្យមានគំនិតនឹងធឹង តាមខ្នាតនៃសេចក្តីជំនឿ ដែលព្រះបានចែកមកអ្នករាល់គ្នានិមួយៗ កុំឱ្យមានគំនិតខ្ពស់លើសជាងគំនិត ដែលគួរគប្បីឱ្យគិតនោះឡើយ ។**

**ការកោតខ្លាចដល់មនុស្ស**

ការកោតខ្លាចចំពោះអ្វី ដែលមនុស្សដទៃទៀតគិតដល់យើងថា ជាអ្នកជាប់ចំណង និងជាអ្នកដែលបិទព្រះវិញ្ញាណបរិសុទ្ធ ពីសកម្មភាពដឹកនាំ និងពីអត្តចរិតរបស់យើង ។ ការកោតខ្លាចដល់មនុស្ស គឺជាលទ្ធផលដែលធ្វើឱ្យមានការព្រួយបារម្ភ និងការថប់បារម្ភ ព្រមទាំងចាប់យកប្រស្រីភ្នែករបស់យើងចេញពីព្រះអម្ចាស់ ដែលទ្រង់ជាមួយអង្គដែលយើងត្រូវតែមករកទ្រង់នោះឯង ។

ការកោតខ្លាចចំពោះប្រភេទខ្លះៗ ដែលផ្ទុយនឹងសេចក្តីជំនឿ ។

ព្រះគម្ពីរសុភាសិត ២៩:២៥ ចែងថា: **ការដែលខ្លាចចំពោះមនុស្ស នោះនាំឱ្យជាប់អន្ទាក់ តែអ្នកណាដែលទុកចិត្តដល់ព្រះយេហូវ៉ាពិត នោះនឹងបានសុខវិញ ។**

ព្រះគម្ពីរសុភាសិត ៩:១០ ចែងថា: **សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ាជាដើមចមនៃប្រាជ្ញា ហើយការដែលស្គាល់ដល់ ព្រះដ៏បរិសុទ្ធនោះគឺជាយោបល់ ។**

➡ ***ដំណោះស្រាយ***

នៅពេលដែលយើងដាក់ព្រះ ដ៏មានពេញដោយសេចក្តីសុចរិតសន្តិភាពនៅក្នុងជីវិតរបស់យើង គឺនៅពេលដែលយើងចាប់ផ្តើមស្គាល់ទ្រង់

ថាទ្រង់ជានរណា នោះសេចក្តីភ័យខ្លាចចំពោះអ្នកដទៃទៀតនឹងត្រូវវិនាសបាត់ទៅ ។

### ការរារាំងរបស់សាតាំង

សាតាំងស្អប់ដល់ព្រះ ដូច្នេះវាក៏ស្អប់ដល់ការសរសើរតម្កើង ថ្វាយដល់ព្រះដែរ ។ វាធ្វើការសម្រេចចិត្តកំចាត់ដល់អស់អ្នក ដែលសរសើរតម្កើងដល់ព្រះអង្គ ។ ប្រសិនបើលោកអ្នកនៅតែសរសើរតម្កើងដល់ព្រះ នោះសាតាំងនឹងមិនអាចនៅជុំវិញយើងបានឡើយ!

➥ ***ដំណោះស្រាយ***

ដំណោះស្រាយសម្រាប់ការរារាំងដ៏ធ្ងន់ធ្ងរ គឺជាការរំដោះចេញពីចំណងនៃវិញ្ញាណអាក្រក់ ។

ព្រះគម្ពីរម៉ាកុស ១៦:១៧ក ចែងថា: **ទីសំគាល់ទាំងនេះនឹងជាប់តាមអស់អ្នកដែលជឿ គឺថា គេនឹងដេញអារក្សដោយនូវឈ្មោះខ្ញុំ... ។**

ព្រះគម្ពីរយ៉ាកុប ៤:៧ ចែងថា: **ដូច្នេះ ត្រូវចុះចូលចំពោះព្រះ ហើយតស៊ូនឹងអារក្សវិញចុះ នោះវានឹងរត់ចេញពីអ្នករាល់គ្នាទៅ ។**

### ភាពល្ងង់ខ្លៅ

នៅក្នុងតំបន់ជាច្រើន គឺជាការសំខាន់សម្រាប់ការសរសើរតម្កើង និងការថ្វាយបង្គំ នៅក្នុងជីវិតរបស់ពួកអ្នកជឿ ដែលបានទទួលការបាត់បង់ទៅនោះ ។

➥ ***ដំណោះស្រាយ***

ដំណោះស្រាយចំពោះការនេះ គឺជាការសិក្សាពីអ្វីដែលព្រះទ្រង់សរសេរចែងទុកនៅលើប្រធានបទនេះ ។

ព្រះគម្ពីរហូសេ ៤:៦ ចែងថា: **រាស្ត្រអញ គេត្រូវបំផ្លាញទៅដោយខ្វះខាតដំរិះ ដូច្នេះ ដោយព្រោះឯងមិនព្រមទទួលដំរិះ បានជាអញក៏នឹងបោះបង់ចោលឯង មិនឲ្យធ្វើជាសង្ឃដល់អញទៀតដែរ ហើយដោយ**

**ហេតុដែលឯងបានភ្លេចច្បាប់របស់ព្រះនៃឯង នោះអញក៏នឹងភ្លេចកូនចៅរបស់ឯងដូចគ្នា ។**

**ការធ្វើសកម្មភាព! មិនមែនជាការប្រតិកម្មទេ!**

មានមនុស្សជាច្រើនបានធ្វើការប្រតិកម្ម នៅក្នុងមធ្យោបាយជាអវិជ្ជមាន ចំពោះអស់អ្នកដែលបានស្ថិតនៅ "ក្នុងសាច់ឈាម" គឺកំឡុងពេលសរសើរតម្កើង និងថ្វាយបង្គំនោះឯង ។ ពួកអ្នកជឿខ្លះក៏មានប្រតិកម្ម និងមានការស្ថិតនៅ "ការដោះខ្លួនចេញ" ដោយការហួសចិត្តដល់អ្នកដទៃទៀត ។ ការនេះគឺបានក្លាយជាឧបស័គ្គមួយ ចំពោះលទ្ធភាពក្នុងការចូលទៅដោយសេរីក្នុងគ្រប់ការ ដែលចង្អុលបង្ហាញពីការសរសើរតម្កើង និងការថ្វាយបង្គំនៅក្នុងព្រះគម្ពីរ ។

➡ ***ដំណោះស្រាយ***

ជំនួសឱ្យការប្រតិកម្មដល់អ្នកដទៃទៀត នោះយើងត្រូវការធ្វើសកម្មភាពតាមព្រះបន្ទូលរបស់ព្រះ ។ យើងត្រូវការទទួលខុសត្រូវ ដែលមានពេញដោយឆន្ទៈស្តាប់បង្គប់ ដល់ការបើកសម្តែងនៃព្រះបន្ទូលរបស់ផងព្រះ ។ យើងរាល់គ្នាគឺជាកូនរបស់ទ្រង់ យើងគួរគប្បីសម្តែងបង្ហាញដោយសេរី គឺត្រូវតែសរសើរតម្កើងយ៉ាងអស់ពីចិត្តរបស់យើង ហើយនិងថ្វាយបង្គំដល់ទ្រង់ជារៀងរហូតតទៅ ។

ការធ្វើប្រតិកម្មគឺត្រូវតែបានគេកំណត់ព្រំដែន និងគាំទ្រនូវបន្ទុកចំពោះប្រពៃណីយ៍សាសនា និងមានការភ័យខ្លាចចំពោះមនុស្ស ។ ការធ្វើសកម្មភាពគឺត្រូវតែបានធ្វើដោយសេរី ដើម្បីធ្វើចលនា និងបង្ហូរមកដោយនូវព្រះវិញ្ញាណនៃព្រះ ។

ព្រះយេស៊ូវទ្រង់បានយាងមក ដើម្បីដោះយើងឱ្យមានសេរី!

ព្រះគម្ពីរយ៉ូហាន ៨:៣២ ចែងថា: **អ្នករាល់គ្នានឹងស្គាល់សេចក្តីពិត ហើយសេចក្តីពិត នោះនឹងប្រោសឱ្យអ្នករាល់គ្នាបានរួច ។**

## ការបូកសរុប

ការគ្មានលទ្ធភាពសរសើរតម្កើង និងថ្វាយបង្គំគឺជាការបង្ហាញនូវមូលដ្ឋានបញ្ហា ដែលជាសេចក្តីត្រូវការ ដើម្បីឱ្យបានប្រកបទាក់ទងសារជាថ្មីឡើងវិញជាមួយនឹងព្រះ ។ ចូរស្វែងរកព្រះ រហូតដល់លោកអ្នកដឹងនូវបញ្ហា ហើយបន្ទាប់មក ចូរធ្វើការទាក់ទងឱ្យមានកិត្តិយសឡើងវិញ ។ ប្រសិនបើលោកអ្នកនៅតែមិនអាចចូលទៅក្នុងការសរសើរតម្កើងដល់ព្រះ ចូរសម្រេចចិត្តឯពួកជំនុំចាស់ទុំ និងស្វែងរកជំនួយពីគាត់ ឬពីនាងនោះ ។

## សំណួររំឭកសារឡើងវិញ

**១** ចូរដាក់ឈ្មោះនូវឧបស័គ្គមួយ ចំពោះការសរសើរតម្កើង ហើយដោះស្រាយនូវបញ្ហាដែលបានរកឃើញ នៅក្នុងព្រះបន្ទូលនៃព្រះនោះ ។

**២** ចូរដាក់ឈ្មោះនូវឧបស័គ្គមួយ ចំពោះការសរសើរតម្កើង ដែលលោកអ្នកបានទុកឱ្យនៅក្នុងជីវិតរបស់លោក អ្នកផ្ទាល់ ។ តើលោកអ្នកបានទទួលនូវជ័យជម្នះលើវាឬទេ ឬតើលោកអ្នកមានបំណងនឹងយកជ័យជម្នះ លើវាដោយវិធីណាដែរ?

**៣** តើលោកអ្នកត្រូវធ្វើដូចម្តេច ប្រសិនបើការខំប្រឹងប្រែងទាំងអស់របស់លោកអ្នក បានទទួលនូវការបរាជ័យ ដែលជាឧបស័គ្គដល់ការសរសើរតម្កើងនោះ?

# មេរៀនទី ១០
## *ការថ្វាយយញ្ញបូជានៃការសរសើរ*

### ការផ្សេងគ្នារវាងការសរសើរតម្កើង និងយញ្ញបូជានៃការសរសើរ

ព្រះគម្ពីរហេព្រើរ ១៣:១៥ ចែងថា: **ដូច្នេះ ត្រូវឱ្យយើងរាល់គ្នាថ្វាយពាក្យសរសើរ ដោយសារទ្រង់ទុកជាគ្រឿងបូជាដល់ព្រះជានិច្ច គឺជាផលនៃបបូរមាត់ ដែលថ្លែងប្រាប់ពីព្រះនាមទ្រង់ ។**

មានការផ្សេងគ្នារវាងការសរសើរតម្កើងដល់ព្រះ និងយញ្ញបូជានៃការសរសើរ ។

### ការសរសើរតម្កើង

ការសរសើរតម្កើងគឺហូរមកយ៉ាងងាយស្រួល នៅពេលដែលយើងនៅក្នុង "ការប្រកបទាក់ទងដ៏ត្រឹមត្រូវ" ជាមួយនឹងព្រះ ។ វាជាការហូរមកដោយឯង១ នៅពេលដែលយើងគិតដល់គ្រប់ការទាំងអស់ ដែលទ្រង់បានធ្វើសម្រាប់យើងរាល់គ្នាហើយ ។

### យញ្ញបូជានៃការសរសើរ

យញ្ញបូជានៃការសរសើរ គឺបានថ្វាយទៅដល់ព្រះ នៅពេលដែលការទាំងឡាយហាក់បីដូចជាមិនទាន់បានមានដំណើរការត្រឹមត្រូវល្អ ។ ការនោះគឺយ៉ាងដូច្នេះ:

- *ការសរសើរដែលបានថ្វាយដោយការបញ្ជើចិត្តខ្លួន គឺចំពោះការទាំងឡាយជាមធ្យោបាយ ដែលកំពុងតែដំណើរការទៅ*
- *ការសរសើរដែលបានថ្វាយដោយសេចក្តីជំនឿនិងការស្តាប់បង្គាប់*
- *ការសរសើរដែលបានថ្វាយដោយសារអស់អ្នកដែលព្រះគង់នៅ*

## យញ្ញបូជានៃការសរសើរ

### នៅតែបន្ត

យញ្ញបូជានៃការសរសើរ គឺជាការសរសើរតម្កើងជាបន្ត ។

ព្រះគម្ពីរទំនុកដំកើង ៣៤:១ ចែងថា: **ខ្ញុំនឹងលើកសរសើរដល់ព្រះយេហូវ៉ាគ្រប់ពេលវេលា សេចក្តីសរសើរពីទ្រង់នឹងនៅក្នុងមាត់ខ្ញុំជានិច្ច ។**

### ការស្តាប់ឮ

យញ្ញបូជានៃការសរសើរ គឺជាការសរសើរតម្កើងដែលអាចស្តាប់ឮបាន ។ មានពេលជាច្រើន ដែលស្តេចដាវីឌមានបន្ទូលថា **ការសរសើរតម្កើងរបស់ទ្រង់ គឺនៅតែបន្តក្នុងមាត់របស់ទូលបង្គំជានិច្ច ។**

### លោកសាវ័កប៉ុលនិងស៊ីឡាសធ្វើជាគំរូ

លោកសាវ័កប៉ុលនិងស៊ីឡាស នៅក្នុងគុក បានសរសើរតម្កើងដល់ព្រះ ដោយនូវចម្រៀង និងការអស្ចារ្យដែលបានជាប់តាម ។

ព្រះគម្ពីរកិច្ចការ ១៦:២២-២៦ ចែងថា: **ហ្វូងមនុស្សក៏លើកគ្នាទាស់នឹងប៉ុល ហើយនឹងស៊ីឡាសដែរ រួចមេនគរបាលបានកន្ត្រាក់ហែកអាវគេចេញ ហើយបង្គាប់ឱ្យវាយនឹងរំពាត់ ក្រោយដែលវាយមានស្នាមជាច្រើនហើយ នោះក៏យកទៅដាក់គុក បង្គាប់មេភូឃុំ ឱ្យរក្សាដោយប្រយ័ត្នប្រយែង មេភូឃុំទទួលបង្គាប់យ៉ាងដូច្នោះហើយ ក៏នាំយកគេទៅដាក់ក្នុងគុកជ្រៅ ព្រមទាំងដាក់ខ្នោះភ្ជាប់នៅជើងផង លុះពេលប្រហែលជាកណ្តាលអធ្រាត្រ ប៉ុល និងស៊ីឡាស កំពុងតែអធិស្ឋាន ហើយច្រៀងសរសើរដល់ព្រះ ឯពួកអ្នកទោសក៏ស្តាប់ដែរ នោះស្រាប់តែកើតមានកក្រើកដីជាខ្លាំង ដល់ម៉្លេះបានជារញ្ជួយដល់ជើងជញ្ជាំងគុកផង ហើយទ្វារទាំងប៉ុន្មានរបើកចេញភ្លាម ខ្នោះក៏របើបចេញទាំងអស់ទៅ ។**

➢ *ជាលក្ខណៈរូបកាយ*

ពួកគេបានទទួលនូវការប្រយុទ្ធប្រឆាំង និងការបៀតបៀន ។ សម្លៀកបំពាក់របស់គេត្រូវបានដោះចេញ ។ ពួកគេបានទទួលនូវភាពល្វឹងជូរចត់ និងត្រូវបានចាប់ចងនាំចូលទៅក្នុងគុកជ្រៅ គឺជាអ្នកជាប់ទោសឧក្រិដ្ឋដ៏ធ្ងន់ធ្ងរបំផុត និងត្រូវបានគេដាក់ខ្នោះមិនឱ្យរើរួចឡើយ ក៏មិនអាចទាំងធ្វើចលនាបានផង ។

**ជាលក្ខណៈខាងវិញ្ញាណ**

ពួកគេកំពុងតែអធិស្ឋាន និងច្រៀងចម្រៀងទំនុកតម្កើង ។

តើពួកគេបានអធិស្ឋានយ៉ាងដូច្នេះថា "ឱព្រះអើយ! ហេតុអ្វីបានជាទ្រង់អនុញ្ញាតឱ្យការនេះកើតឡើងយ៉ាងដូច្នេះ" ឬ?

យើងរាល់គ្នាកំពុងតែបម្រើទ្រង់ទេតើ ។

យើងរាល់គ្នាបាននៅកន្លែងដែលទ្រង់បានបញ្ជូនមកទេតើ!

យើងរាល់គ្នាបានដឹងថា ពួកគេមិនត្រូវបានចាត់មកទេ!

ពួកគេបានច្រៀងសរសើរតម្កើង ហើយពួកអ្នកជាប់គុកដទៃទៀតក៏បានឮពួកគេច្រៀងដែរ ។

➢ *ជាលទ្ធផល*

ពួកគេរួចពីចំណង និងត្រូវបានដោះឱ្យមានសេរីភាពឡើងវិញ

រីឯនាយមេភូឃុំ និង "អ្នកផ្ទះ" របស់គាត់ទាំងអស់ បានទទួលនូវសេចក្ដីសង្គ្រោះ ។

គ្រប់គ្នានៅក្នុងគុកបានឮពីព្រះយេស៊ូវ ។

ពួកអ្នកជឿដទៃទៀតនៅទីក្រុងភីលីពក៏បានទទួលនូវការកម្សាន្តចិត្តផងដែរ ។

**ស្តេចយ៉ូសាផាតក៏ជាគំរូម្នាក់ទៀតដែរ**

ស្តេចយ៉ូសាផាតបានដើរតាមព្រះរាជបញ្ញត្តិរបស់ព្រះ និងបានទទួលនូវការពិសោធន៍នៃជ័យជម្នះដ៏អស្ចារ្យ ។ នាមរបស់ទ្រង់ គឺយេហូសមានន័យថា "ព្រះយេហូវ៉ាគ្រប់គ្រង" ។

➢ *ការបង្រៀនពួកបណ្តាជនពីព្រះបន្ទូល*

ព្រះគម្ពីរ២របាក្សត្រ ១៧:៣-៦ ចែងថា: **ព្រះយេហូវ៉ាទ្រង់ក៏គង់នៅជាមួយនឹងយ៉ូសាផាត ពីព្រោះស្តេចបានប្រព្រឹត្ត តាមអស់ទាំងផ្លូវដើមរបស់ដាវីឌ ជាឰយុកោទ្រង់ ឥតរកតាមព្រះបាលឡើយ គឺបានស្វែងរកតាមតែព្រះនៃពួកឰយុកោទ្រង់ ហើយប្រព្រឹត្តតាមបញ្ញត្តិទ្រង់វិញ ឥតធ្វើតាមអំពើរបស់សាសន៍អ៊ីស្រាអែលឡើយ ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់តាំងរាជ្យឱ្យមាំមួនក្នុងអំណាចយ៉ូសាផាត ហើយពួកយូដាទាំងអស់គ្នាក៏នាំយកគ្រឿងបណ្ណាការមកថ្វាយស្តេច ទ្រង់មានព្រះរាជទ្រព្យ និងកិត្តិយសជាបរិបូរ ព្រះទ័យទ្រង់បានតាំងឡើង ក្នុងអស់ទាំងផ្លូវនៃព្រះយេហូវ៉ា មួយទៀតទ្រង់ក៏បំបាត់អស់ទាំងទីខ្ពស់ និងរូបព្រះចេញពីស្រុកយូដាទៅ ។**

➢ *ការអធិស្ឋានទៅពេលមានបញ្ហា*

អស់រយៈកាលជាច្រើនឆ្នាំមក ដែលពួកជនជាតិទាំងបានចុះចូលដោយកោតខ្លាចដល់ទ្រង់ ព្រមទាំងបានទុកឱ្យជនជាតិមួយនៅឯកោ ប៉ុន្តែក្រោយមក ពួកគេបានរួបរួមគ្នាចូលមកទាស់ទទឹងនឹងទ្រង់វិញ ។ ស្តេចយ៉ូសាផាតក៏បានយាងមកចំពោះពួកបងប្អូន និងបាននាំគ្នាអធិស្ឋាន ។ សេចក្តីអធិស្ឋានរបស់ទ្រង់ គឺចាប់ផ្តើមដោយការសរសើរតម្កើង ។

ព្រះគម្ពីរ២របាក្សត្រ ២០:៦-៩ ចែងថា: **ឱព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោយើងខ្ញុំរាល់គ្នាអើយ តើទ្រង់មិនមែនជាព្រះនៅស្ថានសួគ៌ទេឬអី តើទ្រង់មិនគ្រប់គ្រងលើអស់ទាំងនគររបស់សាសន៍ដទៃទេឬអី ហើយនៅព្រះហស្តទ្រង់ នោះក៏មានព្រះចេស្តានិងឥទ្ធិឫទ្ធិដែរ ដល់ម្លេះ**

បានជាគ្មានអ្នកណា អាចនឹងទប់ទល់នឹងទ្រង់បានឡើយ ឱព្រះនៃយើងខ្ញុំរាល់គ្នាអើយ តើទ្រង់មិនបានបណ្តេញពួកអ្នកស្រុកនេះពីមុខពួកអ៊ីស្រា-អែល ជារាស្ត្រទ្រង់ចេញ ហើយប្រទានដល់ពូជពង្សរបស់លោកអ័ប្រាហាំ ជាមិត្រសំឡាញ់ទ្រង់ ជាដរាបតទៅទេឬអី គេបានអាស្រ័យនៅ ហើយក៏បានស្អាងទីបរិសុទ្ធនៅស្រុកនេះ សំរាប់ព្រះនាមទ្រង់ ដោយពាក្យថា បើសិនជាមានសេចក្តីអាក្រក់ណា មកសង្កត់លើយើងរាល់គ្នា ទោះបើជាដាវ ឬទុក្ខទោស អាសន្នរោគឬអំណត់ក្តី បើយើងរាល់គ្នានឹងឈរនៅមុខព្រះវិហារនេះ ហើយនៅចំពោះទ្រង់ (ដ្បិតព្រះនាមទ្រង់នៅក្នុងព្រះវិហារនេះ) ហើយយើងរាល់គ្នាអំពាវនាវដល់ទ្រង់ ក្នុងសេចក្តីវេទនារបស់យើង នោះទ្រង់នឹងព្រមទទួល ហើយនឹងជួយសង្គ្រោះយើង ។

➢ *ព្រះទ្រង់បានឆ្លើយតប*

បន្ទាប់មក ព្រះទ្រង់បានឆ្លើយតបតាមរយៈហោរា ។

ព្រះគម្ពីរ២របាក្សត្រ ២០:១៥-១៨ ចែងថាៈ **រួចលោកពោលថា ឱពួកយូដាទាំងអស់គ្នា និងពួកអ្នកនៅក្រុងយេរូសាឡិម ព្រមទាំងព្រះករុណាយ៉ូសាផាតអើយ ចូរស្តាប់ចុះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកអ្នករាល់គ្នាដូច្នេះថា កុំឱ្យភ័យខ្លាចអ្វីឡើយ ក៏កុំឱ្យស្រយុតចិត្តដោយព្រោះពួកធំទាំងម្នីរនេះដែរ ដ្បិតចំបាំងនេះ មិនមែនស្រេចនៅអ្នករាល់គ្នាទេ គឺស្រេចនៅព្រះវិញ ស្អែកឡើង ចូរអ្នករាល់គ្នាចុះ ទៅទាស់នឹងគេចុះ មើលគេកំពុងតែឡើងមកតាមផ្លូវភ្នំស៊ីស អ្នករាល់គ្នានឹងចួបគេនៅចុងច្រកភ្នំទល់មុខនឹងទីរហោស្ថានយេរូល អ្នករាល់គ្នាមិនបាច់នឹងតស៊ូក្នុងចំបាំងនេះទេ ឱ្យគ្រាន់តែដំរៀបគ្នាឈរស្ងៀម ហើយចាំមើលសេចក្តីសង្គ្រោះ ដែលព្រះយេហូវ៉ានឹងប្រោសដល់អ្នករាល់គ្នាប៉ុណ្ណោះ ឱពួកយូដានិងពួកអ្នកនៅក្រុងយេរូសាឡិមអើយ កុំឱ្យភ័យខ្លាចអ្វីឡើយ ក៏កុំឱ្យស្រយុតចិត្តដែរ ស្អែកនេះចូរចេញទៅទាស់នឹងគេចុះ ពីព្រោះព្រះយេហូវ៉ាទ្រង់គង់នៅជាមួយនឹងអ្នករាល់គ្នាហើយ ។**

➢ *ទាំងអស់គ្នាបានថ្វាយបង្គំ*

**នោះយ៉ូសាផាតទ្រង់ក្រាបព្រះភក្ត្រចុះដល់ដី ហើយពួកយូដា និងពួកអ្នកនៅក្រុងយេរូសាឡិមទាំងអស់គ្នា ក៏ក្រាបថ្វាយបង្គំនៅចំពោះព្រះយេហូវ៉ាដែរ ។**

➢ *ការតែងតាំងពួកអ្នកចម្រៀង*

ការប្រុងប្រៀបរៀបចំសម្រាប់សមរភូមិ ស្ដេចយ៉ូសាផាតបានធ្វើការតែងតាំងពួកបុរស១ឱ្យច្រៀងសរសើរដល់ព្រះយេហូវ៉ា ។ ពួកបុរសទាំងនេះ គឺបានឈរនៅពីមុខពួកកងទ័ព!

ខ.២១-២២ ចែងថាៈ **រួចកាលទ្រង់បានពិគ្រោះនឹងបណ្ដាជនហើយ នោះទ្រង់ក៏ដំរូវឱ្យមានពួកអ្នក ដែលត្រូវច្រៀងថ្វាយព្រះយេហូវ៉ាហើយពោលសរសើរ ដោយស្លៀកពាក់ជាប្រដាប់បរិសុទ្ធ ក្នុងកាលដែលគេនាំមុខពួកទ័ពចេញទៅ ដោយពោលថា ចូរអរព្រះគុណដល់ព្រះយេហូវ៉ាចុះ ដ្បិតសេចក្ដីសប្បុរសទ្រង់នៅជាប់អស់កល្បជានិច្ច ដូច្នេះ កាលគេចាប់តាំងច្រៀង ហើយសរសើរឡើង នោះព្រះយេហូវ៉ាទ្រង់បង្កប់ទ័ពទាស់នឹងពួកកូនចៅអាំម៉ូន ម៉ូអាប់ និងពួកភ្នំសេអ៊ីរ ដែលមកច្បាំងនឹងពួកយូដា ឱ្យគេត្រូវចាញ់ ។**

➢ *ជ័យជម្នះ*

ខ.២៣ ចែងថាៈ **ដ្បិតពួកកូនចៅអាំម៉ូន និងម៉ូអាប់ គេលើកគ្នាបំផ្លាញពួកនោះអស់ហើយ នោះក៏ព្រួតគ្នាបំផ្លាញដល់គ្នាទៅវិញទៅមកទៀត ។**

ខ.២៤-២៦ ចែងថាៈ **ដូច្នេះ កាលពួកយូដាមកដល់ប៉មចាំយាមនៅត្រង់ទីរហោស្ថាននោះ គេក្រឡេកមើលទៅពួកធំនោះ ក៏ឃើញគេសុទ្ធតែជាខ្មោចដេករដូកនៅដី គ្មានអ្នកណាមួយបានរួចជីវិតឡើយ រួចកាលយ៉ូសាផាត និងពលទ័ពរបស់ទ្រង់បានទៅដល់ ដើម្បីយករឹប នោះក៏ឃើញមានទាំងរបស់ទ្រព្យ សំលៀកបំពាក់ និងប្រដាប់មានដំឡៃយ៉ាង**

**សន្ទឹក ហើយនាំគ្នាដោះចេញទុកសំរាប់ខ្លួន លើសពីកំឡាំងនឹងយកទៅបាន មានរបឹបជាច្រើនដល់ម្ល៉េះ បានជាគេប្រមូលយកអស់រវាង៣ថ្ងៃទើប ហើយ នៅថ្ងៃទី៤គេប្រជុំគ្នា នៅច្រកភ្នំបេរ៉ាកា គឺដោយព្រោះនៅទីនោះ គេបានសូមឱ្យព្រះយេហូវ៉ាបានព្រះពរ បានជាគេហៅទីនោះថា ច្រកភ្នំបេរ៉ាកា ដរាបដល់សព្វថ្ងៃនេះ ។**

**សេចក្ដីសង្ខេប**

➢ *លក្ខណៈខាងឯរូបកាយ*

ពួកគេបែរជាកំពុងតែពើបប្រយុទ្ធគ្នាទៅវិញទៅមក ដោយមានហ្វូងមនុស្សជាច្រើន មកពីបីជនជាតិ ។

➢ *លក្ខណៈខាងឯវិញ្ញាណ*

ពួកគេបានដឹងនូវព្រះបន្ទូលរបស់ព្រះ ដែលបានថែងមក ។ ពួកគេបានចាប់ផ្ដើមថ្វាយនូវការសរសើរ គឺមិនមែនដោយនៅបន្ទាប់ពីការបរាជ័យរបស់ខ្មាំងសត្រូវប៉ុណ្ណោះទេ គឺនៅពេលដែលខ្មាំងសត្រូវបានចុះចូលចំពោះពួកគេ ហើយគ្រប់យ៉ាងទាំងអស់ ក៏ហាក់ដូចជាគ្មានសេចក្ដីសង្ឃឹមនោះផងដែរ ។ ពួកគេបានថ្វាយនូវដង្វាយនៃការសរសើរ ។

➢ *ជាលទ្ធផល*

លទ្ធផលគឺជាជ័យជម្នះពេញលេញ នៅពេលដែលខ្មាំងសត្រូវរបស់ពួកគេ ត្រូវបានសម្លាប់គ្នាទៅវិញទៅមក ហើយពួកគេក៏បានទទួលនូវរបឹបដ៏ធំធេងបំផុត ។

➢ *ជំហានដើម្បីទទួលនូវជ័យជម្នះ*

តាមរយៈស្ដេចយ៉ូសាផាត យើងរកឃើញនូវជំហាននៃជ័យជម្នះទាំង៥យ៉ាងដូចខាងក្រោមនេះ:

➢ *ដឹងនូវព្រះបន្ទូលព្រះ*

➢ *ស្វែងរកព្រះវត្តមាននៃព្រះ*

- *ស្តាប់ឮមកពីព្រះ*
- *ជឿលើព្រះបន្ទូលនិងស្តាប់បង្គាប់ព្រះ*
- *ធ្វើសកម្មភាពដោយសេចក្តីជំនឿ: សរសើរតម្កើងដល់ព្រះនៅចំពោះជ័យជម្នះ ដែលបានបើកសម្តែងហើយ ។*

## សង្គ្រាមនៅក្នុងការសរសើរតម្កើង

សិទ្ធិអំណាច និងអំណាចចេស្តាខាងឯវិញ្ញាណដ៏អស្ចារ្យ គឺតែងតែត្រូវបានទទួលនូវការរំដោះ ដោយការចង្អុលបង្ហាញនូវការសរសើរតម្កើងដល់ព្រះ ដោយឱ្យបករណ៏ភ្លេង ។ គំរូដែលយើងបានទទួលមកពីសិក្សា គឺដែលលោកសាវ័កប៉ុល និងស៊ីឡាស បានច្រៀងនូវចម្រៀងសរសើរតម្កើង ហើយបន្ទាប់មក ការរំដោះក៏បានមកតាមមធ្យោបាយ នៃការរំជួយផែនដីដ៏អស្ចារ្យនោះ ។

### ការសរសើរតម្កើងគឺមានជ័យជម្នះនាំមុខជានិច្ច

នៅពេលដែលស្តេចយ៉ូសាផាត បានធ្វើការតែងតាំងពួកបុរសឱ្យច្រៀងសរសើរតម្កើងដល់ព្រះយេហូវ៉ា ហើយពួកគេក៏បានធ្វើដំណើរពីមុខជួរកងទ័ព នោះជ័យជម្នះដ៏ធំក៏បានមកដល់ពួកគេ ។ ពួកគេបានប្រើនូវឫទ្ធិអំណាច ដោយគ្រឿងសាស្ត្រាវុទ្ធខាងឯវិញ្ញាណ ហើយនៅពេលដែលពួកគេបានកំពុងតែសរសើរតម្កើងដល់ព្រះ នោះអំណាចចេស្តាដ៏ធំ និងសិទ្ធិអំណាចខាងឯវិញ្ញាណ ធ្វើឱ្យពួកគេត្រូវបានទទួលនូវការរំដោះ ។ ជារឿយៗ នៅពេលដែលយើងបានច្រៀងសរសើរតម្កើងដល់ព្រះ នោះព្រះវិញ្ញាណរបស់ទ្រង់ នឹងដឹកនាំយើងឱ្យចូលទៅក្នុងចម្រៀងនៃសង្គ្រាមខាងឯវិញ្ញាណនោះ ។

ព្រះគម្ពីរទំនុកដំកើង ១៤៩:៦-៩ ចែងថា: **គួរឱ្យមានសេចក្តីសរសើរយ៉ាងប្រសើរពីព្រះ នៅក្នុងមាត់គេ និងដាវមានមុខ២នៅដៃគេដែរ ដើម្បីនឹងសំរេចការសងសឹកដល់សាសន៍ដទៃទាំងប៉ុន្មាន និងការវាយ**

**ផ្ទាលដល់បណ្ដាជនទាំងឡាយ ប្រយោជន៍នឹងដាក់ច្រវាក់ដល់ពួកស្ដេចគេ និងខ្នោះដែកដល់ពួកអ្នកមានត្រកូលខ្ពស់របស់គេដែរ ដើម្បីនឹងសំរេចការវិនិច្ឆ័យដល់គេ ដូចជាបានកត់ទុកហើយ ការនេះជាកិត្តិយសដល់ពួកអ្នកដែលបរិសុទ្ធរបស់ទ្រង់ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។**

នៅក្នុងសង្គ្រាមខាងឯវិញ្ញាណ នោះយើងមិនត្រឹមតែបានទទួលនូវជ័យជម្នះ គឺដោយសារដាវដែលមានមុខពីរដ៏មុតស្រួច នៃព្រះបន្ទូលរបស់ព្រះ គឺជាព្រះបន្ទូលដែលត្រូវបាននិយាយចេញមកពីមាត់របស់យើង ប៉ុន្តែជ័យជម្នះចំធំឧត្តម នោះក៏ត្រូវបានឈ្នះដោយសារវិញ្ញាណ ដែលជាការសរសើរតម្កើងរបស់ព្រះដោយចម្រៀងនោះឯង ។

ព្រះគម្ពីរអេសាយ ៣០:៣១,៣២ ចែងថាៈ **ដ្បិតដោយសារព្រះសូរសៀងនៃព្រះយេហូវ៉ា នោះសាសន៍អាសស៊ើរនឹងស្រយុតចិត្ត ទ្រង់នឹងវាយគេដោយដំបងរបស់ទ្រង់ ហើយគ្រប់ៗរយៈដំបងដែលព្រះយេហូវ៉ាបានដំរូវឱ្យត្រូវវាយគេ នោះនឹងឮសូរក្រាប់និងស៊ុងប្រគំឡើងជាដរាប ឯក្នុងគ្រប់ទាំងពេលតគ្នានោះ ទ្រង់នឹងច្បាំងនឹងគេ ដោយព្រះពាហុលើកសំរេច ។**

ការសរសើរតម្កើងដោយឧបករណ៍ភ្លេង គឺមានផ្នែកមួយដ៏សំខាន់ ដោយមានជ័យជម្នះនៅគ្រប់សមរភូមិខាងឯវិញ្ញាណ ។

**ការថ្វាយបង្គំ ការអធិប្បាយ និងការធ្វើសង្គ្រាម**

ព្រះគម្ពីរវិវរណៈ ១៩:៦-៨ ចែងថាៈ **នោះខ្ញុំឮសូរដូចជាសំឡេងនៃមនុស្ស១ហ្វូងយ៉ាងធំ ដូចសូរទឹកច្រើន ហើយដូចសូរផ្គរលាន់យ៉ាងខ្លាំងថា ហាលេលូយ៉ា ដ្បិតព្រះអម្ចាស់ដ៏ជាព្រះ ដែលមានព្រះចេស្ដាបំផុត ទ្រង់សោយរាជ្យឡើងហើយ ចូរឱ្យយើងអរសប្បាយ ហើយរីករាយឡើង ទាំងថ្វាយសិរីល្អដល់ទ្រង់ចុះ ដ្បិតបានដល់ពេលរៀបវិវាហមង្គលនៃកូនចៀមហើយ ភរិយាទ្រង់បានរៀបខ្លួនជាស្រេច ទ្រង់ប្រទានឱ្យនាងបាន**

**ស្បៀកពាក់សំពត់ទេសយ៉ាងម៉ដ្ឋ ស្អាតហើយភ្លឺ ដ្បិតសំពត់ទេសយ៉ាងម៉ដ្ឋ នោះជាសេចក្ដីសុចរិតរបស់ពួកបរិសុទ្ធ ។**

➢ *ការថ្វាយបង្គំ*

មានសម្លេងនៃការសរសើរតម្កើងថ្មីមួយ ដែលកំពុងតែធ្វើដំណើរមកកាន់ពួកជំនុំនៅសម័យសព្វថ្ងៃនេះ ។ វាតែងតែមកជាសម្លេញខ្លាំងដូចជាទឹកហូរដ៏មានឫទ្ធិអំណាច និងការចង្អុលបង្ហាញនូវសម្លេងដ៏ខ្លាំងនោះដែលជាសម្លេងដូចជាផ្គរលាន់ និងសម្លេងអាវុធដែលបាញ់ចេញយ៉ាងខ្លាំងនៃជ័យជម្នះ ។ នៅក្នុងសម្លេងដ៏ខ្លាំង គឺដែលព្រះយេស៊ូវទ្រង់បានត្រូវបើកសម្ដែងពីមុនមកនោះ ធ្វើជាកូនចៀមនៃព្រះ ដែលឥឡូវនេះទ្រង់បានបើកសម្ដែងជាសិង្ហនៃសាសន៍យូដាវិញ ។

លោកសាវ័កយ៉ូហានបានពណ៌នាពីសង្គ្រាមដ៏ធំចុងក្រោយ គឺនៅពេលដែលសាតាំងនឹងត្រូវបានចងនៅលើផែនដីនេះ ។ ទេវតាក៏បានលេចចេញឡើង ។

ព្រះគម្ពីរវិវរណៈ ១៩:១០,១១ ចែងថា: **នោះខ្ញុំទំលាក់ខ្លួនចុះនៅទៀបជើងទេវតានោះ ដើម្បីថ្វាយបង្គំ តែទេវតាប្រាប់ខ្ញុំថា កុំឱ្យធ្វើដូច្នេះឡើយ ដ្បិតខ្ញុំជាបាវបំរើជាមួយនឹងអ្នក ហើយនិងបងប្អូនអ្នក ដែលមានសេចក្ដីបន្ទាល់ពីព្រះយេស៊ូវដែរ ចូរថ្វាយបង្គំដល់ព្រះវិញ ដ្បិតការធ្វើបន្ទាល់ពីព្រះយេស៊ូវ នោះហើយជាវិញ្ញាណនៃសេចក្ដីទំនាយ ខ្ញុំក៏ឃើញមេឃបើកចំហឡើង នោះឃើញមានសេះ១ និងព្រះអង្គដែលគង់លើវាទ្រង់មានព្រះនាមថា «ស្មោះត្រង់ ហើយពិតប្រាកដ» ទ្រង់ជំនុំជំរះ ហើយច្បាំងដោយសុចរិត ។**

មានទ្រង់ទ្រាយដ៏សំខាន់បីយ៉ាងនៃសមរភូមិខាងជាវិញ្ញាណដ៏ធំ ។

➢ *ការថ្វាយបង្គំ*

➢ *ការអធិប្បាយ*

➢ *ការធ្វើសង្គ្រាម*

➢ *ការអធិប្បាយ*

ជារឿយៗ នៅក្នុងការសរសើរតម្កើង និងការថ្វាយបង្គំ នោះ "វិញ្ញាណនៃសេចក្តីទំនាយ" នឹងត្រូវបានបើកសម្តែងនៅក្នុង "ចម្រៀងខាងឯវិញ្ញាណ" នៅក្នុងពេលធ្វើចម្បាំងនោះឯង ។ ជារៀងរាល់ពេល ការនេះបានកើតឡើង ចំពោះសង្គ្រាមដ៏ធំ ដែលត្រូវបានទទួលនូវជ័យជម្នះនូវវិញ្ញាណលោកិយ ។ មានការចងនៅផ្នែកខាងក្រោមនេះ:

➢ *នៃគោលការណ៍*

➢ *អំណាចចេស្តា*

➢ *និងការគ្រប់គ្រប់លើសេចក្តីងងឹត*

ព្រះគម្ពីរទំនុកដំកើង ១៤៩:៨ ចែងថា: **ប្រយោជន៍នឹងដាក់ច្រវាក់ដល់ពួកស្តេចគេ និងខ្នោះដែកដល់ពួកអ្នកមានត្រកូលខ្ពស់របស់គេដែរ ។**

➢ *ការធ្វើសង្គ្រាម*

ការឆ្លងកាត់របស់យើងនៅក្នុងព្រះគម្ពីរ វិវរណៈ ជំពូកទី១៩ បានបន្តនូវការផ្តល់ឱ្យចំពោះការពណ៌នារបស់ព្រះយេស៊ូវ និងពួកសង្ឃរបស់ទ្រង់ នូវការយាងត្រឡប់មកវិញ មកកាន់សមរភូមិនៃជ័យជម្នះដ៏ធំនេះទៅលើវិញ្ញាណអាក្រក់ ព្រមទាំងពួកអំណាចវិញ្ញាណរបស់វា ។

ព្រះគម្ពីរវិវរណៈ ១៩:១២-១៦ ចែងថា: **ព្រះនេត្រទ្រង់ដូចជាអណ្តាតភ្លើង ហើយនៅលើព្រះសិរសា មានមកុដជាច្រើន ទ្រង់មានព្រះនាមកត់ទុក ដែលគ្មានអ្នកណាស្គាល់ឡើយ លើកតែអង្គទ្រង់ប៉ុណ្ណោះ ទ្រង់ក៏ទ្រង់ព្រះពស្ត្រជ្រលក់ដោយឈាម ហើយព្រះនាមទ្រង់ហៅថា «ព្រះបន្ទូលនៃព្រះ» អស់ទាំងពលបរិវានៅស្ថានសួគ៌ ក៏ជិះសេះសជង្ហែទ្រង់ទាំងស្លៀកពាក់សំពត់ទេស ហើយស្អាតផង មានដាវយ៉ាងមុតចេញពីព្រះឱសទ្រង់ ដើម្បីនឹងកាប់អស់ទាំងសាសន៍ ហើយទ្រង់នឹងឃ្វាលគេ ដោយដំបងដែកទ្រង់ ក៏ជាន់ក្នុងធុងឃ្នាបនៃស្រាទំពាំងបាយជូរ ជាសេចក្តី**

**ឃោរឃៅរបស់សេចក្តីខ្លាល់នៃព្រះដ៏មានព្រះចេស្ដាបំផុត ទ្រង់មានព្រះនាមកត់នៅព្រះពស្ត្រ ហើយនៅព្រះឱ្យទ្រង់ថា «ស្ដេចលើអស់ទាំងស្ដេច ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់» ។**

## យញ្ញបូជានៃការសរសើរ គឺបានប្រទានឱ្យតាមរយៈព្រះយេស៊ូវ

យញ្ញបូជានៃការសរសើរ អាចត្រូវបានប្រទានមកត្រឹមតែតាមរយៈព្រះយេស៊ូវទេប៉ុណ្ណោះ ។

ព្រះគម្ពីរហេព្រើរ ១៣:១៥ ចែងថា: **ដូច្នេះ ត្រូវឱ្យយើងរាល់គ្នាថ្វាយពាក្យសរសើរ ដោយសារទ្រង់ទុកជាគ្រឿងបូជាដល់ព្រះជានិច្ច គឺជាផលនៃបបូរមាត់ ដែលថ្លែងប្រាប់ពីព្រះនាមទ្រង់ ។**

វាជាការថ្វាយនូវការអរព្រះគុណ ដោយនូវព្រះនាមទ្រង់សម្រាប់ដល់អស់អ្នកដែលទ្រង់ គង់នៅជាមួយ និងអ្វីដែលទ្រង់បានធ្វើរួចហើយ ។

ព្រះគម្ពីរអេភេសូរ ៥:២០ ចែងថា: **ទាំងអរព្រះគុណដល់ព្រះដ៏ជាព្រះវរបិតាជាដរាប ក្នុងគ្រប់ការទាំងអស់ ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ។**

វាជាការថ្វាយនូវការអរព្រះគុណ ដោយនូវព្រឹត្តិការណ៍ទាំងអស់ មិនមែនដោយគ្រាន់តែជាការដែលយើង បានធ្វើការប្រឹក្សាដ៏ល្អនោះទេ ។

ព្រះគម្ពីរ១ថែស្សាឡូនិច ៥:១៦-១៨ ចែងថា: **ចូរអរសប្បាយជានិច្ច ចូរអធិស្ឋានឥតឈប់ឈរ ចូរអរព្រះគុណក្នុងគ្រប់ការទាំងអស់ ពីព្រោះព្រះទ្រង់សព្វព្រះហឫទ័យឱ្យអ្នករាល់គ្នាធ្វើយ៉ាងដូច្នោះ ដោយនូវព្រះគ្រីស្ទយេស៊ូវ ។**

យើងអាចធ្វើការនេះបាន នៅពេលដែលយើងប្រតិបត្តិបានពេញលេញ គឺជារបៀបដែលព្រះទ្រង់បានបង្វិលគ្រប់ការទាំងអស់ ឱ្យធ្វើការរួមគ្នា សម្រាប់ជាសេចក្តីល្អនៅក្នុងជីវិតរបស់យើងរាល់គ្នា ។

ព្រះគម្ពីររ៉ូម ៨:២៨ ចែងថា: **តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សំរាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលហៅទ្រង់មក តាមព្រះដំរិះទ្រង់ ។**

**ការនាំមកនូវសិរីល្អថ្វាយដល់ព្រះ**

ដង្វាយនៃការសរសើរនាំមកសិរីល្អថ្វាយដល់ព្រះ ។

ព្រះគម្ពីរទំនុកដំកើង ៥០:២៣ក ចែងថា: **អ្នកណាដែលថ្វាយដង្វាយជាសេចក្តីអរព្រះគុណ នោះក៏លើកដំកើងអញដែរ... ។**

## របៀបថ្វាយដង្វាយនៃការសរសើរ

**ការធ្វើការសម្រេចចិត្ត**

ការធ្វើកាសម្រេចចិត្តទុកជាមុន ដែលលោកអ្នកមានបំណង នឹងសរសើរតម្កើងដល់ព្រះនៅគ្រប់ពេលទាំងអស់ និងនៅក្នុងរាល់ស្ថានការណ៍ទាំងអស់ផងដែរ ។

**ការចាប់ផ្តើមនៅពេលឥឡូវនេះ**

ចូរសរសើរតម្កើងដល់ព្រះជារៀងរាល់ថ្ងៃ គ្រប់ថ្ងៃទាំងអស់ ។

ចូរធ្វើការឱ្យបានជាទម្លាប់ក្នុងការសរសើរតម្កើង ។

**ប្រសិនបើមានបញ្ហាមកដល់**

- *ចូរចងចាំពីការសម្រេចចិត្តរបស់លោកអ្នក*
- *ចូរបន្តនូវទម្លាប់ក្នុងការសរសើរតម្កើងរបស់លោកអ្នក*
- *ចូរចងចាំថា ការសរសើរតម្កើងនៅក្នុងពេលដ៏លំបាក នោះព្រះទ្រង់នឹងធ្វើការឱ្យបានជាប្រយោជន៍ដល់លោកអ្នក ។*
- *ចូរសរសើរតម្កើងនៅក្នុងពេលដ៏លំបាក នោះនឹងនាំមកនូវសិរីល្អថ្វាយដល់ព្រះដ៏ជាព្រះវរបិតា ។*

ពេលដែលយើងមិនទទួលអារម្មណ៍ ក្នុងការសរសើរតម្កើងដល់ព្រះ នោះគឺជាពេលដែលយើងត្រូវការសរសើរតម្កើងដល់ទ្រង់ ឱ្យស្មើរតែគ្រប់ពេលទាំងអស់វិញ ។ នៅពេលដែលយើងបញ្ចេញសកម្មភាព ក្នុងការ

ស្តាប់បង្គាប់ដល់ព្រះបន្ទូលរបស់ព្រះ និងចាប់ផ្តើមសរសើរតម្កើងដល់ទ្រង់ នោះយើងត្រូវតែថ្វាយដង្វាយនៃការសរសើរដ៏ពិតដល់ព្រះ ហើយដែលគាប់ដល់ព្រះហឫទ័យនៃទ្រង់ ។

## ការចាប់ផ្តើមដោយសេចក្តីជំនឿ

មធ្យោបាយដែលលោកអ្នកចាប់ផ្តើម គឺត្រូវថ្វាយដង្វាយនៃការសរសើរ ដោយនូវសេចក្តីជំនឿ ។ ការសរសើរតម្កើងដល់ទ្រង់សម្រាប់ការដែលទ្រង់បានគង់នៅ និងសម្រាប់អ្វីដែលទ្រង់បានធ្វើរួចមកហើយ ។ បន្ទាប់មក ចូរថ្វាយដង្វាយនៃការអរព្រះគុណដល់ព្រះសម្រាប់ស្ថានការណ៍ទាំងឡាយ ដែលសូម្បីតែលោកអ្នកមិនយល់ក៏ដោយ ។

ចូរសរសើរតម្កើងដល់ទ្រង់ សម្រាប់ការធ្វើផ្លូវនៃការរំដោះ សូម្បីតែលោកអ្នកមិនអាចមើលឃើញផ្លូវចេញពីបញ្ហានោះក៏ដោយ ។ ចូរសរសើរតម្កើងដល់ព្រះសម្រាប់ការដែលទ្រង់បានគង់នៅ និងរំដោះចិត្តគំនិតលោកអ្នកឱ្យបានមកឯទ្រង់ ព្រមទាំងសេចក្តីសន្យាតាមរយៈព្រះបន្ទូលរបស់ទ្រង់ ។

ម្យ៉ាងទៀត លោកអ្នកបានចាប់ផ្តើមថ្វាយដង្វាយនៃការសរសើរ ហើយនៅតែបន្តទៅទៀត ។ ចូរប្រកាសខ្លាំងៗពីព្រះបន្ទូលរបស់ព្រះ ដែលសេចក្តីប្រកាសនោះឱ្យបានជាជ័យជម្នះ និងជាការរំដោះ ។

ទីមួយ លោកអ្នកនឹងបានជាដង្វាយនៃការសរសើរដោយការស្តាប់បង្គាប់ ។ ដោយការធ្វើយ៉ាងដូច្នេះ នោះលោកអ្នកនឹងរក្សាចិត្តគំនិតរបស់លោកអ្នកទៅលើទ្រង់ ហើយនឹងមិនស្ថិតនៅលើព្រឹត្តិការណ៍នោះឡើយ ។ នៅពេលដែលលោកអ្នក រក្សានូវការប្រៀបធៀបពីអំណាចចេស្តា និងសិរីល្អរបស់ទ្រង់ ទៅនឹងព្រឹត្តិការណ៍របស់លោកអ្នក នោះលោកអ្នកនឹងឃើញនូវរបៀបដ៏តូចមួយ ដែលវាពិតប្រាកដជាមានមែន ។

នៅពេលដែលលោកអ្នកបំពេញ ដល់គំនិតរបស់លោកអ្នកជាមួយនឹងព្រះបន្ទូលរបស់ព្រះ ហើយផ្ចង់ចិត្តទៅលើអំណាចចេស្តា និងសេចក្តី

សន្យារបស់ទ្រង់ នោះវិញ្ញាណនៃការសរសើរ នឹងផ្លាស់ប្តូរនូវការសង្ស័យ និងការព្រួយបារម្ភជាមិនខាន ។

ជារឿយៗ នៅពេលដែលវាហាក់ដូចជាមានការលំបាកចំពោះការសរសើរតម្កើង គឺនៅពេលដែលលោកអ្នកចាប់ផ្តើមសរសើរតម្កើង ដោយការស្តាប់បង្គាប់ដល់ព្រះ នោះលោកអ្នកនឹងចាប់ផ្តើមមានការរំភើបខ្លាំង ដោយព្រះវិញ្ញាណនៃការសរសើរតម្កើងនោះឯង ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ លោកអ្នកនឹងរកឃើញដោយខ្លួនឯង នូវការចូលដែលមានពេញទៅដោយសេចក្តីអំណរ ទៅខាងក្នុងការបើកសម្តែងនៃព្រះវត្តមានរបស់ទ្រង់ គឺនៅពេលដែលលោកអ្នកនៅតែបន្តធ្វើការរំដោះវិញ្ញាណរបស់លោកអ្នក ដោយការថ្វាយដង្វាយនៃករសរសើរនោះឯង ។

- ➢ *ទីសម្គាល់នឹងចូលទៅឯទ្រង់*
- ➢ *ការលោតរាំនៅចំពោះទ្រង់*
- ➢ *ថ្វាយសិរីល្អដល់ទ្រង់ និងឫទ្ធិតេជៈដោយនូវព្រះនាមទ្រង់*
- ➢ *ហើយទ្រង់នឹងរៀបផ្លូវនៃសេចក្តីសង្គ្រោះ និងរំដោះលោកអ្នក!*

## សំណួររំឭកសារឡើងវិញ

**១** តើការផ្សេងគ្នារវាងការសរសើរតម្កើងដល់ព្រះ និងកាថ្វាយដង្វាយនៃការសរសើរ នោះយ៉ាងដូចម្តេចខ្លះ?

**២** តើមានអ្វីកើតឡើងនៅពេលស្តេចយ៉ូសាផាត បានយាងទៅកាន់ទីធ្វើសង្គ្រាម ហើយបានដាក់ពួកអ្នកសរសើរតម្កើងនៅខាងមុខពួកកងទ័ព?

**៣** តើមានហេតុការណ៍អ្វីកើតឡើងចំពោះស្តេចយ៉ូសាផាត ដែលទ្រង់បានធ្វើជាគំរូដល់យើងនៅសម័យសព្វថ្ងៃនេះ តើយើងត្រូវធ្វើដោយរបៀបណាដែរ?

# មេរៀនទី ១១
## *មុខងារនៃពួកសង្ឃរបស់យើងគឺជាការសរសើរតម្កើង*

### សេចក្តីផ្តើម

ការងារជាដំបូងរបស់ពួកជំនុំដើម គឺកំពុងតែបំពេញការងារថ្វាយដល់ព្រះអម្ចាស់ ។

ព្រះគម្ពីរកិច្ចការ ១៣:១-៣ ចែងថាៈ **រីឯក្នុងពួកជំនុំនៅក្រុងអាន់ទីយ៉ូក នោះមានគ្រូអធិប្បាយ និងគ្រូបង្រៀនខ្លះ... កំពុងដែលអ្នកទាំងនោះធ្វើការងារថ្វាយព្រះអម្ចាស់ទាំងតម នោះព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលប្រាប់ថា ចូរញែកបាណាបាស និងសុលចេញឱ្យខ្ញុំ សំរាប់ការងារដែលខ្ញុំហៅគេឱ្យធ្វើ ដូច្នេះ ក្រោយដែលបានតម ហើយអធិស្ឋាន ព្រមទាំងដាក់ដៃលើអ្នកទាំង២ នោះក៏បើកឱ្យគេទៅ ។**

នៅពេលដែលពួកជំនុំបានចាប់ផ្តើម រៀបចំការងារជាដំបូង នោះពួកគេក៏បានរអិលភ្លាត់ដួលផងដែរ រីឯការបំពេញការងារដទៃទៀត គឺបានក្លាយទៅជាការចាំបាច់កាន់តែច្រើនឡើងៗ ។ ពួកជំនុំត្រូវការការបំពេញការងារដល់អ្នកដែលមានជម្ងឺ ដល់ពួកអ្នកដែលមានការរងទុក្ខដោយពួកវិញ្ញាណអាក្រក់ ដល់ពួកអ្នកក្រ និងដល់ពួកអ្នកដែលមានចិត្តសោះកក្រោះជាដើម ។ ការប្រឹក្សាការងារគឺបានចាប់ផ្តើមទាក់ទងជាមួយនឹងបញ្ហានៃការរំជួលក្នុងចិត្ត បញ្ហាអាពាហ៍ពិពាហ៍ ទៅដល់អស់អ្នកដែលស្រវឹងខ្ចប និងញៀនគ្រឿងញៀន ក្រុមយុវជនដែលមានការបះបោរ និងក្មេងៗដែលត្រូវពន្លូតចេញ ។ ការធ្វើបញ្ជីគឺមានជាបន្តៗជាប់ជានិច្ច ។ ការលះលែង ការកំផិត ការងុបងុលក្នុងកាមគុណ ជម្ងឺផ្លូវភេទគឺបានចាប់ផ្តើមរាតត្បាតដល់ពួកជំនុំ ។

តើវាអាចចេះតែកើតមានឡើងឬ នៅពេលដែលរូបកាយរបស់ព្រះគ្រីស្ទបានវិលត្រឡប់មកឯការបំពេញការងារជាទូទៅ ក្នុងការសរសើរតម្កើង និងការថ្វាយបង្គំ គ្រប់ទាំងការបំពេញការងារដទៃទៀតទាំងអស់នេះ នឹងក្លាយមកជាមានការចាំបាច់ កាន់តែតិចតួចទៅៗឬ? មានពេលជាច្រើនដែលពួកក្រុមនិមួយៗ ចូលទៅក្នុងការសរសើរតម្កើង និងការថ្វាយបង្គំដ៏ពិត ហើយក៏មានមនុស្សជាច្រើនបានចាប់ផ្តើមធ្វើការប្រោសឱ្យជាខាងឯអារម្មណ៍ ខាងឯរូបកាយ ហើយសូម្បីតែនៅពេលដែលពួកគេ បានចូលមកឯព្រះវត្តមាននៃព្រះ នោះក៏ត្រូវបានទទួលនូវការរំដោះផងដែរ ។

## ការបំពេញការងារជាសង្ឃ

សូម្បីតែព្រះយេស៊ូវទ្រង់ក៏ជាសម្តេចសង្ឃនៃយើងផងដែរ គឺដែលយើងបានចែកចាយនូវភាពជាសម្តេចសង្ឃរបស់ទ្រង់នោះឯង ។ អ្នកជឿគ្រប់រូបគឺជាសង្ឃនៅចំពោះ ។

ព្រះគម្ពីរវិវរណៈ ១:៦ ចែងថា: **ព្រមទាំងតាំងយើងរាល់គ្នាឡើងជានគរ ហើយជាពួកសង្ឃថ្វាយព្រះដ៏ជាព្រះវរបិតា នោះសូមឱ្យទ្រង់បានសិរីល្អ និងព្រះចេស្តានៅអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន ។**

ភាពជាសម្តេចសង្ឃរបស់យើងគឺត្រូវបានបើកសម្តែងតាមរបៀបលោកម៉ិលគីស្សាដែក ។ វាត្រូវបានបើកសម្តែងក្រោយមកទៀត តាមរយៈការងារជាសង្ឃរបស់ស្តេចដាវីឌ ។ ភាពជាសង្ឃទាំងពីរនេះ គឺត្រូវបានសម្រេចនៅក្នុងការងារជាសង្ឃរបស់ព្រះយេស៊ូវ ។ ព្រះយេស៊ូវគឺជាសម្តេចសង្ឃដ៏អស់កល្ប ហើយយើងរាល់គ្នាត្រូវតែអនុវត្តនៅក្នុងភាពជាសង្ឃដែលនៅពីក្រោមទ្រង់ ឬតាមរយៈទ្រង់ ។

វាជាការចាំបាច់ ដើម្បីសិក្សាពីមុខងារនៃភាពជាសង្ឃ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដើម្បីឱ្យយើងអាចទទួលនូវការបើកសម្តែង នូវមុខងាររបស់យើងបានច្បាស់លាស់ គឺជាសង្ឃដូចជាយើងបានថ្វាយនូវដង្វាយនៃការសរសើរជាបន្តទៅទៀត ។

## ភាពជាសម្តេចសង្ឃ

### លោកម៉ិលគីស្សាដែក

ព្រះគម្ពីរលោកុប្បត្តិ ១៤:១៨ ចែងថា: **ហើយម៉ិលគីស្សាដែកជាស្តេចក្រុងសាឡិម ក៏នាំយកនំបុ័ង និងស្រាទំពាំងបាយជូរមក ពីព្រោះទ្រង់ជាសង្ឃរបស់ព្រះដ៏ខ្ពស់បំផុត ។**

លោកម៉ិលគីស្សាដែកគឺជាសម្តេចសង្ឃ នៃក្រុងសាឡិម (បច្ចុប្បន្នគឺជាក្រុងយេរូសាឡិម) ។ លោកអ័ប្រាហាំបានថ្វាយ១ភាគក្នុង១០ ទៅដល់ម្នាក់នេះ ដែលឈ្មោះគាត់មានន័យថា "ស្តេចនៃសេចក្តីសុចរិត" ។ ផ្ទុយពីភាពជាសង្ឃរបស់លោកអើរ៉ុន គឺចំពោះលោកម៉ិលគីស្សាដែក គ្មានត្រកូល គ្មានតំណវង្សទេ ។ គាត់គឺជាសម្តេចសង្ឃដែលបានទទួលការជ្រើសរើសដោយព្រះផ្ទាល់ មិនមែនតាមរយៈក្រឹត្យវិន័យទេ ។

នៅក្នុងព្រះគម្ពីរទំនុកដំកើង យើងរកឃើញពាក្យទំនាយអំពីព្រះយេស៊ូវថាជាសង្ឃតាមរបៀបលោកម៉ិលគីស្សាដែក ។

ព្រះគម្ពីរទំនុកដំកើង ១១០:៤ ចែងថា: **ព្រះយេហូវ៉ាទ្រង់បានស្បថហើយ ថាឯងជាសង្ឃនៅអស់កល្បជានិច្ច តាមរបៀបលោកម៉ិលគីស្សាដែក ទ្រង់នឹងមិនប្រែព្រះហឫទ័យឡើយ ។**

អ្នកនិពន្ធព្រះគម្ពីរហេព្រើរក៏បើកសម្តែង ពីការងារជាសង្ឃរបស់ព្រះយេស៊ូវ គឺជាសម្តេចសង្ឃដែលគង់នៅជាសង្ឃអស់កល្បជានិច្ច តាមរបៀបលោកម៉ិលគីស្សាដែក ។

ព្រះគម្ពីរហេព្រើរ ៧:១-៣,១៧ ចែងថា: **រីឯលោកម៉ិលគីស្សាដែក ស្តេចក្រុងសាឡិម ជាសង្ឃរបស់ព្រះដ៏ខ្ពស់បំផុតនេះ ដែលទៅចួបនឹងលោកអ័ប្រាហាំ ក្នុងកាលដែលត្រឡប់ពីវាយបំផ្លាញពួកស្តេចវិញ ក៏បានប្រទានពរដល់លោក ហើយលោកអ័ប្រាហាំ បានយក១ភាគក្នុង១០ ពីរបស់ទាំងអស់ជូនលោក នាមស្តេចនោះ ដើមដំបូងស្រាយថា ស្តេចនៃសេចក្តីសុចរិតរួចមកជាស្តេចក្រុងសាឡិម គឺថា ជាស្តេចនៃសេចក្តីសុខ**

**សាន្ត... ដ្បិតមានសេចក្តីបន្ទាល់ពីទ្រង់ថា «ឯងជាសង្ឃនៅអស់កល្ប ជានិច្ច តាមរបៀបលោកម៉ិលគីស្សាដែក» ។**

មុខងារជាសង្ឃរបស់លោកម៉ិលគីស្សាដែកគឺជា "អ្នកដែលនៅជិត ព្រះ" ។ ភាពជាសង្ឃមានន័យថា "អ្នកដែលនៅជិត" ។

ព្រះគម្ពីរហេព្រើរ ៧:១៩ ចែងថា: (**ពីព្រោះក្រិត្យវិន័យមិន ដែលនាំឱ្យបានគ្រប់លក្ខណ៍ឡើយ) ក៏មានសេចក្តីសង្ឃឹមដ៏ប្រសើរជាង បានចូលមកផង ដែលយើងរាល់គ្នានឹងចូលទៅជិតព្រះបាន ដោយសារ សេចក្តីសង្ឃឹមនោះ ។**

## ដាវីឌ គឺជាស្តេច និងជាសង្ឃ

ដាវីឌដ៏ជាស្តេច ក៏មានមុខងារជាសង្ឃផងដែរ ។ ទ្រង់បានសង់ រោងឧបោសថ ហៅថារោងឧបោសថរបស់ស្តេចដាវីឌ ដែលបាននាំហឹប ត្រឡប់មកវិញ និងបានធ្វើសម្រេចនូវដង្វាយនៃការសរសើរ ។ នៅពេល ដែលស្តេចដាវីឌដាក់មុខងារ ជាសង្ឃតាមរបៀបលោកម៉ិលគីស្សាដែក របស់ទ្រង់ នោះទ្រង់ក៏យករបៀបការងារជាសង្ឃ មកឯព្រះយេស៊ូវផង ដែរ ។ ស្តេចដាវីឌក៏បានអនុញ្ញាតឱ្យពួកបណ្តាជនសរសើរតម្កើង និងថ្វាយ បង្គំ គឺទ្រង់បាននាំពួកគេឱ្យចូលទៅជិតព្រះនោះឯង ។

ព្រះគម្ពីរយ៉ាកុប ៤:៨ ចែងថា: **ត្រូវចូលទៅជិតព្រះ នោះទ្រង់ នឹងចូលមកជិតអ្នករាល់គ្នា ដែរឱពួកមានបាបអើយ ចូរលាងដៃឱ្យស្អាតចុះ ឱពួកអ្នកមានចិត្ត២អើយ ចូរសំអាតចិត្តឡើង ។**

## គ្រប់ការសម្រេចនៅក្នុងព្រះយេស៊ូវ

ដោយសារតែការងារជាសង្ឃរបស់ព្រះយេស៊ូវ នោះយើងរាល់គ្នា ក៏ជាសង្ឃដែលអាចចូលទៅក្នុងព្រះវត្តមាននៃព្រះដោយអង់អាច និងចូល ទៅជិតទ្រង់ដោយការសរសើរតម្កើង និងការថ្វាយបង្គំរបស់យើង ។

## ភាពជាសង្ឃដ៏បរិសុទ្ធ គឺជាលោកអើរ៉ុន

លោកអើរ៉ុនគឺត្រូវបានតែងតាំងឡើង ជាសម្ដេចសង្ឃលើកទីមួយ ហើយពួកកូនរបស់គាត់ ក៏ត្រូវបានតែងតាំងធ្វើជាសង្ឃដែរ ។ ភាពជាសង្ឃរបស់លោកអើរ៉ុន គឺត្រូវបានសម្រេចតែងតាំងឡើងដោយមេលើវង្សត្រកូល គឺជាពូជរបស់លេវី ។

ព្រះគម្ពីរលេវីវិន័យ ២១:១៧,២១ ចែងថា: **ឱ្យប្រាប់ដល់អើរ៉ុនថា បើមានអ្នកណាក្នុងពួកកូនចៅឯង នៅអស់ទាំងដំណតរៀងទៅដែលវិកលវិការ នោះមិនត្រូវចូលមកថ្វាយព្រះស្ងោយរបស់ព្រះនៃខ្លួនឡើយ ។**

### ការតម្រូវឱ្យបានគ្រប់ល័ក្ខណ៍

**អ្នកណាដែលវិកលវិការក្នុងពូជអើរ៉ុនដ៏ជាសង្ឃ នោះមិនត្រូវចូលមកថ្វាយដង្វាយដុតនៃព្រះយេហូវ៉ាទេ អ្នកនោះវិកលវិការហើយ ដូច្នេះមិនត្រូវចូលទៅថ្វាយព្រះស្ងោយរបស់ព្រះនៃខ្លួនឡើយ ។**

នៅពេលដែលពួកសង្ឃកំពុងតែថ្វាយដង្វាយ នោះពួកគេធ្វើជារូបភាពនៅលើផែនដី ឬជាប្រភេទមួយ របស់ព្រះយេស៊ូវតែប៉ុណ្ណោះ ។ ព្រះយេស៊ូវទ្រង់គ្រប់ល័ក្ខណ៍ ហើយទ្រង់ក៏តែងតែធ្វើគ្រប់រូបទាំងអស់ បានគ្រប់ល័ក្ខណ៍ដែរ ដូច្នេះគ្មានអ្នកណាមួយដែលមានការខ្វះចន្លោះ អាចធ្វើសម្រេចបានតាមរូបភាពនោះឡើយ ។

សព្វថ្ងៃនេះ ពួកអ្នកជឿត្រូវបានគ្រប់ល័ក្ខណ៍នៅក្នុងទ្រង់ ។

### អំពីសម្លៀកបំពាក់

សម្លៀកបំពាក់របស់ពួកសង្ឃ គឺជាការសម្គាល់ពីមនុស្សដទៃទៀតទាំងអស់ នៅពេលដែលពួកគេមិនបានបំពេញការងារនោះ ។ ព្រះទ្រង់បានប្រទាននូវអត្ថន័យនៃសេចក្ដីបង្រៀន
អំពីអ្វីដែលពួកគេត្រូវតែស្លៀកពាក់ នៅគ្រប់ពេលទាំងអស់ ។ ឃុតសម្លៀកបំពាក់នីមួយៗ
គឺទៅតាមប្រភេទនៃការទាក់ទងរបស់យើងជាមួយនឹងព្រះ ។

សម្លៀកបំពាក់នៅពេលបំពេញការងារ គឺមានបួនប្រភេទ:

- *ខោវែងខ្លូតទេស (Linen)*
- *កំណាត់មួយដុំធ្វើពីរោមចៀម ដោយគ្មានថ្នេរ*
- *ខោទ្រនាប់មានបួនពណ៌*
- *កំណាត់ខ្លូតទេស (Linen) សម្រាប់ទទូរ*

ខោអាវខ្លូតទេស (Linen) គឺតំណាងឱ្យសេចក្តីសុចរិតជាប់ជានិច្ច ហើយយើងរាល់គ្នា គឺជាសេចក្តីសុចរិតនៃព្រះ ។

ព្រះគម្ពីរ២កូរិនថូស ៥:២១ ចែងថា: **ដ្បិតឯព្រះអង្គដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឱ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឱ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង ។**

ពួកគេមិនអាចស្លៀកសម្លៀកបំពាក់ ដែលធ្វើពីរោមចៀមបានទេ ពីព្រោះរោមចៀមបណ្តាលឱ្យម្នាក់ៗមានការបែកញើស ។ ការបែកញើស គឺជាតំណាងឱ្យសេចក្តីបណ្តាសា និងជាតំណាងឱ្យការខិតខំប្រឹងប្រែងជាអាត្មានិយម ។ រោមចៀមមិនដែលអាចត្រូវបានគេបោកសម្អាត យ៉ាងហ្មត់ចត់បានឡើយ ។

## ការចាក់ប្រេងតាំង

បន្ទាប់មក ពួកសង្ឃក៏បានចាក់ប្រេងតាំងដោយប្រេង ជាតំណាងឱ្យព្រះវិញ្ញាណបរិសុទ្ធ ។

នៅសម័យសព្វថ្ងៃនេះ ពួកសង្ឃគឺជាពួកអ្នកជឿ ដែលមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយពួកគេ ។

## ការពិពណ៌នាពីមុខងារជាសង្ឃ

**ភ្លើងត្រូវឆេះជានិច្ច**

ពួកសង្ឃគឺត្រូវតែដុតភ្លើងឱ្យឆេះ នៅលើអាសនាដង្វាយជានិច្ច ។

ព្រះគម្ពីរលេវីវិន័យ ៦:៩,១៣ ចែងថា: **ចូរបង្គាប់ដល់អើរ៉ុននិងពួកកូនលោកថា នេះជារបៀបដង្វាយដុត គឺដង្វាយនេះត្រូវតែនៅលើជើងក្រានៃអាសនាពេញ១យប់ទាល់ព្រឹក ហើយភ្លើងដែលនៅលើអាសនាក៏ត្រូវតែឆេះនៅជានិច្ចដែរ... ត្រូវតែមានភ្លើងឆេះនៅជានិច្ចលើអាសនា មិនត្រូវឱ្យរលត់ឡើយ ។**

លោកសាវ័កប៉ុលបានបង្រៀនដល់លោកធីម៉ូថេឱ្យភ្លើងនៅតែឆេះក្នុងគាត់ជាប់ជានិច្ច ។

ព្រះគម្ពីរ២ធីម៉ូថេ ១:៦ ចែងថា: **ដោយហេតុនោះបានជាខ្ញុំរំឭកដល់អ្នក ឱ្យដាស់តឿនអំណោយទានរបស់ព្រះ ដែលនៅក្នុងអ្នកដោយខ្ញុំដាក់ដៃលើ ។**

នៅក្នុងនគរស្ថានសួគ៌ បាននិយាយពីស្រីព្រហ្មចារីយ៍ទាំង១០នាក់ នោះព្រះយេស៊ូវទ្រង់បានទូន្មានដល់យើងរាល់គ្នា ចំពោះការចាំបាច់ឱ្យរក្សាភ្លើងឱ្យនៅតែឆេះ នៅក្នុងជីវិតរបស់យើងជាប់ជានិច្ច ។

**ការបោសសម្អាតផេះ**

ពួកសង្ឃត្រូវតែបោសសម្អាតផេះ ពីលើអាសនាចេញ ។

ព្រះគម្ពីរលេវីវិន័យ ៦:១០,១១ ចែងថា: **ឯសង្ឃត្រូវឱ្យពាក់អាវខ្លូតទេស ហើយស្លៀកខោខ្លូតទេស ទៅកើបផេះដែលភ្លើងបានឆេះដង្វាយនៅលើអាសនា ហើយដាក់នៅក្បែរអាសនាសិន រួចដោះសំលៀកបំពាក់នោះចេញ ស្លៀកពាក់បន្លាស់ឯទៀត យកផេះចេញទៅក្រៅទីដំឡើងត្រសាលចាក់នៅកន្លែងស្អាត ។**

ភ្លើងមិនអាចនឹងនៅតែឆេះបន្តទៅទៀតបានឡើយ ប្រសិនបើគេទុកឱ្យផេះនៅកាន់តែច្រើនឡើងនៅលើអាសនា ។ យើងអាចក្លាយមកជា

enamored យ៉ាងដូច្នោះ នៅក្នុងរស្មី ការកម្សាន្តចិត្ត "គឺជាភ្លើង" នៅថ្ងៃម្សិលមិញ ដែលយើងមិនបានបន្តនូវអ្វីដែលព្រះវិញ្ញាណទ្រង់មានបន្ទូលនៅសម័យសព្វថ្ងៃនេះ ។ យើងអាចត្រូវបានធ្វើឱ្យរលោង ដោយការចងចាំពីអតីតកាល ។ យើងត្រូវតែមានបំណងនឹងចាកចេញពីការនៅអតីតកាល ទាំងការពិសោធន៍នូវសេចក្តីល្អ និងសេចក្តីអាក្រក់ ល្អិកណាដែលយើងត្រូវតែបន្ត នូវអ្វីដែលនៅសល់ត្រឹមពាក់កណ្តាល នោះទុកឱ្យព្រះទ្រង់បានធ្វើនៅសម័យសព្វថ្ងៃនេះវិញ ។

ព្រះគម្ពីរភីលីព ៣:១៣ ចែងថា: **បងប្អូនអើយ ខ្ញុំមិនរាប់ថា ខ្លួនខ្ញុំចាប់បានហើយនោះទេ តែមានសេចក្តីនេះ១ គឺថា ខ្ញុំភ្លេចសេចក្តីទាំងប៉ុន្មានដែលកន្លងទៅហើយ ក៏ខំមមុលឈោងទៅឯសេចក្តីខាងមុខទៀត។**

**ចូរថ្វាយយញ្ញបូជា**

ពួកសង្ឃគឺមានតែម្នាក់ទេដែលអាចថ្វាយយញ្ញបូជាបាន ។

ព្រះគម្ពីរនិក្ខមនំ ២៩:៣៨,៣៩,៤២ ចែងថា: **រីឯដង្វាយដែលត្រូវថ្វាយនៅលើអាសនារាល់តែថ្ងៃជានិច្ច នោះគឺកូនចៀម២អាយុ១ខួប កូនចៀម១ត្រូវថ្វាយក្នុងពេលព្រឹក ហើយ១ទៀតក្នុងពេលល្ងាច... នេះហើយជាដង្វាយដុតជានិច្ច ដែលកូនចៅឯងតទៅមុខ ត្រូវថ្វាយនៅមាត់ទ្វារត្រសាលជំនុំនៅចំពោះព្រះយេហូវ៉ា ជាកន្លែងដែលអញនឹងមកជួបនឹងឯងរាល់គ្នា ដើម្បីនឹងនិយាយជាមួយនឹងឯង ។**

យើងរាល់គ្នាត្រូវបានទទួលបញ្ញត្តិឱ្យថ្វាយដង្វាយនៃការសរសើរនោះ ។

**ការប្រទានព្រះពរ**

ពួកសង្ឃគឺត្រូវតែសូមព្រះប្រទានពរដល់ពួកបណ្តាជន ។

ព្រះគម្ពីរលេវីវិន័យ ៩:២២ ចែងថា: **នោះអើរ៉ុនក៏លើកដៃឱ្យពរដល់ពួកបណ្តាជន រួចចុះមកពីការថ្វាយដង្វាយលោះបាប ដង្វាយដុតនិងដង្វាយមេត្រី ។**

ព្រះគម្ពីរជនគណនា ៦:២៣-២៧ ចែងថា: **ឱ្យប្រាប់ដល់អើរ៉ុន និងពួកកូនលោកថា ត្រូវឱ្យឯងរាល់គ្នាឱ្យពរដល់ពួកកូនចៅអ៊ីស្រាអែល ដោយពាក្យយ៉ាងនេះ គឺត្រូវពោលនឹងគេថា សូមឱ្យព្រះយេហូវ៉ាប្រទានពរ ហើយរក្សាឯង សូមឱ្យព្រះយេហូវ៉ាធ្វើឱ្យព្រះភក្ត្រទ្រង់ភ្លឺមកដល់ឯង ព្រមទាំងផ្តល់ព្រះគុណដល់ឯងផង សូមឱ្យព្រះយេហូវ៉ាងើបព្រះនេត្រទ្រង់មកចំពោះឯង ហើយប្រទានឱ្យឯងបានសេចក្តីសុខ គឺយ៉ាងដូច្នោះ ដែលត្រូវដាក់ឈ្មោះអញលើពួកកូនចៅអ៊ីស្រាអែល ហើយអញនឹងឱ្យពរដល់គេ ។**

ព្រះយេស៊ូវទ្រង់មានបន្ទូលថា យើងរាល់គ្នាជាអំបិលនៃផែនដី ។ យើងត្រូវតែឱ្យពរនោះទៅដល់អស់អ្នកដែលនៅជុំវិញយើង ។

ព្រះគម្ពីរម៉ាថាយ ៥:១៣ក ចែងថា: **អ្នករាល់គ្នាជាអំបិលនៃផែនដី បើអំបិលបាត់ជាតិប្រៃហើយ នោះតើនឹងយកអ្វី ដើម្បីធ្វើឱ្យប្រៃឡើងវិញបាន... ។**

## ចង្វាយខាងផ្នែករូបកាយ

ពួកសង្ឃគឺតែងតែចូលមកក្នុងព្រះវត្តមាននៃព្រះអម្ចាស់ ដោយមានដង្វាយ ។

ព្រះគម្ពីរ១របាក្សត្រ ១៦:២៩ ចែងថា: **ចូរទទួលថ្លែងប្រាប់ពីសិរីល្អនៃព្រះយេហូវ៉ា ឱ្យសំណំនឹងព្រះនាមទ្រង់ ចូរនាំយកដង្វាយ១មកនៅចំពោះព្រះយេហូវ៉ាចុះ ហើយថ្វាយបង្គំដល់ទ្រង់ ដោយសិរីលំអនៃសេចក្តីបរិសុទ្ធ ។**

ព្រះគម្ពីរនិក្ខមនំ ២៣:១៥ ចែងថា: **ត្រូវធ្វើបុណ្យនំបុ័ងឥតដំបែ គឺដល់កំណត់ក្នុងខែចេត្រ នោះត្រូវធ្វើនំបុ័ងឥតដំបែក្នុង៧ថ្ងៃ ដូចជាអញបានបង្គាប់មកហើយ ដ្បិតគឺនៅខែនោះហើយ ដែលឯងរាល់គ្នាបានចេញពីស្រុកអេស៊ីព្ទមក ហើយមិនត្រូវមកនៅមុខអញដោយដៃទទេឡើយ ។**

ព្រះគម្ពីរនិក្ខមនំ ៣៤:២០ ចែងថា: **ឯកូនច្បងរបស់សត្វលា នោះត្រូវឱ្យលោះដោយកូនចៀម១ តែបើមិនចង់លោះទេ នោះត្រូវបំបាក់ក**

**ទៅ ឯអស់ទាំងកូនប្រុសច្បងនៃឯង នោះត្រូវតែលោះជាកុំខាន ហើយមិនត្រូវមកដោយដៃទទេនៅមុខអញឡើយ ។**

ព្រះគម្ពីរចោទិយកថា ១៦:១៧ ចែងថា: **ត្រូវឱ្យគ្រប់គ្នាថ្វាយតាមកំឡាំងរៀងខ្លួន គឺតាមព្រះពរដែលព្រះយេហូវ៉ា ជាព្រះនៃឯង បានប្រទានឱ្យ ។**

**ការថ្វាយយញ្ញបូជា**

មុខងាររបស់លោកអើរ៉ុនដ៏ជាសង្ឃ គឺត្រូវតែថ្វាយយញ្ញបូជា ។ រីឯយើងរាល់គ្នាក៏ត្រូវតែថ្វាយយញ្ញបូជាខាងឯវិញ្ញាណផងដែរ ។

ព្រះគម្ពីរ១ពេត្រុស ២:៥ ចែងថា: **នោះអ្នករាល់គ្នាក៏បានស្អាងឡើង ដូចជាថ្មរស់ដែរ ឱ្យបានធ្វើជាផ្ទះខាងឯវិញ្ញាណ ជាពួកសង្ឃបរិសុទ្ធ សំរាប់នឹងថ្វាយគ្រឿងបូជាខាងព្រលឹងវិញ្ញាណដែលព្រះទ្រង់សព្វព្រះហឫទ័យទទួល ដោយព្រះយេស៊ូវគ្រីស្ទ ។**

ព្រះគម្ពីរហេព្រើរ ១៣:១៥ ចែងថា: **ដូច្នេះ ត្រូវឱ្យយើងរាល់គ្នាថ្វាយពាក្យសរសើរ ដោយសារទ្រង់ទុកជាគ្រឿងបូជាដល់ព្រះជានិច្ច គឺជាផលនៃបបូរមាត់ ដែលថ្លែងប្រាប់ពីព្រះនាមទ្រង់ ។**

យើងរាល់គ្នាត្រូវតែចូលមក ដោយការសរសើរតម្កើង ការថ្វាយបង្គំ ការគោរពបូជា និងការអរព្រះគុណ គឺជាការចង្អុលបង្ហាញចំពោះការសរសើរតម្កើងរបស់យើង ដោយចម្រៀង សេចក្ដីអធិស្ឋាន និងដោយទ្រព្យសម្បត្តិរបស់យើង ។

## ការតម្រូវឱ្យមាននៃភាពជាសង្ឃរបស់លោកអើរ៉ុន

វាជាការសំខាន់ចំពោះការយល់ដឹង នូវរឿងរ៉ាវបួនយ៉ាង ដែលបានជាប់ទាក់ទងទៅនឹងពួកសង្ឃនៅព្រះគម្ពីរសញ្ញាចាស់ ។

**ការជ្រើសរើសជាផ្នែក**

តួនាទីរបស់សង្ឃគឺត្រូវតែបានជាអ្នកដែលត្រូវទទួលការបំបួស ឬជាអ្នកដែលត្រូវបានជ្រើសរើសចេញពីលោកិយមក ។

ព្រះគម្ពីរនិក្ខមនំ ១៩:២២ ចែងថាៈ **ឯពួកសង្ឃដែលចូលមកឯព្រះយេហូវ៉ា នោះត្រូវឱ្យគេញែកខ្លួនចេញជាបរិសុទ្ធដែរ ក្រែងទ្រង់នឹងប្រហារគេ ។**

**ភាពបរិសុទ្ធ**

ពួកសង្ឃត្រូវតែបានបរិសុទ្ធ គឺជាអ្នកដែលបានទទួលនូវការបំបួសដ៏ពេញលេញ ចំពោះព្រះអម្ចាស់ ។

ព្រះគម្ពីរជនគណនា ១៦:៥ ចែងថាៈ **ឆ្លើយនឹងកូរេ ហើយនិងពួកគេថា ព្រឹកស្អែកនេះ ព្រះយេហូវ៉ានឹងសំដែងឱ្យស្គាល់អ្នកណាដែលជារបស់ផងទ្រង់ និងអ្នកណាដែលបរិសុទ្ធ ទ្រង់នឹងនាំឱ្យអ្នកនោះចូលទៅជិតទ្រង់ គឺជាអ្នកណាដែលទ្រង់នឹងរើស ទ្រង់នឹងនាំអ្នកនោះឯងឱ្យចូលទៅជិតទ្រង់ ។**

**ការបំបួស**

ការងារ និងមុខងាររបស់ពួកសង្ឃ គឺត្រូវតែជាអ្នកបាននៅជិតព្រះ ។ សង្ឃជាអ្នកតំណាងឱ្យពួកបណ្ដាជន ហើយពួកបណ្ដាជនត្រូវតែៈ

- *បានញែកចេញពីអ្នកដទៃទៀតដែលនៅលោកិយ*
- *បានជាសាសន៍បរិសុទ្ធ ជាមនុស្សពិសេស*
- *បានជាសាសន៍មួយ គឺជាពួកសង្ឃរបស់ព្រះ*

ព្រះគម្ពីរនិក្ខមនំ ១៩:៤,៦ក ចែងថាៈ **ឯងរាល់គ្នាបានឃើញអស់ទាំងការដែលអញធ្វើដល់សាសន៍អេស៊ីព្ទហើយ និងការដែលអញបានទ្រឯងរាល់គ្នាលើស្លាបឥន្ទ្រីនាំមកឯអញនេះផង ដូច្នេះបើឯងរាល់គ្នានឹងស្តាប់តាមអញឥឡូវ ហើយកាន់តាមសេចក្តីសញ្ញារបស់អញ នោះឯងរាល់គ្នានឹងបានជាចំជារបស់ផងអញលើសជាងអស់ទាំងសាសន៍ ដ្បិតផែនដីទាំងមូលជារបស់ផងអញ ឯងរាល់គ្នានឹងបានធ្វើជានគរដល់អញដែលសុទ្ធតែជាសង្ឃ ហើយជាសាសន៍បរិសុទ្ធឱ្យអញដែរ... ។**

**ការសម្អាត**

ពួកសង្ឃគឺត្រូវបានតម្រូវឱ្យលាងដៃ លាងជើង នៅចំពោះការបំពេញការងារ ។

ព្រះគម្ពីរនិក្ខមនំ ៣០:២១ ចែងថា: **នោះគេត្រូវលាងដៃលាងជើងដែរ ដើម្បីកុំឱ្យត្រូវស្លាប់ នេះជាច្បាប់សំរាប់នៅអស់កល្បជានិច្ច ដល់អើរ៉ុននឹងពូជពង្សលោកអស់ទាំងដំណតរៀងទៅ ។**

ព្រះគម្ពីរនិក្ខមនំ ៤០:១២,១៣ ចែងថា: **ត្រូវនាំអើរ៉ុន និងពួកកូនលោកមកជិតទ្វារត្រសាលជំនុំ ហើយផ្ងូតអ្នកទាំងនោះដោយទឹក រួចយកសំលៀកបំពាក់បរិសុទ្ធមកបំពាក់អើរ៉ុន ហើយចាក់ប្រេងញែកលោកចេញជាបរិសុទ្ធ ដើម្បីឱ្យលោកបានធ្វើការងារជាសង្ឃដល់អញ ។**

➢ *ក្រុមគ្រួសាររបស់លោកយ៉ាកុប*

លោកយ៉ាកុបបានធ្វើការច្បាស់លាស់ថា គ្រប់គ្នាទាំងអស់ដែលរស់នៅផ្ទះរបស់គាត់ គឺត្រូវតែបានសម្អាតមុនពេលដែលគាត់បានស្វែងរកព្រះយេហូវ៉ា នៅក្នុងគ្រាមានទុក្ខព្រួយ ។

ព្រះគម្ពីរលោកុប្បត្តិ ៣៥:២,៣ ចែងថា: **នោះយ៉ាកុបគាត់ប្រាប់ដល់ពួកគ្រួគាត់ និងអស់អ្នកដែលនៅជាមួយថា ចូរចោលព្រះដទៃទាំងប៉ុន្មាន ដែលនៅក្នុងពួកឯងរាល់គ្នាចេញ រួចសំអាតខ្លួន ហើយផ្លាស់សំលៀកបំពាក់ឯងចុះ ចូរយើងរៀបចំឡើងទៅឯបេត-អែល នៅទីនោះអញនឹងស្អាងអាសនា១ថ្វាយព្រះ ដែលទ្រង់បានឆ្លើយមកអញ ក្នុងកាលដែលអញមានសេចក្តីវេទនា ហើយបានគង់ជាមួយនឹងអញ តាមផ្លូវដែលអញដើរដំណើរមក ។**

➢ *ពួកបណ្តាជន*

លោកម៉ូសេបានបញ្ជាដល់ពួកបណ្តាជនអ៊ីស្រាអែល ឱ្យឧទ្ទិសថ្វាយដោយខ្លួនគេ ព្រមទាំងលាងសម្អាតសម្លៀកបំពាក់របស់ពួកគេ ។

ព្រះគម្ពីរនិក្ខមនំ ១៩:១០ ចែងថា: **ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងម៉ូសេថា ចូរទៅឯពួកជន ដើម្បីនឹងញែកគេឱ្យបរិសុទ្ធនៅថ្ងៃនេះ ហើយថ្ងៃស្អែកផង ត្រូវឱ្យគេបោកខោអាវដែរ ។**

នៅសម័យសព្វថ្ងៃនេះ យើងរាល់គ្នាជាអ្នកជឿគឺជាសង្ឃរបស់ព្រះ ដែលត្រូវបានសម្អាតពីអំពើបាបណាមួយ នៅក្នុងជីវិតរបស់យើង មុនពេលដែលគេចូលមកថ្វាយដង្វាយនៃការសរសើររបស់យើង ។

ព្រះគម្ពីរ១យ៉ូហាន ១:៩ ចែងថា: **បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឱ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង ។**

យើងត្រូវតែចំណាយពេលជាប្រចាំថ្ងៃ ចំពោះព្រះបន្ទូល ។ នៅពេលដែលយើងអាន ជញ្ជឹងគិត និងស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះ គឺជាព្រះគ្រីស្ទនៅក្នុងសេចក្តីស្រឡាញ់របស់ទ្រង់ សម្រាប់យើងរាល់គ្នា ដែលកំពុងតែធ្វើឱ្យយើងបានបរិសុទ្ធ ។

ព្រះគម្ពីរអេភេសូរ ៥:២៥-២៧ ចែងថា: **បុរសរាល់គ្នាអើយ ចូរស្រឡាញ់ប្រពន្ធខ្លួន ដូចជាព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ ហើយបានប្រគល់ព្រះអង្គទ្រង់ជំនួសផង ដើម្បីឱ្យទ្រង់បានញែកពួកជំនុំចេញជាបរិសុទ្ធ ដោយបានលាងសំអាតនឹងទឹក គឺជាព្រះបន្ទូល ប្រយោជន៍នឹងថ្វាយពួកជំនុំនេះដល់ព្រះអង្គទ្រង់ទុកជាពួកជំនុំដ៏ឧត្តម ឥតប្រឡាក់ ឥតជ្រួញ ឬមានអ្វីឱ្យដូចឡើយ គឺឱ្យបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបានវិញ ។**

## ការព្រមាន

លោកណាដាប និងលោកអ័ប៊ីហ៊ូវ ជាកូនប្រុសរបស់លោកអើរ៉ុន ការបំបួសជាសង្ឃឱ្យបានជាបរិសុទ្ធ ប៉ុន្តែពួកគេបានចូលទៅឯព្រះវត្តមាននៃព្រះ ដោយការមិនសមរម្យ ។

ព្រះគម្ពីរលេវីវិន័យ ១០:១-៣ ចែងថាៈ **ឯណាដាប និងអ័ប៊ីហ៊ូវ ជាកូនអើរ៉ុនទាំង២នាក់ ក៏យកជើងពានរៀងខ្លួនទៅដាក់ភ្លើង ហើយរោយគ្រឿងក្រអូបពីលើ គឺបានយកភ្លើងដទៃទៅថ្វាយនៅចំពោះព្រះយេហូវ៉ា ដែលទ្រង់ឥតបានបង្គាប់ឡើយ នោះស្រាប់តែមានភ្លើងចេញពីចំពោះព្រះយេហូវ៉ាមក បញ្ឆេះអ្នកទាំង២នោះ ឱ្យស្លាប់នៅចំពោះព្រះយេហូវ៉ាទៅ ម៉ូសេក៏និយាយនឹងអើរ៉ុនថា នេះហើយជាសេចក្ដីដែលព្រះយេហូវ៉ាមានបន្ទូលមកថា ត្រូវឱ្យអស់អ្នកដែលចូលមកជិតអញ បានលើកអញជាបរិសុទ្ធ ហើយត្រូវឱ្យអញបានសិរីល្អនៅចំពោះមុខជនទាំងឡាយដែរ ដូច្នេះអើរ៉ុនក៏នៅស្ងៀម ។**

ដើម្បីឱ្យសង្ឃមានកិត្តិយស និងមានឯសិទ្ធិ ដែលបានតម្រូវឱ្យមានការស្ដាប់បង្គាប់ជារួម ។

វាជាការសំខាន់ដែលយើងជាអ្នកជឿជាសង្ឃ ដែលដឹង និងស្ដាប់បង្គាប់នូវសេចក្ដីបង្រៀនពីព្រះបន្ទូលរបស់ព្រះ គឺនៅពេលដែលយើងបានចូលមកថ្វាយនូវការសរសើរតម្កើងរបស់យើងដល់ព្រះអង្គ ។ យើងមិនត្រូវចូលមកទាំងមិនមានការខ្វល់ព្រួយ មិនមានការស្ដាប់បង្គាប់ ឬដោយបានធ្វើការសម្រេចចិត្តធ្វើតាមតែផ្លូវខ្លួនឯង ឬក៏តាមទំនៀមទម្លាប់ចាស់របស់យើងនោះឡើយ ប្រសិនបើយើងមិនមានការថ្លឹងថ្លែងពីគំរូ និងការបង្រៀនរបស់ព្រះ សម្រាប់ការសរសើរតម្កើងនោះទេ ។ យើងត្រូវតែប្រុងប្រយ័ត្នចំពោះចម្រៀង គ្រឿងភ្លេង និងម៉ូយដែលនៅលោកិយនេះ ឬក៏សាសនាដទៃទៀត ដែលមិនអាចនាំយើងឱ្យចូលទៅក្នុងការថ្វាយបង្គំដែលជាតំណាងឱ្យ ដោយ "ភ្លើងដទៃទៀត" ដែលលោកណាដាប និងអ័ប៊ីហ៊ូវបានប្រើក្នុងការថ្វាយយញ្ញបូជារបស់ពួកគេនៅចំពោះព្រះយេហូវ៉ានោះ ។

ព្រះគម្ពីរ១ពេត្រុស ២:៩ ចែងថាៈ **តែអ្នករាល់គ្នាជាពូជជ្រើសរើស ជាពួកសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជារាស្ត្រដ៏ជាកេរ្តិ៍អាករនៃព្រះ ដើម្បីឱ្យ**

**អ្នករាល់គ្នាបានសំដែងចេញ ឱ្យឃើញអស់ទាំងលក្ខណៈរបស់ព្រះ ដែលទ្រង់បានហៅអ្នករាល់គ្នាចេញពីសេចក្ដីងងឹត មកក្នុងពន្លឺអស្ចារ្យរបស់ទ្រង់ ។**

## សំណួររំឭកសារឡើងវិញ

**១** តាមព្រះគម្ពីរ ១ពេត្រុស ២:៥ និងហេព្រើរ ១៣:១៥ តើអ្វីទេជាយញ្ញបូជាដែលយើងជាអ្នកជឿ ជាសង្ឃដែលត្រូវថ្វាយដល់ព្រះអម្ចាស់នោះ?

**២** ពួកសង្ឃនៅព្រះគម្ពីរសញ្ញាចាស់ ត្រូវតែសម្អាតមុនពេលបំពេញការងារចំពោះព្រះអម្ចាស់ដោយនូវដង្វាយរបស់ពួកគេ ។ យោងតាមព្រះគម្ពីរ ១យ៉ូហាន ១:៩ និងអេភេសូរ ៥:២៥-២៧ តើយើងត្រូវតែសម្អាតមុនពេលចូលទៅឯព្រះដោយការសរសើរតម្កើងរបស់យើងដោយវិធីណាដែរ?

**៣** តើមេរៀនអ្វីខ្លះដែលអាចឱ្យយើងរៀនសូត្រ ដកស្រង់ចេញពីការពិសោធន៍របស់លោកណោដាប និងអ័ប៊ីហ៊ូវ នោះ?

# មេរៀនទី ១២
## *អំពីការរស់នៅជាសង្ឃ*

អ្នកជឿគឺជាសង្ឃដែលបំពេញការងារចំពោះព្រះអម្ចាស់ ដោយការសរសើរតម្កើង និងការថ្វាយបង្គំ នោះយើងត្រូវដឹងថា ការត្រាស់ហៅរបស់យើង ការដើររបស់យើង សម្លៀកបំពាក់របស់យើង និងដង្វាយរបស់យើង ។

ព្រះគម្ពីរ១ពេត្រុស ២:៥,៩ ចែងថា: **នោះអ្នករាល់គ្នាក៏បានស្អាងឡើង ដូចជាថ្មរស់ដែរ ឱ្យបានធ្វើជាផ្ទះខាងឯវិញ្ញាណ ជាពួកសង្ឃបរិសុទ្ធ សំរាប់នឹងថ្វាយគ្រឿងបូជាខាងព្រលឹងវិញ្ញាណដែលព្រះទ្រង់សព្វព្រះហឫទ័យទទួល ដោយព្រះយេស៊ូវគ្រីស្ទ... តែអ្នករាល់គ្នាជាពូជជ្រើសរើស ជាពួកសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជារាស្ត្រដ៏ជាកេរ្តិ៍អាករនៃព្រះ ដើម្បីឱ្យអ្នករាល់គ្នាបានសំដែងចេញ ឱ្យឃើញអស់ទាំងលក្ខណៈរបស់ព្រះ ដែលទ្រង់បានហៅអ្នករាល់គ្នាចេញពីសេចក្តីងងឹត មកក្នុងពន្លឺអស្ចារ្យរបស់ទ្រង់ ។**

### ការជ្រើសរើសសម្រាប់ភាពជាសង្ឃ

ឥឡូវនេះព្រះយេស៊ូវទ្រង់ជាសម្តេចសង្ឃរបស់យើង ។

ព្រះគម្ពីរហេព្រើរ ៧:១៥-១៧ ចែងថា: **សេចក្តីនេះក៏រឹងរឹតតែច្បាស់ជាងទៅទៀត ដោយមានសង្ឃ១ផ្សេងទៀតកើតឡើង ទាមបែបលោកម៉ិលគីស្សាដែក សង្ឃនោះមិនបានតាំងឡើងតាមក្រិត្យវិន័យ ដែលមានសេចក្តីបញ្ញត្តិខាងសាច់ឈាមទេ គឺតាមព្រះចេស្តារបស់ជីវិតដ៏មិនចេះសូន្យឡើយនោះវិញ ដ្បិតមានសេចក្តីបន្ទាល់ពីទ្រង់ថា «ឯងជាសង្ឃនៅអស់កល្បជានិច្ច តាមរបៀបលោកម៉ិលគីស្សាដែក» ។**

ព្រះគម្ពីរហេព្រើរ ៨:១ ចែងថា: **រីឯដែលបង្រួមសេចក្តីអធិប្បាយទាំងប៉ុន្មានអម្បាញ់មិញនេះ នោះគឺថា យើងរាល់គ្នាមានសំដេចសង្ឃ១អង្គយ៉ាងនោះ ដែលទ្រង់បានគង់ខាងស្តាំបល្ល័ង្កនៃឫទ្ធានុភាពនៅស្ថានសួគ៌ ។**

**នគររបស់ពួកសង្ឃ**

ការសម្រេចព្រះទ័យរបស់ព្រះ សម្រាប់ពួកកូនចៅអ៊ីស្រាអែល គឺដែលពួកគេត្រូវតែនៅក្នុងនគររបស់ពួកសង្ឃ ។

ព្រះគម្ពីរនិក្ខមនំ ១៩:៦ក ចែងថា: **ឯងរាល់គ្នានឹងបានធ្វើជានគរដល់អញដែលសុទ្ធតែជាសង្ឃ ហើយជាសាសន៍បរិសុទ្ធឲ្យអញដែរ... ។**

ការសម្រេចព្រះទ័យរបស់ព្រះ គឺមិនមានការផ្លាស់ប្តូរឡើយ ។ អ្នកជឿគ្រប់រូប គឺជាសង្ឃ ។ ចាប់តាំងពីយើងរាល់គ្នាបាន "នៅក្នុងព្រះគ្រីស្ទ" មក នោះយើងបានចែកចាយនូវភាពជាសង្ឃរបស់ទ្រង់ ។

ព្រះគម្ពីរវិវរណៈ ១:៦ ចែងថា: **ព្រមទាំងតាំងយើងរាល់គ្នាឡើងជានគរ ហើយជាពួកសង្ឃថ្វាយព្រះដ៏ជាព្រះវរបិតា នោះសូមឲ្យទ្រង់បានសិរីល្អ និងព្រះចេស្តានៅអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន ។**

**ការដើរដោយមានតម្លៃចំពោះការត្រាស់ហៅរបស់យើង**

លោកសាវ័កប៉ុលបានជម្រុញ ឲ្យយើងរស់នៅជាជីវិតដែលមានតម្លៃចំពោះការត្រាស់ហៅរបស់យើង ។

ព្រះគម្ពីរអេភេសូរ ៤:១ ចែងថា: **ដូច្នេះ ខ្ញុំជាអ្នកជាប់គុកក្នុងព្រះអម្ចាស់ ខ្ញុំទូន្មានអ្នករាល់គ្នាថា ចូរឲ្យអ្នករាល់គ្នាដើរបែបគួរនឹងការងារ ដែលទ្រង់បានហៅមកធ្វើចុះ ។**

**ជារាស្ត្របរិសុទ្ធ**

ព្រះគម្ពីរហេព្រើរ ១២:១៤ ចែងថា: **ចូរដេញតាមសេចក្តីមេត្រីចំពោះមនុស្សទាំងអស់ចុះ ហើយឲ្យបានញែកជាបរិសុទ្ធដែរ បើអ្នកណាគ្មានសេចក្តីបរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ ។**

ព្រះគម្ពីរ១ពេត្រុស ១:១៥,១៦ ចែងថា: **តែចូរឱ្យអ្នករាល់គ្នាបានបរិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់ ដូចជាព្រះដែលហៅអ្នករាល់គ្នាទ្រង់បរិសុទ្ធដែរ ដ្បិតមានសេចក្តីចែងទុកមកថា «ចូរឱ្យឯងរាល់គ្នាបានបរិសុទ្ធ ដ្បិតអញជាបរិសុទ្ធ» ។**

ព្រះគម្ពីរអេភេសូរ ៥:២៧ ចែងថា: **ប្រយោជន៍នឹងថ្វាយពួកជំនុំនេះដល់ព្រះអង្គទ្រង់ ទុកជាពួកជំនុំដ៏ឧត្តម ឥតប្រឡាក់ ឥតជ្រួញ ឬមានអ្វីឱ្យដូចឡើយ គឺឱ្យបានបរិសុទ្ធ ហើយឥតកន្លែងបន្ទោសបានវិញ ។**

**ការប្រោះញែកជាស្អាត**

ការតម្រូវឱ្យមានសម្រាប់ការថ្វាយបង្គំ គឺមិនមានការផ្លាស់ប្តូរឡើយ ។ គ្រាន់តែព្រះទ្រង់បានតម្រូវ ឱ្យមានការងាររបស់ពួកសង្ឃដ៏ពិតប្រាកដ នោះទ្រង់ក៏បានតម្រូវឱ្យមានពួកគេ គឺជាយើងរាល់គ្នា ។

ព្រះគម្ពីរហេព្រើរ ១០:២២ ចែងថា: **នោះត្រូវឱ្យយើងចូលទៅជិតទាំងមានចិត្តស្មោះត្រង់ និងចិត្តដឹងពិតប្រាដក ហើយសេចក្តីជំនឿព្រមទាំងមានចិត្តប្រោះញែកជាស្អាត រួចពីបញ្ញាចិត្តដែលសៅហ្មងផង ហើយបានលាងរូបកាយនឹងទឹកដ៏ស្អាតដែរ ។**

តាមរយៈព្រះលោហិតរបស់ព្រះយេស៊ូវ នោះយើងរាល់គ្នាអាចចូលទៅឯព្រះវត្តមានរបស់ទ្រង់ ដោយមានសេចក្តីជឿជាក់នោះឯង ។

**ចិត្តរួមមកតែមួយ**

ព្រះគម្ពីរទំនុកដំកើង ៨៦:១១ ចែងថា: **ឱព្រះយេហូវ៉ាអើយ សូមបង្រៀនទូលបង្គំឱ្យស្គាល់ផ្លូវនៃទ្រង់ ទូលបង្គំនឹងដើរក្នុងសេចក្តីពិតរបស់ទ្រង់ សូមបំព្រួមចិត្តទូលបង្គំមក ឱ្យកោតខ្លាចដល់ព្រះនាមទ្រង់ ។**

"ចិត្តរបស់ទូលបង្គំបានរួមមកតែមួយ ដោយកោតខ្លាចដល់ព្រះនាមទ្រង់" គឺមានន័យថា ការនាំមកនូវគ្រប់ទាំងគំនិត ឱ្យបានរួមមកតែមួយក្នុងការថ្វាយបង្គំ ។ វាជាការប្រមាថដល់ព្រះ ចំពោះការថ្វាយបង្គំ

ទ្រង់ ដោយមិនស្មោះចំពោះ ប៉ុន្តែនៅក្នុងសេចក្តីពិត មានតែចិត្តគំនិតរបស់យើង ទៅលើរឿងរ៉ាវដទៃទៀតនោះវិញ!

ព្រះគម្ពីរយ៉ាកុប ៤:៨,១០ ចែងថា: **ត្រូវចូលទៅជិតព្រះ នោះទ្រង់នឹងចូលមកជិតអ្នករាល់គ្នាដែរ ឱពួកមានបាបអើយ ចូរលាងដៃឱ្យស្អាតចុះ ឱពួកអ្នកមានចិត្ត២អើយ ចូរសំអាតចិត្តឡើង... ចូរបន្ទាបខ្លួននៅចំពោះព្រះអម្ចាស់ នោះទ្រង់នឹងដំកើងអ្នករាល់គ្នាឡើង ។**

**ចិត្តបរិសុទ្ធ**

ព្រះគម្ពីរទំនុកដំកើង ២៤:៣,៤ ចែងថា: **តើអ្នកណានឹងឡើងទៅឯភ្នំនៃព្រះយេហូវ៉ា តើអ្នកណានឹងឈរនៅក្នុងទីបរិសុទ្ធរបស់ទ្រង់បាន គឺជាអ្នកដែលមានដៃស្អាត និងចិត្តបរិសុទ្ធ ជាអ្នកដែលមិនបណ្តោយឱ្យព្រលឹងខ្លួនទៅតាមសេចក្តីភូតភរ ហើយមិនបានស្បថប្រវ័ញ្ចគេឡើយ ។**

ការសម្អាតដៃ និងចិត្តឱ្យបានបរិសុទ្ធ គឺជាការបង្ហាញពីអារម្មណ៍របសខ្ញុំយើង ។

តើយើងកំពុងតែចូលទៅក្នុងការថ្វាយបង្គំ ដើម្បីឱ្យបានមើលឃើញនូវរឿងរ៉ាវដទៃទៀតឬអី?

តើយើងកំពុងតែថ្វាយបង្គំ ដើម្បីទទួលការចំណេញពីការឯកភាពរបស់ផងព្រះ និងចម្លើយយ៉ាងដូច្នោះ ចំពោះរឿងរ៉ាវខ្លះៗដែលយើងចង់បានឬអី?

យើងត្រូវតែធ្វើការប្រឡងពីអារម្មណ៍របស់យើងនៅចំពោះព្រះ ។

**វិញ្ញាណដែលខ្ទេចខ្ទាំ**

ព្រះគម្ពីរទំនុកដំកើង ៥១:១៧ ចែងថា: **ឯដង្វាយដែលគួរថ្វាយដល់ព្រះ នោះគឺជាវិញ្ញាណខ្ទេចខ្ទាំ ឱព្រះអង្គអើយ ទ្រង់មិនមើលងាយចំពោះចិត្តខ្ទេចខ្ទាំ ហើយទន់ទាបឡើយ ។**

វិញ្ញាណដែលខ្ទេចខ្ទាំ គឺជាការមួយដែលបានរៀនសូត្ររួចមកហើយ ពីការដាក់ពិន័យ និងការស្ដាប់បង្គាប់ ព្រមទាំងបានថ្វាយនូវភាពជាព្រះអម្ចាស់របស់ព្រះយេស៊ូវ ។

**ការគោរពប្រួសហេតុចំពោះព្រះ**

ព្រះគម្ពីរទំនុកដំកើង ៨៩:៧ ចែងថាៈ **ជាព្រះដែលគួរស្ញែងខ្លាចណាស់ នៅក្នុងទីប្រជុំនៃអស់អ្នកបរិសុទ្ធ ក៏គួរកោតខ្លាចលើសជាងអស់អ្នកនៅជុំវិញទ្រង់ផង ។**

**ការញែកខ្លួនចេញពីលោកិយ**

ព្រះគម្ពីរកូល៉ូស ១:១៣ ចែងថាៈ **ទ្រង់បានប្រោសឱ្យយើងរួចពីអំណាចនៃសេចក្ដីងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់ ។**

## **សម្លៀកបំពាក់ដល់ភាពជាសង្ឃរបស់យើង**

**កាស្លៀកពាក់នូវសេចក្ដីសង្គ្រោះ**

ព្រះគម្ពីរហេព្រើរ ១២:១៤ ចែងថាៈ **ចូរដេញតាមសេចក្ដីមេត្រីចំពោះមនុស្សទាំងអស់ចុះ ហើយឱ្យបានញែកជាបរិសុទ្ធដែរ បើអ្នកណាគ្មានសេចក្ដីបរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ ។**

➢ *សម្លៀកបំពាក់នៃការសរសើរ*

ព្រះគម្ពីរអេសាយ ៦១:៣ ចែងថាៈ **នឹងចែកឱ្យដល់ពួកអ្នកដែលសោយសោកនៅក្រុងស៊ីយ៉ូនបានភួងលំអជំនួសផេះ ហើយប្រេងនៃសេចក្ដីអំណរជំនួសសេចក្ដីសោកសៅ ព្រមទាំងអាវពាក់នៃសេចក្ដីសរសើរជំនួសទុក្ខធ្ងន់ដែលគ្របសង្កត់ ដើម្បីឱ្យគេបានហៅថា ជាដើមឈើនៃសេចក្ដីសុចរិត គឺជាដើមដែលព្រះយេហូវ៉ាបានដាំ មានប្រយោជន៍ឱ្យទ្រង់បានថ្កើងឡើង ។**

វាជាការសំខាន់ដែលយើងបានស្លៀកពាក់ នូវសម្លៀកបំពាក់នៃការសរសើររបស់យើង ។ ការសំខាន់ដ៏ធំធេង គឺត្រូវបានប្រទានមកនៅក្នុងព្រះបន្ទូល ទៅដល់ការសំខាន់នៃសម្លៀកបំពាក់របស់ពួកសង្ឃ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ យើងគឺជាអ្នកជឿជាសង្ឃខាងឯវិញ្ញាណ ហើយសម្លៀកបំពាក់របស់យើង ក៏ខាងឯវិញ្ញាណដែរ ។

➢ *សម្លៀកបំពាក់ខ្លួតទេសគឺតំណាងឱ្យសេចក្តីសុចរិត*

ព្រះគម្ពីរវិវរណៈ ៧:៩ ចែងថាៈ **ក្រោយនោះមក ខ្ញុំក្រឡេកទៅឃើញមនុស្ស១ហ្វូងយ៉ាងធំ ដែលគ្មានអ្នកណាអាចនឹងរាប់បានឡើយ គេមកពីគ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ ហើយគ្រប់ទាំងភាសា ក៏ឈរនៅមុខបល្ល័ង្ក និងកូនចៀម ទាំងពាក់អាវសវែង ហើយកាន់ធាងចាកនៅដៃ ។**

ព្រះគម្ពីរវិវរណៈ ១៩:៨ ចែងថាៈ **ទ្រង់ប្រទានឱ្យនាងបានស្លៀកពាក់សំពត់ទេសយ៉ាងម៉ដ្ឋ ស្អាតហើយភ្លឺ ដ្បិតសំពត់ទេសយ៉ាងម៉ដ្ឋ នោះជាសេចក្តីសុចរិតរបស់ពួកបរិសុទ្ធ ។**

## ការថ្វាយដង្វាយក្នុងភាពជាសង្ឃរបស់យើង

**ដង្វាយនៃការអរព្រះគុណ ការសរសើរ**

មានគោលបំណង និងមុខងារជាច្រើន របស់ពួកសង្ឃនៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺនៅក្នុងការថ្វាយដង្វាយ ដែលពួកគេបានធ្វើថ្វាយទៅព្រះ ។ នៅសម័យសព្វថ្ងៃនេះ យើងក៏មានដង្វាយដ៏ច្បាស់លាស់ និងមានន័យ ដែលយើងត្រូវតែធ្វើថ្វាយទៅព្រះ ។

យើងត្រូវតែចូលទៅឯព្រះវត្តមានរបស់ទ្រង់ដោយការសរសើរ ។

ព្រះគម្ពីរទំនុកដំកើង ១០០:៤ ចែងថាៈ **ចូរនាំគ្នាចូលតាមទ្វារទ្រង់ ដោយពោលពាក្យអរព្រះគុណ ហើយចូលទៅក្នុងទីលានទ្រង់ ដោយបទសរសើរ ចូរអរព្រះគុណដល់ទ្រង់ ហើយសរសើរព្រះនាមទ្រង់ចុះ ។**

**ភាពជាម្ចាស់របស់យើង**

យើងត្រូវតែចូលឯព្រះវត្តមានរបស់ទ្រង់ដោយការថ្វាយដង្វាយ ។

ព្រះគម្ពីរសុភាសិត ៣:៩,១០ ចែងថាៈ **ចូរថ្វាយកិត្តិនាមដល់ព្រះយេហូវ៉ា ដោយទ្រព្យសម្បត្តិ ហើយនិងផលដំបូង ពីសេចក្តីចំរើនរបស់ឯងទាំងអំបាលម៉ានចុះ យ៉ាងនោះ អស់ទាំងជង្រុកឯងនឹងបានពេញបរិបូរ ឯអស់ទាំងធុងឯង នឹងបានទឹកទំពាំងបាយជូរហូរហៀរផង ។**

**ចំពោះខ្លួនយើងផ្ទាល់**

យើងត្រូវតែនាំយកនូវដង្វាយ ដោយខ្លួនយើងផ្ទាល់ ។

ព្រះគម្ពីររ៉ូម ១២:១ ចែងថាៈ **ដូច្នេះ បងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នាដោយសេចក្តីមេត្តាករុណានៃព្រះ ឲ្យបានថ្វាយរូបកាយទុកជាយញ្ញបូជារស់ ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ជាការគោរពនៃអ្នករាល់គ្នា ដែលមានទំនង ។**

ព្រះគម្ពីរ១ថែស្សាឡូនិច ៥:២៣ ចែងថាៈ **សូមឲ្យព្រះនៃសេចក្តីសុខសាន្ត ញែកអ្នករាល់គ្នាចេញជាបរិសុទ្ធសព្វគ្រប់ ហើយឲ្យទាំងព្រលឹង និងវិញ្ញាណ ហើយរូបកាយទាំងមូលបានបំរុងទុកឥតសៅហ្មង ដរាបដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងទ្រង់យាងមក ។**

**ដង្វាយនៃការសរសើរ**

ព្រះគម្ពីរហេព្រើរ ១៣:១៥,១៦ ចែងថាៈ **ដូច្នេះ ត្រូវឲ្យយើងរាល់គ្នាថ្វាយពាក្យសរសើរ ដោយសារទ្រង់ទុកជាគ្រឿងបូជាដល់ព្រះជានិច្ច គឺជាផលនៃបបូរមាត់ ដែលថ្លែងប្រាប់ពីព្រះនាមទ្រង់ កុំឲ្យភ្លេចនឹងធ្វើគុណ ហើយចែកចាយឡើយ ដ្បិតព្រះទ្រង់សព្វព្រះហឫទ័យនឹងគ្រឿងបូជាយ៉ាងនោះ ។**

ពាក្យថា "យញ្ញបូជា" (sacrifice) គឺបញ្ជាក់ថា ការសរសើរតម្កើងមិនមែនងាយស្រួល ឬស្រណុកជានិច្ចនោះទេ ។ ហើយវាក៏ត្រូវតែបានគេថ្វាយជាបន្តទៅជានិច្ចនោះដែរ ។

## ការរស់នៅជាសង្ឃ ឬការគាំទ្រទម្លាប់ចាស់

ជារៀងរាល់ថ្ងៃ យើងត្រូវបានប្រឈមមុខជាមួយនឹងការសម្រេចចិត្ត ។ តើយើងរស់នៅជាសង្ឃ ឬយើងត្រូវគាំទ្រចំពោះទម្លាប់ចាស់របស់យើង ផ្លូវដែលត្រូវធ្វើជាធម្មតាៗរបស់យើង?

ព្រះគម្ពីរ១ពេត្រុស ២:៥ ចែងថា: **នោះអ្នករាល់គ្នាក៏បានស្អាងឡើង ដូចជាថ្មរស់ដែរ ឱ្យបានធ្វើជាផ្ទះខាងឯវិញ្ញាណ ជាពួកសង្ឃបរិសុទ្ធ សំរាប់នឹងថ្វាយគ្រឿងបូជាខាងព្រលឹងវិញ្ញាណដែលព្រះទ្រង់សព្វព្រះហឫទ័យទទួល ដោយព្រះយេស៊ូវគ្រីស្ទ ។**

### ចូលទៅនៅពេលពួកសង្ឃបានចូល

លោកអើរ៉ុនដ៏ជាសង្ឃ បានចូលទៅក្នុងរោងឧបោសថរបស់លោកម៉ូសេជាប្រចាំថ្ងៃ ក្រោយមកទៀត ក៏ចូលទៅក្នុងព្រះវិហាររបស់ស្តេចសាឡូម៉ូន ។

នៅសម័យសព្វថ្ងៃនេះ យើងក៏ត្រូវតែចូលមកឯព្រះវត្តមាន របស់ទ្រង់ជាប្រចាំថ្ងៃដែរ ។

រោងឧបោសថរបស់លោកម៉ូសេ មានទ្វាររបងដែលឱ្យបើកឱ្យចូលទៅឯទីលាន ។ ពួកសង្ឃបានចូលទៅតាមផ្លូវនេះ ដើម្បី "បំពេញការងារថ្វាយព្រះយេហូវ៉ា" នៅក្នុងទីបរិសុទ្ធ ។ ក្នុងមួយឆ្នាំ១ សម្តេចសង្ឃបានចូលទៅក្នុងទីបរិសុទ្ធបំផុត ដែលមានហឹបនៃសេចក្តីសញ្ញានៅក្នុងនោះ ។

ទីបរិសុទ្ធគឺជាតំណាងឱ្យស្ថានសួគ៌ដែលនៅលើផែនដី គឺជាបន្ទប់ដែលមានបល្ល័ង្កនៃព្រះ ។ រីឯហឹបនៃសេចក្តីសញ្ញា ដែលបានគ្របទីសន្តោសប្រោស គឺជាប្រភេទនៃបល្ល័ង្កនៃព្រះ ។ ដើម្បីឱ្យបាននៅក្នុងទីបរិសុទ្ធ គឺត្រូវតែបាននៅក្នុងព្រះវត្តមាននៃព្រះ ។

នៅពេលដែលព្រះយេស៊ូវទ្រង់បានសុគតនៅលើឈើឆ្កាង នោះវាំងនន ដែលបាំងទីបរិសុទ្ធ និងទីបរិសុទ្ធបំផុត ក៏របែកពុះជាពីរចាប់ពីលើចុះមកក្រោម ។ មនុស្សជាតិគឺមិនត្រូវបាននៅដាច់ចេញពីព្រះអស់រយៈ

កាលយូរតទៅទៀតឡើយ ។ ឥឡូវនេះ តាមរយៈព្រះលោហិតរបស់ព្រះយេស៊ូវ អ្នកជឿគ្រប់រូបអាចចូទៅឯព្រះវត្តមាននៃព្រះដោយមានសេចក្តីក្លាហាន ។

សូម្បីតែពេលមានការជឿនទៅមុខចំពោះ "ការចូលទៅខាងក្នុង" ដោយពួកសង្ឃនៅក្នុងគ្រាសញ្ញាចាស់ក៏ដោយ ក៏នៅមានការជឿនទៅមុខនៅពេលដែលយើងបានចូលមកក្នុងព្រះវត្តមនានៃព្រះ ជាប្រចាំថ្ងៃនោះផងដែរ ។ យើងរាល់គ្នាត្រូវតែ "ចូលទៅខាងក្នុង" គឺយើងត្រូវចូលទៅខាងក្នុងជាប្រចាំថ្ងៃដោយផ្ទាល់ខ្លួន ក្នុងការសរសើរតម្កើង និងការថ្វាយបង្គំ ។ យើងក៏ត្រូវតែចូលទៅខាងក្នុងជារួម នៅពេលដែលយើងរួបរួមគ្នាជាបងប្អូនផងដែរ ។

➢ *ត្រូវចូលទៅតាមទ្វារ*

ព្រះគម្ពីរទំនុកដំកើង ១០០:៤ ចែងថាៈ **ចូរនាំគ្នាចូលតាមទ្វារទ្រង់ ដោយពោលពាក្យអរព្រះគុណ**...

ដើម្បី "ចូលទៅ" តាមតម្រូវការដោយមានសកម្មភាពនៃការស្តាប់បង្គាប់ ។ យើងត្រូវតែចូលទៅដោយអរព្រះគុណ មិនមែនដោយចិត្តអកតញ្ញូនោះទេ ។ ទីមួយគឺជាចម្រៀងរបស់យើងត្រូវតែបានជាការចង្អុលបង្ហាញ នូវចិត្តរបស់យើងដែលមានពេញដោយការអរព្រះគុណដល់ព្រះអម្ចាស់ ។ នៅពេលដែលយើងចាប់ផ្តើមអរព្រះគុណ ហើយបន្ទាប់មកត្រូវសរសើរតម្កើងដល់ទ្រង់ នោះយើងត្រូវធ្វើចលនាចេញពីព្រឹត្តិការណ៍ជាលក្ខណៈធម្មជាតិដែលនៅជុំវិញយើង ឱ្យបានចូលទៅក្នុងតំបន់ខាងឯវិញ្ញាណ ។

➢ *ទីលាន*

**....ហើយចូលទៅក្នុងទីលានទ្រង់ ដោយបទសរសើរ...**

នៅពេលដែលយើងឆ្លងកាត់ទ្វារ នោះយើងបានចូលទៅនៅក្នុងទីលាន ។ យើងត្រូវតែត្រៀមខ្លួន ដើម្បីប្រញាប់ប្រញាល់ចូលទៅក្នុងទី

បរិសុទ្ធ នៃព្រះវិត្តមានរបស់ព្រះអង្គ គឺចូលទៅក្នុងពេលវេលាដ៏ស្និទ្ធស្នាលបំផុត នៃការថ្វាយបង្គំដ៏មានចិត្តព្រឺព្រួច រហូតដល់យើងបានចំណាយពេលនៅក្នុងទីលាននៃការសរសើរតម្កើងនោះ ។ នៅក្នុងទីលាន យើងកំពុងតែស្ថិតនៅក្នុងការបង្រៀនសរសើរតម្កើង ។ យើងមានសេចក្ដីអំណរអរសប្បាយដែលបានចូលទៅក្នុងការប្រគំបទភ្លេង ការច្រៀងចម្រៀង ការទះដៃ និងការសរសើរដោយដៃរបស់យើងចំពោះព្រះអម្ចាស់ ក្នុងពេលជារឿយៗ យើងក៏មានការលោតរាំនៅចំពោះព្រះអម្ចាស់ គឺនៅពេលដែលយើងបង្ហាញពីការសរសើរតម្កើងរបស់យើងចំពោះទ្រង់ ។

➢ *ទីបរិសុទ្ធ*

**...ចូរអរព្រះគុណដល់ទ្រង់ ហើយសរសើរព្រះនាមទ្រង់ចុះ ។**

នៅពេលដែលយើងមានការបង្អែបង្អង់ នឹងចូលទៅក្នុងទីលាននៃការសរសើរ នោះយើងមានអារម្មណ៍ថាបានចូលមកកាន់តែជិត នៅក្នុងព្រះវត្តមាននៃព្រះ ។ យើងមានជ័យជម្នះដោយការស្វែងរក ហើយដឹងថាទ្រង់ជាអ្នកណា ។ យើងចូលទៅក្នុងទម្រង់កាន់តែខ្ពស់ឡើងនៃការសរសើរតម្កើងនោះ ។ យើងរកឃើញដោយខ្លួនឯង នៅទីលានផ្នែកខាងក្នុង គឺនៅក្នុងទីដ៏បរិសុទ្ធនោះ ។

យើងក៏មិនមែនចំណាយពេលក្នុងការលោតរាំ ឬការទះដៃរបស់យើងយូរពេកឡើយ ។ យើងស្ថិតនៅក្នុងការចូលទៅក្នុងព្រះវត្តមាននៃព្រះ ដោយទះដៃ និងចាប់ផ្ដើមសរសើរតម្កើងដល់ទ្រង់ ដោយមានអារម្មណ៍ដ៏គួរឱ្យព្រឺព្រួចនោះបានតែក្នុងរយៈពេលខ្លីប៉ុណ្ណោះ ។ ការប្រគំបទភ្លេងក៏ត្រូវតែបន្ថយកាន់តែយឺតទៅៗ រហូតដល់ពេលត្រូវបញ្ឈប់ ។ តើ "លំដាប់លំដោយ" អ្វីទៅតែក្នុងរយៈពេលមួយភ្លែតប៉ុណ្ណោះ ហើយក៏បានត្រូវផ្លាស់ប្ដូរទៅ ។ ភាពបរិសុទ្ធនៃព្រះវត្តមានរបស់ព្រះ គឺស្ទើរតែជាការដ៏លើសលប់បំផុតនោះឯង ។

➢ *ទីបរិសុទ្ធបំផុត*

នៅពេលនោះ ក៏មានទឹកភ្នែកហូរធ្លាក់មកតាមផែនថ្ពាល់របស់យើងរាល់គ្នា ។ ជួនកាល គ្រប់ការទាំងអស់ដែលយើងអាចធ្វើ គឺត្រូវតែបញ្ឈប់ការប្រគំបទភ្លេង ការច្រៀងចម្រៀង និងការដែលមានទាំប៉ុន្មាននោះឱ្យនៅស្ងៀម នៅចំពោះព្រះវត្តមានដ៏បរិសុទ្ធនៃព្រះ ។ យើងក៏ត្រូវតែមានការប្រយ័ត្នប្រយែងចំពោះអស់អ្នកដែលនៅជុំវិញយើងផងដែរ ។ និយាយរួម គឺយើងត្រូវប្រយ័ត្នប្រយែងសម្រាប់ព្រះ ។ យើងកំពុងឈរកំពុងលុតជង្គង់ចុះ ជួនកាល សូម្បីតែមានការដុនដាបនៅក្នុងព្រះវត្តមាននៃទ្រង់ នោះក៏បាត់អស់ដែរ ដោយសារសេចក្ដីស្រឡាញ់របស់ផងទ្រង់ ។

បើគ្មានកន្លែងស្ពុកនៅនេះទេ ដែលយើងបានឆ្លងផុតទៅក៏ឥតប្រយោជន៍ដែរ សូម្បីតែសម្ដេចសង្ឃជំនាន់ដើម ដែលបានធ្លាប់ចេញចូលពីទីបរិសុទ្ធ តៅទីបរិសុទ្ធបំផុតក៏ដោយ ក៏មិនអាចដំណើរការទៅបានល្អឡើយ ។

យើងមានគំរូនៃការដែលគួរឱ្យព្រឺព្រួចមួយរបស់ព្រះ នៅពេលដែលហឹបនៃសេចក្ដីសញ្ញា ត្រូវបាននាំចូលទៅក្នុងព្រះវិហាររបស់ស្ដេចសាឡូម៉ូន

ព្រះគម្ពីរ១ពង្សាវតារក្សត្រ ៨:១០,១១ ចែងថាៈ **លុះពួកសង្ឃបានចេញពីទីបរិសុទ្ធមកវិញ នោះពពកក៏មកពេញក្នុងព្រះវិហារនៃព្រះយេហូវ៉ា លំម្ល៉េះបានជាពួកសង្ឃឈរធ្វើការងារពុំបាន ដោយព្រោះពពកនោះ ដ្បិតសិរីល្អនៃព្រះយេហូវ៉ាបាននៅពេញក្នុងព្រះវិហារនៃព្រះអង្គហើយ ។**

**ឬជាការប្រកាន់ខ្ជាប់តាមទម្លាប់ចាស់**

មានមនុស្សជាច្រើនដែលនៅក្នុងពួកជំនុំ ពីសម័យចាស់គឺរបស់គេ គឺមានការច្រៀងយ៉ាងទន់ភ្លន់ និងយ៉ាងស្រងូតស្រងាត់ ដែលស្រង់ចេញពីសៀវភៅទំនុកតម្កើង គឺដែលមានអារម្មណ៍នោតល្ងង់ នៅក្នុងការ

បើកសម្ដែងនូវការសរសើរតម្កើងរបស់ពួកគេនោះ ។ មានមនុស្សជាច្រើន មានអារម្មណ៍ថា វាមិនអាច "ជាការស្អាងឡើង" បានទេ ចំពោះការបើក សម្ដែងក្នុងការសរសើរតម្កើងដល់ព្រះនោះ ។ ស្ដេចដាវីឌបានសរសេរថា:

**ឱពួកអ្នកសុចរិតអើយ ចូរមានចិត្តរីករាយក្នុងព្រះយេហូវ៉ាចុះ ដ្បិតសេចក្ដីសរសើរនោះ សំណំដល់មនុស្សទៀងត្រង់** (ទំនុកដំកើង ៣៣:១) ។

ព្រះគម្ពីរទំនុកដំកើង ១៤៧:១ ចែងថា: **ចូរសរសើរដល់ព្រះ យេហូវ៉ា ដ្បិតការដែលច្រៀងសរសើរ ដល់ព្រះនៃយើងខ្ញុំ នោះជាការ សំណំហើយ ក៏ពិរោះផង សេចក្ដីសរសើរជាការគួរគប្បី ។**

យើងត្រូវតែជ្រើសរើសនូវការស្ដាប់បង្គាប់ដល់ព្រះ ។ យើងត្រូវ តែឈានមួយជំហាន១ គឺជាការកម្សាន្តចិត្ត ដល់អ្នកជំនាន់ចាស់របស់យើង ព្រមទាំងចូលទៅឱ្យបានពេញលេញទាំងស្រុង ទៅក្នុងការបើកសម្ដែងនៃ ការសរិរតម្កើងនៅក្នុងព្រះគម្ពីរ ដើម្បីទទួលពីគ្រប់ការទាំងអស់ដែលព្រះ ទ្រង់បានធ្វើសម្រាប់យើង ។

ព្រះទ្រង់មានហេតុផលសម្រាប់សេចក្ដីបង្រៀនដល់យើង ឱ្យមាន សេចក្ដីអំណរអរសប្បាយ ឱ្យបានទះដៃ ស្រែកហោរ និងលោតរាំផងដែរ។ ការសរសើរតម្កើងរបស់យើងរាល់គ្នា គឺកំពុងតែបានសម្រេចនៅក្នុងទ្រង់ ហើយយើងត្រូវការការប្រទានពរនោះ ។ ផលកម្រៃគឺសម្រាប់យើងរាល់ គ្នា!

## សំណួររំឭកសារឡើងវិញ

**១** ចំពោះពួកសង្ឃ ដែលនៅក្នុងព្រះគម្ពីរសញ្ញាចាស់ បានស្លៀកពាក់នូវសម្លៀកបំពាក់ ដែលពិតប្រាកដ ។ ចូរពណ៌នាពី "សម្លៀកបំពាក់" នៃភាពជាសង្ឃនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។

**២** តើអ្វីទៅជាការថ្វាយតង្វាយ ដែលយើងត្រូវតែថ្វាយទៅដល់ព្រះ?

**៣** ចូរពណ៌នានូវការជឿនទៅមុខនៃការចូលទៅឯព្រះវត្តមាននៃព្រះ ដែលយើងត្រូវតែបញ្ជាក់បង្ហាញ នៅក្នុងការសរសើរតម្កើង និងការថ្វាយបង្គំនោះ?

# មេរៀនទី ១៣

## *ជ័យជម្នះតាមរយៈការសរសើរតម្កើង និងការថ្វាយបង្គំ*

### ការថ្វាយបង្គំដោយវិញ្ញាណ

ព្រះយេស៊ូវទ្រង់មានបន្ទូលថាៈ

**ឯព្រះទ្រង់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់ នោះត្រូវតែថ្វាយបង្គំដោយវិញ្ញាណ និងសេចក្តីពិតដែរ** ( យ៉ូហាន ៤:២៤) ។

យើងអាចសរសើរតម្កើងដល់ព្រះ ដោយអស់ពីចិត្ត អស់ពីព្រលឹង និងអស់កម្លាំងរបស់យើង ។ ប៉ុន្តែ យើងអាចថ្វាយបង្គំទ្រង់ ដោយវិញ្ញាណតែប៉ុណ្ណោះ ។

ដូចជាសម្តេចសង្ឃនៅថ្ងៃនៃការលាងទោសរបស់ខ្លួន ដែលយើងមើលឃើញប្រាំងនៃវាំងននទៅខាងក្នុង ។ នេះគឺជាការដ៏គួរឱ្យព្រឺព្រួច នៅក្នុងពេលមួយរំពេចនោះ ។ ប្រសិនបើសម្តេចសង្ឃបានមានបាបនៅក្នុងជីវិតរបស់គាត់ នោះគាត់ត្រូវតែដឹងថា គាត់នឹងត្រូវស្លាប់នៅចំពោះព្រះវត្តមានដ៏បរិសុទ្ធនៃព្រះ ។ ចំពោះរឿងរ៉ាវដែលយើងបានទទួលនៅក្នុងទីលាន នោះនឹងមិនត្រូវបានទទួលការអនុញ្ញាត ឱ្យនៅបានយូរអង្វែង នៅក្នុងជីវិតរបស់យើងនោះទេ ។ វានឹងត្រូវបានជាថ្ងៃ ដែលលោកអាន៉ានាសនិងនាងសាភីរ៉ា បានកុហក់ព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងព្រះគម្ពីរកិច្ចការជំពូកទី៥នោះឯង ។

ដើម្បីថ្វាយបង្គំដោយសេចក្តីពិត នោះមានន័យថា "គ្មានការលាក់កំបាំង" ណាមួយឡើយ ។ យើងឈរនៅទីភ្លឺ គឺជាទីបើកចំហនៅចំពោះទ្រង់ ដោយគ្មានការលាក់កំបាំងណាមួយឡើយ ។ ដូចជាសម្តេចសង្ឃពីជំនាន់ចាស់ យើងត្រូវតែប្រុងប្រៀបរៀបចំដោយខ្លួនឯង ចំពោះការចូលមកក្នុងព្រះវត្តមាននៃទ្រង់ ។ គ្រប់អំពើបាបទាំងអស់ គឺត្រូវតែបានទទួលនូវការអត់ទោសឱ្យ និងបានទទួលនូវការសម្អាត ដោយព្រះលោហិតរបស់ព្រះយេស៊ូវ ។

ព្រះគម្ពីរ១យ៉ូហាន ១:៩ ចែងថា: **បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឱ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង ។**

**ការបកស្រាយនៅផ្នែកខាងក្នុងនៃវាំងនន**

នៅថ្ងៃនៃការលាងទោសរបស់ខ្លួន នោះសម្តេចសង្ឃបានឈរនៅក្នុងទីបរិសុទ្ធ ទាំត្រៀមខ្លួនដើម្បីចូលទៅផ្នែកខាងក្នុងនៃវាំងនន ។ គាត់មានដំបងឈើនៅក្នុងដៃម្ខាង ហើយដៃម្ខាងទៀតកាន់ចានខ្លាំដាក់ពេញដោយឈាម ។ រីឯវាំងននបានលាតសន្ធឹង ពីជញ្ជាំងម្ខាងទៅដល់ជញ្ជាំងម្ខាងទៀត គឺចាប់ពីកម្រាលទៅដល់ពិដាន ។ គ្មានផ្លូវចូលទៅតាមខាងក្រោម ខាងលើ ឬតាមចំហៀងឡើយ ។ ក៏គ្មានទ្វារសម្រាប់ចូលដែរ ។

អ្នកនិពន្ធព្រះគម្ពីរហេព្រើរបានសម្តែងពីការនេះចែងថា:

**យ៉ាងនោះព្រះវិញ្ញាណបរិសុទ្ធសំដែងថា កាលរោងឧបោសថមុននោះនៅ៧ឡើយ នោះផ្លូវចូលទៅក្នុងទីបរិសុទ្ធបំផុត មិនទាន់បើកទេ** (ហេព្រើរ ៩:៨) **។**

នៅពេលដែលសង្ឃបានចូលទៅខាងក្នុងនៃវាំងនន គាត់បានចូលទៅតាមព្រះវិញ្ញាណ ។ គាត់បានចូលមកថ្វាយបង្គំ "ដោយវិញ្ញាណ និងសេចក្តីពិត" ។ តើវាអាចបានឬទេដែលថា សម្តេចសង្ឃបានបកស្រាយខាងវិញ្ញាណដែលនៅខាងក្នុងនៃវាំងនន គឺដែលលោកសាវ័កភីលីពបានបកស្រាយ ដោយព្រះវិញ្ញាណ គឺពេលដែលចេញពីទឹកដែលទើបតែបានធ្វើពិធីជ្រមុជឱ្យអ្នកកម្រៀវនៅទីក្រុងអេភេសូរ ដែលធ្វើណើរទៅកាន់ទីក្រុងអេម៉ោសនោះ?

ដើម្បីចូលទៅក្នុងការថ្វាយបង្គំដោយសេចក្តីពិត នោះយើងត្រូវតែបានរើចូលទៅខាងក្នុងតំបន់នៃព្រះវិញ្ញាណ ។ ព្រះដ៏ជាព្រះវិញ្ញាណ និងព្រះយេស៊ូវទ្រង់មានបន្ទូលថា អស់អ្នកដែលថ្វាយបង្គំទ្រង់ គឺត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណ ។

## ការបង្កើនបង្អង់នីចូលទៅក្នុងព្រះវត្តមានរបស់ទ្រង់

នៅពេលដែលយើងចូលទៅក្នុងព្រះវត្តមានរបស់ទ្រង់ នោះចិត្តរបស់យើងកំពុងតែនិយាយជាមួយនឹងស្តេចដាវីឌថា "ទូលបង្គំចង់ស្វែងរកព្រះភ័ក្ត្រទ្រង់" ។ តើយើងបានស្វែងរកព្រះហស្តរបស់ព្រះដោយញឹកញាប់របៀបណាហ្ន៎! គឺជាការសម្រេចចិត្តតាមផ្នែកសាច់ឈាមរបស់យើង ត្រូវបានសម្រេច ។

មានពេលជាច្រើន ដែលយើងបានចូលមកឯព្រះវត្តមានប្រកបដោយការព្រឺព្រួចរបស់ផងទ្រង់ គឺកំឡុងពេលនៃការថ្វាយបង្គំជារួម ។ ការទទួលអារម្មណ៍នៃការចាក់ប្រេងតាំងដ៏គួរឱ្យព្រឺព្រួចរបស់ព្រះ ក៏មានអ្នកខ្លះបានចាកចេញពីការនេះ ជាលក្ខណៈទូលតែម្នាក់ឯង ហើយក៏បានវិលបែរទៅរកការនៅ "ខាងក្រៅទីលាន" ដើម្បីផ្តល់ឱ្យនូវការនិយាយភាសាដទៃចេញមក ទាំងមានការបកប្រែ ឬជាការទាយទំនាយជាដើម ។ ក្នុងពេលភ្លាមៗនោះ ការចាក់ប្រេងតាំងដ៏ខ្លាំងក្លាបានចេញមក ហើយពួកបណ្តាជនក៏បានសូមឱ្យអង្គុយនៅ ហើយយើងរាល់គ្នាក៏បានសម្រេចចិត្តធ្វើតាម "កម្មវិធីដែលមាននោះ" ។

ព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ ក៏មិនទុកឱ្យយើងនៅតែឯងដែរ ។ តើទ្រង់បានទុកឱ្យយើងនៅ និងចំណាយពេលជាមួយនឹងទ្រង់យូរប៉ុណ្ណាទៅហ្ន៎!

យើងត្រូវការរៀនសូត្រពីការបង្អង់ចាំនូវព្រះវត្តមានរបស់ទ្រង់ ។

## ការអនុលោមតាមរូបភាពរបស់ទ្រង់

នៅក្នុងទីលាន គឺនៅពេលដែលយើងកំពុងតែលោតរាំ នៅចំពោះព្រះអម្ចាស់ដ៏មានគ្រប់ទាំងឫទ្ធិអំណាចរបស់យើង គឺជាការរកឃើញអ្វីមួយដ៏សំខាន់ ចូលមកក្នុងវិញ្ញាណ ។ ឃ្លាំងផ្ទុកទម្លាប់សាសនា ព្រមទាំងការព្រងើយកន្តើយខាងឯវិញ្ញាណ ត្រូវបានទម្លាក់ចេញហុងស់ហើយ ។ កម្ទិច

កម្មីចិត្តរបស់យើង ដូចជាដីឥដ្ឋនៅក្នុងដៃរបស់ស្មូនឆ្នាំង គឺត្រូវបានឡើងទន់ជ្រាយ និងក្តៅឧណ្ហៗនៅចំពោះព្រះ ។

កំឡុងពេលនៃការថ្វាយបង្គំ គឺមានរយៈពេលយូរ និងកាន់តែជិតស្និទ្ធ គឺនៅពេលទ្រង់បានទ្រយើង ឱ្យកាន់តែជិតស្និទ្ធដោយព្រះអង្គទ្រង់ផ្ទាល់ ដូចជាដីឥដ្ឋដែលមានភាពទន់ជ្រាយ ដែលបានច្របាច់ចូលទៅក្នុងពុម្ព នោះយើងបានត្រូវទទួលនូវការសម្រេបទៅតាមរូបភាពរបស់ព្រះអង្គ ។

ព្រះគម្ពីររ៉ូម ៨:២៩ ចែងថា: **ដ្បិតអ្នកណាដែលទ្រង់បានស្គាល់ជាមុន នោះទ្រង់ក៏ដៅវទុកជាមុន ឱ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់ ដើម្បីឱ្យព្រះរាជបុត្រាបានធ្វើជាបងច្បងគេ ក្នុងពួកបងប្អូនជាច្រើន ។**

ព្រះគម្ពីរ២កូរិនថូស ៣:១៨ ចែងថា: **ហើយយើងរាល់គ្នាទាំងអស់ ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់ ទាំងមុខទទេ ដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់ យើងកំពុងតែផ្លាស់ប្រែទៅ ឱ្យដូចជារូបឆ្លុះនោះឯងពីសិរីល្អទៅដល់សិរីល្អ គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ ។**

## ការសង់អាសនានៃការថ្វាយបង្គំ

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ទាំងមូល មានការសាងសង់អាសនានៃការសរសើរជាច្រើន ជាលក្ខណៈបុគ្គល និងជាក្រុម សម្រាប់ការអ្វីដែលព្រះទ្រង់បានធ្វើរួចមកហើយ ។ ពាក្យជាភាសាហេព្រើរសម្រាប់អាសនាមានន័យថា "ទីសក្ការបូជា" ។

ព្រះទ្រង់នៅតែមានបន្ទូលដល់ពួកបណ្តាជន អំពីការសង់អាសនាខាងឯវិញ្ញាណ ។ យើងធ្វើយ៉ាងដូច្នេះ គឺដោយការចូលមកឯទ្រង់ជាលក្ខណៈទោល ឬជាក្រុម ការធ្វើយញ្ញបូជាគឺតាមរយៈការសរសើរតម្កើង និងការថ្វាយបង្គំ ។

## លោកអ័ប្រាហាំនៅភ្នំម៉ូរីយ៉ា

នៅពេលដែលយើងបានសិក្សានៅក្នុងមេរៀនទី១ នៅពេលដំបូង

ពាក្យ "ថ្វាយបង្គំ" គឺត្រូវបានប្រើនៅពេលដែលលោកអ័ប្រាហាំមានបំណងនឹងសង់អាសនាមួយនៅលើភ្នំម៉ូរីយ៉ា ដោយការស្តាប់បង្គាប់តាមព្រះរាជបញ្ញត្តិរបស់ព្រះ ឱ្យថ្វាយកូនប្រុសរបស់គាត់គឺលោកអ៊ីសាកទុកជាយញ្ញបូជា ។

ព្រះគម្ពីរលោកុប្បត្តិ ២២:៥ ចែងថា: **រួចប្រាប់ទៅបាវថា ចូរឯងនៅទីនេះសិនមើលលាផង អញនឹងទៅឯណោះថ្វាយបង្គំជាមួយនឹងកូនអញ រួចសឹមមកឯឯងវិញ ។**

ចាប់ពីពាក្យនេះ "ការសម្តែងលើកទីមួយ" នៃការថ្វាយបង្គំ នោះយើងរៀនពីការថ្វាយបង្គំនោះ ជាសកម្មភាពនៃការស្តាប់បង្គាប់ ដែលទាមទារនូវយញ្ញបូជាដ៏មានកម្លាំង!

ដោយសារតែការស្តាប់បង្គាប់របស់លោកអ័ប្រាហាំ នៅក្នុងការថ្វាយបង្គំ នោះព្រះទ្រង់បានប្រទាននូវយញ្ញបូជាជំនួស សម្រាប់លោកអ៊ីសាក ។ ទ្រង់បានបើកសម្តែងដោយអង្គទ្រង់ផ្ទាល់ជា យេហូវ៉ា-យីរេ គឺជាព្រះអម្ចាស់ដ៏ជាអ្នកផ្គត់ផ្គង់របស់យើង ។

ព្រះគម្ពីរលោកុប្បត្តិ ២២:១៣,១៤ក ចែងថា: **នោះអ័ប្រាហាំគាត់ងើបភ្នែកឡើង ឃើញចៀមឈ្មោល១ជាប់ស្នែងនៅព្រៃខាងក្រោយខ្លួន រួចក៏ទៅយកចៀមឈ្មោលនោះ មកថ្វាយជាដង្វាយដុតជំនួសកូនខ្លួនវិញ អ័ប្រាហាំហៅកន្លែងនោះថា «យេហូវ៉ា-យីរេ»... ។**

➢ *ហេតុអ្វីបានជាមានភ្នំម៉ូរីយ៉ា*

ហេតុអ្វីបានជាព្រះទ្រង់បានបញ្ជូនលោកអ័ប្រាហាំ ទៅកាន់ទឹកដីភ្នំម៉ូរីយ៉ា ហើយនៅពេលដែលមានភ្នំនោះ? ហេតុអ្វីបានជាកន្លែងលោកអ័ប្រាហាំបានធ្វើជាយញ្ញបូជាដ៏សំខាន់យ៉ាងដូច្នោះ? ហេតុអ្វីបានជាព្រះទ្រង់ឱ្យបញ្ជូនតែលោកអ៊ីសាកជាកូនគាត់ឱ្យទៅ?

ព្រះគម្ពីរលោកុប្បត្តិ ២២:២ ចែងថា: **រួចទ្រង់មានបន្ទូលថា ចូរយកអ៊ីសាកកូនឯង ដែលជាកូនសំឡាញ់តែ១នោះទៅឥឡូវ នាំគ្នាទៅឯ**

**ស្រុកម៉ូរីយ៉ា រួចថ្វាយវាជាដង្វាយដុត នៅលើភ្នំ១ក្នុងស្រុកដែលអញនឹងបង្ហាញប្រាប់ឯងនោះ ។**

មានមនុស្សជាច្រើនជឿថា ភ្នំម៉ូរីយ៉ា គឺជាកន្លែងដែលលោកអ័ប្រាហាំបានធ្វើជាអ្នកស្តាប់បង្គាប់ ហើយមានបំណងនឹងបញ្ជូនលោកអ៊ីសាកជាកូនគាត់ គឺជាតំណាងឱ្យព្រះយេស៊ូវ ដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះ ឱ្យត្រូវជាប់លើឈើឆ្កាងធ្វើជាយញ្ញបូជា ។ គឺជាការប្រទានរបស់ព្រះ ឱ្យព្រមធ្វើជាយញ្ញបូជាជំនួសអំពើបាបរបស់យើងរាល់គ្នា ។

តើលោកអ័ប្រាហាំបានទ្រាំទ្ររង់ចាំ អស់រយៈកាលជាច្រើនឆ្នាំតាមពាក្យទំនាយដែលនឹងត្រូវបានសម្រេច គឺជាច្រើនឆ្នាំនោះហើយ ដែលគាត់ត្រូវតែបានទទួលដោយភាពគ្រប់ល័ក្ខណ៍ ដោយនូវសេចក្តីជំនឿ និងការស្តាប់បង្គាប់ ដើម្បីឱ្យគាត់អាចចូលមកកាន់កន្លែងនេះបាន?

## ការស្តារសុខទុក្ខតាមរយៈការថ្វាយបង្គំ

គ្រប់ទីកន្លែង ដែលលោកអ័ប្រាហាំ អ៊ីសាក និងលោកយ៉ាកុបបានទៅ នោះពួកគេសុទ្ធតែបានសង់អាសនាសម្រាប់ថ្វាយបង្គំដល់ព្រះ ។

មានពេលជាច្រើន ដែលព្រះគម្ពីរបានបើកសម្តែងជាបន្តបន្ទាប់អំពីការសង់អាសនានោះ គឺមានការបង្ហាញខ្លួនរបស់ពួកទេវតា ឬជាការបង្ហាញដោយព្រះអង្គទ្រង់ផ្ទាល់ នៅទីកន្លែងដែលបានសង់អាសនានោះ ។

នៅពេលដែលយើងថ្វាយបង្គំព្រះ ដោយវិញ្ញាណ និងសេចក្តីពិត នោះយើងកំពុងតែសង់អាសនាខាងឯវិញ្ញាណហើយ ។

## លោកអ័ប្រាហាំ លោកអ៊ីសាក នៅបេតអែល

នៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូកទី១២ បានប្រាប់យើងថា លោកអ័ប្រាហាំបានសង់អាសនាមួយនៅបេតអែល ។ ជាច្រើនឆ្នាំក្រោយមកលោកយ៉ាកុបបានធ្វើដំណើរទៅបេតអែល ហើយគាត់បានយល់សប្តិឃើញអ្វីមួយដែលបានកើតឡើង នៅតំបន់ខាងឯវិញ្ញាណនោះ ។

ព្រះគម្ពីរលោកុប្បត្តិ ២៨:១២,១៣ក ចែងថា: **គាត់យល់សប្តិឃើញថា មានជណ្តើរ១បញ្ឈរនៅលើដី មានចុងទល់នឹងផ្ទៃមេឃ ក៏ឃើញមានពួកទេវតារបស់ព្រះឡើងចុះតាមជណ្តើរនោះ ព្រះយេហូវ៉ាក៏សណ្ឋិតនៅពីលើជណ្តើរ ទ្រង់មានបន្ទូលថា... ។**

ព្រះទ្រង់បានលេចមក និងមានបន្ទូលទៅកាន់លោកអ៊ីសាកនៅបេតអែលនោះ ។ រឿងរ៉ាវដ៏គួរឱ្យព្រឺព្រួចដែលបានកើតឡើង នៅក្នុងតំបន់ខាងឯវិញ្ញាណ គឺនៅកន្លែងដែលយើងបានសរសើរតម្កើង និងថ្វាយបង្គំនោះឯង ។

**ការថ្វាយបង្គំគឺជាការបើកទ្វារ**

ព្រះគម្ពីរលោកុប្បត្តិ ២៨:១៦,១៧ ចែងថា: **នោះយ៉ាកុបគាត់ភ្ញាក់ពីដេកឡើង ក៏នឹកក្នុងចិត្តថា ពិតប្រាកដជាព្រះយេហូវ៉ាទ្រង់គង់នៅទីនេះហើយ តែអញមិនបានដឹងទេ គាត់ក៏នឹកភ័យ ហើយនិយាយថា ទីកន្លែងនេះគួរឱ្យស្ញែងខ្លាចណាស់ ទីនេះមិនមែនជាអ្វីទេ គឺជាដំណាក់នៃព្រះ ហើយជាទ្វារស្ថានសួគ៌ពិត ។**

តាមរយៈការថ្វាយបង្គំ នោះទ្វារនៃស្ថានសួគ៌នឹងបានបើកឡើង ។

ព្រះគម្ពីរទំនុកដំកើង ២៤:៧ ចែងថា: **ឱទ្វារទាំងឡាយអើយ ចូរងើបក្បាលឡើង ឱទ្វារដ៏នៅអស់កល្បជានិច្ចអើយ ចូរនៅជាចំហរចុះ នោះមហាក្សត្រដ៏មានសិរីល្អ ទ្រង់នឹងយាងចូលមក ។**

**ដាវីឌបាននៅឯវាលជាអ្នកឃ្វាលសត្វ**

តើវាគ្រាន់តែជាការកើតឡើងព្រមគ្នាចំពោះដាវីឌឬ នៅពេលដែលគាត់បានឃ្វាលសត្វនោះ គឺបានចំណាយពេលជាច្រើនម៉ោងក្នុងការសរសើរតម្កើងព្រះនៅឯទីវាល នៅវេលថ្ងៃហិមនោះ? ឬតើគាត់បានបើកទ្វារស្ថានសួគ៌ គឺនៅពេលគាត់បានថ្វាយបង្គំដល់ព្រះឬទេ?

អស់រយៈកាលជាច្រើនឆ្នាំក្រោយមក គឺនៅរយៈពេលកំណើតរបស់ព្រះយេស៊ូវ នោះពួកទេវតាបានលេចមកឯពួកអ្នកគង្វាល និងបានច្រៀងចម្រៀងដូច្នេះថា:

**សួស្តីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្តីសុខសាន្តនៅផែនដី នៅកណ្តាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់** (លូកា ២:១៤) ។

## ការសរសើរតម្កើងគឺជាការបើកស្បៃវាំងននវាំងននៃសេចក្តីងងឹត

លូស៊ីហ្វើរគឺជាចេរូប៊ីនដែលបានទទួលការចាក់ប្រេងតាំង ឱ្យគ្របបាំង ។ ធម្មជាតិរបស់គាត់ គឺជាអ្នកគ្របបាំង ។ ប៉ុន្តែ ឥឡូវនេះគឺជំនួសឱ្យអ្នកគ្របបាំងនូវបល្ល័ង្កនៃនគរស្ថានសួគ៌ ដោយមានការសរសើរតម្កើង និងការថ្វាយបង្គំ នោះគាត់បានជាអ្នកមកគ្របបាំងនៅផែនដី ដោយស្បៃវាំងននៃសេចក្តីងងឹតវិញ ។

ព្រះគម្ពីរអេសាយ ៦០:២ ចែងថា: **ដ្បិតមើល សេចក្តីងងឹតនឹងគ្របលើផែនដី ហើយសេចក្តីសូន្យសុងនឹងគ្របលើអស់ទាំងជនជាតិ តែព្រះយេហូវ៉ាទ្រង់នឹងរះឡើងភ្លឺដល់ឯង ហើយគេនឹងឃើញសិរីល្អនៃទ្រង់ស្ថិតលើឯង ។**

សាតាំងបានតាំងខ្លួនជាព្រះងអម្ចាស់ ដែលគ្រប់គ្រងលើទឹកដីនៃសេចក្តីងងឹត ។

ព្រះគម្ពីរអេភេសូរ ៦:១២ ចែងថា: **ដ្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ គឺនឹងពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតនៅលោកិយនេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ដែរ ។**

គោលបំណងរបស់ស្បៃរាំងននៃសេចក្ដីងងឹត គឺត្រូវតែធ្វើឱ្យមនុស្សជាតិទាំងអស់ងងឹត គឺវាបិទបាំងមិនឱ្យបានទទួលនូវសិរីល្អរបស់ព្រះថែមទៀតផង ។

ព្រះគម្ពីរ២កូរិនថូស ៤:៣,៤ ចែងថា: **បើសិនណាជាដំណឹងល្អរបស់យើងខ្ញុំត្រូវគ្របបាំង នោះគឺត្រូវគ្របបាំងចំពោះតែពួកអ្នក ដែលកំពុងវិនាសទេ ជាពួកអ្នកដែលព្រះរបស់លោកិយនេះ បានបង្អាប់ដល់គំនិតពួកគេដែលមិនជឿ ក្រែងរស្មីពន្លឺនៃដំណឹងល្អ ដែលសំដែងពីសិរីល្អនៃព្រះគ្រីស្ទដ៏ជារូបអង្គព្រះ បានភ្លឺមកដល់គេ ។**

**សង្គ្រាមដែលមានពេញដោយអំណាច**

រឿងរ៉ាវដែលមានពេញដោយអំណាច គឺនៅពេលដែលយើងបានកសាងអាសនានៃការសរសើរតម្កើង និងការថ្វាយបង្គំនោះឯង ។ "ផ្ទៃខាងក្រៅនៃការគ្របបាំង" របស់ស្បៃរាំងននៃសេចក្ដីងងឹត គឺត្រូវបានបង្ហូរទឹកភ្នែកដោយផ្ទែក២ និងត្រូវបានបំភ្លេចបំផ្លាញហើយ ។ ការគ្រប់គ្រងនៃសេចក្ដីងងឹត គឺត្រូវបានទទួលការបរាជ័យហើយ ។

ព្រះគម្ពីរអេសាយ ២៥:៧ ចែងថា: **នៅលើភ្នំនេះ ទ្រង់នឹងបំផ្លាញស្បៃដែលបាំងមុខគ្រប់ទាំងសាសន៍ ព្រមទាំងគំរបដែលគ្របលើជនជាតិទាំងប៉ុន្មានផង ។**

នៅពេលដែលយើងបានបើកនគរស្ថានសួគ៌ តាមរយៈការសរសើរតម្កើង និងការថ្វាយបង្គំ គឺពួកទេវតាអាចលេចឡើង ព្រះអង្គទ្រង់ផ្ទាល់ក៏បានយាងមក ហើយព្រះវត្តមានរបស់ទ្រង់ ក៏ត្រូវបានគង់នៅផងដែរ ។

**គំរូរបស់ហោរាដានីយ៉ែល**

នៅក្នុងព្រះគម្ពីរដានីយ៉ែលជំពូកទី១០ គឺទេវតាដែលជាអ្នកនាំសារដោយប្រញាប់ នោះក៏បានទទួលការខុសត្រូវចំពោះពាក្យរបស់ហោរាដានីយ៉ែល ក៏ត្រូវបានបញ្ឈប់ថ្ងៃឱ្យនៅទ្រឹង អស់រយៈពេល២១ថ្ងៃ ដោយសារព្រះអង្គម្ចាស់នៃនគរពើរស៊ី ។

សង្គ្រាមខាងឯវិញ្ញាណ គឺបានចាប់យកនគរស្ថានសួគ៌ ។ ទេវតាក៏មានការយឺតយ៉ាវ ដោយពួកគ្រប់លើសេចក្តីងងឹត បានវាយឈ្នះនគរពើរស៊ី រហូតដល់មហាទេវតាមីកែល បានមកជួយដល់គាត់ ។ ការទទួលខុសត្រូវចំពោះពាក្យរបស់ហោរាដានីយ៉ែល គឺស្បៃវាំងននៃសេចក្តីងងឹតត្រូវបានបើកហើយ ហើយទេវតាក៏បានបំបាក់បំបែកចូលទៅបានដែរ ។

## ជ័យជម្នះរបស់ស្តេចយ៉ូសាផាត

ជ័យជម្នះរបស់ស្តេចយ៉ូសាផាត គឺជាជ័យជម្នះមួយដែលជាគំរូដ៏ធំបំផុត នៃជ័យជម្នះតាមរយៈការសរសើរតម្កើង និងការថ្វាយបង្គំនោះ ។ យើងបានសិក្សាអំពីរឿងនេះលម្អិតបន្ថែមទៀត នៅក្នុងមេរៀនទី១០ ។

នៅពេលដែលពួកយូដាត្រូវទទួលការហ៊ុំព័ទ្ធ ដោយពួកកងទ័ពទាំងបីជនជាតិ គឺដែលពួកគេបានឃើញដោយផ្ទាល់ នូវចំនួនដ៏លើសលុបដែលធ្វើឱ្យពួកគេបាត់បង់សេចក្តីសង្ឃឹមអស់រលីង ។ ប៉ុន្តែស្តេចយ៉ូសាផាត និងបណ្តាជននៅស្រុកយូដាបានដឹងពីអ្វីដែលពួកគេត្រូវធ្វើ ។ ពួកគេក៏បានស្រែកទៅរកព្រះយេហូវ៉ា ។

ព្រះគម្ពីរ២របាក្សត្រ ២០:១៥ ចែងថា: **រួចលោកពោលថា ឱពួកយូដាទាំងអស់គ្នា និងពួកអ្នកនៅក្រុងយេរូសាឡិម ព្រមទាំងព្រះករុណាយ៉ូសាផាតអើយ ចូរស្តាប់ចុះ ព្រះយេហូវ៉ាទ្រង់មានបន្ទូលមកអ្នករាល់គ្នាដូច្នេះថា កុំឱ្យភ័យខ្លាចអ្វីឡើយ ក៏កុំឱ្យស្រយុតចិត្តដោយព្រោះពួកធំទាំងម្ល៉េះនេះដែរ ដ្បិតចំបាំងនេះ មិនមែនស្រេចនៅអ្នករាល់គ្នាទេ គឺស្រេចនៅព្រះវិញ ។**

## យើងមានតួនាទីដោយខ្លួនឯង

ខ.១៧ក.១៨ ចែងថា: **អ្នករាល់គ្នាមិនបាច់នឹងតស៊ូក្នុងចំបាំងនេះទេ ឱ្យគ្រាន់តែដំរៀបគ្នាឈរស្ងៀម ហើយចាំមើលសេចក្តីសង្គ្រោះ ដែលព្រះយេហូវ៉ានឹងប្រោសដល់អ្នករាល់គ្នាប៉ុណ្ណោះ... នោះយ៉ូសាផាតទ្រង់**

**ក្រាបព្រះភក្ត្រចុះដល់ដី ហើយពួកយូដា និងពួកអ្នកនៅក្រុងយេរូសាឡិម ទាំងអស់គ្នា ក៏ក្រាបថ្វាយបង្គំនៅចំពោះព្រះយេហូវ៉ាដែរ ។**

ព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់ពួកគេថា "ចូរបំពេញតាមតួនាទីដោយខ្លួនឯង" ហើយពួកគេក៏បានធ្វើយ៉ាងដូច្នោះ តាមរយៈការថ្វាយបង្គំ!

ខ.១៩ ចែងថា: **ឯពួកលេវី ខាងពួកកូនចៅកេហាត់ និងពួកកូនចៅកូរេគេឈរឡើង សរសើរដល់ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ដោយសំឡេងយ៉ាងខ្លាំងក្រៃលែង ។**

**ការដាក់អ្នកចម្រៀងនៅពីមុខពួកទ័ព**

ខ.២១,២២ ចែងថា: **រួចកាលទ្រង់បានពិគ្រោះនឹងបណ្តាជនហើយ នោះទ្រង់ក៏ដំរូវឱ្យមានពួកអ្នក ដែលត្រូវច្រៀងថ្វាយព្រះយេហូវ៉ា ហើយពោលសរសើរ ដោយស្លៀកពាក់ជាប្រដាប់បរិសុទ្ធ ក្នុងកាលដែលគេនាំមុខពួកទ័ពចេញទៅ ដោយពោលថា ចូរអរព្រះគុណដល់ព្រះយេហូវ៉ាចុះ ដ្បិតសេចក្តីសប្បុរសទ្រង់នៅជាប់អស់កល្បជានិច្ច ដូច្នេះ កាលគេចាប់តាំងច្រៀង ហើយសរសើរឡើង នោះព្រះយេហូវ៉ាទ្រង់បង្កប់ទ័ពទាស់នឹងពួកកូនចៅអាំម៉ូន ម៉ូអាប់ និងពួកភ្នំសៀរ ដែលមកច្បាំងនឹងពួកយូដា ឱ្យគេត្រូវចាញ់ ។**

**ពួកខ្មាំងសត្រូវបានបំផ្លាញគ្នាទៅវិញទៅមក**

ខ.២៣,២៤ ចែងថា: **ដ្បិតពួកកូនចៅអាំម៉ូន និងម៉ូអាប់ គេលើកគ្នាបំផ្លាញពួកនោះអស់ហើយ នោះក៏ព្រួតគ្នាបំផ្លាញដល់គ្នាទៅវិញទៅមកទៀត ដូច្នេះ កាលពួកយូដាមកដល់ប៉មចាំយាម នៅត្រង់ទីរហោស្ថាននោះ គេក្រឡេកមើលទៅពួកធំនោះ ក៏ឃើញគេសុទ្ធតែជាខ្មោចដេករដូកនៅដី គ្មានអ្នកណាមួយបានរួចជីវិតឡើយ ។**

សូម្បីតែនៅពេលដែលការនោះបានកើតឡើង គឺដែលពួកខ្មាំងសត្រូវបានហ៊ុំព័ទ្ធយើងនៅជុំវិញដោយមានចំនួនច្រើនលើសលុប ប្រសិនបើ

យើងបំពេញតាមតួនាទីរៀងខ្លួននៅក្នុងព្រះអម្ចាស់ ហើយចាប់ផ្តើមសរសើរតម្កើង និងថ្វាយបង្គំដល់ទ្រង់ នោះយើងនឹងវាយទម្លុះចូលបានដល់តំបន់ខាងឯវិញ្ញាណជាមិនខាន ។

## ការធ្វើសង្គ្រាមតាមរយៈការសរសើរតម្កើង

ខ្មាំងសត្រូវរបស់យើង ដែលជាអ្នកធ្លាប់បានសរសើរតម្កើងម្តងនៅក្នុងនគរស្ថានសួគ៌ នោះមិនអាចឈរនៅក្នុងការបញ្ចេញសម្លេងនៃការសរសើរតម្កើងនោះបានទៀតឡើយ ។ អ្នកដែលត្រូវបានបញ្ជូនដោយប្រញាប់ប្រញាល់ ដោយព្រះយេហូវ៉ា នោះគឺជាទេវតាចម្បាំង នឹងចាំពួនស្ទាក់វាយបណ្តេញវិញ្ញាណអាក្រក់ទាំងនោះ ។ នៅក្នុងការច្របូកច្របល់នោះពួកវានឹងរុញច្រានគ្នាទៅវិញទៅមក ហើយពួកវានឹងត្រូវទទួលការបរាជ័យ នៅពេលដែលពួកយើងចាប់ផ្តើមសរសើរតម្កើងដល់ព្រះអម្ចាស់នោះ ។

មានមនុស្សជាច្រើន គឺនៅពេលដែលពួកគេបានរៀនសូត្រ ដែលយើងបាននៅឯទីធ្វើសង្គ្រាមជាមួយនឹងពួកខ្មាំងសត្រូវនោះ គឺត្រូវចំណាយពេលជាច្រើន ក្នុងការស្រែកទៅកាន់អារក្ស និងពួកវិញ្ញាណអាក្រក់របស់វា ។ ពួកគេគឺបានផ្ចង់ចិត្តទៅឯពួកខ្មាំងសត្រូវ ។

មានកន្លែងសម្រាប់ធ្វើសង្គ្រាមខាងឯបទភ្លេង នៅសម័យសព្វថ្ងៃនេះ ។ វាគួរតប្បីបានរំឭកយើងចំពោះជ័យជម្នះរបស់យើង ដោយមានសិទ្ធិអំណាចលើខ្មាំងសត្រូវ ហើយនិងរំឭកដល់វាផងដឹងថា វាធ្លាប់បានទទួលនូវការបរាជ័យរួចហើយ!

កាធ្វើសង្គ្រាមដែលមានជោគជ័យ គឺមិនមែនជាការស្រែកជ័យឃោសទៅលើខ្មាំងសត្រូវនោះទេ ។ គឺវាជាការសរសើរតម្កើងដែលបានតាំងនៅហើយប៉ុណ្ណោះ ។ វាជាការផ្ចង់ចិត្តទៅលើភាពដ៏អស្ចារ្យនៃព្រះរបស់យើងវិញ ។

ព្រះគម្ពីរទំនុកដំកើង ១៤៩:៦-៩ ចែងថា: **គួរឱ្យមានសេចក្តីសរសើរយ៉ាងប្រសើរពីព្រះ នៅក្នុងមាត់គេ និងដាវមានមុខ២នៅដៃគេដែរ ដើម្បីនឹងសំរេចការសងសឹកដល់សាសន៍ដទៃទាំងប៉ុន្មាន និងការវាយផ្ចាលដល់បណ្តាជនទាំងឡាយ ប្រយោជន៍នឹងដាក់ច្រវាក់ដល់ពួកស្តេចគេ និងខ្នោះដែកដល់ពួកអ្នកមានត្រកូលខ្ពស់របស់គេដែរ ដើម្បីនឹងសំរេចការវិនិច្ឆ័យដល់គេ ដូចជាបានកត់ទុកហើយ ការនេះជាកិត្តិយសដល់ពួកអ្នកដែលបរិសុទ្ធរបស់ទ្រង់ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ។**

ព្រះគម្ពីរអេសាយ ៣០:៣២ ចែងថា: **ហើយគ្រប់១រយៈដំបងដែលព្រះយេហូវ៉ាបានដំរូវឱ្យត្រូវវាយគេ នោះនឹងឮសូរក្រាប់និងស៊ុងប្រគំឡើងជាដរាប ឯក្នុងគ្រប់ទាំងពេលតក្លានោះ ទ្រង់នឹងច្បាំងនឹងគេ ដោយព្រះពាហុលើកសំរេច ។**

ពួកអ្នកសរសើរតម្កើងគឺនៅពីមុខពួកទ័ពរបស់ស្តេចយ៉ូសាផាត គឺមិនមែនកំពុងច្រៀងចម្រៀងនៅឯសមរភូមិផ្ទាល់ចំពោះអារក្សនោះទេ ។ ពួកគេបានកំពុងតែច្រៀង ដោយការសរសើរតម្កើង សម្រាប់ភាពបរិសុទ្ធដ៏ស្រស់ល្អត្រកាលតែប៉ុណ្ណោះ ។ ការសរសើរតម្កើងដល់ព្រះអម្ចាស់ គឺសម្រាប់សេចក្តីមេត្តាករុណាដ៏ស្ថិតស្ថេរចេរកាលរបស់ទ្រង់នោះឯង ។ ពួកគេបានកំពុងតែថ្វាយបង្គំដល់ព្រះ!

**លោកសាវ័កប៉ុល និងស៊ីឡាស**

លោកសាវ័កប៉ុ និងស៊ីឡាស ក៏បានត្រូវទទួលនូវការអាក្រាត ការល្ងីងជូរចត់ និងត្រូវគេចាប់បញ្ចូលទៅក្នុងគុក ជាមួយនឹងជើងជាប់ខ្នោះចាក់សោរជាប់ ។

ព្រះគម្ពីរកិច្ចការ ១៦:២៥,២៦ ចែងថា: **លុះពេលប្រហែលជាកណ្តាលអធ្រាត្រ ប៉ុល និងស៊ីឡាស កំពុងតែអធិស្ឋាន ហើយច្រៀងសរសើរដល់ព្រះ ឯពួកអ្នកទោសក៏ស្តាប់ដែរ នោះស្រាប់តែកើតមាន**

**កក្រើកដីជាខ្លាំង ដល់ម្ល៉េះបានជារញ្ជួយដល់ជើងជញ្ជាំងគុកផង ហើយទ្វារទាំងប៉ុន្មានរបើកចេញភ្លាម ខ្នោះក៏របើបចេញទាំងអស់ទៅ ។**

យើងត្រូវតែបន្តនូវការថ្វាយដង្វាយនៃកាសរសើរ គ្មានបញ្ហាអ្វីទេចំពោះស្ថានការណ៍ដែលកើតមានឡើ ដោយគ្មាលទ្ធភាពយ៉ាងណានោះ ។ នៅពេលដែលយើងធ្វើយ៉ាងដូច្នេះ នោះនឹងតែងតែមានលទ្ធផលនៃការពេញដោយអំណាចចេស្តា ។ ជ័យជម្នះអាចមកតាមរយៈការសរសើរតម្កើងនិងថ្វាយបង្គំដោយមានកម្រិតខ្ពស់ ។ យើងអាចព្រមព្រៀងគ្នាជាមួយនឹងស្តេចដាវីឌ នូវការនិពន្ធរបស់ទ្រង់ ។

ព្រះគម្ពីរទំនុកដំកើង ៦៨:១ក ចែងថាៈ **សូមព្រះអង្គទ្រង់ឈរឡើង ឲ្យពួកខ្មាំងសត្រូវទ្រង់ត្រូវខ្ចាត់ខ្ចាយទៅ... ។**

## សំណួររំឭកសារឡើងវិញ

១ ។តើយើងត្រូវ "ចូលទៅ" ក្នុងព្រះវត្តមាននៃព្រះដោយការថ្វាយបង្គំយ៉ាងដូចម្តេច?

២ ចូរពិពណ៌នាពី "ការវាយទម្លុះចូលបាន" ដែលអាចចាប់យកនូវកន្លែងដែលយើងត្រូវថ្វាយបង្គំដល់ព្រះបាន ។

៣ តើពួកទាហានរបស់សាសន៍យូដា ដែលនៅក្រោមស្តេចយ៉ូសាផាតបានទទួលនូវការវាយទម្លុះចូលបាន ប្រឆាំងនឹងខ្មាំងសត្រូវដែលនៅព័ទ្ធជុំវិញ នោះដោយរបៀបណា?

# មេរៀនទី ១៤
## *ភាពជាអ្នកដឹកនាំក្នុងការសរសើរតម្កើង និងការថ្វាយបង្គំ*

យើងត្រូវតែដើរតាមគម្រោងផែនការ និងគំរូនៃការបំបួសរបស់ព្រះ សម្រាប់ការដឹកនាំខាងឯវិញ្ញាណនៅក្នុងពួកជំនុំ ប្រសិនបើយើងបានគោរពតាមការចាក់ប្រេងតាំងរបស់ព្រះ ចំពោះការងារសរសើរតម្កើង និងការងារថ្វាយបង្គំ ។

## គ្រូគង្វាល និងពួកចាស់ទុំដែលត្រូវបំពេញការងារដទៃទៀត

**ភាពជាអ្នកដឹកនាំខាងឯវិញ្ញាណ**

គ្រូគង្វាល និងពួកចាស់ទុំដែលកំពុងតែបំពេញការងារដទៃទៀតរបស់ពួកជំនុំ ត្រូវតែផ្តល់ឱ្យភាពជាអ្នកដឹកនាំ សិទ្ធិអំណាចខាងឯវិញ្ញាណទាំងដោយផ្ទាល់ និងទុកជាគំរូសម្រាប់ការបំពេញការងារក្នុងការសរសើរតម្កើង និងការថ្វាយបង្គំដែលមានប្រសិទ្ធិភាព នៅក្នុងពួកជំនុំ ។

ព្រះគម្ពីរ១ពេត្រុស ៥:២,៣ ចែងថា: **ចូរឃ្វាលហ្វូងចៀមរបស់ព្រះ ដែលនៅជាមួយនឹងអ្នករាល់គ្នាចុះ ទាំងគ្រប់គ្រង ដោយស្ម័គ្រពីចិត្ត មិនមែនដោយបង្ខំទេ ក៏មិនមែនដោយចង់បានកំរៃដែរ គឺដោយគាប់ចិត្តវិញ មិនមែនបែបដូចជាមានអំណាចលើរបស់ទ្រព្យទេ គឺដើម្បីឱ្យបានធ្វើជាគំរូដល់ហ្វូងចៀមវិញប៉ុណ្ណោះ ។**

**ការចូលរួមធ្វើសកម្មភាព**

វាជាការល្អនៅពេលដែលគ្រូគង្វាល និងពួកចាស់ទុំដែលបំពេញការងារដទៃទៀត បានចូលរួមយ៉ាងសកម្មនៅក្នុងការសរសើរតម្កើង និងថ្វាយបង្គំទាំងអស់គ្នា ចាប់ពីពេលភ្លាមៗនោះមក ឱ្យការងារបានចាប់ផ្តើមទៅដោយរលូន ។ ដោយការធ្វើយ៉ាងដូច្នោះ នោះពួកគេនឹងបានក្លាយជាគំរូ និងជាការលើកទឹកចិត្តដល់អ្នកចូលរួមនៅក្នុងព្រះវិហារនោះ ។

ព្រះគម្ពីរ១ធីម៉ូថេ ៤:១២ ចែងថា: **កុំឱ្យអ្នកណាមើលងាយអ្នក ដោយព្រោះនៅក្មេងនោះឡើយ ចូរធ្វើជាគំរូដល់ពួកអ្នកជឿ ដោយពាក្យសំដី កិរិយាប្រព្រឹត្ត សេចក្តីស្រឡាញ់ សេចក្តីជំនឿ និងសេចក្តីបរិសុទ្ធ ។**

**អំពីគំរូល្អ**

ប្រសិនបើពួកធ្វើការបានចូលមកយឺត នោះតាមសកម្មភាពរបស់ពួកគេ នឹងធ្វើឱ្យមានតម្លៃដ៏តិចតួច យោលទៅលើពេលវេលាសរសើរតម្កើង និងថ្វាយបង្គំនៅក្នុងពេលធ្វើការងារក្នុងពួកជំនុំនោះ និងមានមនុស្សជាច្រើន ដែលនៅក្នុងព្រះវិហារនឹងស្មានថា ជាការមានទម្លាប់ដូចៗគ្នាជាមិនខាន ។

ព្រះគម្ពីរ១កូរិនថូស ១១:១ ចែងថា: **ចូរត្រាប់តាមខ្ញុំ ដូចជាខ្ញុំបានត្រាប់តាមព្រះគ្រីស្ទដែរ ។**

**ការប្រុងប្រៀបរៀបចំសម្រាប់ការងារ**

គ្រូគង្វាល និងពួកអ្នកធ្វើការដទៃទៀតក៏ត្រូវការពេលវេលាដូច្នេះដែរ គឺដើម្បីធ្វើការប្រុងប្រៀបរៀបចំយ៉ាងច្បាស់លាស់ នៅក្នុងចិត្តរបស់ពួកគេ សម្រាប់ការចាក់ប្រេងតាំង ដើម្បីឱ្យបានបញ្ចេញសម្រាប់ធ្វើការងារដល់ពួកបណ្តាជន ។

ព្រះគម្ពីរកិច្ចការ ៦:២ ចែងថា: **ពួកសាវក១២នាក់ក៏ហៅសិស្សទាំងអស់មកនិយាយថា មិនគួរគប្បីឱ្យយើងខ្ញុំទុកព្រះបន្ទូលចោល ដើម្បីនឹងទៅបំរើតុទេ ។**

**ការមើលឃើញនូវការបង្ហូរមកនៃព្រះវិញ្ញាណ**

វាក៏ជាការសំខាន់ផងដែរ សម្រាប់អស់អ្នកដែលបំពេញការងារទាំង៥យ៉ាង ដើម្បីជៀសវាងនូវការបំបែកចេញដទៃទៀត ហើយចំពោះការផ្តល់ឱ្យក៏បានពេញលេញដោយខ្លួនគេផងដែរ ចំពោះការមើលឃើញនូវការបង្ហូរមក និងកាធ្វើចលនារបស់ព្រះវិញ្ញាណបរិសុទ្ធ សម្រាប់អ្នកចូលរួមធ្វើការងារនោះ ។

**ការតែងតាំងពួកអ្នកដឹកនាំថ្វាយបង្គំ**

ទាំងគ្រឿងភ្លេង និងពួកអ្នកដឹកនាំថ្វាយបង្គំ ត្រូវតែបានទទួលការតែងតាំង ដោយពួកចាស់ទុំដែលបំពេញការងារនៅក្នុងពួកជំនុំ ហើយនឹងត្រូវបានជាអ្នកបំពេញការងារនៅក្រោមសិទ្ធិអំណាចរបស់ពួកគេ ។ ជាការដែលមានលទ្ធភាព គឺការសរសើរតម្កើង និងការថ្វាយបង្គំ នោះនឹងត្រូវបានអនុញ្ញាតដោយគ្រូគង្វាល ឬពីម្នាក់នៅក្នុងចំណោមគ្រូអធិប្បាយ ឬក៏ជាពួកចាស់ទុំដែលបំពេញការងារ ដែលជាអ្នកមានអំណោយទាននៅក្នុងតំបន់នេះជាដើម ។

គំរូនៅក្នុងព្រះគម្ពីរដែលនិយាយពីការនេះ គឺត្រូវបានគេរកឃើញនៅកន្លែងដែលស្តេចដាវីឌ បានតែងតាំងអ្នកខ្លះនៅក្នុងពូជលេវី ដែលជាអ្នកប្រគំបទភ្លេង ដើម្បីបំពេញការងារនៅចំពោះព្រះអម្ចាស់ ។

ព្រះគម្ពីរ១របាក្សត្រ ១៦:៤ ចែងថា: **ទ្រង់ក៏ដំរូវពួកលេវីខ្លះ ឱ្យធ្វើការងារនៅចំពោះហឹបនៃព្រះយេហូវ៉ា ដើម្បីនឹងរំឭក អរព្រះគុណ ហើយនិងសរសើរដល់ព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែល ។**

**ក្រុមថ្វាយបង្គំត្រូវបានតែងតាំងដោយស្តេចដាវីឌ**

មានក្រុមការងារមួយក្រុម ដែលបានទទួលការតែងតាំងដោយស្តេចដាវីឌ ។

**អ្នកដឹកនាំថ្វាយបង្គំ**

សិទ្ធិអំណាចអ្នកដឹកនាំ គឺត្រូវបានផ្តល់ឱ្យទៅលោកអេសាភ ជាអ្នកដឹកនាំក្រុមភ្លេង ។

ព្រះគម្ពីរ១របាក្សត្រ ១៦:៥ ចែងថា: **គឺអេសាភជាមេ ហើយបន្ទាប់មកមានសាការី យីអែល សេមីរ៉ាម៉ូត យេហ៊ីអែល ម៉ាធិធា អេលាប បេណាយ៉ាអូបិឌ-អេដំម និងយីអែល សុទ្ធតែកាន់ពិណនិងស៊ុង ហើយអេសាភជាអ្នកវាយឈឹងឱ្យឮរងំ ។**

### អ្នកដឹកនាំក្រុមចម្រៀង

អ្នកដឹកនាំក្រុមចម្រៀង ក៏ត្រូវបានទទួលការតែងតាំងផងដែរ ។

ព្រះគម្ពីរ១របាក្សត្រ ១៥:២២ ចែងថា: **ហើយកេណានា ជាមេពួកលេវីលោកត្រួតលើការចំរៀង គឺលោកដែលបង្ហាត់ការនោះ ពីព្រោះលោកជាអ្នកប្រសប់ ។**

ព្រះគម្ពីរ១របាក្សត្រ ១៥:២៧ ចែងថា: **ឯដាវីឌទ្រង់ព្រះពស្ត្រសំពត់ខ្លូតទេសយ៉ាងម៉ដ្ត ព្រមទាំងពួកលេវីដែលសែងហឹប ពួកចំរៀង និងកេណានា ជាមេលើពួកចំរៀងផង ហើយដាវីឌក៏ពាក់អេផូឌធ្វើពីសំពត់ខ្លូតទេសដែរ ។**

### ពួកអ្នកកាន់គ្រឿងភ្លេង

ពួកអ្នកកាន់គ្រឿងភ្លេងក៏ត្រូបាមទទួលការតែងតាំង សម្រាប់ការងារផងដែរ ។

ព្រះគម្ពីរ១របាក្សត្រ ២៥:៦,៧ ចែងថា: **អ្នកទាំងនោះសុទ្ធតែនៅក្នុងបង្គាប់របស់ឪពុក សំរាប់ការចំរៀងក្នុងព្រះវិហារនៃព្រះយេហូវ៉ា ដោយលេងឈឹង ពិណ និងស៊ុង ដើម្បីធ្វើការងាររបស់ព្រះវិហារនៃព្រះ ឯអេសាភយេឌូថិន និងហេម៉ាន លោកនៅក្នុងបង្គាប់របស់ស្តេច អ្នកទាំងនោះ និងបងប្អូនគេដែលបានហាត់ច្រៀងថ្វាយព្រះយេហូវ៉ា គឺអស់ដែលប្រសប់ នោះមានចំនួន២៨៨នាក់ ។**

## ពួកអ្នកដឹកនាំក៏បានទទួលនូវការហ៊ឹកហាត់នូវអំណោយទានរបស់ពួកគេ

---

### ការងារកាត់ចុះងារជាពួកគ្រូអធិប្បាយ

ជារឿយៗ អស់អ្នកដែលព្រះទ្រង់បានជ្រើសរើស ជាអ្នកដឹកនាំថ្វាយបង្គំ នោះនឹងបានបំពេញការងារតាម "អំណោយទាន" ជាគ្រូអធិប្បាយផងដែរ ។ រីឯពួកអ្នកលេងភ្លេងក៏ប្រើដោយការបញ្ចេញ ពីព្រះវិញ្ញាណជាគ្រូអធិប្បាយ ទៅក្នុងសកម្មភាពនោះដែរ ។

ព្រះគម្ពីរ១របាក្សត្រ ២៥:១ក ចែងថា: **ដាវីឌ និងពួកមេទ័ព ក៏ញែកពួកកូនចៅអេសាភ ហេម៉ាន និងយេឌូថិនខ្លះ ចេញទុកសំរាប់ការងារ ឱ្យបានពោលតាមស៊ុង ពិណ និងឃឹង... ។**

ព្រះគម្ពីរ១របាក្សត្រ ២៥:៣ ចែងថា: **ខាងយេឌូថិន ពួកកូនចៅលោក គឺកេដាលា សេរី យេសាយ៉ា ហាសាបយ៉ា ម៉ាធិធា និងស៊ីម៉ាយ ទាំងអស់មាន៦នាក់ គេកាន់ស៊ុងនៅក្នុងបង្គាប់យេឌូថិន ជាឪពុកគេ ដែលជាអ្នកពោលពំនោល ដោយពាក្យអរព្រះគុណ និងពាក្យសរសើរដល់ព្រះយេហូវ៉ា ។**

**អ្នកលេងភ្លេងក៏ត្រូវបានទទួលការហ្វឹកហ្វឺនជំនាញផងដែរ**

ការត្រាស់ហៅ និងការទទួលខុសត្រូវចំពោះការបំពេញការងារថ្វាយដល់ព្រះ នៅក្នុងការប្រគំបទភ្លេង នោះមិនគួរគប្បីត្រូវបានគេមើលស្រាលឡើយ ។ អស់អ្នកដែលដឹកនាំនៅក្នុងការសរសើរតម្កើង ទោះបីជាអ្នកចម្រៀង ឬជាគ្រឿងភ្លេងក៏ដោយ ក៏គួរគប្បីមានការហ្វឹកហ្វឺនបានល្អិតល្អន់ ព្រមទាំងបានអនុវត្តឱ្យបានត្រឡប់ជាអ្នកលេងភ្លេងដ៏ជំនាញដែរ ។

ព្រះគម្ពីរ១របាក្សត្រ ២៥:៦,៧ ចែងថា: **អ្នកទាំងនោះសុទ្ធតែនៅក្នុងបង្គាប់របស់ឪពុក សំរាប់ការចំរៀងក្នុងព្រះវិហារនៃព្រះយេហូវ៉ា ដោយលេងឃឹង ពិណ និងស៊ុង ដើម្បីធ្វើការងាររបស់ព្រះវិហារនៃព្រះ ឯអេសាភយេឌូថិន និងហេម៉ាន លោកនៅក្នុងបង្គាប់របស់ស្តេច អ្នកទាំងនោះ និងបងប្អូនគេដែលបានហាត់ច្រៀងថ្វាយព្រះយេហូវ៉ា គឺអស់ដែលប្រសប់ នោះមានចំនួន២៨៨នាក់ ។**

**គុណសម្បត្តិរបស់ពួកអ្នកដឹកនាំថ្វាយបង្គំ**

➢ *បានទទួលការចាក់ប្រេងតាំងរបស់ព្រះ*

ចំពោះអ្នកដែលដឹកនាំក្នុងការសរសើរតម្កើង និងថ្វាយបង្គំ គឺត្រូវតែជាអ្នកបានទទួលនូវការចាក់ប្រេងតាំងដោយព្រះ សម្រាប់ការងារដ៏ពិសេស និងដ៏សំខាន់នេះនៅក្នុងពួកជំនុំ ។ វាជាអំណោយទាន និងជាការ

ត្រាស់ហៅមកពីព្រះវិញ្ញាណបរិសុទ្ធ ដែលត្រូវតែបានទទួលនូវសេចក្តីសង្ឃឹម និងការដុះដាលបាន ។

ព្រះគម្ពីរ១យ៉ូហាន ២:២០,២៧ ចែងថា: **រីឯអ្នករាល់គ្នា បានព្រះដ៏បរិសុទ្ធចាក់លាបឱ្យហើយក៏ចេះគ្រប់ទាំងអស់ផង... រីឯដំណើរដែលទ្រង់ចាក់លាបឱ្យ នោះក៏នៅជាប់នឹងអ្នករាល់គ្នាពិត ហើយអ្នករាល់គ្នាមិនត្រូវការ ឱ្យអ្នកណាបង្រៀនពីការអ្វីទេ ប៉ុន្តែ ដូចជាដំណើរចាក់លាបនោះបានបង្រៀនពីគ្រប់ការទាំងអស់ ហើយមិនមែនជាសេចក្តីកំភូតទេ គឺជាសេចក្តីពិតវិញ នោះត្រូវឱ្យអ្នករាល់គ្នានៅជាប់ក្នុងទ្រង់ចុះ តាមដែលដំណើរនោះបានបង្រៀនមក ។**

➢ *អ្នកថ្វាយបង្គំ*

អ្នកដឹកនាំសរសើរតម្កើង នោះមិនអាចដឹកនាំមនុស្សនៅកន្លែងដែលពួកគេមិនបានរស់នៅនោះឡើយ ។ ការសរសើរតម្កើង និងថ្វាយបង្គំដ៏ខ្លាំងក្លា នោះត្រូវតែជាផ្នែកមួយប្រចាំថ្ងៃ ក្នុងការដឹកនាំជាលក្ខណៈបុគ្គល និងជាក្រុមពិចារណាពេលថ្វាយបង្គំ ។

ព្រះគម្ពីរយ៉ូហាន ៤:២៣,២៤ ចែងថា: **តែនឹងមានពេលវេលាមក ក៏នៅឥឡូវនេះហើយ នោះពួកអ្នកដែលថ្វាយបង្គំដោយពិតត្រង់ គេនឹងថ្វាយបង្គំព្រះវរបិតាដោយវិញ្ញាណ និងសេចក្តីពិត ពីព្រោះព្រះវរបិតាទ្រង់រកពួកអ្នកយ៉ាងនោះ ឱ្យបានថ្វាយបង្គំទ្រង់ ឯព្រះទ្រង់ជាវិញ្ញាណហើយអ្នកណាដែលថ្វាយបង្គំទ្រង់ នោះត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណនិងសេចក្តីពិតដែរ ។**

➢ *ការពេញវ័យខាងឯព្រលឹងវិញ្ញាណ*

ដើម្បីឱ្យបានទៅជាអ្នកដឹកនាំនៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ នោះបុគ្គលម្នាក់ៗត្រូវតែបានជាអ្នកជឿមានលក្ខណៈពេញវ័យហើយ ។ គំនិតប្រាជ្ញារបស់គាត់ ឬរបស់នាង ត្រូវតែមានការពិសោធន៍ និងមានជំនាញ

ជាអ្នកដឹកនាំខាងឯវិញ្ញាណ នឹងលើកទឹកចិត្តដល់រូបកាយដែលបានចូលរួមទាំងអស់នោះ ។

ព្រះគម្ពីរអេភេសូរ ៤:១២,១៣ ចែងថា: **ប្រយោជន៍នឹងនាំឱ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សំរាប់ធ្វើការជំនួយ ហើយនិងស្អាងរូបកាយព្រះគ្រីស្ទឡើង ទាល់តែយើងរាល់គ្នាបានរួបរួម ខាងឯសេចក្ដីជំនឿរួចជាស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះ ដូចគ្នាទាំងអស់ គឺដល់បានពេញជាមនុស្ស ហើយដល់ខ្នាតកំពស់នៃសេចក្ដីពោរពេញផងព្រះគ្រីស្ទ ។**

➢ *អ្នកដឹកនាំត្រូវមានលទ្ធភាព*

ពួកគេត្រូវតែជាអ្នកមានលទ្ធភាពធ្វើឱ្យសមហេតុផល និងដឹកនាំពួកបណ្ដាជនបាន ។

ព្រះគម្ពីរ១កូរិនថូស ១១:១ ចែងថា: **ចូរត្រាប់តាមខ្ញុំ ដូចជាខ្ញុំបានត្រាប់តាមព្រះគ្រីស្ទដែរ ។**

➢ *ការយល់ដឹងដោយវិញ្ញាណ*

ពួកគេត្រូវតែបានជាអ្នកយល់ដឹងខាងឯវិញ្ញាណ ដើម្បីធ្វើតាមការចាក់ប្រេងតាំង និងការដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ បានជាអ្នកវាងវៃ និងយល់ដឹងចំពោះរបៀប ដែលអ្នកបម្រើព្រះត្រូវតែទទួលខុសត្រូវ ។

ព្រះគម្ពីរទំនុកដំកើង ៧៨:៧២ ចែងថា: **ដូច្នេះ លោកក៏ធ្វើជាអ្នកគង្វាលឃ្វាលគេ ដោយចិត្តទៀងត្រង់ ព្រមទាំងនាំផ្លូវគេដោយថ្វីដៃដ៏ជំនាញ ។**

➢ *ដោយការគោរពប្រណិបត្តន៍*

ពួកគេត្រូវតែទទួលសារភាព និងចុះចូលចំពោះគ្រូគង្វាយ និងពួកអ្នកដឹកនាំខាងឯវិញ្ញាណដទៃទៀត នៅក្នុងពួកជំនុំ ។

ព្រះគម្ពីរ១ពេត្រុស ៥:៥ ចែងថា: **ឯអ្នករាល់គ្នាដែលនៅក្មេងនោះត្រូវចុះចូលនឹងពួកចាស់ទុំដែរ ហើយត្រូវឱ្យគ្រប់គ្នាមានចិត្តសុភាព**

**ដល់គ្នាទៅវិញទៅមក ពីព្រោះព្រះទ្រង់តែងតតាំងនឹងមនុស្សអួតអាង តែផ្តល់ព្រះគុណដល់ពួករាបសាវិញ ។**

➢ *អ្នកដែលបរិសុទ្ធ សុចរិត និងចេះបន្ទាបខ្លួន*

អ្នកដឹកនាំថ្វាយបង្គំ គឺត្រូវតែជាអ្នកដែលមានអត្តចរិតបង្ហាញភស្តុតាង គឺជាអស់ដែលរស់នៅជាឯកជន និងជាអ្នកសុចរិត គឺជាអ្នកដែលចេះទទួលទោស ។ អ្នកបម្រើព្រះដែលចេះបន្ទាបខ្លួន នោះសកម្មភាពរបស់គាត់ នឹងតែងតែមានការប្រុងប្រយ័ត្នចំពោះការត្រាស់ហៅរបស់ព្រះ ហើយក៏មិនដែលស្វែងរកនូវការនាំមកនូវសិរីល្អ សម្រាប់តែខ្លួនឯងនោះឡើយ ។

ព្រះគម្ពីរ១ពេត្រុស ៥:៦ ចែងថា: **ដូច្នេះ ចូរឱ្យអ្នករាល់គ្នាបន្ទាបខ្លួន នៅក្រោមព្រះហស្តដ៏ពូកែរបស់ព្រះចុះ ដើម្បីឱ្យទ្រង់បានដំកើងអ្នករាល់គ្នាឡើង នៅវេលាកំណត់ ។**

➢ *ការចុះចូល និងការពេញដោយសេចក្តីស្មោះត្រង់*

ត្រូវតែបានពេញដោយសេចក្តីស្មោះត្រង់ និងទេងទាត់ពេលវេលាដោយការសម្រេចនូវការទទួលខុសត្រូវ ដែលព្រះទ្រង់បានប្រទានឱ្យនេះ។

ព្រះគម្ពីរ១កូរិនថូស ៤:២ ចែងថា: **រីឯអ្នករ៉ាប់រង ត្រូវឱ្យគេបានស្មោះត្រង់ ។**

## អ្នកកាន់គ្រឿងភ្លេង

### ការជ្រើសរើសអ្នកជំនាញខាងគ្រឿងភ្លេង

ជារឿយៗ ពួកប្រគំបទភ្លេងគឺត្រូវបានទទួលការត្រាស់ហៅដោយព្រះ ដើម្បីលេងតាមឧបករណ៍ភ្លេងដ៏ពិតប្រាកដ គឺជាផ្នែកមួយនៃក្រុមថ្វាយបង្គំ ដែលត្រូវបានប្រទានពរឱ្យមានលទ្ធភាពជាអធិធម្មជាតិ ដើម្បីអាចលេងនូវឧបករណ៍ភ្លេងនោះ ។ ទោះជាយ៉ាងណាក៏ដោយ ការនេះគឺមិនមែនជាការបង្រួមឱ្យតូច ចំពោះការទទួលខុសត្រូវរបស់អ្នកណាម្នាក់នោះទេ គឺដើម្បីហ្វឹកហ្វឺន និងដើម្បីហាត់សមឱ្យមានពេញដោយសេចក្តី

ស្មោះត្រង់ និងរីកចម្រើនឱ្យមានជំនាញជាការចាំបាច់ ដែលរាប់ជាការមានតម្លៃដល់ការត្រាស់ហៅរបស់អ្នកណាមួយតែប៉ុណ្ណោះ ។

ព្រះគម្ពីរ១របាក្សត្រ ២៥:៦,៧ ចែងថា: **អ្នកទាំងនោះសុទ្ធតែនៅក្នុងបង្គាប់របស់ឪពុក សំរាប់ការចំរៀងក្នុងព្រះវិហារនៃព្រះយេហូវ៉ា ដោយលេងឈឹង ពិណ និងស៊ុង ដើម្បីធ្វើការងាររបស់ព្រះវិហារនៃព្រះ ឯអេសាភ យេឌូថិន និងហេម៉ាន លោកនៅក្នុងបង្គាប់របស់ស្តេច អ្នកទាំងនោះ និងបងប្អូនគេដែលបានហាត់ច្រៀងថ្វាយព្រះយេហូវ៉ា គឺអស់ដែលប្រសប់ នោះមានចំនួន២៨៨នាក់ ។**

**អំពីឧបករណ៍ភ្លេង**

គ្រប់ប្រភេទនៃឧបករណ៍ភ្លេងទាំងអស់ (ប្រដាប់មានខ្សែ មានខ្យល់ និងមានប្រដាប់ដែលទង្គិចគ្នា) ជាដើមដែលត្រូវបានគេប្រើនៅក្នុងការសរសើរតម្កើង និងការថ្វាយបង្គំនោះឯង ។

ព្រះគម្ពីរទំនុកដំកើង ១៥០:៣-៥ ចែងថា: **ចូរសរសើរទ្រង់ដោយត្រែ ចូរសរសើរដល់ទ្រង់ដោយដេញពិណ និងចាប់ស៊ុង ចូរសរសើរដល់ទ្រង់ដោយវាយក្រាប់ ហើយលោតកញ្ឆេង ចូរសរសើរទ្រង់ដោយប្រដាប់មានខ្សែ ហើយនិងខ្លុយ ចូរសរសើរដល់ទ្រង់ដោយវាយឈឹងឱ្យឮរងំ ចូរសរសើរទ្រង់ដោយវាយឈឹងឮសូររំពង ។**

សូម្បីតែចំពោះការសរសើរតម្កើង និងការថ្វាយបង្គំ ក៏ត្រូវបានទទួលនូវការថតចម្លងយកពីក្នុងព្រះគម្ពីរសញ្ញាចាស់មកដែរ ដូចជាយើងបានបន្ថែមនូវទំហំខ្នាត និងគុណសម្បត្តិជាច្រើននៃការងារសរសើរតម្កើង និងការងារថ្វាយបង្គំ ដោយការប្រើឧបករណ៍បន្ថែម ដែលព្រះទ្រង់បានប្រទានពរមកឱ្យមានបញ្ញា ឱ្យចេះលេងតាមឧបករណ៍ភ្លេង និងមានចំណុចសម្រាប់ប្រើប្រាស់របស់ពួកគេ ។

អ្នកដឹកនាំអាចជ្រើសរើសបន្ថែមនូវឧបករណ៍ជាច្រើន ដែលបានទទួលនូវការហ្វឹកហាត់រួចមកហើយ គឺនៅពេលដែលគេចេះថ្លឹងថ្លែងនូវ

ប្រភេទនៃឧបករណ៍ភ្លេង និងអាចបញ្ចូលទៅក្នុងកម្មវិធីវិទ្យុ ឬក៏ការលេងភ្លេងនៅក្នុងព្រះសាលាជំនុំដែលមានទំហំធំបាន ។

**ការរួបរួម ការស៊ីសង្វាក់ និងការពង្រីកសម្លេង**

គ្រឿងឧបករណ៍ភ្លេងគឺត្រូវតែមានការយល់ដឹង និងវាងវៃរបស់អ្នកដឹកនាំផ្ទាល់ ។ មានការអនុវត្តន៍ជាច្រើន គឺជាការចាំបាច់ចំពោះការរួបរួម ការស៊ីសង្វាក់ និងការថ្លឹងថ្លែងជាមួយនឹងឧបករណ៍ភ្លេងដទៃៗទៀត ។

គ្រឿងឧបករណ៍ភ្លេងគឺត្រូវតែបានទទួលនូវផ្តល់មកពីអ្នកកវីនិពន្ធ ដោយអាចធ្វើការពង្រីកសម្លេង ដោយគ្មានការហៅមកដោយខ្លួនឯង ឬក៏ជាការលង់ទៅក្នុងសម្លេងរបស់ពួកអ្នកថ្វាយបង្គំនោះឡើយ ។

**ការយល់ដឹងចំពោះវិញ្ញាណ**

គ្រឿងឧបករណ៍ភ្លេងគឺត្រូវតែបានទទួលនូវការយល់ដឹង ចំពោះចលនានៃព្រះវិញ្ញាណបរិសុទ្ធ គឺជា "អ្នកប្រគំបទភ្លេងដែលមានជំនាញ" នោះឯង ។ ដោយការធ្វើកាយ៉ាងដូច្នោះ នោះពួកគេនឹងអាចបញ្ចេញការចាក់ប្រេងតាំងមកពីព្រះ ឱ្យបានចូលទៅក្នុងការបើកសម្តែងនៃព្រះវិញ្ញាណ កំឡុងពេលបំពេញការងារសរីរតម្កើង និងថ្វាយបង្គំនោះជាក់ជាមិនខាន ។

គ្រឿងឧបករណ៍ភ្លេងគឺត្រូវតែបានទទួលនូវការយល់ដឹង ដើម្បីធ្វើការបង្ហូរពីការបញ្ចេញសម្លេងដោយទោលម្នាក់ឯង ទៅគ្នាច្រើនបាន ។

ព្រះគម្ពីរ២របាក្សត្រ ៣៤:១២ ចែងថា: **ពួកជាងទាំងនោះគេធ្វើការដោយស្មោះត្រង់ ឯអ្នកដែលត្រួតលើគេ គឺយ៉ាហាត និងអូបាឌា ជាពួកលេវី ខាងពួកកូនចៅម្រ៉ារី ហើយសាការី និងមស៊ូឡាម ខាងពួកកូនចៅកេហាត់ ដើម្បីនឹងបញ្ឆៀនការនោះ ហើយមានពួកលេវី ដែលប៉ិនប្រសប់នឹងលេងភ្លេងដែរ ។**

## ក្រុមអ្នកដឹកនាំនៅក្នុងព្រះវិហារ

ការទទួលខុសត្រូវ និងភាពជាចម្បងរបស់អ្នកជឿគ្រប់រូប ត្រូវតែចូលទៅក្នុងការងារសរសើរតម្កើង និងការងារថ្វាយបង្គំយ៉ាងខ្ជាប់ខ្ជួនជាទីបំផុត ។

ព្រះគម្ពីរហេព្រើរ ២:១២ ចែងថា: **ទ្រង់មានបន្ទូលថា «ទូលបង្គំនឹងប្រកាសប្រាប់ពីព្រះនាមទ្រង់ ដល់ពួកបងប្អូន ទូលបង្គំនឹងច្រៀងសរសើរពីទ្រង់ នៅកណ្តាលពួកជំនុំ» ។**

### ការប្រុងប្រៀបរៀបចំ

គ្រប់គ្នាគឺត្រូវតែមានការប្រុងប្រៀបរៀបចំចិត្តរបស់គាត់ ហើយឱ្យមានអាកប្បកិរិយា ក្នុងការសរសើរតម្កើង និងការថ្វាយបង្គំ គឺត្រូវឱ្យមកដល់ព្រះវិហារមុនគេ ឬមុនពួកបងប្អូនអ្នកជឿទាំងអស់ ។

### ការគិតទុកជាមុន

ចំពោះអត្តចរិតដែលមានការគិតទុកជាមុន និងការជឿជាក់ នោះគួរគប្បីមានដល់យើងម្នាក់ៗ នៅក្នុងការងារសរសើរតម្កើង និងការងារថ្វាយបង្គំ ។

### ការមកទាន់ពេល

ការមកទាន់ពេល គឺជាការបង្ហាញនូវវត្តមាន និងសេចក្តីស្រឡាញ់របស់យើងចំពោះព្រះ ។ យើងមិនគួរគប្បីធ្វើឱ្យបាត់បង់ការមកលឿនឱ្យទាន់ពេលនោះឡើយ គឺដែលយើងនឹងបានចំណាយពេលនៅក្នុងព្រះវត្តមានរបស់ទ្រង់នោះឯង ។

នៅពេលដែលមានការជឿនទៅមុខ គឺជា "ការចូលមកក្នុង" ពីទ្វាររបង មកដល់ទីលាន ទាំងនៅខាងក្រៅទីលាន និងខាងក្នុងទីលាន នោះយើងត្រូវតែបាននៅពីខាងក្រោយ គឺមិនមែនជាការពិសោធន៍យ៉ាងពេញលេញ ក្នុងការថ្វាយបង្គំដ៏ពិតនោះឡើយ យ៉ាងហោចណាស់ក៏យើងបានចាប់យកពេលពីមួយជំហានទៅមួយជំហានទៀត នៅក្នុការចូលទៅ

ក្នុងព្រះវត្តមានរបស់ទ្រង់ផងដែរ ។ យើងគួរគប្បីរៀបចំគម្រោងចូលមកឱ្យបានមុនគេ និងបានរៀបចំវិញ្ញាណរបស់យើង ព្រមទាំងបានទទួលនូវការស្ងៀមស្ងាត់ និងត្រៀមបំពេញការងាររួចជាស្រេចចូលទៅចំពោះព្រះអម្ចាស់ នៅក្នុងការពិសោធន៍ដ៏ពេញលេញបំផុត ព្រមទាំងបានទទួលនូវការពិសោធន៍ចំពោះការសរសើរតម្កើង និងការថ្វាយបង្គំនោះ ។

មានមនុស្សជាច្រើនបានរកឃើញ នូវតម្លៃដ៏អស្ចារ្យបំផុតនៅក្នុងពេលនៃការងារសរសើរតម្កើង និងការងារថ្វាយបង្គំ ។

**ដោយការថ្វាយចិត្តទាំងស្រុងរបស់យើង**

ចាប់ពីការកំណត់ត្រាលើកទីមួ នៃការប្រគំបទភ្លេងមក នោះយើងគួរគប្បីស្ថិតនៅក្នុងអាកប្បកិរិយា នៃការគិតទុកជាមុនយ៉ាងពេញលេញ នោះកម្លាំង និងសេចក្ដីសង្ឃឹមខាងឯវិញ្ញាណ នឹងមានការពិសោធន៍ចំពោះព្រះវត្តមានរបស់ព្រះ ដែលយើងមិនធ្លាប់មានពីមុនមកនោះ ។

យើងត្រូវតែបញ្ចេញដោយនូវវិញ្ញាណ ទីសម្គាល់ និងការសរសើរតម្កើងព្រះរបស់យើង អស់ពីវិញ្ញាណ ព្រលឹង និងកម្លាំងរបស់យើង ។ យើងគួរគប្បីស្រាយនូវអ្វីៗដោយខ្លួនយើង ដើម្បីឱ្យបានទទួលនូវព្រះវត្តមានរបស់ព្រះ ។ សេចក្ដីស្រឡាញ់របស់យើងចំពោះ គួរគប្បីត្រូវបានចង្អុលបង្ហាញ ដោយការបំពេញការងារថ្វាយដល់ព្រះអម្ចាស់ ដោយមានគ្រប់ទាំងកម្លាំង អស់ពីឋាមពល សម្លេង រូបកាយ និងអស់ពីចិត្តទាំងស្រុងរបស់យើង ។

ព្រះគម្ពីរទំនុកដំកើង ១៣៨:១ ចែងថា: **ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់អស់អំពីចិត្ត ទូលបង្គំនឹងច្រៀងសរសើរទ្រង់ នៅចំពោះមុខនៃអស់ទាំងព្រះ ។**

**ការធ្វើតាមអ្នកដឹកនាំថ្វាយបង្គំ**

យើងមិនគួរគប្បីបានក្លាយមកជាអ្នកបាត់បង់ខាងឯវិញ្ញាណ ដែលយើងមិនបានធ្វើតាម និងបង្ហូរមកដោយនូវភាពជាសង្ឃរបស់ព្រះ ជាអ្នក

ដឹកនាំសរសើរតម្កើង និងថ្វាយបង្គំនោះឡើយ ។ យើងត្រូវតែបានជាអ្នកយល់ដឹងនូវការបង្ហូរ និងការធ្វើសកម្មភាពដោយមានការចាក់ប្រេងតាំងពីព្រះវិញ្ញាណបរិសុទ្ធវិញ ។

## ការចៀសវាងនូវការធ្វេសប្រហែស

តើលោកអ្នកមិនបានធ្វើខ្លួនឱ្យទៅជាអ្នកធ្វេសប្រហែស ដោយគំនិតខ្លួនឯងផ្ទាល់ ឬដោយនូវសកម្មភាពចំពោះអ្នកដទៃទៀតទេឬអី ។

សៀវភៅចម្រៀង ឬពាក្យសម្ដីនៅលើកញ្ចក់ប្រដាប់បញ្ចាំង នៅពីក្បាល គឺបានត្រឹមតែជួយយើងឱ្យដឹងស្គាល់ពីពាក្យពេចន៍ និងទីសម្គាល់រួមផ្សំតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត ការទាំងនេះគឺជាការស្រាវជ្រាវរាវរកតែប៉ុណ្ណោះ មិនមែនអាចបន្តផ្ដោតទៅលើការប្រុងប្រយ័ត្នរបស់លោកអ្នកទៅលើពួកគេនៅពេលដែលវាមិនមែនជាការចាំបាច់ណាមួយ យូរអង្វែងនោះឡើយ ។

ជួនកាលក៏វាអាចជួយឱ្យបានជិតស្និទ្ធចំពោះភ្នែករបស់លោកអ្នក ឬក៏វាហាក់ដូចជាពិដានដែលធ្វើតាមលំដាប់លំដោយ ដែលធ្វើឱ្យលោកអ្នកអាចបំភ្លេចអំពីគ្រប់ការដទៃទៀតទាំងអស់ ហើយធ្វើការផ្ចង់ចិត្តទៅរកព្រះអម្ចាស់វិញ (ចំពោះពួកអ្នកដឹកនាំថ្វាយបង្គំមិនអាចធ្វើដូច្នេះបានឡើយ) ។

## ការច្រៀងដោយវិញ្ញាណ

តាមអ្នកដឹកនាំថ្វាយបង្គំ និងភាពជាអ្នកដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធជាបន្តបន្ទាប់ នោះមានពេលដែលត្រូវសរសើរតម្កើង នឹងមានការផ្លាស់ប្តូរទៅក្នុងការបើកបង្ហាញ ចំពោះការសរសើរតម្កើងតាមបទភ្លេងដោយ "ភាសាដទៃ" ។ នៅពេលនោះ យើងអាចបានត្រឡប់មកជាអ្នកមានសម្បជញ្ញៈ ដែលពួកទេវតាកំពុងតែច្រៀងនៅក្នុងចំណោមពួកយើង គឺនៅពេលដែលយើងបានច្រៀង "ដោយវិញ្ញាណ" នោះ ។

ព្រះគម្ពីរ១កូរិនថូស ១៤:១៥ ចែងថា: **ដូច្នេះ ត្រូវធ្វើដូចម្តេច ខ្ញុំត្រូវអធិស្ឋាន ដោយនូវវិញ្ញាណ ហើយត្រូវអធិស្ឋានដោយនូវប្រាជ្ញាផង ខ្ញុំនឹងច្រៀងដោយវិញ្ញាណ ហើយនឹងច្រៀងដោយប្រាជ្ញាដែរ ។**

នៅពេលដែលការនេះកើតឡើង នោះចូររំដោះឱ្យខ្លួនលោកអ្នកផ្ទាល់ បានចូលទៅក្នុងភាពសេរី ដើម្បីឱ្យ "ភាសាដែលមកពីស្ថានសួគ៌" បានបង្ហូរមកក្នុងចិត្តលោកអ្នក ។

ព្រះវិញ្ញាណបរិសុទ្ធទ្រង់នឹងបានប្រទាន មិនត្រឹមតែពាក្យសម្តីប៉ុណ្ណោះទេ គឺទ្រង់នឹងប្រទានជាពាក្យជួនថែមទៀតផង គឺនៅពេលដែលយើងបានយល់ដឹងដល់ទ្រង់នោះ ។

## ចម្រៀងខាងវិញ្ញាណ

ចូរធ្វើឱ្យបានជាអ្នកយល់ដឹង ពីព្រះវិញ្ញាណបរិសុទ្ធចុះ ។ ជារឿយៗ ទ្រង់សម្រេចព្រះទ័យនឹងប្រទាន "ចម្រៀងខាងវិញ្ញាណ" ដល់រូបកាយផងដែរ ។ ប្រសិនបើព្រះទ្រង់សព្វព្រះហឫទ័យបំពេញព្រះរាជកិច្ចតាមមធ្យោបាយនេះ គឺឆ្លងតាមរយៈយើង ដែលយើងបានទទួលនូវសិទ្ធិអំណាចណាមួយ ដែលអាចបានជាតម្រូវការដោយភាពជាអ្នកដឹកនាំ នៅចំពោះការប្រទានពរនោះ ។

វាអាចជាការចាប់ផ្តើមនិយាយភាសាដទៃ ហើយបន្ទាប់មក ក៏មានការផ្លាស់ប្តូរចលនាចូលទៅក្នុងការយល់ដឹងរបស់លោកអ្នក ។ វាអាចបានត្រឡប់មកជាអ្នកចេះអធិប្បាយ ។ ព្រះទ្រង់នឹងប្រទាននូវពាក្យសម្តីព្រមទាំងពាក្យជួន ។ ចម្រៀងសរសើរតម្កើងថ្មីៗ គឺតែងតែបានប្រទានឱ្យដល់រូបកាយរបស់ព្រះគ្រីស្ទ នៅកំឡុងពេលទាំងនោះ ។

ព្រះគម្ពីរអេភេសូរ ៥:១៩ ចែងថា: **ហើយនិយាយគ្នាទៅវិញទៅមក ដោយបទទំនុកដំកើង ទំនុកបរិសុទ្ធ និងចំរៀងខាងឯវិញ្ញាណ ទាំងច្រៀង ហើយសរសើរដល់ព្រះអម្ចាស់ដោយចិត្ត ។**

ព្រះគម្ពីរកូល៉ុស ៣:១៦ ចែងថាៈ **ចូរឱ្យព្រះបន្ទូលនៃព្រះគ្រីស្ទបានសណ្ឋិតនៅក្នុងអ្នករាល់គ្នាជាបរិបូរ ដោយប្រាជ្ញាគ្រប់យ៉ាង ទាំងបង្រៀនហើយទូន្មានគ្នា ដោយនូវទំនុកដំកើង ទំនុកបរិសុទ្ធ និងចំរៀងខាងឯវិញ្ញាណ ទាំងច្រៀងក្នុងចិត្តថ្វាយព្រះ ដោយព្រះគុណ ។**

## អំណោយទាននៃការបញ្ចេញសម្លេងរបស់ព្រះវិញ្ញាណបរិសុទ្ធ

ជារឿយៗ មានការឈប់ទ្រឹងនូវពេលវេលានៃការសរសើរតម្កើងនៅចុងបំផុតនៃចម្រៀង ដែលបានប្រទានឱ្យហើយនូវសេចក្ដីល្អ សម្រាប់ការសម្ដែងព្រះបន្ទូលជាភាសាដទៃ ក៏មានការបកប្រែភាសាដទៃផង ឬក៏មានការអធិប្បាយផងដែរ ។

ចូរទទួលយកនូវសិទ្ធិអំណាច ឬការទទួលស្គាល់នីមួយៗ ដែលអាចជាតម្រូវការដោយភាពជាអ្នកដឹកនាំ នៅចំពោះការប្រទានឱ្យនូវការសម្ដែងព្រះបន្ទូល ដែលព្រះទ្រង់បានប្រទានឱ្យដល់លោកអ្នក ។ វាគួរតែប្បីត្រូវបានប្រទានឱ្យដោយនូវមធ្យោបាយ ដែលអាចបានឮ និងបានយល់យ៉ាងច្បាស់លាស់ ដោយសារពួកអ្នកដឹកនាំព្រះវិហារទាំងមូល ។

## ការទទួលនូវភាពស្ងៀមស្ងាត់

គ្រប់ទាំងការទ្រឹងនៅ ឬការស្ងៀមស្ងាត់ កំឡុងពេលសរសើរតម្កើង និងថ្វាយបង្គំ នោះគឺមិនមែនជាការចាំបាច់ ដោយមានអ្នកណាម្នាក់ជាទោល ដែលជាអ្នកសម្ដែងព្រះបន្ទូល ដែលគួរតែប្បីត្រូវបានប្រទានឱ្យ ។ ចូរធ្វើការយល់ដឹងចំពោះព្រះវិញ្ញាណបរិសុទ្ធ ។

ការស្ងៀមស្ងាត់អាចបានមក ដោយសារតែមានកម្លាំងនៃព្រះវត្តមានរបស់ព្រះ ដែលយើងបានចូលមក នៅពេលដែលយើងបានថ្វាយបង្គំព្រះអង្គនោះ ។ ដើម្បីនិយាយនៅពេលនោះ យើងគួរតែប្បីមានការបកស្រាយនូវអ្វី ដែលព្រះទ្រង់សព្វព្រះហឫទ័យឱ្យកើតឡើង នៅពេលភ្លាមៗនោះ ។

ព្រះគម្ពីរហាបាកុក ២:២០ ចែងថា: **ឯព្រះយេហូវ៉ាទ្រង់គង់នៅក្នុងព្រះវិហារបរិសុទ្ធរបស់ទ្រង់វិញ ចូរឲ្យផែនដីទាំងមូលស្ងៀមនៅចំពោះទ្រង់ចុះ ។**

## សំណួររំឭកសារឡើងវិញ

១ ចូរពិពណ៌នាពីគុណសម្បត្តិ និងពីមុខងាររបស់ពួកអ្នកដឹកនាំថ្វាយបង្គំតាមព្រះគម្ពីរ ។

២ ចូរពិពណ៌នាពីមុខងាររបស់ឧបករណ៍ភ្លេង ដែលមាននៅក្នុងព្រះគម្ពីរ ។

៣ តើការទទួលខុសត្រូវរបស់អ្នកដឹកនាំព្រះវិហារ ក្នុងការសរសើរតម្កើង និងការថ្វាយបង្គំនោះយ៉ាងដូចម្ដេចខ្លះ?

# មេរៀនទី ១៥

## *ការបំពេញការងារជាអ្នកដឹកនាំថ្វាយបង្គំ*

### ការប្រុងប្រៀបរៀបចំ

ការងារថ្វាយបង្គំដែលមានពេញជោគជ័យ និងពេញដោយការចាក់ប្រេងតាំង គឺមិនមែនត្រឹមតែជាការកើតឡើងនោះទេ ។ វាជាការចំណាយម៉ោងពេលនៃការប្រុងប្រៀបរៀបចំអធិស្ឋាន មុនពេលការងារបានចាប់ផ្ដើម ។

ការងារដ៏ប្រសើរជាចម្បង នឹមិនមែនជាការចាំបាច់ឱ្យបានជាគំរូសម្រាប់ការអ្វី ដែលនឹងកើតឡើងដល់អ្នកដទៃទៀតនោះទេ ។ ព្រះទ្រង់ដ៏ជាព្រះនៃការប្រែប្រួល ។ ចូរអធិស្ឋាន និងទទួលការដឹកនាំរបស់ទ្រង់សម្រាប់ការងារបម្រើពិសេសមួយៗ ។ ចូរអនុញ្ញាតឱ្យព្រះវិញ្ញាណបរិសុទ្ធ និងការយល់ដឹងពីការចាក់ប្រេងតាំងរបស់ទ្រង់ ។

ព្រះគម្ពីរបរិទេវ ៣:២២,២៣ ចែងថាៈ **គឺនឹកពីសេចក្ដីនេះថា កុំតែមានសេចក្ដីសប្បុរសរបស់ព្រះយេហូវ៉ា នោះយើងបានសូន្យបាត់អស់រលីងទៅហើយ ឯសេចក្ដីមេត្តាករុណារបស់ទ្រង់ នោះមិនចេះផុតឡើយ សេចក្ដីទាំងនោះ ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច សេចក្ដីស្មោះត្រង់របស់ទ្រង់ធំណាស់ ។**

នៅក្នុងការសរសើរតម្កើង និងការថ្វាយបង្គំខ្លះ ស្ទើរតែគ្រប់ពេលទាំងអស់ នឹងត្រូវបានគេចំណាយក្នុងការសរសើរតម្កើងដល់ព្រះ ដែលមានពេញដោយសេចក្ដីអំណរអរសប្បាយ ។ នៅក្នុងការដទៃទៀត ការងារបម្រើនឹងផ្លាស់ប្ដូរយ៉ាងឆាប់រហ័សបន្ថែមទៀត ចូលទៅក្នុងពេលនៃការថ្វាយបង្គំដ៏មានភាពខ្លាំងក្លា ។

### ការជ្រើសរើសចម្រៀង

ពេលដែលមានប្រសិទ្ធិភាព នោះវាជាការសំខាន់ដើម្បីរកឃើញនូវប្រធានបទនៃការសម្ដែងព្រះបន្ទូល ដែលត្រូវបានគេរៀបចំគម្រោង

សម្រាប់ការងារបម្រើ ។ បន្ទាប់មក ចម្រៀងដែលត្រូវបានគេជ្រើសរើស អាចបង្ហូរមកជាមួយនូវការតាំងមូលដ្ឋានខាងឯវិញ្ញាណ សម្រាប់ការបង្រៀនព្រះបន្ទូល ដែលនឹងមានជាបន្តបន្ទាប់ ។

ការចំណាយពេលជ្រើសរើសយកចម្រៀង ដែលមានពេញដោយសេចក្តីអធិស្ឋាន ដែលនឹងត្រូវបានគេប្រើកំឡុងពេលការងារសរសើរតម្កើង និងការងារថ្វាយបង្គំនោះ ។

ការជ្រើសរើសចម្រៀង ដែលអាចត្រូវបានគេច្រៀងដោយមានសម្លេងដែលអាចកម្សាន្តចិត្ត ទៅតាមលំដាប់ថ្នាក់សម្រាប់អ្នកដឹកនាំក្នុងព្រះវិហារ ។

ជួនកាល គេអាចច្រៀងចម្រៀងដដែលៗសារចុះសារឡើង ជាច្រើនដង ដែលនឹបើកឱ្យពាក្យពេចន៍ និងការសម្តែងព្រះបន្ទូល បានត្រឡប់ជាផ្នែកមួយនៃគំនិត និងការសម្រេចចិត្ត របស់អ្នកថ្វាយបង្គំជាលក្ខណៈបុគ្គល ។

### ចម្រៀងដែលមានការរៀបចំឡើង

ចម្រៀងដែលបានត្រៀមតាមមធ្យោបាយរបៀបនេះ គឺដែលចម្រៀងទាំងនោះ នឹបានជាគំរូនៃ "ការចូលទៅក្នុង" ជាបន្តបន្ទាប់៖

- ចម្រៀងនៃការអរព្រះគុណ និងចម្រៀងនៃការសរសើរតម្កើង ដែលនឹងទាញនាំឱ្យកាន់តែមានកម្រិតខ្ពស់ឡើងៗ ចំពោះការចូលរួម ទាំងផ្នែករូបកាយ ទាំងផ្នែកខាងការបញ្ចេញសម្លេង
- ចម្រៀងដែលនឹងបញ្ចេញ នូវការចាក់ប្រេងតាំងរបស់ព្រះ ហើយមនុស្សក៏នឹងចូលកម្រិតនៃការសរសើរតម្កើង កាន់តែខ្ពស់ឡើង
- ចម្រៀងនៃការថ្វាយបង្គំចុងក្រោយ ដែលនឹងបំផ្លាស់បំប្រែដល់ពួកអ្នកជឿ ឱ្យកាន់តែចូលទៅជិតព្រះវត្តមាននៃព្រះ ។

ចម្រៀងគួរគប្បីត្រូវបានរៀបជាក្រុម តាមមធ្យោបាយដែលពួកអ្នកថ្វាយបង្គំមិនត្រូវបានផ្លាស់ប្ដូរទៅខាងមុខខាងក្រោយ រវាងចម្រៀងថ្វាយបង្គំ និងចម្រៀងសរសើរតម្កើងនោះឡើយ គឺត្រូវឱ្យមានការជឿនទៅមុខ ដោយមិនមានការរំជួយ សូម្បីតែការបង្ហូរមកនៃការថ្វាយបង្គំនោះក៏មានកម្រិតកាន់តែខ្ពស់ឡើងៗផងដែរ ។

ចូរធ្វើការជ្រើសរើសយ៉ាងប្រុងប្រយ័ត្ន នូវគន្លឹះទាំងឡាយ នៅក្នុងចម្រៀងដែលនឹងត្រូវច្រៀង និងក្រុមដែលត្រូវច្រៀងរួមគ្នាឱ្យបានពិតប្រាកដច្បាស់លាស់ ទៅតាមចំណងជើងបទចម្រៀងនោះ ។

វាជាការល្អចំពោះការផ្ដល់នូវឧបករណ៏ភ្លេង និងប្រដាប់បញ្ចាំងរូបភាពនៅខាងលើ ប្រសិនបើអ្នកបានប្រើតាមបញ្ជីដែលបង្ហាញនូវបទចម្រៀងតាមលំដាប់លំដោយ នោះពួកអ្នកច្រៀងក៏ត្រូវតែធ្វើតាមបញ្ជីចម្រៀងនោះដែរ ។ លោកអ្នកអាចធ្វើការផ្ដល់ឱ្យនូវគ្រឿងឧបករណ៏ភ្លេង ឬក៏បង្ហាញនូវទីកន្លែងចម្រៀងដែលនៅកន្លែងណា គឺធ្វើទៅតាមអ្នកចងក្រងនូវបទភ្លេងសម្រាប់ថ្វាយបង្គំនោះ ។ ចូរធ្វើការផ្ដល់ឱ្យនូវគ្រឿងឧបករណ៏ភ្លេង ដោយធ្វើការសម្រួលភ្លេងដែលមានខ្សែ សម្រាប់ការផ្លាស់ប្ដូរកូនសោរភ្លេង ដើម្បីឱ្យការប្រគំបទភ្លេងអាចបន្តបង្ហូរនូវចម្រៀងនីមួយៗបានល្អ ។

ប្រសិនបើមានចម្រៀងថ្មីដែលត្រូវយកមកច្រៀង ត្រូវរៀបចំការបញ្ចាំងឱ្យបានល្អបើសិនជាមានប្រដាប់បញ្ចាំង ដែលត្រូវយកមកប្រើ ។

ព្រះគម្ពីរទំនុកដំកើង ៣៣:៣ ចែងថា: **ចូរច្រៀងទំនុកថ្មីថ្វាយទ្រង់ ហើយលេងភ្លេងឱ្យឮរងំ ដោយប៉ិនប្រសប់ ។**

ប្រដាប់បញ្ចាំងត្រូវតែមានកញ្ចក់ស្រស់ភ្លឺថ្លា ហើយត្រូវតែបានរៀបចំតាមលំដាប់លំដោយ ដែលពួកគេនឹងត្រូវប្រើប្រាស់វានោះ ។

ចម្រៀងនឹងត្រូវតែបានហូរមក ពីមួយបទទៅមួយបទទៀត ដោយគ្មានការរអាក់រអួលឡើយ ដើម្បីឱ្យអាចបានជាការប្រាកដប្រជា គឺឱ្យមានការបង្ហូរមកនៃព្រះវិញ្ញាណ ។

**ការរៀបចំខាងវិញ្ញាណ**

អ្នកដឹកនាំល្អនឹងមិនដែលចូលមកឯការងារបម្រើដោយ "ត្រជាក់" នោះឡើយ ។ ការប្រុងប្រៀបរៀបចំ គឺរាប់បញ្ចូលទាំងពេលវេលាដ៏ច្រើន ដែលត្រូវចំណាយក្នុងការអធិស្ឋាន និងការសរសើរតម្កើង និងការថ្វាយបង្គំ ជាលក្ខណៈទោល ដើម្បីឱ្យបានយល់លក្ខណៈនៃព្រះវិញ្ញាណ សម្រាប់ការងារបម្រើមុនពេលអង្គប្រជុំបានចាប់ផ្ដើម ។ បន្ទាប់មក គាត់នឹងមានលទ្ធភាពចាប់ផ្ដើមក្រុមបន្ទរតាមបទចម្រៀងជាដំបូង "អ្នកនៅតាមតំបន់ផ្ទាល់" ។ ជារៀងរាល់នាទីនៃការងារបម្រើ ដែលត្រូវតែមានអ្នកដឹកនាំ ដើម្បីធ្វើចលនាចូលទៅក្នុងការបង្ហូរមកនៃព្រះវិញ្ញាណបរិសុទ្ធ គឺជាពេលដែលត្រូវសរសើរតម្កើង និងថ្វាយបង្គំដល់ព្រះដ៏ពិតប្រាកដ ។

**ការរៀបចំខាងផ្នែករូបកាយ**

ចូរស្លៀកពាក់ឱ្យបានសមរម្យ ចំពោះឱកាសនេះ ។ កុំបណ្ដោយឱ្យអាការៈខាងក្រៅរបស់លោកអ្នក មានអាកប្បកិរិយារាយមាយដល់ពួកអ្នកថ្វាយបង្គំឡើយ ។

អ្នកអនាម័យ អ្នកសម្អាត និងអ្នករៀបចំតុបតែង គឺសុទ្ធតែជាអ្នកសំខាន់ ក៏ដូចជាលោកអ្នក ដែលជាតំណាងឱ្យព្រះនៅចំពោះមុខពួកបណ្ដាជនដូច្នោះដែរ ។

ព្រះគម្ពីរលោកុប្បត្តិ ៤១:១៤ ចែងថា: **នោះផារ៉ោន ទ្រង់ចាត់គេឱ្យទៅហៅយ៉ូសែបមក គេក៏ទៅនាំគាត់ចេញពីគុកជ្រៅនោះមកជាប្រញាប់ គាត់កោរពុកមាត់ ហើយផ្លាស់សំលៀកបំពាក់ រួចចូលទៅគាល់ផារ៉ោន ។**

**ក្រុមដឹកនាំថ្វាយបង្គំ**

**អ្នកចម្រៀង និងឧបករណ៍ភ្លេង**

ការជ្រើសរើសដែលពេញដោយការអធិស្ឋាន គឺជាសមាជិកនីមួយៗនៃក្រុមថ្វាយបង្គំ ។ ចូរធ្វើការការពារដល់ក្រុមអ្នកដាក់ពិន័យ និងក្រុមអ្នកមានភាពស្រឡាញ់ដ៏ស្មោះខាងឯវិញ្ញាណ ប៉ុន្តែ ត្រូវឱ្យតឹងរឹងចំពោះអស់អ្នកដែលមានការទាក់ទងនឹងអំពើបាប ឬចងសម្ពន្ធជាមួយនឹងបញ្ហាដែលអាចកើតមានឡើង ។

ចូរសម្តែងនូវភាពជាអ្នកដឹកនាំខាងឯវិញ្ញាណ ដែលមានកម្រិតខ្ពស់ ការលើកទឹកចិត្ត និងការរីកចម្រើនខាងឯជំនាញ តាមមុខសញ្ញានីមួយៗ ។ ចូរដាក់ឱ្យមានស្តង់ដាខ្ពស់ដ៏លើសលប់ និងបង្ហាញនូវការសរសើរចំពោះការនីមួយៗសម្រាប់ផ្នែករបស់គាត់ ឬរបស់នាង។ ចូរតម្រូវឱ្យមានភាពស្មោះត្រង់ ការប្តេជ្ញា និងបង្រួមវិញ្ញាណមកតែមួយ ។

ក្រុមថ្វាយបង្គំគួរគប្បីអធិស្ឋានរួមគ្នា មុនពេលចាប់ផ្តើមការងារថ្វាយបង្គំ ។

## ការអនុវត្តន៍នូវសេចក្តីបង្រៀន

**ថ្វាយសិរីល្អដល់ព្រះ**

ចូរកុំធ្វើការអូសទាញនូវការប្រុងប្រយ័ត្ន ចំពោះខ្លួនឯងនោះឡើយ ។ ពួកអ្នកជឿ គឺត្រូវតែមានការមើលឃើញព្រះយេស៊ូវ និងថ្វាយបង្គំទ្រង់ ព្រមទាំងដល់ព្រះវរបិតាផង ។

ព្រះគម្ពីរម៉ាថាយ ១៧:៨ ចែងថា: **កាលគេបានងើបឡើង នោះមិនបានឃើញអ្នកណាសោះ ឃើញតែព្រះយេស៊ូវតែប៉ុណ្ណោះ ។**

**ចូរធ្វើជាអ្នកយល់ដឹង**

វាជាការសំខាន់ដែលអ្នកដឹកនាំមានការយល់ដឹង ចំពោះគ្រប់ទាំងអស់ ដែលកំពុងតែធ្វើដំណើរកំឡុងពេលធ្វើការងារបម្រើ:

- *ដល់ព្រះ និងការដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ*

- *ចំពោះសហដឹកនាំនៃការងារថ្វាយបង្គំ*
- *ចំពោះគ្រឿងឧបករណ៍ភ្លេង*
- *ពួកចាស់ទុំដែលមានប្រាជ្ញា និងមានភាពជាអ្នកដឹកនាំ*
- *ចំពោះអ្នកដឹកនាំព្រះវិហារទាំងមូល*

**ការបានជាអ្នកគួរឱ្យជឿជាក់**

ចូរធ្វើខ្លួនឱ្យបានជាអ្នកគួរឱ្យជឿជាក់ នៅក្នុងការត្រាស់ហៅ និងលទ្ធភាពរបស់លោកអ្នក ។ នៅក្នុងការបន្ទាបខ្លួន ការថ្វាយទៅព្រះពីគ្រប់ទាំងសិរីល្អ ពីសេចក្តីពិតដែលព្រះអម្ចាស់ទ្រង់បានចាក់ប្រេងតាំងឱ្យលោកអ្នកធ្វើជាអ្នកដឹកនាំក្នុងការងារថ្វាយបង្គំ ដែលទ្រង់បានប្រទានឱ្យលោកអ្នក មានលទ្ធភាពដើម្បីធ្វើការឱ្យបានកាន់តែល្អប្រសើរឡើង ។

ព្រះគម្ពីរភីលីព ៤:១៣ ចែងថា: **ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បានដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ ។**

**ការដឹកនាំពួកគេឱ្យចូលទៅក្នុង**

ពួកបណ្តាជនត្រូវតែបានទទួលការអនុញ្ញាត ពីកន្លែងដែលពួកគេចូលទៅក្នុងព្រះវត្តមានរបស់ព្រះ ។ លោកអ្នកមិនអាចដឹកនាំពួកគេចេញពីកន្លែងដែលលោកអ្នកនៅនោះទេ ជំនួសឱ្យការនេះ លោកអ្នកត្រូវតែមានជំនាញក្នុងការដឹកនាំពួកគេគ្រប់ការទាំងអស់ដែលនៅខាងក្នុងគឺជារូបកាយតែមួយ ចេញពីកន្លែងដែលពួកគេនៅនោះ ឱ្យបានចូលទៅក្នុងកន្លែងដែលមានការសហការណ៍គ្នាដោយនូវព្រះវិញ្ញាណនោះឯង ។

ចូរស្វែងរក ដើម្បីធ្វើការដោយប្រញាប់ប្រញាល់ ក្នុងការទាក់ទងជាមួយពួកអ្នកដឹកនាំព្រះវិហារ ត្រូវជួយកសាងនូវការជឿជាក់ចំពោះពួកបណ្តាជន ដោយមានភាពជាអ្នកដឹកនាំរបស់លោកអ្នក ហើយបន្ទាប់មកប្រញាប់ប្រញាល់ធ្វើការបំផ្លាស់បំប្រែពួកគេ ឱ្យអាចបានចូលទៅក្នុងការសរសើរតម្កើងនោះ ។

មានចម្រៀងដ៏ពិតប្រាកដ និងបច្ចេកទេសខាងឯវិញ្ញាណ ដែលនឹងបម្រើចំពោះការអូសទាញពួកបណ្តាជន ឱ្យបានមកជារូបកាយតាមរយៈការចូលតាម "ទ្វារ" ដោយមានដង្វាយនៃការអរព្រះគុណ និងការស្អានទុកជាមុន និងក្នុងការពិសោធន៍ចំពោះព្រះវត្តមាននៃព្រះ ។ អ្នកដឹកនាំថ្វាយបង្គំ ត្រូវតែអភិវឌ្ឍនូវលទ្ធភាពនេះ ដោយការចាក់ប្រេងតាំងរបស់ព្រះ ឱ្យបានជាផ្នែកមួយនៃជំនាញជាសង្ឃនៃព្រះរបស់គាត់ ។

## តើមានមូលហេតុអ្វីទៅដែលពួកគេមិនបានចូល

ប្រសិនបើពួកបណ្តាជនមើលឃើញបានយ៉ាងឆាប់រហ័ស គឺចំពោះ "ការចូលទៅក្នុង" ទាំងស្រុង និងការធ្វើចលនាជារូបកាយមួយនៅក្នុងព្រះវត្តមាននៃព្រះអម្ចាស់នោះឯង ។ ប្រសិនបើមិនដូច្នោះទេ ចូរទូលសូមដល់ព្រះនូវប្រាជ្ញាដែលមកពីទ្រង់ គឺជារបៀបធ្វើឱ្យមានជ័យជម្នះនូវឧបស័គ្គ ព្រមទាំងមានលទ្ធភាព អាចធ្វើការបំផ្លាស់បំប្រែជាមុនយ៉ាងឆាប់រហ័សនោះឯង ។

ចូរធ្វើការដាស់តឿនក្រើនរំឭកដល់ពួកគេ ចំពោះការប្រើដោយមានការប្រុងប្រយ័ត្ន ដើម្បីនាំមកនូវការផ្តន្ទាទោស គឺឱ្យមានចលនាចូលទៅក្នុងព្រះវត្តមាននៃព្រះ ។ ការបង្រៀនដល់ពួកគេដែលមានពេញដោយសេចក្តីស្រឡាញ់ នោះគឺជារបៀបចូលទៅខាងក្នុង ។ ចូរធ្វើកាចងពួកវិញ្ញាណក្រោយៗទៀត ដែលអាចធ្វើការព្យាយាមបញ្ឈប់នូវការហូរមករបស់ព្រះវិញ្ញាណ ។ ប្រសិនបើជាការចាំបាច់ ចូរធ្វើចលនាទៅលើការច្រៀងចម្រៀងផ្សេងៗទៀត ។

## អស់អ្នកដែលមិន

យើងត្រូវតែពិតប្រាកដថា មានហេតុផលជាច្រើនដែលអ្នកខ្លះមិនបានបញ្ចេញសកម្មភាពជាមួយនឹងអ្នកដទៃទៀត ដើម្បីចូលទៅក្នុងការសរសើរតម្កើង និងការថ្វាយបង្គំនោះទេ ។ មានអ្នកខ្លះក៏ជាអ្នកមិនជឿដែរ ហើយមានអ្នកខ្លះគឺជាអ្នកជឿ តែបានរស់នៅក្នុងការបះបោរ ឬមិន

ស្តាប់បង្គាប់ដល់ព្រះវិញ ។ ចំពោះពួកអ្នកដទៃទៀតគឺអាចនៅក្រោមការបន្ទោសពីខ្មាំងសត្រូវ ឬនៅក្រោមបន្ទុកនៃការខ្វល់ខ្វាយវិញ ។ មានអ្នកដទៃទៀតដែលអាចនៅក្រោមការផ្តន្ទាទោសពីខ្មាំងសត្រូវ ឬក៏នៅក្រោមបន្ទុកនៃការថែរក្សានោះ គឺគ្រាន់តែមិនដឹងពីរបៀបត្រូវធ្វើតែប៉ុណ្ណោះ ។

លោកអ្នកជាអ្នកដឹកនាំថ្វាយបង្គំ គឺមិនត្រូវបានទៅជាអ្នកដែលមិនត្រូវបានចូលទៅខាងក្នុងនោះឡើយ ។ តើសិរីល្អនឹងត្រូវទៅជាយ៉ាងណាវិញ នៅពេលដែលមនុស្សទាំងអស់មានចិត្តរួមមកតែមួយ ដើម្បីចូលទៅខាងក្នុងបាននោះ ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានអ្នកខ្លះដែលយើងត្រូវតែកុំអើពើដឹងចំពោះអស់អ្នក ដែលនឹងមិនកាន់ខ្ជាប់នូវការប្រុងប្រយ័ត្នដ៏ពេញលេញបំផុត ទៅលើរូបកាយរបស់ពួកអ្នកជឿ ដែលបានសហការណ៍គ្នានោះ ។ ជួនកាល ភាពជាលក្ខណៈបុគ្គទាំងនេះ អាចត្រូវបានគេទាក់ទងដោយមានលក្ខណៈជាឯកជន នៅពេលចុងក្រោយ និងទទួលនូវការបង្រៀន ឬជាការតាំងពិពណ៌ ដែលមានការចូលរួមដោយកម្រិតខ្ពស់ ។

**ចូរកាន់ខ្ជាប់នូវការបើកភ្នែក**

នៅពេលដែលលោកអ្នកបិទភ្នែក នោះលោកអ្នកកំពុងតែបិទមនុស្សដែលលោកអ្នកត្រូវតែដឹកនាំចូលទៅក្នុងការថ្វាយបង្គំនោះហើយ ។ អ្នកដឹកនាំត្រូវតែបានជាអ្នកដែលមានសម្បជញ្ញៈ ចំពោះអ្វីដែលបានកើតឡើង និងទីកន្លែងណាដែលមនុស្សខាងវិញ្ញាណ គឺជាអ្នកមានការងារសរសើរតម្កើងកំពុងតែមានការរីកចម្រើន ។

អ្នកដឹកនាំគឺមិនត្រូវជាអ្នកដែលក្លាយមកជាអ្នក "បាត់បង់ខាងវិញ្ញាណ" យ៉ាងដូច្នោះ ដែលគាត់ ឬនាងបានបាត់បង់នូវការទាក់ទងជាមួយនឹងការដឹកនាំរបស់គាត់ ឬរបស់នាងនោះឡើយ ។ ពេលវេលាគឺត្រូវបាន "ស្រាយ" ហើយ សម្រាប់អ្នកដឹកនាំដែលនៅក្នុងពេលវេលាថ្វាយបង្គំផ្ទាល់

ខ្លួនរបស់គាត់ ឬរបស់នាង ឬក៏នៅពេលដែលមានអ្នកដទៃទៀតខ្លះ កំពុងតែធ្វើកាដឹកនាំនោះ ។

ចូរធ្វើការដឹកនាំ និងលើកទឹកចិត្តដល់មនុស្សដោយការប្រើភ្នែកសម្រាប់ធ្វើការទាក់ទងចំពោះពួកគេនោះ ។ ផ្នែកនីមួយៗចំពោះអំណោយទាននៃការដឹកនាំថ្វាយបង្គ គឺត្រូវតែបានចូលទៅក្នុងការថ្វាយបង្គំដ៏ពិត គឺនៅពេលដែលការស្រាវជ្រាវរាវរកនូវអ្នកដឹកនាំព្រះវិហារ នៅពេលតែ១នោះ ។

**កុំធ្វើការចែកចាយឡើយ**

កំឡុងពេលសរសើរតម្កើង និងអធិស្ឋានគឺមិនមែនជាពេលវេលាដើម្បីបញ្ឈប់ និងដើម្បី "ចែកចាយ" នោះឡើយ ។ ការតាំងពិពណ៌ខ្លីៗ គឺជួនកាល ពិតជាបានជួយនៅក្នុងការនាំមនុស្សឱ្យចូលទៅក្នុងការសរសើរតម្កើងដ៏មានកម្រិតខ្ពស់ ។ កុំបញ្ឈប់នូវការបង្ហូរមកនៃការងារបម្រើ ឬក៏ជាការប្រើពេលវេលាពីដំបូង ដោយការនិយាយពីសាច់រឿងទាំងឡាយដែលនឹងមិននាំឱ្យមានការបង្អាក់នូវចលនារបស់ព្រះវិញ្ញាបរិសុទ្ធ នៅក្នុងការសរសើរតម្កើង និងការថ្វាយបង្គំនោះបានឡើយ ។

**ការទាក់ទងទៅនឹងកំហុស**

ចូរចងចាំថា យើងទាំងអស់គ្នាគឺជា "អ្នករៀនសូត្រ" ហើយការធ្វើខុសគឺជាផ្នែកមួយនៃការបានមកពីការរៀនសូត្រនោះ ។ កុំដាក់ខ្លួនឯងឱ្យនៅក្រោមការបេទ្មាសនោះឱ្យសោះ ។ ចូរឱ្យមានការផ្អែមល្ហែមបំផុតជាមួយនឹងមនុស្ស ប្រសិនបើលោកអ្នកមានកំហុសចំពោះព្រះ ហើយធ្វើការផ្លាស់ប្តូរចំពោះកំហុសឆ្គងនោះ តាមការដឹកនាំរបស់ព្រះ ។

ជួនកាលបន្ទាប់ពីការងារបម្រើនោះត្រូវបានបញ្ចប់ ចូរចំណាយពេលវេលាទូទៅព្រះដោយទោលតែម្នាក់ឯង អំពីកំហុសឆ្គងនោះ ។ ទូលដល់ទ្រង់ពីកន្លែងដែលលោកអ្នកមានអារម្មណ៍ថា បានធ្វើខុសនោះ ។ ចូរទូលសូមដល់ទ្រង់ពីអ្វីដែលនៅខាងក្នុងចិត្ត ដើម្បីឱ្យមានការយល់ដឹង

បន្ថែមទៀត នៅក្នុងការប្រើសភាពការណ៍ដូចគ្នានោះ នៅពេលបន្ទាប់ទៀត ដែលវានឹងមានការរីកចម្រើនឡើង ។

ទាំងអស់ខាងលើនេះ ចូរបើកឱ្យទ្រង់មានបន្ទូលមកកាន់លោកអ្នក អំពីរឿងរ៉ាវដែលលោកអ្នកបានធ្វើត្រឹមត្រូវ! ចូរបើកឱ្យទ្រង់បង្រៀនលោកអ្នកដោយនូវសេចក្តីស្រឡាញ់ តាមផ្លូវរបស់ព្រះវិញ្ញាណ ។ ចូរទទួលនូវសេចក្តីបង្រៀនរបស់ទ្រង់ គឺនៅពេលដែលមានការបដិសេធន៍ណាមួយ ដោយការមិនយល់ព្រមពីខ្មាំងសត្រូវជាដើម ។

ព្រះគម្ពីររ៉ូម ៨:១ ចែងថាៈ **ហេតុនោះ នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះគ្មានទោសសោះ ។**

ប្រសិនបើជាតម្រូវការ ចូរស្វែងរក និងទូលសូមនូវការប្រឹក្សា និងការឱ្យដំបូន្មាន របស់លោកគ្រូគង្វាល ឬពួកចាស់ទុំដែលបំពេញការងារដទៃទៀត ។

## ការងារថ្វាយបង្គំ

### អ្នកចាស់តឿនក្រើនរំឭក

វាជាការល្អចំពោះអ្នកដាស់តឿនក្រើនរំឭក ដើម្បីច្រៀងថ្វាយទៅព្រះអម្ចាស់ ។ ពួកគេមិនគួរគប្បីច្រៀងដោយសារតែជាទម្លាប់នោះឡើយ ឬក៏ជាអ្នកដែលគ្រាន់តែធ្វើការច្រៀងនោះឡើយ ។ គឺពួកគេគួរគប្បីច្រៀងសរសើរតម្កើងដល់ព្រះអម្ចាស់ និងចូលទៅក្នុងព្រះវត្តមានរបស់ទ្រង់យ៉ាងពេញលេញ ក្នុងការថ្វាយបង្គំដ៏ពិត ។

### ចូរចាប់ផ្តើមដោយការអរព្រះគុណ

មុនពេលដែលយើងសរសើរតម្កើងដល់ព្រះយ៉ាងពេញលេញ នោះទីមួយយើងត្រូវតែចូលទៅក្នុងទីសរសើរតម្កើងនោះ ។

ព្រះគម្ពីរទំនុកដំកើង ១០០:៤ ចែងថាៈ **ចូរនាំគ្នាចូលតាមទ្វារទ្រង់ ដោយពោលពាក្យអរព្រះគុណ ហើយចូលទៅក្នុងទីលានទ្រង់ ដោយបទសរសើរ ចូរអរព្រះគុណដល់ទ្រង់ ហើយសរសើរព្រះនាមទ្រង់ចុះ ។**

**ចូរធ្វើចលនាក្នុងការសរសើរតម្កើង**

មានពេលវេលាជាច្រើន ដែលគេបានចំណាយកំឡុងពេលសរសើរតម្កើង និងថ្វាយបង្គំនៅក្នុង "ទីលាន" នោះ ។ គឺនៅទីហើយ ដែលម្នាក់ៗត្រូវតែបានទទួលនូវការបញ្ចេញនូវសម្លេង និងការចង្អុលបង្ហាញខាងឯផ្នែករូបកាយ កាន់តែល្អប្រសើរឡើង ចំពោះការសរសើរតម្កើង និងការថ្វាយបង្គំដល់ព្រះ សម្រាប់គ្រប់ទាំងព្រះពរដ៏អស្ចារ្យរបស់ផងទ្រង់ ។

**ចូរបង្ហូរចូលនៅក្នុងការថ្វាយបង្គំ**

ចូរឱ្យបានយល់ដឹងចំពោះព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងពេលរបស់ទ្រង់ចុះ ហើយចាប់ផ្ដើមធ្វើចលនាឱ្យមនុស្សបានចូលទៅក្នុងសេចក្ដីពិតកាន់តែមានជម្រៅជ្រៅ និងចូលរួមថ្វាយបង្គំព្រះសម្រាប់អស់អ្នក ដែលទ្រង់គង់ជាមួយ ។

**ចូរធ្វើតាមការចាក់ប្រេងតាំង**

ចូរទុកបំណងផែនការរបស់លោកអ្នកនៅម្ខាងសិន ទម្រាំតែលោកអ្នកបានចំណាយពេលឱ្យបានច្រើន ក្នុងការប្រុងប្រៀបរៀបចំ ។ លោកអ្នកអាចផ្អាកនូវចម្រៀងខ្លះៗ នៅពេលដែលមានការបង្អែបង្អង់ ឱ្យបានពេលយូរសម្រាប់ការដទៃទៀតដែលត្រូវធ្វើ ។

នៅពេលដែលមានការចាក់ប្រេងតាំង នៃព្រះវិញ្ញាបរិសុទ្ធដ៏ពេញកម្លាំង ចូរចាប់ផ្ដើមចូលមក ដោយកុំធ្វើការប្រញាប់ប្រញាល់ពេក ចំពោះចម្រៀងជាបន្តបន្ទាប់នោះ ។ ការបង្អែបង្អង់នៅទីនោះអស់រយៈពេលយូរ គឺជាការទទួលចាក់ប្រេងតាំង ដែលកំពុងតែមានការលូតលាស់នៅក្នុងប្រពលភាព ។ ការសម្ដែងជាបន្តទៀត នូវចម្រៀងនោះរហូតដល់ព្រះវិញ្ញាណទ្រង់បានបំពេញ នូវការងារដែលទ្រង់កំពុងតែធ្វើការនោះ គឺជាការនាំមកនូវភាពជាបងប្អូន ចូលទៅក្នុងការសរសើរតម្កើងកាន់តែខ្ពស់ឡើង ឬការចូលទៅកាន់តែជិតនៅក្នុងព្រះវត្តមានរបស់ទ្រង់ ក្នុងការថ្វាយបង្គំនោះ ។

**អំណោយទាននៃការបញ្ចេញសម្លេង**

ចូរធ្វើការលើកទឹកចិត្តដោយឯកឯង ឱ្យមានការបង្ហូរមកដោយសេរី ចំពោះការអនុវត្តន៍ នូវអំណោយទាននៃការបញ្ចេញសម្លេងរបស់ព្រះវិញ្ញាណបរិសុទ្ធ ចេញពីចំណោមអ្នកដឹកនាំព្រះវិហារ ។ ជានិច្ចកាល គឺត្រូវបង្អង់ចាំនូវទីកន្លែងដ៏សមរម្យ ដែលនឹងថ្វាយពេលវេលាសម្រាប់ព្រះទ្រង់បានមានបន្ទូលទៅកាន់ប្រជារាស្ត្ររបស់ទ្រង់ តាមរយៈអំណោយទាននៃការនិយាយភាសាដទៃ និងការបកប្រែភាសាដទៃ ឬក៏តាមរយៈការអធិប្បាយជាដើម ។

ព្រះគម្ពីរ១កូរិនថូស ១២:៧-១០ ចែងថា: **ហើយទ្រង់ប្រទានឱ្យព្រះវិញ្ញាណសំដែងមកក្នុងគ្រប់គ្នា ដើម្បីឱ្យបានកើតផល ដ្បិតទ្រង់ប្រទានឱ្យម្នាក់មានពាក្យសំដីនៃប្រាជ្ញាវាងវៃ ដោយសារព្រះវិញ្ញាណ ឱ្យម្នាក់ទៀតមានពាក្យសំដីនៃចំណេះចេះស្ទាត់ តាមព្រះវិញ្ញាណដដែល ហើយឱ្យម្នាក់ផ្សេងទៀតមានសេចក្តីជំនឿ ដោយនូវព្រះវិញ្ញាណដដែល ឱ្យមួយទៀតបានអស់ទាំងអំណោយទាន និងអាចប្រោសឱ្យជា ដោយនូវព្រះវិញ្ញាណដដែល ឱ្យមួយទៀតបានសំដែងការឫទ្ធិបារមី និងឱ្យមួយទៀតចេះអធិប្បាយ ឱ្យមួយទៀតសង្កេតស្គាល់អស់ទាំងវិញ្ញាណ ឱ្យមួយទៀតចេះនិយាយភាសាដទៃផ្សេងៗ ហើយឱ្យមួយទៀតចេះបកប្រែភាសាដទៃ ។**

ជួនកាល អាចមានពាក្យសម្តីនៃការដាស់តឿនក្រើនរំឭក តាមរយៈព្រះគម្ពីរ ឬតាមរយៈចម្រៀងខាងឯវិញ្ញាណ ។

ព្រះគម្ពីរទំនុកដំកើង ៤០:៣ ចែងថា: **ទ្រង់បានបណ្តាលឱ្យមានទំនុកថ្មីនៅក្នុងមាត់ខ្ញុំ គឺជាសេចក្តីសរសើរដល់ព្រះនៃយើងខ្ញុំ មនុស្សជាច្រើននឹងឃើញ ព្រមទាំងមានសេចក្តីកោតខ្លាច ហើយនឹងទុកចិត្តដល់ព្រះយេហូវ៉ាផង ។**

អ្នកដឹកនាំថ្វាយបង្គំ គឺត្រូវតែរក្សាទុកនូវសិទ្ធិអំណាចខាងឯវិញ្ញាណ នៅលើគ្រប់ទាំងការងារបម្រើទាំងអស់ ។ នៅក្នុងក្រុមមនុស្សជាបងប្អូនដ៏ធំ ដែលត្រូវបានគេសម្រេចចិត្តលើកដៃរបស់គាត់ ឬរបស់នាងឡើង ឱ្យបានចូលមកជាម្នាក់ក្នុងពួកចាស់ទុំ សម្រាប់ទទួលស្គាល់នៅចំពោះមុខអំណោយជាអ្នកសម្តែងព្រះបន្ទូល ។

ការសម្តែងព្រះបន្ទូលអាចជាតម្រូវការ ចំពោះការផ្តល់ឱ្យនូវការប្រើប្រពន្ធសម្លេង ឬក្នុងការបញ្ចេញសម្លេងល្អមនឹងអាចល្អបាន ដោយក្រុមអ្នកដឹកនាំព្រះវិហារទាំងមូល ។

**សម្រាប់ការសាង**

រឿងរ៉ាវទាំងអស់ គួរគប្បីត្រូវបានធ្វើសម្រេច សម្រាប់ការសាងដែលមានលក្ខណៈពេញវ័យ ។ គ្រប់ការបើកសម្តែងខាងឯវិញ្ញាណ គឺជាការត្រូវច្បាប់ និងជាការសមរម្យ ប៉ុន្តែ គ្រប់ការទាំងអស់ដែលត្រូវបានធ្វើរួចហើយ នោះគួរគប្បីបានធ្វើសម្រាប់ជាការកសាងរួមគ្នាទាំងអស់វិញ ។

ព្រះគម្ពីរ១កូរិនថូស ១៤:២៦ ចែងថា: **ដូច្នេះ ធ្វើដូចម្តេច បងប្អូនអើយ កាលណាអ្នករាល់គ្នាប្រជុំ នោះគ្រប់គ្នាមានទំនុកដំកើង មានសេចក្តីបង្រៀន មានសេចក្តីបើកសំដែង មាននិយាយភាសាដទៃ មានសេចក្តីបកប្រែដែរ ត្រូវឱ្យធ្វើការទាំងអស់សំរាប់នឹងស្អាងចិត្តឡើង ។**

**ចូរជៀសវាងនូវការភាន់ច្រឡំ**

ព្រះទ្រង់មិនមែនជាអ្នកនិពន្ធដោយមានការភាន់ច្រឡំទេ ។

ព្រះគម្ពីរ១កូរិនថូស ១៤:៣៣ក ចែងថា: **ដ្បិតព្រះទ្រង់មិនមែនជាព្រះនៃសេចក្តីវឹកវរទេ គឺទ្រង់ជាព្រះនៃសេចក្តីសុខសាន្តវិញ... ។**

ប្រសិនបើការងារបម្រើចាប់ផ្តើមដោយមានការភាន់ច្រឡំ នោះចូរធ្វើការផ្លាស់ប្តូរ និងនាំត្រឡប់ចេញមកពីការភាន់ច្រឡំនោះមកវិញ ។ ប្រសិនបើជាការចាំបាច់ ចូរទុកការនោះសិន ហើយធ្វើការពន្យល់ពីអ្វី ដែលកំពុងតែមានការកើតឡើង ដូច្នេះ គឺជាការធ្វើឱ្យបានច្បាស់លាស់នូវ

ស្ថានការណ៍នោះ ។ ចូរប្រើប្រាស់នូវពេលវេលាទាំងនេះ ដើម្បីបង្រៀនតាមមធ្យោបាយត្រឹមត្រូវ នៃចលនាដោយនូវព្រះវិញ្ញាណ ។

**ចូរជៀសវាងពីការរំលោភ និងការឆ្លងកាត់ខ្សែទឹក**

ប្រសិនបើមានការរំលោភនៅក្នុងអ្វី ដែលបានបង្ហូរមកដោយនូវព្រះវិញ្ញាណបរិសុទ្ធ ដែលកំពុងតែធ្វើក្នុងពេលភ្លាមៗនោះ អ្នកដឹកនាំត្រូវតែមានការយល់ដឹងគ្រប់គ្រាន់ចំពោះការចោទប្រកាន់ និងការទាក់ទងជាមួយនឹងស្ថានការណ៍ ដោយគ្មានការបំបែកបំបាក់នូវការបង្ហូរមក ជាលំដាប់លំដោយនោះឡើយ ។ ចូរអធិស្ឋានសុំការរីកចម្រើននូវអំណោយទានខាងឯវិញ្ញាណនៃការ "សង្កេតខាងឯវិញ្ញាណ" វិញ ។ ហើយចូររៀនសូត្រឱ្យមានការយល់ដឹងពីពេលវេលារបស់ព្រះ ។ ការរំលោភបំពានអាចបានជាការចង្អុលបង្ហាញ នៃអំណោយទានខាងការបញ្ចេញសម្លេងដ៏ស្រស់បំព្រងនៃព្រះវិញ្ញាណបរិសុទ្ធ ឬជាចម្រៀងខាងឯវិញ្ញាណ ដែលកំពុងតែត្រូវបានប្រទានឱ្យនូវពេលវេលាគ្រប់លក្ខណ៍របស់ព្រះ ។

អ្នកដឹកនាំថ្វាយបង្គំត្រូវតែមានសេចក្តីជំនឿ មានភាពអង់អាចមានការប្រុងប្រយ័តក្នុងការនិយាយ មានប្រាជ្ញា មានព្រះគុណ និងសេចក្តីពិត ដើម្បីដឹកនាំការងារបម្រើយ៉ាងមានជំនាញ យ៉ាងស្លូតបូត និងមានសេចក្តីស្រឡាញ់ ត្រឡប់ទៅឯពាក់កណ្តាល នៃការចាក់ប្រេងតាំង និងការបង្ហូរមកនៃព្រះវិញ្ញាណបរិសុទ្ធ ។

**ការរួបរួមគ្នាដោយនូវព្រះវិញ្ញាណ**

អ្នកដឹកនាំសរសើរតម្កើង និងថ្វាយបង្គំ ដែលពេញដោយជំនាញនោះនឹងធ្វើការសម្រេចបាននូវការរួបរួមរវាងខ្លួនគាត់ផ្ទាល់ និងអ្នកដឹកនាំព្រះវិហារ រវាងអ្នកដឹកនាំព្រះវិហារជាលក្ខណៈបុគ្គល និងក្នុងចំណោមរូបកាយទាំងមូល ព្រមទាំងព្រះវិញ្ញាណបរិសុទ្ធ ។ នៅពេលដែលការរួបរួមដោយនូវព្រះវិញ្ញាណនេះ បានត្រឡប់មកជាមានកម្លាំងកាន់តែខ្លាំងឡើង

នោះការថ្វាយបង្គំដ៏ពិត នឹងបានចាប់ផ្តើមបង្ហូរមកនូវវង្វាស់ចំពោះព្រះក៏តែល្អប្រសើរឡើងជាលំដាប់ដែរ ។

**អំពីពេលវេលា**

ចំពោះអ្នកដឹកនាំថ្វាយបង្គំ គឺត្រូវតែមានភាពប្រយ័ត្នប្រយែងចំពោះការស្នាក់នៅក្នុងពេល ដែលមានការជ្រើសរើសដោយលោកគ្រូគង្វាល ឬពួកចាស់ទុំ ។ ប្រសិនបើចលនានៃព្រះវិញ្ញាណកំពុងតែដឹកនាំចូលទៅក្នុងរយៈពេលនៃការសរសើរតម្កើង និងការថ្វាយបង្គំ គឺត្រូវតែទទួលយ៉ាងមានការប្រុងប្រយ័ត្ន ដើម្បីបញ្ជាក់ពីការនោះ ចំពោះខាងឯវិញ្ញាណ និងសិទ្ធិអំណាចរបស់លោកអ្នក ឱ្យបានធ្វើយ៉ាងដូច្នោះដោយទោលតែម្នាក់ឯង ពីលោកគ្រូគង្វាល ឬពីចាស់ទុំដែលមានភាពជាអ្នកដឹកនាំខាងឯវិញ្ញាណ ចំពោះការប្រជុំមុនពេលការធ្វើបន្តទៅទៀត ។

**ការរាប់បញ្ចូល**

ចូរឱ្យមានការយល់ដឹងចំពោះព្រះវិញ្ញាណបរិសុទ្ធ ដោយការរាប់បញ្ចូលនូវការងារសរសើរតម្កើង និងការងារថ្វាយបង្គំ ដោយការចាកចេញយ៉ាងសុភាព ដែលអ្នកថ្វាយបង្គំម្នាក់ៗ នៅក្នុងព្រះវត្តមាននៃព្រះ ។ ការមានពេញដោយជំនាញដឹកនាំនៅក្នុងព្រះវិហារ ឆ្លងតាមរយៈទ្វាររបងដោយមានការអរព្រះគុណ និងចូលទៅក្នុងទីលានដ៏ប្រសើរ គឺជាការពិសោធន៍នៃការសរសើរតម្កើង ហើយបន្ទាប់មក មានចលនាសុភាពដល់ពួកគេ ឱ្យបានចូលទៅក្នុងភាពគួរឱ្យភ័យខ្លាច និងព្រះវត្តមានដ៏ជិតស្និទ្ធនៃព្រះនៅក្នុងការថ្វាយបង្គំអស់ពីចិត្តដ៏ពិតប្រាកដ ដែលលោកអ្នកបាននាំឱ្យពួកគេចូលទៅក្នុងការកៀកកិតរបស់ទ្រង់ ។

ចូរធ្វើការប្រុងប្រយ័ត្ន កុំធ្វើការឆាឆៅបង្អាក់នូវអ្វីដែលបានកើតឡើង ចំពោះការរស់នៅ និងវិញ្ញាណរបស់ពួកអ្នកជឿ កំឡុងពេលប្រញាប់ដ៏ពិសេសនោះ ចូរអនុញ្ញាតឱ្យម្នាក់ៗ ដែលជាអ្នកថ្វាយបង្គំឱ្យបានកាន់ជិត

ស្និទ្ធ កុំបង្អែបង្អង់នៅពេលភ្លាមៗនោះ ត្រូវឱ្យមានការស្ងប់ស្ងាត់ នៅក្នុងសិរីល្អនៃព្រះវត្តមានរបស់ព្រះ ។

នៅពេលដែលលោកអ្នកដើរចេញទៅ នោះលោកអ្នកនឹងដឹងថាការរស់នៅមានការផ្លាស់ប្តូរ គឺកំឡុងពេលការងារបម្រើនោះ ដែលលោកអ្នកមានជំនាញ ក្នុងការដឹកនាំដល់អ្នកជឿដទៃទៀត ឱ្យបានចូលទៅក្នុងការពិសោធន៍ពីសេចក្តីអំណរដែលមិនអាចពណ៌នាបាន នៃកាសរសើរតម្កើង និងការថ្វាយបង្គំដ៏ពិត ដែលបាននាំមកនូវការគាប់ព្រះហឫទ័យដ៏ធំដល់ព្រះ ។

## សំណួររំឭកសារឡើងវិញ

១ ចូរធ្វើបញ្ជីពីការប្រុងប្រៀបរៀបចំ ដែលអ្នកដឹកនាំថ្វាយបង្គំពេញដោយជំនាញ ដែលគួរគប្បីធ្វើពីដំបូង ចំពោះការចាប់ផ្តើមការងារសរសើរតម្កើង និងការងារថ្វាយបង្គំ ។

២ ចូរផ្តល់ឱ្យនូវគំរូពីរបៀបអ្នកដឹកនាំថ្វាយបង្គំ ដែលអាចខិតខំដឹកនាំដល់បណ្តាជនបន្ថែមទៀត ឱ្យបានកាន់តែល្អប្រសើរឡើង ក្នុងការសរសើរតម្កើង និងការថ្វាយបង្គំ ។

៣ ចូរធ្វើការពន្យល់នូវអ្វីដែលមានន័យតាម "ការធ្វើការចាក់ប្រេងតាំងជាបន្តបន្ទាប់" កំឡុងពេលនៃការសរសើរតម្កើង និងការថ្វាយបង្គំនោះ ។


ព្រះយេស៊ូវបានគង់ជាកណ្តាល មូលដ្ឋានគ្រឹះនៃព្រះបន្ទូល សេចក្តីជំនឿ
បានសម្រេច ជីវិតផ្លាស់ប្រែ ការបង្រៀនដោយព្រះវិញ្ញាណ
www.gillministries.com